fidh

Fédération internationale des ligues des droits de l'Homme
International federation for human rights
Federacion international de los derechos humanos
الفدرالية الدولية لحقوق الانسان

មីនា ២០០៦
លេខ ៤៤៣

# របាយការណ៍

## តុលាការព្រហ្មទណ្ឌអន្តរជាតិ

## ការសម្របនីតិកម្មកម្ពុជាទៅនឹងលក្ខន្តិកៈ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ


សេចក្តីផ្តើម

ផ្នែកទី១៖ ការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាប់ពីឆ្នាំ២០០០មកទល់នឹងបច្ចុប្បន្ន

ផ្នែកទី២៖ ការសិក្សាលើប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា

ផ្នែកទី៣៖ ការបញ្ចូលនិយមន័យនៃបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមទៅក្នុងនីតិកម្ពុជា

ផ្នែកទី៤៖ គោលការណ៍ទូទៅនៃនីតិ

ផ្នែកទី៥៖ កិច្ចសហប្រតិបត្តិការរវាង តុលាការព្រហ្មទណ្ឌអន្តរជាតិ និងប្រទេសកម្ពុជា

ផ្នែកទី៦៖ ការជួសជុលការខូចខាតដល់ជនរងគ្រោះ

ផ្នែកទី៧៖ ការថែរក្សាសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ចំពោះការបង្ក្រាបបទឧក្រិដ្ឋទាំងឡាយដោយអនុវត្តនូវបទដ្ឋាន

អន្តរជាតិដែលមានលក្ខណៈសមស្រប

# មាតិកា

**សេចក្តីផ្តើម**

**ផ្នែកទី១៖ ការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាប់ពីឆ្នាំ២០០០ មកទល់នឹងបច្ចុប្បន្ន……………………………………………………………១២**

**ជំពូកទី១៖ ការផ្តល់សច្ចាប័នដល់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ……………………………១២**

**ជំពូកទី២៖ កិច្ចព្រមព្រៀងទ្វេរភាគីរវាងកម្ពុជា និងសហរដ្ឋអាមេរិកនៅថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០០៣…….១៤**

ក. លក្ខណៈទូទៅនៃកិច្ចព្រមព្រៀងទ្វេរភាគី……………………………………………………………១៥

ខ. ការអត្ថាធិប្បាយរិះគន់លើកិច្ចព្រមព្រៀង……………………………………………………………១៦

*១- អំពីគោលការណ៍បន្ថែម……………………………………………………………………………១៧*

*២- អំពីមាត្រា ៩៨ វាក្យខ័ណ្ឌទី២ នៃលក្ខន្តិកៈទីក្រុងរ៉ូម……………………………………………………១៩*

**តារាងទី១៖ បញ្ជីឈ្មោះរដ្ឋដែលបានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិកលក្ខន្តិកៈទីក្រុងរ៉ូម…………២២**

**ផ្នែកទី២៖ ការសិក្សាលើប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា……………………………………………២៦**

**ជំពូកទី១៖ នីតិជាធរមាន…………………………………………………………………………២៦**

**ជំពូកទី២៖ អានុភាពនៃសន្ធិសញ្ញាអន្តរជាតិ………………………………………………………២៩**

ក. ការតំរូវឱ្យមានច្បាប់ដើម្បីបញ្ចូលសន្ធិសញ្ញាអន្តរជាតិទៅក្នុងនីតិជាតិ……………………………២៩

ខ. ឧត្តមភាពនៃសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សលើច្បាប់បង្កើតថ្មី………………………………………៣១

*១- លក្ខណៈពិសេសនៃសិទ្ធិមនុស្ស……………………………………………………………………៣១*

*២- សិទ្ធិរបស់ពលរដ្ឋក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព*.......................................................................៣២

**ជំពូកទី៣: អង្គជំនុំជម្រះវិសាមញ្ញ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ........................................៣៤**

**ក. ភាពដូចគ្នានៃអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ..................................................៣៥**

*១- ការកំណត់បទល្មើស*.......................................................................................................៣៥

*១-ក. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*.............................................................................................៣៥

*១-ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*..............................................................................................៣៦

*១-គ. ឧក្រិដ្ឋកម្មសង្គ្រាម*.........................................................................................................៣៨

*២- ការគ្មានអាជ្ញាយុកាលនៃបទល្មើស*.........................................................................................៣៩

**ខ. លក្ខណៈខុសគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ..........................................៣៩**

*១- ការដាក់បញ្ចូលអង្គជំនុំជម្រះវិសាមញ្ញទៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា*.......................................៣៩

*២- អធិបតេយ្យភាពនៃអង្គជំនុំជម្រះវិសាមញ្ញ និងគោលការណ៍នៃការបំពេញបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ*.......................................................................................................៤០

*៣- ការដាក់ដែនកំណត់ចំពោះជនដែលអាចត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ*..........៤២

**ផ្នែកទី៣: ការបញ្ចូលនិយមន័យនៃបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមទៅក្នុងនីតិកម្ពុជា.........................................................................៤៤**

**ជំពូកទី១: បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍.............................................................៤៥**

**ក. បទប្រល័យពូជសាសន៍...........................................................................................................៤៧**

*១- នីតិវិជ្ជមាន*......................................................................................................៤៧

*២- ច្បាប់ដែលកំពុងត្រូវបានធ្វើការសិក្សា*..............................................................................៥០

**ខ. ការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍**..........................................៥៣

*១- នីតិកម្មរបស់កម្ពុជាស្តីពីការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យ*

*ពូជសាសន៍*..........................................................................................................៥៤

*២- សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី*...........................................................................................៥៥

**ជំពូកទី២: បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**..................................................៥៨

**ក. ការប៉ះពាល់ដល់សុខភាពផ្លូវកាយនិងខាងសតិបញ្ញា**.......................................................................៦២

**ខ. ការចាំបាច់ក្នុងការបញ្ជាក់ឱ្យបានច្បាស់ក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនូវអត្ថន័យនៃបណ្តា**
**អំពើមួយចំនួនដែលជាធាតុផ្សំចំបងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**.........................................................៦៣

**ជំពូកទី៣: ឧក្រិដ្ឋកម្មសង្គ្រាម**.........................................................................៦៦

**ក. ការកំណត់អំពីការបង្ក្រាបឧក្រិដ្ឋកម្មសង្គ្រាមក្នុងនីតិវិជ្ជមានកម្ពុជា**.......................................................៦៧

*១- ប្រភពពីនីតិកម្ពុជា*.............................................................................................................៦៧

*២- ការប្រៀបធៀបជាមួយនឹងលក្ខន្តិកៈទីក្រុងរ៉ូម*.................................................................................៦៨

**ខ. ឧក្រិដ្ឋកម្មសង្គ្រាមក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី**.........................................................................៦៨

*១- ការប្រៀបធៀបមាត្រា កម ២១៣១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ជាមួយមាត្រា ៨ កថាខ័ណ្ឌ ២*
*វាក្យខ័ណ្ឌ ក នៃលក្ខន្តិកៈទីក្រុងរ៉ូម*..................................................................................................៧០

*១-ក. ឃ្លា "ការបំផ្លាញ ឬ ការកេងយកនូវទ្រព្យសម្បត្តិ "*..........................................................................៧០

*១-ខ. ពាក្យ "ជនស៊ីវិល" នៃមាត្រា កម ២១៣១-១ នៃសេចក្តីព្រាង ក្រមព្រហ្មទណ្ឌថ្មី និងពាក្យ "ជនដែលទទួលបានការការពារ" នៃមាត្រា ៨ កថា ខ័ណ្ឌ ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម..........៧០*

*២- ការប្រៀបធៀបមាត្រា កម ២១៣១-២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ជាមួយមាត្រា ៨ កថាខ័ណ្ឌ២ (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម..........៧១*

*២-ក. មាត្រា ៨ កថាខ័ណ្ឌ ២ (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម..........៧១*

*២-ខ. មាត្រា កម ២១៣១-២ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី..........៧២*

**ជំពូកទី៤:   ការអនុវត្តគោលការណ៍បំពេញបន្ថែម..........៧៩**

**ក. ការលើកលែងទោសៈ ឧបសគ្គចំពោះការអនុវត្តនៃគោលការណ៍បំពេញបន្ថែម..........៧៩**

*១- អំពីច្បាប់ខ្មែរ..........៧៩*

*១-ក. ការលើកលែងទោសជាទូទៅ..........៧៩*

*១-ខ. ការអនុគ្រោះទោស..........៨១*

*២- ការប្រៀបធៀបច្បាប់ខ្មែរទៅនឹងលក្ខន្តិកៈទីក្រុងរ៉ូម..........៨២*

**ខ. បញ្ហាទាក់ទងនឹងទោសទណ្ឌ..........៨៥**

**ផ្នែកទី៤ :  គោលការណ៍ទូទៅនៃនីតិ..........៨៨**

**ជំពូក១ :  ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗៈមាត្រា២៥នៃលក្ខន្តិកៈទីក្រុងរ៉ូម..........៨៩**

**ក. អវត្តមាននៃការទទួលស្គាល់ថា មានការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល..........៨៩**

**ខ. ទំរង់ផ្សេងៗនៃការចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិមួយ..........៩០**

*១-ការសមគំនិត..........៩១*

*២- ការប៉ុនប៉ង..........៩២*

**ជំពូក២: អភ័យឯកសិទ្ធិ: មាត្រា២៧នៃលក្ខន្តិកៈទីក្រុងរ៉ូម..........៩៤**

**ក. អភ័យឯកសិទ្ធិក្នុងស្រុក..........៩៥**

*១- អភ័យឯកសិទ្ធិរបស់អង្គព្រះមហាក្សត្រ..........៩៥*

*២- អភ័យឯកសិទ្ធិសភា..........៩៦*

*៣- អវត្តមានអភ័យឯកសិទ្ធិ ចំពោះសមាជិករដ្ឋាភិបាល..........៩៨*

**ខ. អភ័យឯកសិទ្ធិអន្តរជាតិ..........៩៩**

**ជំពូក ៣ : ការទទួលខុសត្រូវរបស់មេបញ្ជាការកងទ័ព និងថ្នាក់លើផ្សេងៗទៀត : មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម..........១០៣**

**ក. សេចក្តីកត់សំគាល់បឋម..........១០៣**

**ខ. ដែនអនុវត្តរបស់មាត្រា២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម..........១០៣**

**គ. អត្ថប្រយោជន៍របស់មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម..........១០៤**

**ឃ. ច្បាប់កម្ពុជា..........១០៥**

*១- ថ្នាក់លើខាងយោធា..........១០៥*

*២- ថ្នាក់លើខាងស៊ីវិល..........១០៧*

**ជំពូក៤ : ភាពគ្មានអាជ្ញាយុកាលនៃបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម : មាត្រា២៩នៃលក្ខន្តិកៈទីក្រុងរ៉ូម..........១០៩**

**ក. អនុសញ្ញារបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៦ វិច្ឆិកា ១៩៦៨..........១០៩**

*១- ការអធិប្បាយអំពីអនុសញ្ញា..........១០៩*

*២- តំលៃរបស់អនុសញ្ញានៅក្នុងច្បាប់ខ្មែរ..........១១០*

*៣- ភាពគ្មានអាជ្ញាយុកាល ជាបទដ្ឋានទំនៀមទំលាប់អន្តរជាតិ ?..........១១០*

**ខ. ស្ថានភាពរបស់ច្បាប់កម្ពុជា..........១១១**

**ជំពូក៥ : មូលហេតុនៃការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌៈ មាត្រា៣១នៃលក្ខន្តិកៈទីក្រុងរ៉ូម......១១២**

**ក. ការអធិប្បាយអំពីមាត្រា ៣១ និងការបកស្រាយរិះគន់.....................................................១១២**

**ខ. ស្ថានភាពច្បាប់កម្ពុជា.....................................................................................................១១៤**

**ជំពូក៦ : បញ្ជាថ្នាក់លើ និងសេចក្តីបង្គាប់របស់ច្បាប់ : មាត្រា៣៣នៃលក្ខន្តិកៈទីក្រុងរ៉ូម.................១១៨**

**ក. ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់អ្នកប្រតិបត្តិ.....................................................១១៨**

**ខ. ការអធិប្បាយអំពីមាត្រា ៣៣ និងការបកស្រាយរិះគន់.....................................................១១៩**

**គ. ស្ថានភាពច្បាប់កម្ពុជា.....................................................................................................១២០**

**ផ្នែកទី៥: កិច្ចសហប្រតិបត្តិការរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងប្រទេសកម្ពុជា..................១២៣**

**ជំពូកទោល : សំណើសុំបញ្ចូលមាតិកាមួយស្តីពីកិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ទៅក្នុងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ..................................................១២៣**

**ផ្នែកទី៦ : ការជួសជុលការខូចខាតដល់ជនរងគ្រោះ...................................................១៣៤**

**ជំពូក១ : នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ តុលាការបរទេស....................១៣៤**

**ក. កិច្ចសហប្រតិបត្តិការជាមួយ តុលាការព្រហ្មទណ្ឌអន្តរជាតិ និង ការអនុវត្តដីកាជួសជុលការខូចខាត..........១៣៥**

*១- កាតព្វកិច្ចក្នុងការសហការដើម្បីការជួសជុលការខូចខាត.....................................................១៣៥*

*២- កាតព្វកិច្ចអនុវត្តដីកាជួសជុលការខូចខាត.......................................................................១៣៧*

**ខ. កិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ...................................................................................១៣៧**

**ជំពូក២: នីតិវិធីនៅប្រទេសកម្ពុជា...........................................................................១៣៨**

**ក. នីតិវិធីព្រហ្មទណ្ឌនៅប្រទេសកម្ពុជា...................................................................................១៣៨**

*១- ការកំណត់ពីសមត្ថកិច្ច.....................................................................................................១៣៨*

*២- ការពង្រីកសមត្ថកិច្ច.......................................................................................................១៣៩*

ខ. នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ........................................................................១៣៩

គ. នីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខតុលាការរបស់តតិយរដ្ឋណាមួយ.......................................................១៤០

**ផ្នែកទី៧ ៖ ការធ្វើរក្សាសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះការបង្ក្រាបបទឧក្រិដ្ឋទាំងឡាយ ដោយអនុវត្តនូវបទដ្ឋានអន្តរជាតិដែលមានលក្ខណៈសមស្រប.......................................១៤៥**

**ជំពូក១ ៖ ការធានានានាដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិសម្រាប់រឿងក្តីមួយយុត្តិធម៌.................១៤៦**

ក. សិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ........................................................................................១៤៧

*១- វត្តមានរបស់មេធាវីនៅដំណាក់ចោទសួរនៃការចូលខ្លួនលើកទីមួយ...............................................១៤៧*

*២- នីតិវិធីបដិប្បញ្ញត្តិនៃការចូលខ្លួនភ្លាម ៖ ការយល់ព្រមត្រូវធ្វើឡើងដោយមានវត្តមានរបស់មេធាវី........១៥០*

ខ. ការចូលរួមរបស់ជនរងគ្រោះ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ.......................................................................១៥២

*១- ការចាប់ផ្តើមធ្វើ និងការដាក់អោយមានកិច្ចដំណើរការនៃបណ្តឹងអាជ្ញា............................................១៥៤*

*២- ការនាំខ្លួនឱ្យចូលជំរះផ្ទាល់.....................................................................................................១៥៥*

*៣- សិទ្ធិរបស់សមាគមន៍ផ្សេងៗ ក្នុងការធ្វើបណ្តឹង ប្រឆាំងនឹងបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី....................................១៥៦*

គ. សាធារណៈភាពនៃការពិភាក្សាដេញដោល.........................................................................................១៥៦

ឃ. សិទ្ធិទទួលបានការពិនិត្យសុខភាពនៅអំឡុងពេលនៃការឃាត់ខ្លួន........................................................១៥៨

**ជំពូក២៖ ការធានានានាជាអន្តរជាតិស្តីពីប្រព្រឹត្តកម្មជនជាប់ឃុំ និង ជនជាប់ពន្ធនាគារ.......១៦០**

# សេចក្តីផ្តើម

របាយការណ៍នេះត្រូវបានចងក្រងឡើងក្នុងក្របខ័ណ្ឌកម្មវិធីរបស់សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (FIDH) សំដៅជំរុញអោយមានការផ្តល់សច្ចាប័ន និងការអនុវត្តលក្ខន្តិកៈស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។ កម្មវិធីនេះទទួលបានការជួយឧបត្ថមគាំទ្រ ជាពិសេស ពីសហភាពអឺរ៉ុប ( ការផ្តួចផ្តើមរបស់អឺរ៉ុបដើម្បីប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស - IEDDH )។

ក្នុងក្របខ័ណ្ឌនៃគំរោងនេះ សកម្មភាពទីមួយត្រូវបានចាប់ផ្តើមអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា នាខែ មិនា ២០០៥ តាមរយៈកិច្ចពិភាក្សាតុមូល ដែលបានប្រព្រឹត្តទៅអស់រយៈពេលពីរថ្ងៃ ស្តីពី "ភាពមានទំនាក់ទំនងគ្នា រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការកាត់ទោសខ្មែរក្រហម : តួនាទីរបស់ជនរងគ្រោះ"។ កិច្ចពិភាក្សាតុមូលនេះ ដែលបានរៀបចំរួមគ្នាដោយអង្គការជាសមាជិក នៃសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិពីរនៅកម្ពុជា គឺ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) និងសមាគមការពារសិទ្ធិមនុស្សកម្ពុជា (LICADHO) បានប្រជុំគ្នា ដោយមានអ្នកចូលរួមមកពីបណ្តាអង្គការសង្គមស៊ីវិលកម្ពុជាជាច្រើន រួមទាំងមកពីមហាវិទ្យាល័យនានា និងមកពីស្ថានទូតមួយចំនួនទៀតផង។ អាជ្ញាធរ ដែលបានអញ្ជើញអោយមកចូលរួមជា វាគ្មិននៅក្នុងឱកាសនោះ មិនមកចូលរួមទេ។

កិច្ចពិភាក្សាតុមូលនេះបានផ្តល់នូវការបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលសំយោគរាល់ការធ្វើអត្ថាធិប្បាយ និងការជជែកវែកញែកទាំងឡាយក្នុងកំឡុងពេលនៃកិច្ចពិភាក្សាតុមូលពីរថ្ងៃនេះ និងរួមទាំងអនុសាសន៍ទាំងឡាយ ដែលទាញចេញពីកិច្ចពិភាក្សានោះ រៀបចំដោយ FIDH ADHOC និង LICADHO [1]។

ការផ្តួចផ្តើមគំនិតនេះបាននាំមកនូវផ្លែផ្កាគួរអោយកត់សំគាល់។ វាបានជុំរុញអោយមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ជាលើកដំបូង ទៅលើការចូលរួម និង ការការពារជនរងគ្រោះ នៅចំពោះមុខតុលាការកាត់ទោសខ្មែរ ក្រហម ដែលរហូតមកដល់បច្ចុប្បន្ននេះ ពុំមានការយកចិត្តទុកដាក់ខ្លាំងនោះទេលើបញ្ហានេះ [២]។

បន្ទាប់ពីកិច្ចពិភាក្សាតុមូលនេះរួច សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិបានសំរេចចិត្តរៀបចំសកម្មភាពទីពីរនៅកម្ពុជាដែលលើកនេះ ទាក់ទងទៅនឹងការដាក់អោយអនុវត្តលក្ខន្តិកៈស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងច្បាប់ក្នុងស្រុក។ អ្នកទទួលបន្ទុកបេសកកម្មពីររូបត្រូវបានទទួលអណត្តិពីសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ ដើម្បីធ្វើការសិក្សាលើបញ្ហានេះ ដោយកំណត់នូវចំនុចមួយចំនួន ក្នុងច្បាប់កម្ពុជា ដើម្បីកែប្រែអោយស្របពេញលក្ខណៈទៅនឹងកាតព្វកិច្ចនៃលក្ខន្តិកៈទីក្រុងរ៉ូម។ តាមពិតទៅ ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសទីមួយ ហើយក៏ជារដ្ឋកំរមួយក្នុងចំណោមរដ្ឋដទៃទៀត នៅក្នុងតំបន់

---

[១] របាយការណ៍របស់ FIDH លេខ ៤២០ ខែ មិថុនា ២០០៥។ សូមមើលក្នុង http://www.fidh.org/IMG/pdf/kh420f.pdf

[២] សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ២៩ មិនា ២០០៥ របស់ FIDH ADHOC និង LICADHO។
សូមមើលក្នុង http://www.fidh.org/article.php3?id_article=2331

ដែលបានផ្តល់សច្ចាប័នដល់លក្ខន្តិកៈនេះ។ ប៉ុន្តែ រហូតមកទល់បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាពុំទាន់បានបញ្ចូលបញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូមនេះទៅក្នុងច្បាប់ក្នុងស្រុកនៅឡើយទេ។

និស្សិតត្រៀមបណ្ឌិតពីររូប ដែលទទួលភារកិច្ចសិក្សាលើបញ្ហានេះ មានលោក **សាន់ រ៉ាដា** និង លោក **អ៊ីស្សាម មូសារ** ក្រោមការដឹកនាំរបស់លោក បណ្ឌិត **ដាវីដ បិយលី** បានស្នាក់នៅទីក្រុងភ្នំពេញអស់រយៈកាលបីខែ (ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ២០០៥)ដែលមានកន្លែងធ្វើការនៅការិយាល័យនៃសមាគម ADHOC ។ ហើយ សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិសូមថ្លែងអំណរគុណដល់សមាគម ADHOC ដែលបានផ្តល់កន្លែងធ្វើការដល់បេសកជនទាំងពីររូបនេះ។ ក្រៅពី ADHOC និង LICADHO បេសកជនទាំងបីរូបបានទៅជួបឥស្សរៈជនមួយចំនួន ដើម្បីបង្ហាញពីគោលដៅនៃការសិក្សារបស់ពួកគេ ដូចជា ឯឧត្តម **ឡេង ប៉េង ឡុង** ជារដ្ឋលេខាធិការនៃក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច និង ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអ្នកច្បាប់ ឯឧត្តម **សឺន ស៊ូប៊ែ** ជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ឯឧត្តម **ខៀវ សន** ជាប្រធានគណកម្មការនីតិកម្មនៃរដ្ឋសភា ឯឧត្តម **អ៊ុក វ៉ាន់រីត** ជាប្រធានគណកម្មការសិទ្ធិមនុស្ស របស់រដ្ឋាភិបាល អ្នកស្រី **អេលែន ចាវីស** ជាទីប្រឹក្សានៃតុលាការកាត់ទោសខ្មែរក្រហម នៅលេខាធិការដ្ឋានរបស់ Task Force នៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជា លោក Manfred Hornung និងអ្នកស្រី Alice Goodenough ជាមន្ត្រីនៅការិយាល័យនៃឧត្តមស្នងការសិទ្ធិ មនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅទីក្រុងភ្នំពេញ ឯឧត្តម Yvon Roé d'Albert ជាឯកអគ្គរដ្ឋទូតបារាំង ប្រចាំនៅកម្ពុជា និង លោក Laurent Lemarchand ជាទីប្រឹក្សាទូតទីមួយ។ សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិសូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ដែលបានសហការ និងអនុញ្ញាអោយយើងខ្ញុំចូលជួប។

របាយការណ៍នេះ គឺជាលទ្ធផលនៃការងាររបស់អ្នកទទួលបេសកកម្មសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ។ ការសិក្សានៃរបាយការណ៍នេះផ្អែកលើពង្រាងក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ដែលឥឡូវនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុង ពិនិត្យ។ តាមពិតទៅ បន្ទាប់ពីបានជួបពិភាក្សាជាមួយឥស្សរៈជនខាងលើ ក៏ដូចជាតំណាងនៃសង្គមស៊ីវិល អ្នកទទួលបេសកកម្មយល់ថា វាជាការប្រសើ ដែលត្រូវធ្វើការសិក្សាពីលទ្ធភាពបញ្ចូលបញ្ញត្តិនៃលក្ខន្តិកៈ ទៅក្នុងពង្រាងក្រមទាំងពីរខាងលើ ជាជាងសិក្សាទៅលើលទ្ធភាពនៃច្បាប់ដោយឡែកមួយទៀត ដើម្បីដាក់ច្បាប់ខ្មែរអោយស្របទៅនឹងលក្ខន្តិកៈនៃតុលាការព្រហ្ម-ទណ្ឌអន្តរជាតិនោះ។ ម្យ៉ាងទៀត ការកែទំរង់ដែលកំពុងតែដំណើរការ ជាឱកាសដ៏ល្អមួយក្នុងការបញ្ចូលបញ្ញត្តិនៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ទៅក្នុងពង្រាងក្រមទាំងពីរ ដើម្បីអោយបញ្ញត្តិទាំងនេះអាចមានសុពលភាពអនុវត្តបាន បន្ទាប់ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នហើយនោះ។

របាយការណ៍នេះមិនធ្វើអោយប៉ះពាល់ ឬ បង្អាក់ដំណើរ ឬ ការសន្សំសំចៃទូទៅណាមួយរបស់ពង្រាង ក្រមទាំងពីរនេះបន្តិចណាឡើយ។ ផ្ទុយទៅវិញ វាជាការឈានទៅមុខដ៏សំខាន់មួយយ៉ាងពិតប្រាកដ ដើម្បីដាក់ច្បាប់កម្ពុជាអោយស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីការការពារសិទ្ធតមនុស្ស ដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។ ម្យ៉ាងវិញទៀត ការ

អនុម័តជាបន្ទាន់នៃពង្រាងក្រមទាំពីរនេះអាចធានាដល់ សន្តិសុខផ្នែកច្បាប់មួយផ្នែកធំ ផងដែរ ព្រោះថា ពង្រាងក្រមទាំពីរនេះនឹងជំនួសច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌមួយចំនួន ដែលត្រួតគ្នា និងអាចនាំអោយមានភាពផ្ទុយគ្នានោះ។ សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិយល់ថា ត្រូវតែអនុម័តពង្រាងក្រមទាំងពីរ នេះជាប្រញាប់ ដូចដែលក្រុមពិគ្រោះយោបល់នៃម្ចាស់ជំនួយបានលើកឡើងកាលពីឆ្នាំ២០០៤មកនោះ។

ដូច្នេះ របាយការណ៍នេះស្នើសុំអោយមានការកែប្រែ ជាពិសេស លើផ្នែកបច្ចេកទេសនៃពង្រាងក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្ន។ ហើយម្យ៉ាងទៀត ការកែប្រែ ដែលធ្វើដោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាទទួលបន្ទុកធ្វើបញ្ចប់អង្រាងទាំងពីរនេះ នឹងមិនធ្វើអោយយឺតយ៉ាវដល់ការអនុម័តច្បាប់ដ៏សំខាន់នេះទេ។

ការងារនេះត្រូវបានធ្វើឡើងក្នុងស្មារតីសហការគ្នាជាមួយអាជ្ញាធរកម្ពុជា ហើយសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិសង្ឃឹមថា ការងារនេះនឹងទទួលបានការយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរកម្ពុជា។ តាមរបៀបនេះ ព្រះរាជាណាចក្រកម្ពុជានឹងមិនត្រឹមតែជាប្រទេសទីមួយ ក្នុងតំបន់ ដែលបានផ្តល់សច្ចាប័នដល់លក្ខន្តិកៈស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងជាប្រទេសដ៏កំរមួយក្នុងពិភពលោក ដែលបានបញ្ចូលលក្ខន្តិកៈនេះទៅក្នុងច្បាប់ក្នុងស្រុក។

# ផ្នែកទី១៖ ការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាប់ពីឆ្នាំ២០០០មកទល់នឹងបច្ចុប្បន្ន

## សេចក្តីផ្តើម

កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០០ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។ កម្ពុជាបានផ្តល់សច្ចាប័នលើលក្ខន្តិកៈនេះ នៅថ្ងៃទី៧ ខែមករា ឆ្នាំ ២០០២ ហើយបានតំកល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័ននេះនៅឯអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ នៅថ្ងៃ ទី១១ ខែមេសា ឆ្នាំ ២០០២។ យោងតាមមាត្រា ១២៦ លក្ខន្តិកៈទីក្រុងរ៉ូមបានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២។ ចាប់ពីពេលនោះមក កម្ពុជាត្រូវអនុវត្តដោយសុចរិតនូវរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងលក្ខន្តិកៈ។ ក៏ប៉ុន្តែ នៅថ្ងៃ ទី២៧ មិថុនា ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយសហរដ្ឋអាមេរិក ដើម្បីដាក់ពលរដ្ឋអាមេរិក និងពលរដ្ឋខ្មែរ អោយនៅក្រៅសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទៅវិញ។

### ជំពូកទី១៖ ការផ្តល់សច្ចាប័នដល់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

ក្រោយពីការចុះហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូមដោយរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិលបានខិតខំប្រឹងប្រែងដើម្បីជំរុញឱ្យមានការផ្តល់សច្ចាប័នឱ្យបានឆាប់លើលក្ខន្តិកៈនេះ ដោយខ្លួនយល់ឃើញថា យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ គឺជាស្ថាប័នមួយដ៏សំខាន់បំផុត។

នៅថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០០១ សមាគមការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា ADHOC ដោយរួមសហប្រតិបត្តិការ ជាមួយសម្ព័ន្ធអន្តរជាតិសំរាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (CCPI) បានរៀបចំនូវសិក្ខាសាលាមួយ។ គំនិតផ្តួចផ្តើមធ្វើសិក្ខាសាលានេះបានទទួលនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល។ អ្នកជំនាញការ ច្បាប់ មេធាវី មន្ត្រីក្រសួងយុត្តិធម៌ សមាជិកគណៈកម្មការសិទ្ធិមនុស្ស របស់រាជរដ្ឋាភិបាល សមាជិករាជរដ្ឋាភិបាល សមាជិកតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាមកពីគណបក្សធំៗទាំងបី (គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិក) បានចូលរួមក្នុងសិក្ខាសាលានោះ[៣]។

[៣] លទ្ធផលនៃសិក្ខាសាលានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងសន្និសីទកាសែតមួយ។ សូមមើល: ADHOC និងវេទិកាអាស៊ី *សិក្ខាសាលាជាតិស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី៣០ និង៣១ ខែឧសភា ឆ្នាំ២០០១* សណ្ឋាគារសាន់វ៉េ ភ្នំពេញ ៧០ទំព័រ (មានជាភាសាខ្មែរ)។

ក្រោយពីសិក្ខាសាលាជាតិនេះ នាយករដ្ឋមន្ត្រីកម្ពុជាបានទទួលជួបជាមួយគណៈប្រតិភូ ដែលរួមមាន អ្នកជំនាញការអន្តរជាតិ ដឹកនាំដោយលោក **ធន សារ៉ាយ** ប្រធានសមាគម ADHOC និងលោក **សំចៃ ហុំឡាអរ** (Samchai Homlaor) អគ្គលេខាធិការនៃវេទិការអាស៊ីដើម្បីសិទ្ធិមនុស្ស (វេទិការអាស៊ី)។ នៅក្នុងពេល ជួបសន្ទនាគ្នានោះ គណៈប្រតិភូបានផ្តល់នូវអនុសាសន៍មួយចំនួនជូនដល់ប្រមុខរាជរដ្ឋាភិបាល។ ហើយពេលនោះ លោក នាយករដ្ឋមន្ត្រីបានបញ្ជាក់អះអាងថា សេចក្តីព្រាងច្បាប់ស្តីពីការផ្តល់សច្ចាប័នដល់លក្ខន្តិកៈទីក្រុងរ៉ូមនឹងត្រូវដាក់ជូន ទៅសភាជាតិ ក្នុងពេលឆាប់ៗខាងមុខ។

នៅថ្ងៃទី២៦ ខែវិច្ឆិការ ឆ្នាំ ២០០១ សេចក្តីព្រាងច្បាប់ស្តីការផ្តល់សច្ចាប័នដល់លក្ខន្តិកៈទីក្រុងរ៉ូមត្រូវបានដាក់ជូនអង្គសភាដើម្បីពិនិត្យ។ នៅថ្ងៃបន្ទាប់ សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាឯកឆ័ន្ទដោយអ្នកតំណាងរាស្ត្រ[៤]។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ ២០០២ សម្តេច **ជា ស៊ីម** ប្រមុខរដ្ឋស្តីទីបានប្រកាសឱ្យប្រើច្បាប់ស្តីពីការផ្តល់សច្ចាប័ននេះ ដោយព្រះមហាក្សត្រទ្រង់គង់នៅទីក្រុងប៉េកាំង។

ប្រទេសកម្ពុជា និងថៃ គឺជាប្រទេសតែពីរគត់ក្នុងចំណោមសមាជិកសមាគមអាស៊ាន ដែលបានចុះហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូម ហើយកម្ពុជាគឺជាប្រទេសតែមួយគត់ក្នុងអាស៊ាន ដែលបានផ្តល់សច្ចាប័នដល់ លក្ខន្តិកៈនេះ។

[៤] ការជជែកដេញដោលនៅក្នុងរដ្ឋសភាត្រូវបានធ្វើឡើងយ៉ាងឆាប់បំផុត ដោយមិនបានលើកឡើងនូវអភ័យឯកសិទ្ធិនៃព្រះ មហាក្សត្រដែលមានចែងនៅ ក្នុងមាត្រា ៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឡើយ។ ក៏ប៉ុន្តែចំនុចនេះបាននាំឱ្យមាន ការចោទជាសំនួរថាតើអភ័យឯកសិទ្ធិនេះស្របទៅនឹងមាត្រា ២៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែរឬទេ។ យោងតាមអ្នកតំណាងរាស្ត្រ ខៀវ សន ដែលកាលនោះជាសមាជិកព្រឹទ្ធសភា បានឱ្យដឹងថា មិនមានហេតុផលណាមួយ ដែលយើងត្រូវយកបញ្ហាអភ័យឯកសិទ្ធិរបស់ព្រះមហាក្សត្រមកជជែកពិភាក្សានោះទេ ព្រោះថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែង យ៉ាងច្បាស់ណាស់ថា ព្រះមហាក្សត្រទ្រង់គ្រងរាជ តែមិនកាន់អំណាច ហើយអង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបាន ដូចនេះការលើកយកបញ្ហាអភ័យឯកសិទ្ធិ ព្រះមហាក្សត្រមកជជែកពិភាក្សា គឺជាការរំលោភទៅលើរដ្ឋធម្មនុញ្ញ។ ផ្ទុយទៅវិញ មាត្រា ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មិនមានន័យដែល អាចរារាំងការអនុវត្តន៍នូវមាត្រា ២៧ នៃ លក្ខន្តិកៈទីក្រុងរ៉ូមបានទេ ដោយហេតុថា ចៅក្រមអន្តរជាតិតែងតែប្រកាន់នូវគោលការណ៍ ដែលឱ្យបទដ្ឋានអន្តរជាតិមានឧត្តមភាពទៅលើបទដ្ឋានជាតិ ទោះបីជាបទដ្ឋាននោះមានតំលៃជារដ្ឋធម្មនុញ្ញក៏ដោយ។ ក្នុងន័យនេះ តុលាការយុត្តិធម៌ អចិន្ត្រៃយ៍អន្តរជាតិ (CPJI) បានចេញសេចក្តីសំរេចមួយនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៣២ ទាក់ទងនឹងចំណាត់ការលើ ពលរដ្ឋប៉ូឡូញនៅក្រុង Dantzig (Série A/B, n°44, p.24)។ សេចក្តីសំរេចនេះបានចែងថា *"យោងទៅលើ គោលការណ៍ដែលត្រូវបានគេអនុវត្តជាទូទៅ រដ្ឋមួយមិនអាចលើកឡើងជាសំអាងនូវរដ្ឋធម្មនុញ្ញ នៃរដ្ឋមួយទៀតបានទេ គឺ អាចលើកឡើងតែនីតិអន្តរជាតិ និងកាតព្វ កិច្ចរបស់រដ្ឋនោះ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិតែប៉ុណ្ណោះ។ ផ្ទុយមកវិញ រដ្ឋមួយមិនអាចយករដ្ឋធម្មនុញ្ញរបស់ខ្លួនមកធ្វើជាសំអាងឱ្យ រួចផុតពី កាតព្វកិច្ចក្នុងនីតិអន្តរជាតិ ឬកិច្ចព្រម-ព្រៀងជាធរមានបានឡើយ"*។ សេចក្តីសំរេចរបស់មជ្ឈត្តករ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៨៧៥ សំណុំរឿង *Montijo* រវាង សហរដ្ឋអាមេរិក និងកូឡុមប៊ីបានចែងថា: *"សន្ធិសញ្ញា មានតំលៃធំជាងរដ្ឋធម្មនុញ្ញ។ នីតិកម្មរបស់កូឡុមប៊ីត្រូវតែសម្រប នឹងសន្ធិសញ្ញា មិនមែនសន្ធិសញ្ញា ត្រូវសម្របនឹងច្បាប់ផ្ទៃក្នុងនោះទេ"* (Moore, Arbitration, p.1850)។ មាត្រា ៦ នៃ សេចក្តីព្រាងរបស់គណៈកម្មាការនីតិអន្តរជាតិ (CDI) ទាក់ទងនឹងការ ទទួលខុសត្រូវរបស់រដ្ឋបានចែងថា: *"ក្នុងនីតិអន្តរជាតិ សកម្មភាពនៃស្ថាប័នរបស់រដ្ឋមួយត្រូវចាត់ទុកថា ជាសកម្មភាពរបស់រដ្ឋនោះ ទោះបីជាស្ថាប័ននោះជាអំណាចធម្មនុញ្ញ អំណាចនីតិបញ្ញត្តិ អំណាចតុលាការ ឬអំណាចផ្សេងណាទៀតក៏ដោយ ..."*។

## ជំពូកទី២ៈ កិច្ចព្រមព្រៀងទ្វេរភាគីរវាងកម្ពុជា និងសហរដ្ឋអាមេរិក នៅថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០០៣

ក្រោយពីលក្ខន្តិកៈទីក្រុងរ៉ូមបានចូលជាធរមាន រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវសន្និសីទមួយនៅថ្ងៃទី៩-១០ ខែតុលា ឆ្នាំ២០០២ ដែលក្នុងនោះមានប្រទេសប្រមាណ២០ចូលរួម។ ក្នុងសន្និសីទនោះ រាជរដ្ឋាបាលបានជំរុញឱ្យប្រទេសដ៏ទៃទៀតយកតម្រាប់តាមប្រទេសកម្ពុជា ដោយផ្តល់សច្ចាប័នដល់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ[៥] ។

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ មិនអាចរារាំងកម្ពុជាក្នុងការចុះហត្ថលេខាជាមួយសហរដ្ឋអាមេរិកនូវកិច្ចព្រមព្រៀងទ្វេរភាគីដ៏ចំរូងចម្រាស កាលពីថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៣ នោះទេ។ កិច្ចព្រមព្រៀងនេះទាក់ទងនឹង "ការមិនបញ្ជូនខ្លួនជូនតុលាការព្រហ្មទណ្ឌអន្តរជាតិ" និងបង្កើតនូវអភ័យឯកសិទ្ធិយុត្តាធិការចំពោះតុលាការអន្តរជាតិនេះ។ កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃយុទ្ធនាការរបស់សហរដ្ឋអាមេរិកប្រឆាំងនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយត្រូវបានចុះហត្ថលេខាក្រោយពី ទស្សនកិច្ចរបស់រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ខូលីន ផូវ៉ែល នៅកម្ពុជា[៦] ។

ហេតុនេះ កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសប្រមាណមួយរយ[៧] ដែលបានចុះកិច្ចព្រមព្រៀងជាមួយសហរដ្ឋអាមេរិក ដែលក្នុងនោះ មានជាងមួយភាគបីជារដ្ឋសមាជិកលក្ខន្តិកៈទីក្រុងរ៉ូម។

សភាកម្ពុជាបានផ្តល់សច្ចាប័នកិច្ចព្រមព្រៀងជាមួយសហរដ្ឋអាមេរិកនៅខែ ឧសភា ឆ្នាំ ២០០៥[៨] តាមរយៈច្បាប់ផ្តល់សច្ចាប័ន ដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៥[៩] ។

[៥] ក្នុងសន្ទរកថាបិទសន្និសីទ ឯកឧត្តមសុខ អាន ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានមាន ប្រសាសន៍ថាៈ *"តាមរយៈ ការចុះហត្ថលេខា នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៣ និងការផ្តល់សច្ចាប័នថ្មីៗនេះដល់លក្ខន្តិកៈក្រុងរ៉ូម ព្រះរាជាណាចក្រកម្ពុជាបញ្ជាក់យ៉ាងច្បាស់ អំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការរួម ចំណែកលើកកំពស់សិទ្ធិមនុស្ស និងក្នុងនីតិមនុស្សធម៌អន្តរជាតិ ស្របទៅនឹងគោលការណ៍ដ៏ប្រពៃ ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ (បុព្វកថា មាត្រា៣១ និង៣២) យើងជឿជាក់ថា សន្និសីទនេះនឹងជំរុញប្រទេសផ្សេងៗទៀតដែលមិនទាន់បានចុះហត្ថលេខា ឬ ផ្តល់សច្ចាប័នដល់លក្ខន្តិកៈទីក្រុងរ៉ូម ឱ្យចូលរួមជាមួយកម្ពុជាធ្វើជាភាគីនៃលក្ខន្តិកៈនេះ ហើយយើងសូមលើកទឹកចិត្តដល់ប្រទេសដែលជាសមាជិកតុលាការ ព្រហ្មទណ្ឌអន្តរជាតិឱ្យបន្តនូវការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើតនូវមូលដ្ឋានគ្រឹះរឹងមាំមួយសំរាប់តុលាការនេះ"*។ (សន្និសីទស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅសណ្ឋាគារ Intercontinental ភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២) ។

[៦] "Cambodia to exempt US citizens from ICC prosecution", *ABC Radio Australia News*, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣។

[៧] សូមមើលតារាងលេខ១ ទំព័រទី ២២ ។

## ក. លក្ខណៈទូទៅនៃកិច្ចព្រមព្រៀងទ្វេរភាគី

កិច្ចព្រមព្រៀងទ្វេរភាគីនេះបានចែងថា "បុគ្គលទាំងឡាយ" ជាមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្ន ឬ អតីតមន្ត្រីក្តី ជានិយោជិក (រួមទាំងបុគ្គលិកជាប់កិច្ចសន្យាផង) ឬ បុគ្គលិកយោធា ឬពលរដ្ឋរបស់ប្រទេសជាភាគី "ក" ដែលមានវត្តមាននៅលើទឹកដីនៃភាគី "ខ" បើគ្មានការយល់ព្រមដោយជាក់លាក់ពីភាគី "ក" ទេនោះ ប្រទេសជាភាគី "ខ" មិនអាចៈ

-ប្រគល់ ឬ ផ្ទេរបុគ្គលទាំងឡាយខាងលើនេះដោយមធ្យោបាយណាមួយទៅឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិបានទេទោះបីតាមវិធីណា និងក្នុងហេតុផលណាក៏ដោយ ។

-ប្រគល់ ឬផ្ទេរបុគ្គលទាំងឡាយខាងលើនេះដោយមធ្យោបាយណាមួយ ទៅឱ្យស្ថាប័នណាមួយ ឬ ប្រទេសទី៣ណាមួយ ឬ ត្រូវបណ្តេញអោយទៅប្រទេសទី៣ណាមួយក្នុងគោលបំណង ប្រគល់ខ្លួន ឬ ផ្ទេរខ្លួនអោយទៅតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ ។

យើងអាចនិយាយបានម្យ៉ាងទៀតថា នៅពេលដែលកម្ពុជាត្រូវបានស្នើសុំឱ្យចាប់បុគ្គលណាមួយ ក្នុងចំណោមបុគ្គលដូចដែលបានរៀបរាប់ខាងលើ បញ្ជូនទៅតតិយរដ្ឋណាមួយ ដើម្បីឱ្យរដ្ឋនេះបញ្ជូនបុគ្គលខាងលើបន្តទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ កម្ពុជាមិនអាចធ្វើតាមការស្នើសុំនេះបានទេ ប្រសិនបើមិនមានការព្រមព្រៀង ដោយជាក់លាក់ពីរដ្ឋាភិបាលអាមេរិក។ ករណីនេះក៏នឹងត្រូវអនុវត្តផងដែរចំពោះរដ្ឋាភិបាលអាមេរិកក្នុងពេលដែលខ្លួនត្រូវបានស្នើសុំអោយចាប់បញ្ជូនបុគ្គលដែលកម្ពុជាយល់ថាជាប្រភេទបុគ្គលខាងលើ ។

មាត្រា ៥ ចែងថា កិច្ចព្រមព្រៀងនេះនឹងនៅតែបន្តសុពលភាពរបស់ខ្លួនក្នុងរយៈពេលមួយឆ្នាំក្រោយពី ភាគីណាមួយជូនដំណឹងទៅភាគីមួយទៀតពីការលុបចោលកិច្ចព្រមព្រៀងនេះ ។

---

[៨] រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការផ្តល់សច្ចាប័ននៅថ្ងៃទី១៨ ខែឧសភា ២០០៥ ហើយព្រឹទ្ធសភាអនុម័តនៅថ្ងៃទី៣០ ខែ ឧសភា។

[៩] ព្រះរាជក្រម លេខ នស.រកម ០៦០៥/០១៧

## ខ. ការអត្ថាធិប្បាយរិះគន់លើកិច្ចព្រមព្រៀង

ក្នុងការចុះកិច្ចព្រៀងនេះ សហរដ្ឋអាមេរិក និងកម្ពុជាបានលើកយកមកជាសំអាងដោយមិនសមហេតុផលនូវមាត្រា ៩៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលហាមឃាត់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអោយបន្តការអនុវត្តនូវការស្នើសុំចាប់បញ្ជូន ឬ ជំនួយផ្សេងៗទៀត ដែលមានលក្ខណៈជាការចាប់បង្ខំរដ្ឋមួយឱ្យរំលោភលើកាតព្វកិច្ច របស់ខ្លួននៅក្នុងសន្ធិសញ្ញាអន្តរជាតិដែលចែងថា ការចាប់បញ្ជូនពលរដ្ឋរបស់រដ្ឋនេះ ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវតែទទួលបាននូវការព្រមព្រៀងពីខ្លួនជាមុន។ ម្យ៉ាងទៀត ភាគីទាំងពីរនៃកិច្ចព្រមព្រៀងទ្វេភាគីបានលើកឡើងថា សមត្ថកិច្ចរបស់តុលាការអន្តរជាតិនេះ មិនមានសមត្ថកិច្ចធំជាងតុលាការជាតិទេ គឺគ្រាន់តែមានសមត្ថកិច្ចបន្ថែមលើសមត្ថកិច្ចតុលាការជាតិប៉ុណ្ណោះ។

និយាយជារួម ការលើកឡើងនូវលក្ខន្តិកៈទីក្រុងរ៉ូមមកធ្វើជាសំអាងដើម្បីចុះកិច្ចព្រមព្រៀងទ្វេភាគី ដែលប៉ះពាល់ដល់គោលដៅចំបងនៃការបង្កើតតុលាការអន្តរជាតិនេះ បង្ហាញនូវភាពចន្លោះប្រហោងនៃទឡ្ហីករណ៍គតិយុត្ត ដែលភាគីទាំងពីរបានលើកឡើង។

សហរដ្ឋអាមេរិក ក្រោយពីចុះហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូម បានប្រកាសជាសាធារណៈថាខ្លួននឹងមិនផ្តល់សច្ចាប័នដល់លក្ខន្តិកៈនេះទេ[១០] មិនតែប៉ុណ្ណោះបានធ្វើយុទ្ធនាការនៅទូទាំងពិភពលោក ដែលនាំឱ្យប៉ះពាល់ដល់អានុភាពគតិយុត្តនៃលក្ខន្តិកៈនេះ ដោយការចុះកិច្ចព្រមព្រៀងទ្វេភាគីច្រានចោលសមត្ថកិច្ចរបស់តុលាការអន្តរជាតិនេះ[១១]។ អំពើ

[១០] នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០២ សហរដ្ឋអាមេរិកបានប្រកាសថាខ្លួននឹងមិនផ្តល់សច្ចាប័នដល់លក្ខន្តិកៈទីក្រុងរ៉ូមទេ ហើយថែមទាំងបានប្រកាសលុបចោល នូវហត្ថលេខារបស់ខ្លួនលើលក្ខន្តិកៈនេះទៀតផង: "សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រី ការពារជាតិសហរដ្ឋអាមេរិក Rumsfeld ស្តីពីលក្ខន្តិកៈទីក្រុងរ៉ូម" ក្រសួងការពារជាតិសហរដ្ឋអាមេរិក សេចក្តីប្រកាស ពតិមានលេខ ២៣៣-០២ ចុះថ្ងៃទី៦ ឧសភា ២០០២ (www.defenselink.mil/releqses/2002/ b05062002_bt233-02.html)។

[១១] យុទ្ធនាការនេះត្រូវបានធ្វើឡើងតាមវិធីពីរយ៉ាង។ ទីមួយគឺការស្វែងរកដំណោះស្រាយពីក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ នៅថ្ងៃទី១២ កក្កដា ២០០២ ដែលបើកផ្លូវឱ្យមានការលើកឡើងនូវមាត្រា ១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមដើម្បីពន្យារពេល ការស៊ើបអង្កេត ឬ ចោទប្រកាន់ដែលធ្វើឡើងដោយតុលាការអន្តរជាតិ ប្រឆាំងនឹងពលរដ្ឋនៃប្រទេសដែលមិនមែនជា ភាគីនៃលក្ខន្តិកៈ ចំពោះរាល់បទល្មើសទាក់ទងនឹងប្រតិបត្តិការដែលផ្តើមឡើង ឬដែលត្រូវបានអនុញ្ញាតដោយអង្គការ សហប្រជាជាតិ (ដំណោះស្រាយលេខ១៤២២)។ វិធីទីពីរ គឺការចុះហត្ថលេខាទ្វេភាគី ដើម្បីផ្តល់អភ័យឯកសិទ្ធិ យុត្តាធិការដល់ពលរដ្ឋខ្លួន ដែលត្រូវបានចោទប្រកាន់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះបីជាការស៊ើបអង្កេត ឬ ការចោទប្រកាន់នោះត្រូវបានស្នើឡើង ដោយសហរដ្ឋអាមេរិក ឬប្រទេសណាផ្សេងក្តី។ យុទ្ធនាការតាមរូបភាពទីពីរនេះត្រូវបានធ្វើឡើងដោយប្រើប្រាស់ នូវការគំរាមកំហែងផ្តាច់ជំនួយយោធា ចំពោះរាល់ប្រទេសដែលជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលមិនព្រមចុះហត្ថលេខាជាមួយ សហរដ្ឋអាមេរិក។ នៅដើមខែសីហា ឆ្នាំ២០០២ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានជូនដំណឹងដល់ឯកអគ្គរដ្ឋ រាជទូតបរទេសអំពីការជំទាស់របស់សហរដ្ឋអាមេរិកទៅនឹង តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយបានព្រមានថាមាត្រា ២០០៧ នៃច្បាប់ស្តីពីការការពារបុគ្គលិកយោធាអាមេរិកដែលបានចូលជាធរមានកាលពីថ្ងៃទី២ ខែសីហា ២០០២ ហាមប្រាមការផ្តល់នូវរាល់ជំនួយផ្នែកយោធាដល់ប្រទេស ដែលជាភាគីនៃលក្ខន្តិកៈ

នេះ គឺជាការរំលោភទៅលើកាតព្វកិច្ចអន្តរជាតិ ដែលរដ្ឋមួយមិនត្រូវធ្វើឱ្យសន្ធិសញ្ញាមួយបាត់សុពលភាពមុនពេល ដែលសន្ធិសញ្ញានេះចូលជាធរមាននោះឡើយ[១២] ។

យោងតាមមាត្រា ១៨ អនុសញ្ញាក្រុងវីយែន ស្តីពីនីតិសន្ធិសញ្ញា[១៣] រដ្ឋមួយដែលបានចុះហត្ថលេខាលើ សន្ធិសញ្ញាណាមួយ នៅក្នុងកំឡុងពេលរង់ចាំការផ្តល់សច្ចាប័នដល់សន្ធិសញ្ញានេះ មិនត្រូវធ្វើនូវសកម្មភាពណាមួយ ដែលនាំឱ្យប៉ះពាល់ដល់គោលដៅ និងវត្ថុបំណងរបស់សន្ធិសញ្ញាខាងលើនេះឡើយ ។ កាតព្វកិច្ចនេះកើតឡើងនៅមុនពេលដែលសន្ធិសញ្ញានេះចូលជាធរមានទៅទៀត[១៤] ។ វាជាកាតព្វកិច្ចនៅក្នុងនីតិទំនៀមទំលាប់អន្តរជាតិ[១៥] ។

### ១- អំពីគោលការណ៍បន្ថែម

គោលការណ៍បន្ថែមដែលបានលើកឡើងដោយសហរដ្ឋអាមេរិក និង កម្ពុជា មិនអាចជាហេតុផលសមរម្យសំរាប់ការចុះកិច្ចព្រមព្រៀងរវាងប្រទេសទាំង ពីរនេះបានទេ ។

ជាការពិត គោលការណ៍នេះមានគោលដៅផ្តល់ដល់តុលាការព្រហ្មទណ្ឌអន្តរជាតិនូវសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ប្រសិនបើរដ្ឋមួយគ្មានឆន្ទៈ ឬ គ្មានសមត្ថភាពក្នុងការជំនុំជម្រះ

---

ទីក្រុងរ៉ូម ។ ប៉ុន្តែមាត្រាដដែលអនុញ្ញាតឱ្យប្រធានាធិបតី សហរដ្ឋអាមេរិកលុបចោលនូវការហាមប្រាមនេះ ចំពោះប្រទេសណាដែល ចុះកិច្ចព្រមព្រៀងទ្វេរភាគីជាមួយខ្លួន ឬ ប្រសិនបើ ប្រធានាធិបតីយល់ឃើញថា ការលុបចោលការហាមប្រាមនេះធ្វើឡើងក្នុងផល ប្រយោជន៍ជាតិ ។ សំរាប់ការសិក្សាលំអិតទៅលើយុទ្ធនាការនេះ សូមមើលរបាយការណ៍របស់ FIDH, « Non à l’exception américaine », www.fidh.org ។

[១២] ក្រោយពីបានប្រកាសឱ្យដឹងថាខ្លួននឹងមិនផ្តល់សច្ចាប័ន និងលុបចោលនូវហត្ថលេខាលើលក្ខន្តិកៈទីក្រុងរ៉ូម អាមេរិក លែងជាប់ចំណងនៃកាតព្វកិច្ចនេះក្នុងឋានៈ ជាភាគីហត្ថលេខី ដែលបានចុះហត្ថលេខានៅថ្ងៃទី៦ ឧសភា ២០០២ ទៀតហើយ ។

[១៣] *"រដ្ឋមួយមិនត្រូវធ្វើនូវសកម្មភាពណាដែលនាំឱ្យប៉ះពាល់ដល់គោលដៅ និងវត្ថុបំណងរបស់សន្ធិសញ្ញា:*

*ក. នៅពេលដែលខ្លួនបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ឬបានផ្លាស់ប្តូរលិខិតូបករណ៍ទាក់ទងនឹងការបង្កើត សន្ធិសញ្ញានេះ ដោយរង់ចាំការផ្តល់ សច្ចាប័ន ការអនុម័តយល់ព្រម ហើយមិនទាន់បង្ហាញពីចេតនាក្នុងការមិនចូល ជាភាគីនៃសន្ធិសញ្ញា ។*

*ខ. នៅពេលដែលខ្លួនបានព្រមព្រៀងគោរពនូវរាល់កាតព្វកិច្ចក្នុងសន្ធិសញ្ញា នៅក្នុងកំឡុងពេលមុនការចូលជាធរមាននៃសន្ធិសញ្ញា ប្រសិនបើការចូលជាធរមាននេះមិនមានការយឺតយ៉ាវទេ"* (មាត្រា ១៨ អនុសញ្ញាក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីនីតិសន្ធិសញ្ញា) ។

[១៤] Ph. Cahier, “L’obligation de ne pas priver un traité de son objet et de son but avant son entrée en vigueur”, *Mélanges Dehousse*, 1979, p. 31-37 ។ ក្នុងន័យនេះដែរ សូមមើល *Restatement (Third) of the Foreign Relations Law of the United States*, American Law Institute, 1987, n.7, section 312, p.3: ហត្ថលេខី *"មិនត្រូវប្រព្រឹត្តិនូវអំពើណាដែលនាំឱ្យមានការប៉ះពាល់ដល់គោលដៅ និងវត្ថុបំណងរបស់កិច្ចព្រមព្រៀង"* ។

[១៥] យោងតាមគណៈកម្មាការនីតិអន្តរជាតិ វិធាននេះ *"ត្រូវបានទទួលស្គាល់ជាទូទៅ"* (*Annuaire CDI*, vol. 2, 1969, pp. 169-202) ។ សូមមើលផងដែរ *Certains intérêts allemands en Haute-Silésie polonaise*, *Cour permanente de justice internationale*, 1926, série A, n°7, p.30 ។

បទឧក្រិដ្ឋទាំងនេះ (លក្ខណ្ឌនេះមានចែងនៅក្នុង មាត្រា ១៧ នៃលក្ខន្តិកៈ)។ ជាងនេះទៅទៀត គោលការណ៍បង្គ្រប់បន្ថែមនេះ តំរូវឱ្យរដ្ឋជាភាគីសហការជាមួយតុលាការស្របតាមកាតព្វកិច្ច ដែលមានចែងក្នុងលក្ខន្តិកៈ ជាពិសេសនៅ មាត្រា ៨៦ ៨៧ ៨៩ ៩០ និងមាត្រា ២៧។ ដូចនេះ ការច្រានចោលនូវសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយលុបចោលនូវរាល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋជាភាគី និងតុលាការ ក្នុងគ្រប់កាលៈទេសៈ ឬ "ទោះតាមវិធីណា ឬ ក្នុងហេតុផលណាក៏ដោយ" (ឃ្លាដែលបានប្រើក្នុងកិច្ចព្រមព្រៀងទ្វេភាគី) ដោយរារាំងមិនឱ្យមានការប្ដឹងទៅតុលាការ ចំពោះបទល្មើសដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការអន្តរជាតិនេះ ទោះបីក្នុងករណីអសមត្ថភាពរបស់រដ្ឋមួយក៏ដោយ គឺជាការផ្ទុយស្រឡះពីអត្ថន័យរបស់គោលការណ៍បន្ថែម ដែលបានចែងក្នុងបុព្វកថា និងមាត្រា ១ និង១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

តាមរយៈការចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយសហរដ្ឋអាមេរិក កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ ប្រទេសកម្ពុជាបានសន្យាជាមួយសហរដ្ឋអាមេរិកថានឹងមិនសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិទេ។
កម្ពុជាបានសន្យាថានឹងមិនចាប់បញ្ជូនទៅតុលាការនូវពលរដ្ឋអាមេរិក ឬ បុគ្គលណាមួយក្នុងចំណោមបុគ្គល ដែលមានចែងក្នុងកិច្ចព្រមព្រៀងខាងលើនេះ។ កម្ពុជាក៏នឹងមិនចាប់បញ្ជូននូវជនខាងលើនេះទៅអង្គការណា ឬ តតិយរដ្ឋណាមួយក្នុងគោលបំណងដើម្បីបញ្ជូនបន្តទៅតុលាការដែរ។ ការសន្យាបែបនេះគឺជាការរំលោភ លើកាតព្វកិច្ចជាសារវ័ន្តក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដែលចែងថារដ្ឋជាភាគីមានកាតព្វកិច្ចសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ។

សហរដ្ឋអាមេរិក ដែលមិនមែនជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម មិនជាប់កាតព្វកិច្ចដូចនេះទេ។ ហេតុនេះ សហរដ្ឋអាមេរិកមិនបានរំលោភលើលក្ខន្តិកៈទីក្រុងរ៉ូមឡើយ។ ក៏ប៉ុន្តែ នេះជាការដែលគួរឱ្យព្រួយបារម្ភបំផុត ដោយសង្កេតឃើញថា ច្បាប់អាមេរិកមិនអនុញ្ញាតឱ្យបានពេញលេញការផ្ដន្ទាទោសជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម[១៦]។

[១៦] មានភាពចន្លោះប្រហោងយ៉ាងច្រើន ដែលគួរឱ្យបារម្ភ ក្នុងនីតិកម្មរបស់សហរដ្ឋអាមេរិក ដែលនាំឱ្យយុត្តាធិការអាមេរិកមិនមានសមត្ថភាពក្នុងការចោទប្រកាន់ឧក្រិដ្ឋជនសង្គ្រាម (ដែលត្រូវបានឱ្យនិយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូម) ដែលបានប្រព្រឹត្តបទល្មើសនេះនៅឯបរទេស។ បទឧក្រិដ្ឋទាំងនេះមិនត្រូវបានឱ្យនិយមន័យច្បាស់លាស់ទេនៅក្នុងច្បាប់អាមេរិក។ តុលាការអាមេរិកក៏មិនអាចចោទប្រកាន់ ផងដែរ ជនដែលបានប្រព្រឹត្តិបទប្រល័យពូជសាសន៍នៅឯបរទេស ប្រសិនបើជននោះជាសមាជិកយោធាអាមេរិក ឬ ជាជនទាំងឡាយផ្សេងទៀតដែលមានចែងក្នុងកិច្ចព្រមព្រៀងថ្ងៃទី២៧ ខែមិថុនា ២០០៣។ ចំពោះការសិក្សាលំអិតស្ដីពីសមត្ថកិច្ចក្រៅ ដែនដីនៃយុត្តាធិការអាមេរិកលើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការធ្វើទារុណកម្ម សូមមើលឯកសាររបស់អង្គការ លើកលែងទោសអន្តរជាតិ, *Compétence universelle*, index AI : IOR 53/002/01 à 53/018/01 ជំពូកទី៤ ទី៦ ទី៨ និងទី១០ ខែកញ្ញា ២០០១។

ដូចនេះ ឧក្រិដ្ឋជនទាំងឡាយណាដែលមានចែងក្នុងកិច្ចព្រមព្រៀងទ្វេរភាគី ចុះថ្ងៃទី២៧ មិថុនា ២០០៣ នឹងអាចរួចផុតពីរាល់ការចោទប្រកាន់ទាំងអស់អំពីបទឧក្រិដ្ឋរបស់ខ្លួន។ ទោះបីជាមានភាពចន្លោះប្រហោងក្នុងនីតិកម្មរបស់សហរដ្ឋអាមេរិកក្នុងការផ្តន្ទាទោសជនទាំងនេះក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចធ្វើការចោទប្រកាន់ជនទាំងនេះបានដែរ។

## ២-អំពីមាត្រា៩៨ វាក្យខ័ណ្ឌទី២នៃលក្ខន្តិកៈទីក្រុងរ៉ូម

ដើម្បីជាសំអាងក្នុងការចុះកិច្ចព្រមព្រៀងទ្វេរភាគីសហរដ្ឋអាមេរិក និងកម្ពុជា ពួកគេក៏បានលើកឡើង ផងដែរ នូវមាត្រា ៩៨ វាក្យខ័ណ្ឌទី២ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ មាត្រានេះចែងថាៈ

*"តុលាការមិនអាចបន្តធ្វើសំណើសុំបញ្ជូនខ្លួន ដែលគួរអាចតម្រូវឱ្យរដ្ឋទទួលសំណើអនុវត្តផ្ទុយពីកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងនេះ ការយល់ព្រមពីរដ្ឋបញ្ជូនត្រូវតែតម្រូវឱ្យបញ្ជូនខ្លួន មនុស្សណាម្នាក់របស់រដ្ឋនោះទៅតុលាការ លុះត្រាណាតែតុលាការអាចទទួលជាមុន នូវកិច្ចសហប្រតិបត្តិការពីរដ្ឋបញ្ជូនលើការព្រមព្រៀងបញ្ជូនខ្លួន"* ។

អ្នកតាក់តែងលក្ខន្តិកៈទីក្រុងរ៉ូមលើកឡើងនូវកិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈ នៃកងកំលាំងប្រដាប់អាវុធមកធ្វើជាសំអាង។ ការប្រើពាក្យ "រដ្ឋបញ្ជូន" សំដៅ ជាទូទៅ ក្នុងនីតិអន្តរជាតិ លើរដ្ឋដែលបញ្ជូនកំលាំងទ័ពរបស់ខ្លួនឱ្យទៅឈរជើងនៅរដ្ឋមួយទៀត ដែលគេឱ្យឈ្មោះថា "រដ្ឋម្ចាស់ផ្ទះ"។ ការសិក្សាទៅលើសេចក្តីព្រាង និងលើដំណើរការនៃការតាក់តែងលក្ខន្តិកៈទីក្រុងរ៉ូមអាចបញ្ជាក់ច្បាស់លើការអះអាងខាងលើនេះ (អនុសញ្ញាក្រុងវីយែន ស្តីពីនីតិសន្ធិសញ្ញាចែងថា សេចក្តីព្រាង និងដំណើរការនៃការតាក់តែងសន្ធិសញ្ញាមួយ គឺជាឧបករណ៍គតិយុត្តសំរាប់ការបកស្រាយសន្ធិសញ្ញានេះ)[១៧]។

---

[១៧] *"គោលបំណងនៃការតាក់តែងមាត្រា ៩៨-២ គឺដើម្បីដោះស្រាយនូវរាល់វិវាទគតិយុត្ត ដែលអាចកើតមានឡើងដោយសារ កិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈ នៃកងកំលាំងប្រដាប់អាវុធ។ ផ្ទុយទៅវិញ មាត្រា ៩៨-២ មិនមានគោលដៅជំរុញឱ្យរដ្ឋជា ភាគីចុះកិច្ចព្រមព្រៀងដែលនាំឱ្យមានការរារាំងដល់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងការស្នើសុំកិច្ចសហប្រតិបត្តិការពីសំណាក់រដ្ឋជាភាគីនោះទេ។* (Hans-Peter Kaul et Claus Kress, « Jurisdiction and Cooperation in the Statute of the International Criminal Court: Principles and Compromises" [សមត្ថកិច្ច និងកិច្ចសហប្រតិបត្តិការ ក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិៈ គោលការណ៍ និងការសម្របសម្រួល], in *Yearbook of International Humanitarian Law*, vol.2, 1999, pp. 143-165។ សូមមើលផងដែរៈ Christopher Keith Hall, "The First Five Sessions of the UN Preparatory Commission for the International Criminal Court" [កិច្ចប្រជុំចំនួនប្រាំដំបូង នៃគណៈកម្មាការរៀបចំ

កិច្ចព្រមព្រៀងទ្វេភាគី ចុះថ្ងៃទី២៧ ខែមិថុនា ២០០៣ មិនមែនជាកិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈនៃកងកំលាំងប្រដាប់អាវុធទេ។ ការលើកឡើងនូវមាត្រា ៩៨-២ នៃលក្ខន្តិកៈទីក្រុងរ៉ូមមិនអាចជាសំអាងក្នុងការចុះកិច្ចព្រមព្រៀងនេះបានទេ។

នៅក្នុងការអនុវត្តជាអន្តរជាតិ កិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈនៃកងកំលាំងប្រដាប់អាវុធ ប្រសិនបើមានវិវាទខាងសមត្ថកិច្ចរវាងរដ្ឋនឹងរដ្ឋ រដ្ឋទាំងនោះតែងតែចែកគ្នាធ្វើការស៊ើបអង្កេត និងចោទប្រកាន់។ កិច្ចព្រមព្រៀងនេះមិនបានផ្តល់នូវអភ័យឯកសិទ្ធដល់ជនណាមួយនោះឡើយ[១៨]។

ផ្ទុយទៅវិញ កិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែ មិថុនា ២០០៣ បង្កើតជានិទណ្ឌភាពដល់ពលរដ្ឋអាមេរិក និងបុគ្គលផ្សេងទៀត ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ទោះបីជាបុគ្គលនេះបានប្រព្រឹត្តិនូវបទឧក្រិដ្ឋ ដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ ឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ។ ភាពចន្លោះប្រហោងក្នុងនីតិកម្មអាមេរិកជាឧបសគ្គដល់តុលាការអាមេរិកក្នុងការផ្តន្ទាទោសជន ទាំងឡាយខាងលើ ហើយម្យ៉ាងទៀត នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីនេះ សហរដ្ឋអាមេរិកក៏មិនបានសន្យាថានឹង ផ្តើមគំនិតក្នុងការផ្តន្ទាទោសជនទាំងនោះដែរ។

ជាងនេះទៅទៀត យោងតាមវិធាន ១៩៥ វាក្យខ័ណ្ឌទី១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មានតែតុលាការព្រហ្មទណ្ឌអន្តរជាតិតែមួយគត់ ដែលមានសិទ្ធិក្នុងការសំរេច ថាតើការស្នើសុំចាប់បញ្ជូនជនជាប់ចោទ គឺជាការតំរូវឱ្យរដ្ឋពាក់ព័ន្ធរំលោភលើកាតព្វកិច្ចនៃកិច្ចព្រមព្រៀង ដែលមានចែងក្នុង មាត្រា ៩៨-២

តាក់តែងលក្ខន្តិកៈនៃតុលាការ ឧក្រិដ្ឋកម្មអន្តរជាតិ], in *American Journal of International Law*, vol.94, 2000, p.786។ អត្ថបទនេះបង្ហាញថា មាត្រា ៩៨-២ ត្រូវបានគេដាក់បញ្ចូលបន្ថែមក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងកិច្ចព្រមព្រៀងស្តីពី លក្ខន្តិកៈនៃកងកំលាំងប្រដាប់អាវុធ) ។

[១៨] *"កិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈនៃកងកំលាំងប្រដាប់អាវុធ ដែលយកគំរូតាមកិច្ចព្រមព្រៀងរបស់អង្គការ OTAN មិន ផ្តល់អភ័យឯកសិទ្ធិដល់ជនណាមួយទេ គឺផ្តល់តែសិទ្ធិអនុវត្តជាអាទិភាពនូវសមត្ថកិច្ចរបស់"រដ្ឋបញ្ជូន" ចំពោះបទល្មើសមួយចំនួន ដូចជាបទល្មើសដែលបានប្រព្រឹត្តក្នុងការបំពេញតួនាទីរបស់កងកំលាំងប្រដាប់អាវុធតែប៉ុណ្ណោះ។ គោលការណ៍នេះ ក៏ដូចគ្នានឹងគោលការណ៍បន្ថែមនៃលក្ខន្តិកៈទីក្រុងរ៉ូមដែរ។ កិច្ចព្រមព្រៀងទាំងនេះត្រូវតែបកស្រាយទៅ តាមអ្វីដែលមានចែងក្នុង មាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមៈ ការចោទប្រកាន់ក្លែងក្លាយដែលត្រូវបានធ្វើឡើងក្នុងគោលបំណងឱ្យជនសង្ស័យរួចផុតពី ការទទួលខុសត្រូវព្រហ្មទណ្ឌមិនស្របទៅ នឹងគោលដៅនិងវត្ថុបំណងនៃវិធាននានាទាក់ទងនឹងសមត្ថកិច្ចនៃកិច្ចព្រមព្រៀង ស្តីពីលក្ខន្តិកៈនៃកងកំលាំង ប្រដាប់អាវុធ ដែលយកគំរូតាមកិច្ចព្រមព្រៀងនៃអង្គការ OTAN ឡើយ។ បើយោងទៅលើមាត្រា ៩៨-២ កិច្ចព្រមព្រៀងខាងលើនេះមិនមាន ចោទជាបញ្ហាអ្វីទេ* (Steffen Wirth, "Immunities, Related Problems, and Article 98 of the Rome Statute" [អភ័យឯកសិទ្ធិ បញ្ហាពាក់ព័ន្ធនឹងអភ័យឯកសិទ្ធិនេះ និងមាត្រា ៩៨-២ នៃលក្ខន្តិកៈទីក្រុងរ៉ូម], *Criminal Law Forum*, vol.12, 2002)។

នៃលក្ខន្តិកៈទីក្រុងរ៉ូមដែរឬទេ។ រដ្ឋបញ្ជូន និងរដ្ឋដែលទទួលការស្នើសុំមិនមានសិទ្ធិ ធ្វើសេចក្តីសំរេច បែបនេះដោយខ្លួនឯងនោះទេ ខុសពីការចែងក្នុងកិច្ចព្រមព្រៀងទ្វេរភាគី ចុះថ្ងៃទី២៧ មិថុនា ២០០៣។

សារុបសេចក្តីមក កិច្ចព្រមព្រៀងទ្វេរភាគីចុះថ្ងៃទី២៧ ខែមិថុនា ២០០៣ គឺជាការរំលោភទៅលើលក្ខន្តិកៈក្រុងរ៉ូមទាំងស្រុង។ កិច្ចព្រមព្រៀងនេះមានវិសមិតភាពនឹងគោលដៅ និងវត្ថុបំណងនៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលប្រទេសកម្ពុជាបានសន្យាថានឹងអនុវត្តតាម។ ដូចនេះ កិច្ចព្រមព្រៀងទ្វេរភាគី ដែលបានចុះហត្ថលេខាក្រោយពីកម្ពុជាបានផ្តល់សច្ចាប័នរួចហើយដល់លក្ខន្តិកៈទីក្រុងរ៉ូម គឺជាការខុសច្បាប់[១៩]។

**សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្សសូមផ្តល់អនុសាសន៍ដូចតទៅ:**

**ព្រះរាជាណាចក្រកម្ពុជាគួរជូនដំណឹងទៅសហរដ្ឋអាមេរិកពីចេតនារបស់កម្ពុជាក្នុងការលុបចោលនូវកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២៧ ខែមិថុនា ២០០៣។**

[១៩] យុត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់លើបញ្ហានេះ *"អនុសញ្ញាពហុភាគីគឺជាផលផ្លែនៃកិច្ចព្រមព្រៀងដែលត្រូវបានព្រមព្រៀង ដោយសេរីលើគ្រប់មាត្រា ដូចនេះគ្មានភាគីណាមួយនៃអនុសញ្ញានេះ តាមរយៈការសំរេចចិត្តជាឯកត្តោភាគី ឬតាមរយៈ កិច្ចព្រមព្រៀងណាមួយអាចបំផ្លាញ ឬបង្ខូចតំលៃនៃគោលដៅ និងវត្ថុបំណងនៃអនុសញ្ញាបានទេ។ នេះគឺជាគោលការណ៍ ដែលត្រូវបានគេទទួលស្គាល់ជាទូទៅក្នុងនីតិអន្តរជាតិ"* (C.I.J.I., avis du 28 mai 1951, p.21)។ ក្នុងន័យដូចគ្នានេះដែរ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិមិនអនុញ្ញាតឱ្យកិច្ចព្រមព្រៀងរវាងរដ្ឋនិងរដ្ឋរំលោភលើលក្ខន្តិកៈរបស់ខ្លួនឡើយ (សេចក្តី សំរេចចុះថ្ងៃទី១៩ សីហា ១៩២៩, série A, n°22, p.12)។

## តារាងទី១: បញ្ជីឈ្មោះរដ្ឋដែលបានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិកលក្ខន្តិកៈទីក្រុងរ៉ូម

មកទល់នឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០០៥ មានប្រទេសចំនួន១០០ហើយដែលបានផ្តល់សច្ចាប័ន ឬ បានចូលជាសមាជិកនៃលក្ខន្តិកៈទីក្រុងរ៉ូម។ មានប្រទេសចំនួន៤២ ក្នុងចំណោមប្រទេសទាំងនេះ (សំគាល់ដោយសញ្ញាផ្កាយ) បានចុះកិច្ចព្រមព្រៀងនិទណ្ឌភាពជាមួយសហរដ្ឋអាមេរិក[២០] ។

| ប្រទេស | កាលបរិច្ឆេទចុះហត្ថលេខា | កាលបរិច្ឆេទផ្តល់សច្ចាប័ន ឬចូលជាសមាជិក |
|---|---|---|
| អាហ្វហ្កានីស្ថាន* | | ១០ កុម្ភៈ ២០០៣ (ក) |
| អាហ្វ្រិកខាងត្បូង | ១៧ កក្កដា ១៩៩៨ | ២៧ វិច្ឆិកា ២០០០ |
| អាល់បានី* | ១៨ កក្កដា ១៩៩៨ | ៣១ មករា ២០០៣ |
| អាឡឺម៉ង់ | ១០ ធ្នូ ១៩៩៨ | ១១ ធ្នូ ២០០០ |
| អង់ឌរ | ១៨ កក្កដា ១៩៩៨ | ៣០ មេសា ២០០១ |
| អង់ទីហ្គ័រ និង បាប៊ូដា* | ២៣ តុលា ១៩៩៨ | ១៨ មិថុនា ២០០១ |
| អាហ្សង់ទីន | ៨ មករា ១៩៩៩ | ៨ កុម្ភៈ ២០០១ |
| អូស្ត្រាលី | ៩ ធ្នូ ១៩៩៨ | ១ កក្កដា ២០០២ |
| អូទ្រីស | ៧ តុលា ១៩៩៨ | ២៨ ធ្នូ ២០០០ |
| បាបាដ | ៨ កញ្ញា ២០០០ | ១០ ធ្នូ ២០០២ |
| ប៊ែលហ្ស៊ិក | ១០ កញ្ញា ១៩៩៨ | ២៨ មិថុនា ២០០០ |
| បេលីហ្ស* | ៥ មេសា ២០០០ | ៥ មេសា ២០០០ |
| បេណាំង* | ២៤ កញ្ញា ១៩៩៩ | ២៩ មករា ២០០២ |
| បូលីវី* | ១៧ កក្កដា ១៩៩៨ | ២៧ មិថុនា ២០០២ |
| បូស្នី អេហ្សេហ្គោវីន* | ១៧ កក្កដា ២០០០ | ១១ មេសា ២០០២ |
| បុតស្វាណា* | ៨ កញ្ញា ២០០០ | ៨ កញ្ញា ២០០០ |
| ប្រេស៊ីល | ៧ កុម្ភៈ ២០០០ | ២០ មិថុនា ២០០២ |
| ប៊ុលហ្គារី | ១១ កុម្ភៈ ១៩៩៩ | ១១ មេសា ២០០២ |
| ប៊ួរគីណាហ្វាសូ* | ៣០ វិច្ឆិកា ១៩៩៨ | ១៦ មេសា ២០០៤ |

[២០] ប្រភព (អ៊ីនធ័រណែត មើលនៅថ្ងៃទី១០ ខែកុម្ភៈ ២០០៦):

-អង្គការលើកលែងទោសអន្តរជាតិ (http://web.amnesty.org/pages/icc-signatures_ratifications-fra)

-សម្ព័ន្ធដើម្បីតុលាការព្រហ្មទណ្ឌអន្តរជាតិ (http://www.iccnow.org/documents/USandICC/BIAs.html)

| | | |
|---|---|---|
| ប៊ូរុនឌី* | ១៣ មករា ១៩៩៩ | ២១ កញ្ញា ២០០៤ |
| កម្ពុជា* | ២៣ តុលា ២០០០ | ១១ មេសា ២០០២ |
| កាណាដា | ១៨ ធ្នូ ១៩៩៨ | ៧ កក្កដា ២០០០ |
| កោះស៊ីព | ១៥ តុលា ១៩៩៨ | ៧ មិនា ២០០២ |
| កូឡុំប៊ី* | ១០ ធ្នូ ១៩៩៨ | ៥ សីហា ២០០២ |
| កុងហ្គោ* | ១៧ កក្កដា ១៩៩៨ | ៣ ឧសភា ២០០៤ |
| កូរ៉េខាងត្បូង | ៨ មិនា ២០០០ | ១៣ វិច្ឆិកា ២០០២ |
| កូស្តារីកា | ៧ តុលា ១៩៩៨ | ៧ មិថុនា ២០០១ |
| ក្រូអាត | ១២ តុលា ១៩៩៨ | ២១ ឧសភា ២០០១ |
| ដាណឺម៉ាក | ២៥ កញ្ញា ១៩៩៨ | ២១ មិថុនា ២០០១ |
| ជីប៊ូទី* | ៧ តុលា ១៩៩៨ | ៥ វិច្ឆិកា ២០០២ |
| ដូមីនីក* | | ១២ កុម្ភៈ ២០០១ (ក) |
| អេក្វាទ័រ | ៧ តុលា ១៩៩៨ | ៥ កុម្ភៈ ២០០២ |
| អេស្ប៉ាញ | ១៨ កក្កដា ១៩៩៨ | ២៥ តុលា ២០០០ |
| អេស្តូនី | ២៧ ធ្នូ ១៩៩៩ | ៣០ មករា ២០០២ |
| ហ្វ៊ីជហ្ស៊ី* | ២៩ វិច្ឆិកា ១៩៩៩ | ២៩ វិច្ឆិកា ១៩៩៩ |
| ហ្វាំងឡង់ | ៧ តុលា ១៩៩៨ | ២៩ ធ្នូ ២០០០ |
| បារាំង | ១៨ កក្កដា ១៩៩៨ | ៩ មិថុនា ២០០០ |
| ហ្គាបុង* | ២២ ធ្នូ ១៩៩៨ | ២១ កញ្ញា ២០០០ |
| ហ្គំប៊ី* | ៧ ធ្នូ ១៩៩៨ | ២៨ មិថុនា ២០០២ |
| ហ្សកហ្ស៊ី* | ១៨ កក្កដា ១៩៩៨ | ៥ កញ្ញា ២០០៣ |
| ហ្គាណា* | ១៨ កក្កដា ១៩៩៨ | ២០ ធ្នូ ១៩៩៩ |
| ក្រិក | ១៨ កក្កដា ១៩៩៨ | ១៥ ឧសភា ២០០២ |
| ហ្គីណេ* | ៧ កញ្ញា ២០០០ | ១៤ កក្កដា ២០០៣ |
| ហ្គួយ៉ាណា* | ២៨ ធ្នូ ២០០០ | ២៤ កញ្ញា ២០០៤ |
| ហុងឌូរ៉ាស់ * | ៧ តុលា ១៩៩៨ | ១ កក្កដា ២០០២ |
| ហុងគ្រី | ១៥ ធ្នូ ១៩៩៨ | ៣០ វិច្ឆិកា ២០០១ |
| អៀរឡង់ | ៧ តុលា ១៩៩៨ | ១១ មេសា ២០០២ |
| អ៊ីស្លង់ | ២៦ សីហា ១៩៩៨ | ២៥ ឧសភា ២០០០ |

| | | |
|---|---|---|
| អ៊ីតាលី | ១៨ កក្កដា ១៩៩៨ | ២៦ កក្កដា ១៩៩៩ |
| ហ្សកដានី* | ៧ តុលា ១៩៩៨ | ១១ មេសា ២០០២ |
| គែនយ៉ា | ១១ សីហា ១៩៩៩ | ១៥ មិនា ២០០៥ |
| ឡេសូតូ | ៣០ វិច្ឆិកា ១៩៩៨ | ៦ កញ្ញា ២០០០ |
| ឡេតូនី | ២២ មេសា ១៩៩៩ | ២៨ មិថុនា ២០០២ |
| លីបេរីយ៉ា * | ១៧ កក្កដា ១៩៩៨ | ២២ កញ្ញា ២០០៤ |
| លីឆិនស្តែន | ១៨ កក្កដា ១៩៩៨ | ២ តុលា ២០០១ |
| លីទុយអានី | ១០ ធ្នូ ១៩៩៨ | ១២ ឧសភា ២០០៣ |
| លុចហ្សំប៊ួរ | ១៣ ធ្នូ ១៩៩៨ | ៨ កញ្ញា ២០០០ |
| ម៉ាសេឌ័ន* | ៧ តុលា ១៩៩៨ | ៦ មិនា ២០០២ |
| ម៉ាឡាវី* | ៣ មីនា ១៩៩៩ | ១៩ កញ្ញា ២០០២ |
| ម៉ាលី | ១៧ កក្កដា ១៩៩៨ | ១៦ សីហា ២០០០ |
| ម៉ាល់តឹ | ១៧ កក្កដា ១៩៩៨ | ២៩ វិច្ឆិកា ២០០២ |
| កោះម៉ាស្ហាល* | ៦ កញ្ញា ២០០០ | ៧ ធ្នូ ២០០០ |
| ម៉ូរីស* | ១១ វិច្ឆិកា ១៩៩៨ | ៥ មិនា ២០០២ |
| ម៉ិចស៊ិច | ៧ កញ្ញា ២០០០ | ២៨ តុលា ២០០៥ |
| ម៉ុងហ្គោលី* | ២៩ ធ្នូ ២០០០ | ១១ មេសា ២០០២ |
| ណាមីប៊ី | ២៧ តុលា ១៩៩៨ | ២៥ មិថុនា ២០០២ |
| ណាអ៊ូរូ* | ១៣ ធ្នូ ២០០០ | ១២ វិច្ឆិកា ២០០១ |
| នីហ្សេរ | ១៧ កក្កដា ១៩៩៨ | ១១ មេសា ២០០២ |
| នីហ្សេរីយ៉ា * | ១ មិថុនា ២០០០ | ២៨ កញ្ញា ២០០១ |
| ន័រវែហ្ស | ២៨ សីហា ១៩៩៨ | ១៦ កុម្ភៈ២០០០ |
| នូវែលហ្សេឡង់ | ៧ តុលា ១៩៩៨ | ៧ កញ្ញា ២០០០ |
| អ៊ូហ្គាន់ដា* | ១៧ មីនា ១៩៩៩ | ១៤ មិថុនា ២០០២ |
| ប៉ាណាម៉ា * | ១៨ កក្កដា ១៩៩៨ | ២១ មិនា ២០០១ |
| ប៉ារ៉ាហ្គាយ | ៧ តុលា ១៩៩៨ | ១៤ ឧសភា ២០០១ |
| ហូល្លង់ | ១៨ កក្កដា ១៩៩៨ | ១៧ កក្កដា ២០០១ |
| ពេរូ | ៧ ធ្នូ ២០០០ | ១០ វិច្ឆិកា ២០០១ |
| ប៉ូឡូញ | ៩ មេសា ១៩៩៩ | ១២ វិច្ឆិកា ២០០១ |

| | | |
|---|---|---|
| ព័រទុយហ្កាល់ | ៧ តុលា ១៩៩៨ | ៥ កុម្ភៈ ២០០២ |
| សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល* | ៧ ធ្នូ ១៩៩៩ | ៣ តុលា ២០០១ |
| សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ* | ៨ កញ្ញា ២០០០ | ១១ មេសា ២០០២ |
| សាធារណៈរដ្ឋដូមីនីកាំង* | ៨ កញ្ញា ២០០០ | ១២ ឧសភា ២០០៥ |
| រ៉ូម៉ានី* | ៧ កក្កដា ១៩៩៩ | ១១ មេសា ២០០២ |
| ចក្រភពអង់គ្លេស | ៣០ វិច្ឆិកា ១៩៩៨ | ៤ តុលា ២០០១ |
| សាំងម៉ារ៉ាំង | ១៨ កក្កដា ១៩៩៨ | ១៣ ឧសភា ១៩៩៩ |
| សាំងវ៉ាំងសង់ និងឡេហ្គ្រើណាឌីយ៉េ | | ៣ ធ្នូ ២០០២ (ក) |
| សាម៉ូអា | ១៧ កក្កដា ១៩៩៨ | ១៦ កញ្ញា ២០០២ |
| សេណេហ្កាល់ * | ១៨ កក្កដា ១៩៩៨ | ២ កុម្ភៈ ១៩៩៩ |
| សៀរ៉ាឡេអូន* | ១៧ តុលា ១៩៩៨ | ១៥ កញ្ញា ២០០០ |
| ស្លូវ៉ាគី | ២៣ ធ្នូ ១៩៩៨ | ១១ មេសា ២០០២ |
| ស្លូវ៉េនី | ៧ តុលា ១៩៩៨ | ៣១ ធ្នូ ២០០១ |
| ស៊ុយអែដ | ៧ តុលា ១៩៩៨ | ២៨ មិថុនា ២០០១ |
| ស្វីស | ១៨ កក្កដា ១៩៩៨ | ១២ តុលា ២០០១ |
| តាដហ្ស៊ីគីស្តង់ * | ៣០ វិច្ឆិកា ១៩៩៨ | ៥ ឧសភា ២០០០ |
| តង់ហ្សានី | ២៩ ធ្នូ ២០០០ | ២០ សីហា ២០០២ |
| ទីម័រខាងកើត* | | ៦ កញ្ញា ២០០២ (ក) |
| ទ្រីនីតេ និងតូបាហ្គោ | ២៣ មីនា ១៩៩៩ | ៦ មេសា ១៩៩៩ |
| អ៊ុយរ៉ឺហ្កាយ | ១៩ ធ្នូ ២០០០ | ២៨ មិថុនា ២០០២ |
| វេនេហ្ស៊ុយអេឡា | ១៤ តុលា ១៩៩៨ | ៧ មិថុនា ២០០០ |
| យូហ្គោស្លាវី | ១៩ ធ្នូ ២០០០ | ៦ កញ្ញា ២០០១ |
| ហ្សំប៊ី | ១៧ កក្កដា ១៩៩៨ | ១៣ វិច្ឆិកា ២០០២ |

# ផ្នែកទី២:  ការសិក្សាលើប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា

## សេចក្តីផ្តើម

នៅក្នុងកំឡុងពាក់កណ្តាលសតវត្សរ៍ទី២០ ប្រទេសកម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងគំហុកខាងនយោបាយ និងរដ្ឋធម្មនុញ្ញ[២១] ។

ព្រឹត្តិការណ៍ទាំងអស់ ដែលនាំឱ្យមានការផ្លាស់ប្តូរមិនឈប់ឈរនូវនយោបាយ និងធម្មនុញ្ញនេះ នាំឱ្យមានការលំបាកក្នុងការយល់ពីប្រព័ន្ធនៃនីតិកម្ពុជា។

រដ្ឋធម្មនុញ្ញបច្ចុប្បន្ននេះមិនមែនជាដំណោះស្រាយជាស្ថាពរទេ តែវាគ្រាន់តែជាដំណោះស្រាយជាមូលដ្ឋាន ក្នុងការឈានទៅរកនីតិរដ្ឋក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

បញ្ហាទាក់ទងនឹងនីតិព្រហ្មទណ្ឌដែលកំពុងស្ថិតនៅជាធរមាន និង អនុភាពនៃសន្ធិសញ្ញាអន្តរជាតិក្នុងនីតិជាតិ គឺជាសំនួរដែលកំពុងតែចោទឡើងយ៉ាងខ្លាំង។ ឧទាហរណ៍ កម្ពុជាមានការលំបាកក្នុងការផ្តន្ទាទោសបទឧក្រិដ្ឋ ដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម តាមរយៈតុលាការវិសាមញ្ញ ដែលត្រូវបានបង្កើតឡើងសំរាប់ជំនុំជម្រះបទឧក្រិដ្ឋដែលបានប្រព្រឹត្ត នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

### ជំពូកទី១:  នីតិជាធរមាន

មាត្រា ១៥៨ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ១៣៩ចាស់)ចែងថា: *ច្បាប់និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់ បុគ្គលនិង*

[២១] ការផ្លាស់ប្តូរលើកដំបូងនៃរដ្ឋធម្មនុញ្ញកើតមានឡើងនៅឆ្នាំ១៩៧២ ក្រោយពីសម្តេចព្រះនរោត្តម សីហនុត្រូវបានទំលាក់ពី តំណែងដោយរដ្ឋសភាជាតិនៅ ថ្ងៃទី១៨ មិនា ១៩៧០។ ស្ថិតក្នុងសភាពការណ៍ច្របូកច្របល់ដោយសារសង្គ្រាមវៀតណាម និង ចលនាកុម្មុយនីស្ត របបសាធារណៈរដ្ឋមិនអាចបង្កើតច្បាប់អ្វី បានទាំងអស់ ដោយជាប់រវល់នឹងការធ្វើសង្គ្រាមប្រឆាំងនឹងពួកខ្មែរក្រហម។ ជ័យជំនះរបស់ពួកខ្មែរក្រហមនៅថ្ងៃទី១៧ មេសា ១៩៧៥ បាននាំមកនូវ "បដិវត្តន៍ធម្មនុញ្ញ" ដែលដាក់ប្រទេសកម្ពុជាអោយនៅក្រោមប្រព័ន្ធច្បាប់ដ៏ថ្មីស្រឡាងមួយតាមបែបកុម្មុយនីស្ត។ ក្រោយពីរបបនេះបានដួលរលំនៅ ឆ្នាំ១៩៧៩ នៅកម្ពុជាមានរបបពីរ មួយបង្កើតឡើងនៅថ្ងៃទី៧ មករា ១៩៧៩ ក្រោមការជួយជ្រោមជ្រែងពីកងទ័ពវៀតណាម និងមួយទៀតនិរទេសនៅក្រុងប៉េកាំង។ របបទាំងពីរ នេះបានដាក់កម្ពុជាឱ្យស្ថិតក្នុងស្ថានភាពគតិយុត្តមួយដ៏ស្រពិចស្រពិល អស់រយៈពេល១២ឆ្នាំ។ ស្ថានភាពនេះត្រូវបានបញ្ចប់ដោយការចុះកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស។ របបទាំងពីរបានព្រមព្រៀងគ្នាក្នុងការអនុម័តនូវរដ្ឋធម្មនុញ្ញថ្មីមួយនៅ ថ្ងៃទី២៣ កញ្ញា ១៩៩៣ ហើយស្ថិតនៅជាធរមានរហូតមកទល់សព្វថ្ងៃ។

*ដែលសមស្រប នឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។*

សំណេរនៅក្នុងមាត្រានេះហាក់ដូចជាមិនភាពស្រពិចស្រពិលអ្វីទេ ក៏ប៉ុន្តែ អ្នកអនុវត្តច្បាប់ជាច្រើននៅកម្ពុជា ដូចជា ចៅក្រមសាលាដំបូង មេធាវី ទីប្រឹក្សាច្បាប់របស់រាជរដ្ឋាភិបាលជាដើម ធ្វើការបកស្រាយបែបនយោបាយលើមាត្រានេះ។ យោងតាមការបកស្រាយបែបនេះ មាត្រា ១៥៨ មិនទទួលស្គាល់ច្បាប់ទាំងឡាយណា ដែលបានអនុម័តនៅមុនឆ្នាំ១៩៧៩ទេ ដូចជាច្បាប់នៅក្នុងសម័យរាជាណាចក្រទីមួយក្នុងរបបសាធារណៈរដ្ឋ និង ក្នុងរបប កម្ពុជាប្រជាធិបតេយ្យជាដើម។

ការបកស្រាយនេះមានភាពចំលែកយ៉ាងខ្លាំង ព្រោះថាវាហួសពីអ្វីដែលជាសំណេរនៃមាត្រានេះ ដែលមិនបានចែងអំពីដែនកំណត់ដល់ច្បាប់មុនឆ្នាំ ១៩៧៩ ទេ។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាធម្មនុញ្ញមិនបានចេញសេចក្តីសំរេចណាមួយ ដូចការបកស្រាយនេះឡើយ។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នតែមួយគត់ ដែលមានអំណាចបកស្រាយរដ្ឋធម្មនុញ្ញ (មាត្រា ១៣៦ នៃរដ្ឋធម្មនុញ្ញ) ហើយមានតែសេចក្តីសំរេចរបស់ក្រុមប្រឹក្សានេះទេ ដែលជាសេចក្តីសំរេចស្ថាពរ (មាត្រា ១៤២)។

លោក **សឺន ស៊ូប៊ែរ៍** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលយើងបានជួបពិភាក្សាបានច្រានចោលនូវការបកស្រាយបែបនេះលើមាត្រា ១៥៨។ លោកយល់ថា មាត្រានេះបានចែងយ៉ាងច្បាស់លាស់ ហើយផ្តោតទៅលើរាល់ បទបញ្ញត្តិទាំងឡាយណាដែលត្រូវបានបង្កើតឡើងនៅមុនឆ្នាំ១៩៩៣ មិនមែនចំពោះតែបទប្បញ្ញត្តិ ដែលត្រូវបានបង្កើតឡើងចន្លោះ ឆ្នាំ១៩៧៩ និង១៩៩៣នោះទេ។ ការលើកលែងធ្វើឡើងតែរាល់បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹង "ស្មារតីនៃរដ្ឋធម្មនុញ្ញ" តែប៉ុណ្ណោះ ដូចជាបទប្បញ្ញត្តិទាំងឡាយដែលបង្កើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ដែលផ្ទុយនឹងគោលការណ៍នៃការការពារសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ (ជំពូកទី៣) ជាដើម។

---

**FIDH យល់ឃើញថា:**

**ស្របតាមសំណេរនៃមាត្រា ១៥៨ នៃរដ្ឋធម្មនុញ្ញ រាល់ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណា ដូចដែលមានចែងក្នុងមាត្រានេះ ហើយត្រូវបានបង្កើតឡើងនៅមុនការអនុម័តរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ដោយមិនកំណត់ត្រឹមតែបទបញ្ញត្តិ**

**ក្រោយឆ្នាំ១៩៧៩ ស្ថិតនៅជាធរមាន រហូតដល់មានអត្ថបទថ្មីមកកែប្រែឬ លុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។**

ដោយមិនមានសេចក្តីសំរេចស្ថាពរពីក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការបកស្រាយមាត្រា ១៥៨ នៃរដ្ឋធម្មនុញ្ញ និងដោយមិនមានបទប្បញ្ញត្តិណាដែលនិរាករណ៍បទប្បញ្ញត្តិមុនៗ ច្បាប់ និងបទប្បញ្ញត្តិ ដែលអាចយកមកអនុវត្តទាំងស្រុង ឬ ដោយផ្នែក ក្នុងនីតិព្រហ្មទណ្ឌរួមមានៈ

-ព្រះរាជក្រម លេខ៤ ចុះថ្ងៃទី៥ កុម្ភៈ ១៩២៥

-ក្រមស្តីពីតុលាការយោធា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ៨៤៩ នស ចុះថ្ងៃ ទី១២ កុម្ភៈ ១៩៥៤

-ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ៩៣៣ នស ចុះថ្ងៃទី២១ កុម្ភៈ ១៩៥៥

-ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ១០៤ ករ ចុះថ្ងៃទី១៧ សីហា ១៩៦២

-ក្រឹត្យ-ច្បាប់ លេខ១ ឆ្នាំ១៩៧៩

-ក្រឹត្យ-ច្បាប់ លេខ២ ឆ្នាំ១៩៨០ ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-ក្រឹត្យ-ច្បាប់ លេខ៣ ឆ្នាំ១៩៨៩ ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-"បទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធយុត្តាធិការ នីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តក្នុងសម័យអន្តរកាល" (បទប្បញ្ញត្តិអន្តរកាល) ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅថ្ងៃទី១០ កញ្ញា ១៩៩២

-ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៨ កុម្ភៈ ១៩៩៣ ដោយរដ្ឋកម្ពុជា ព្រមទាំងក្រម និងសារាចរណ៍នានាដែលបានអនុម័តអនុលោមតាមច្បាប់នេះ (សារាចរណ៍ ចុះថ្ងៃទី១៨ វិច្ឆិកា ១៩៩៣ ស្តីពីការអនុវត្តច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះ ថ្ងៃទី៨ កុម្ភៈ ១៩៩៣ ព្រះរាជក្រម លេខ ០៨៩៩/០៩ ចុះថ្ងៃទី២៦ សីហា ១៩៩៩ ស្តីពីរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជក្រមលេខ ០១០២/០០៥ ចុះថ្ងៃទី១ មករា ២០០២ ស្តីពីការធ្វើវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៨ កុម្ភៈ ១៩៩៣)

-ច្បាប់ចុះថ្ងៃទី៨ កុម្ភៈ ១៩៩៣ ស្តីពីរចនាសម្ព័ន្ធនៃសាលាជំរះក្តី

-ច្បាប់ចុះថ្ងៃទី១៦ មករា ១៩៩៦ ស្តីពីការផ្តន្ទាទោសការចាប់ជំរិត ការជួញដូរ និងការធ្វើអាជីវកម្មលើ មនុស្ស

-ច្បាប់ស្តីពីស្ថានទម្ងន់ទោសចំពោះបទឧក្រិដ្ឋ ប្រកាសឱ្យប្រើនៅថ្ងៃទី៧ មករា ២០០១

-ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញសំរាប់ជំនុំជម្រះលើបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ សីហា ២០០១ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស រកម ០៨០១/

១២ ហើយត្រូវបានកែប្រែដោយច្បាប់ចុះថ្ងៃទី២៧ តុលា ២០០៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស រកម ១០០៤/០០៦

-ប្រកាសលេខ ២១៧ ចុះថ្ងៃទី៣១ មិនា ១៩៩៨ ស្ដីពីការគ្រប់គ្រងពន្ធនាគារ

## ជំពូកទី២: អានុភាពនៃសន្ធិសញ្ញាអន្តរជាតិ

កម្ពុជាគឺជាប្រទេសឈានមុខគេក្នុងតំបន់អាស៊ី ជាពិសេសអាស៊ីប៉ែកអាគ្នេយ៍ ដែលបានផ្ដល់សច្ចាប័នដល់ស្ទើរតែគ្រប់អនុសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស។

ក៏ប៉ុន្តែនេះមិនទាន់គ្រប់គ្រាន់សំរាប់ឱ្យពលរដ្ឋអាចលើកឡើងនូវសិទ្ធិ និងសេរីភាពទាំងឡាយ ដែលកើតចេញពីអនុសញ្ញាទាំងនេះ នៅចំពោះមុខតុលាការកម្ពុជាឡើយ។

អានុភាពនៃសន្ធិសញ្ញាអន្តរជាតិក្នុងប្រព័ន្ធច្បាប់កម្ពុជាមិនត្រូវបានកំណត់ឱ្យបានជាក់លាក់នោះទេ។

### ក. ការតំរូវឱ្យមានច្បាប់ដើម្បីបញ្ចូលសន្ធិសញ្ញាអន្តរជាតិទៅក្នុងនីតិជាតិ

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឱ្យតំលៃជាពិសេសទៅលើសិទ្ធិមនុស្ស ដែលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាអន្តរជាតិ។ មាត្រានេះបានចែងថា: *ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិការសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស និងសិទ្ធិកុមារ*។

តាមរយៈការចែងនៃមាត្រានេះ រាល់អនុសញ្ញាដែលទាក់ទងទៅនឹងសិទ្ធិមនុស្សមានតំលៃស្មើនឹងរដ្ឋធម្មនុញ្ញពោល គឺមានឋានានុក្រមខ្ពស់ជាងច្បាប់ធម្មតា។ នេះជាការជំរះនូវមន្ទិលសង្ស័យថា តើអនុសញ្ញាទាំងនេះមានតំលៃខ្ពស់ជាងច្បាប់ធម្មតា ឬ ទេ។ យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ អនុសញ្ញាទាំងនេះមានតំលៃខ្ពស់ជាងច្បាប់ធម្មតា។

ក៏ប៉ុន្តែ ការផ្ដល់ឱ្យសិទ្ធិមនុស្សនូវតំលៃស្មើនឹងរដ្ឋធម្មនុញ្ញមិនអនុញ្ញាតឱ្យពលរដ្ឋខ្មែរអនុវត្តនូវសិទ្ធិ និងសេរីភាពរបស់ខ្លួនបាននោះទេ ដោយហេតុថា មាត្រា ៣១ វាក្យខ័ណ្ឌចុងក្រោយបានចែងថា: *ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់*។

យើងអាចនិយាយបានម្យ៉ាងទៀតថា ពលរដ្ឋខ្មែរអាចលើកឡើងនូវសិទ្ធិ សេរីភាពរបស់ខ្លួននៅចំពោះយុត្តាធិការកម្ពុជាបាន លុះត្រាតែផ្អែកទៅលើបទបញ្ញត្តិច្បាប់ណាមួយ ។

យោងទៅលើមាត្រា ៧៤ នៃបទប្បញ្ញត្តិអន្តរកាល ការប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សំណុំនៃវិធានអប្បបរមាទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាប់ឃុំ កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយ សេចក្តីប្រកាសនៃគោលការណ៍យុត្តិធម៌ជាមូលដ្ឋានស្តីពីជនរងគ្រោះដោយសារបទឧក្រិដ្ឋ និងជនរងគ្រោះដោយការរំលោភអំណាច គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃអង្គចៅក្រម បណ្តុំនៃគោលការណ៍ស្តីពីការការពារ នូវរាល់ជនទាំងឡាយណាដែលត្រូវបានជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារ និងគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កំលាំងទ័ព និងការប្រើប្រាស់កាំភ្លើង ដោយអ្នកទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ "អាចយកមកអនុវត្តបាននៅប្រទេសកម្ពុជា"។ មានន័យថា អត្ថបទ និងសន្ធិសញ្ញាអន្តរជាតិ ទាំងនេះមានអានុភាពអនុវត្តដូចច្បាប់ដែរ ហើយអាចត្រូវបានលើកឡើងដោយពលរដ្ឋខ្មែរ នៅចំពោះមុខតុលាការកម្ពុជា ។

ក្រៅពីលិខិតូបករណ៍អន្តរជាតិទាំង៨នេះ មកទល់នឹងបច្ចុប្បន្ននេះ អ្នកតំណាងរាស្ត្រមិនបានរៀបចំធ្វើច្បាប់ដើម្បីបញ្ចូលលិខិតូបករណ៍ជាង១០ទៀតមកក្នុងនីតិជាតិនៅឡើយទេ ។

ដោយគ្មានច្បាប់បញ្ចូលក្នុងនីតិជាតិនូវកាតព្វកិច្ចអន្តរជាតិនៃកម្ពុជាទាក់ទងនឹងសិទ្ធិមនុស្ស ក្នុងការអនុវត្តជាក់ស្តែងពលរដ្ឋខ្មែរមិនអាចលើកឡើងនូវសិទ្ធិ សេរីភាពជាសារវ័ន្តរបស់ខ្លួន នៅចំពោះមុខតុលាការកម្ពុជាឡើយ ។

ដូចនេះ កម្ពុជាចាំបាច់ត្រូវរៀបចំច្បាប់ដើម្បីដាក់បញ្ចូលក្នុងនីតិជាតិ នូវរាល់អនុសញ្ញាអន្តរជាតិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស ដែលកម្ពុជាបានផ្តល់សច្ចាប័ន (ឬបានចូលជាសមាជិក)រួចហើយ មានជាអាទិ៍ លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ[២២] ដើម្បីឱ្យពលរដ្ឋខ្មែរអាចអនុវត្តដោយពេញលេញ នូវសិទ្ធិសេរីភាព ដែលកើតចេញពីលិខិតូបករណ៍អន្តរជាតិទាំងនេះ ។

**FIDH សូមផ្តល់នូវអនុសាសន៍ដូចតទៅ:**

**ព្រះរាជាណាចក្រកម្ពុជាគួរតែបង្កើតនូវច្បាប់ដើម្បីដាក់បញ្ចូលក្នុងនីតិអន្តរជាតិ នូវរាល់សិទ្ធិសេរីភាពបុគ្គល ដូចមានចែងនៅក្នុងគ្រប់អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សដែលមាត្រា៣១ នៃរដ្ឋធម្មនុញ្ញបានឱ្យតំលៃស្មើនឹងរដ្ឋធម្មនុញ្ញ ។**

[២២] បើមិនដូច្នោះទេ កម្ពុជានឹងត្រូវតុលាការព្រហ្មទណ្ឌអន្តរជាតិចាត់ទុកថា មិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ហើយបាត់បង់នូវសមត្ថកិច្ចរបស់ខ្លួនក្នុងការផ្តន្ទាទោស ចំពោះរាល់បទឧក្រិដ្ឋទាំងឡាយដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ( មាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម) ។ *សូមមើលផ្នែកទី៧*

## ខ. ឧត្តមភាពនៃសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សលើច្បាប់បង្កើតថ្មី

ជាទូទៅ ឋានានុក្រមនៃបទដ្ឋានគតិយុត្តរវាងសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ក៏ចោទជាបញ្ហាដែរ ប្រសិនបើវិធាននៃច្បាប់ដែលមានស្រាប់ផ្ទុយទៅនឹងអនុសញ្ញាអន្តរជាតិ។

មាត្រា ២៦ និងមាត្រា ៥៥ នៃរដ្ឋធម្មនុញ្ញចែងពីឋានានុក្រមរវាងរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ[២៣] ។ ក៏ប៉ុន្តែមិនមានមាត្រាណាមួយចែងពីឋានានុក្រមរវាងសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ផ្ទៃក្នុងកម្ពុជានោះឡើយ។ នៅមិនទាន់មានសេចក្តីសំរេចពីក្រុមប្រឹក្សាធម្មនុញ្ញ ឬ ស្ថាប័នយុត្តាធិការជាន់ទាបណាមួយ ដែលធ្វើការវិនិច្ឆ័យលើបញ្ហានេះនៅឡើយទេ។

### ១- លក្ខណៈពិសេសនៃសិទ្ធិមនុស្ស

លោក **សាយ បូរី** អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញយល់ថា សន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិ មានឋានានុក្រមស្មើនឹងច្បាប់ផ្ទៃក្នុង ដោយហេតុថា សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងនេះត្រូវបានគេបញ្ចូលមកក្នុងនីតិជាតិដោយច្បាប់ស្តីពីការផ្តល់សច្ចាប័ន។ យោងតាមលោកអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរូបនេះ ប្រសិនបើ ក្នុងករណីមានវិវាទរវាងច្បាប់ផ្ទៃក្នុង និងសន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានផ្តល់សច្ចាប័នដោយច្បាប់ គេត្រូវអនុវត្តវិធានស្តីពីវិវាទរវាងច្បាប់ដោយយោងទៅលើពេលនៃការអនុម័តច្បាប់ទាំងនេះ។ តាមរយៈវិធាននេះ ច្បាប់ដែលបង្កើតថ្មីនិរាករណ៍ច្បាប់មុន ដែលផ្ទុយនឹងច្បាប់ក្រោយនេះ[២៤] ។

ផ្ទុយមកវិញ ទាក់ទងនឹងសិទ្ធិមនុស្ស ហេតុផលដូចដែលបានលើកឡើងដោយលោក **សាយ បូរី** ខាងលើមិនអាចយកមកអនុវត្តបានទេ ដោយហេតុដូចដែលយើងបានឃើញខាងលើរួចមកហើយថា រាល់អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សមានតំលៃស្មើនឹងរដ្ឋធម្មនុញ្ញ ដោយសារតែមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងដូច្នោះ។

---

[២៣] មាត្រា ២៦ នៃរដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រទ្រង់ផ្តល់សច្ចាប័នដល់រាល់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ បន្ទាប់ ពីសភាបានអនុម័តយល់ព្រមរួចហើយ។ រាល់ច្បាប់ស្តីពីការផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអន្តរជាតិអាចត្រូវបានត្រួតពិនិត្យធម្មនុញ្ញភាព។ ម្យ៉ាងទៀត មាត្រា ៥៥ បានចែងថា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយនាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវលុបចោល។ ការចែងបែបនេះមានន័យថា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញ បើមិនដូច្នោះទេនឹងត្រូវលុបចោល។ នេះហាក់ដូចជាបង្ហាញឱ្យឃើញថា រដ្ឋធម្មនុញ្ញ មានឋានានុក្រមលើសន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិ។

[២៤] សាយ បូរី, *នីតិអន្តរជាតិទូទៅ*, ការបោះពុម្ពលើកទី២, Blossum Lotus, ២០០១

ហេតុនេះ ទាក់ទងនឹងវិស័យសិទ្ធិមនុស្ស ប្រសិនបើច្បាប់ដែលបង្កើតថ្មី ក្រោយច្បាប់ដែលផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិផ្ទុយនឹងអនុសញ្ញាអន្តរជាតិនេះ ច្បាប់ថ្មីនេះនឹងមិនមានសុពលភាពទេ ដោយមូលហេតុអធម្មនុញ្ញភាព ។

## ២- សិទ្ធិរបស់ពលរដ្ឋក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព

មាត្រា ១៤១ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញចែងថា: *ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬ តុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។*

មាត្រានេះមិនបានចែងថា ពលរដ្ឋធម្មតាអាចធ្វើការប្តឹងដោយផ្ទាល់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការពិនិត្យធម្មនុញ្ញភាពនៃច្បាប់នោះឡើយ ។

ដូចនេះ ពលរដ្ឋខ្មែរអាចលើកឡើងនូវអធម្មនុញ្ញភាពនៃច្បាប់តែតាមរយៈតំណាងរាស្ត្រមួយភាគដប់ សមាជិកព្រឹទ្ធសភាមួយភាគបួន ប្រធានរដ្ឋសភា ឬ ប្រធានព្រឹទ្ធសភា (មាត្រា ១៤១ វាក្យខ័ណ្ឌទី២) ដែលជាការលំបាកបំផុតសំរាប់ពលរដ្ឋធម្មតាក្នុងការធ្វើបែបនេះ ។ ពលរដ្ឋខ្មែរក៏អាចលើកឡើងផងដែរ នូវអធម្មនុញ្ញភាពនៃច្បាប់នៅចំពោះមុខតុលាការនៅពេលដែលខ្លួនមានក្តីក្តាំ ស្របទៅនឹងមាត្រា ១៤១ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៩ នៃព្រះរាជក្រមចុះថ្ងៃទី៨ មេសា ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលចែងថា:

*ភាគីនៅក្នុងរឿងក្តីមួយដែលយល់ឃើញថា ច្បាប់ដែលអនុវត្តដោយតុលាការ ឬ ដោយស្ថាប័នណាមួយរំលោភលើសិទ្ធិ សេរីភាពជាមូលដ្ឋានរបស់ខ្លួន អាចលើកឡើងនូវអធម្មនុញ្ញភាពនៃច្បាប់នេះ នៅចំពោះមុខតុលាការ ។ ប្រសិនបើតុលាការយល់ឃើញថា ការលើកឡើងនេះសមហេតុផល ត្រូវតែបញ្ជូនសំណុំរឿងនេះទៅតុលាការកំពូលក្នុងរយៈពេលយ៉ាងយូរ១០ថ្ងៃ ។*

*តុលាការកំពូលត្រូវតែធ្វើការពិនិត្យ និង សំរេចបញ្ជូនច្បាប់នេះទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ លើកលែងតែខ្លួនយល់ថា ការស្នើសុំពិនិត្យធម្មនុញ្ញភាពនេះមិនអាចទទួលយកបាន ។*

ប៉ុន្តែ បើទោះបីជាមានច្បាប់ណាមួយដែលអាចរំលោភលើសិទ្ធិ សេរីភាពជាមូលដ្ឋានរបស់ខ្លួនក៏ដោយ ក៏គ្មានអ្វីដែលអាចធានាបានថា នៅពេលដែលពលរដ្ឋខ្មែរលើកឡើងនូវអធម្មនុញ្ញភាពនៃច្បាប់នេះ ក្រុមប្រឹក្សាធម្មនុញ្ញនឹងអាចពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះបានដែរ ពីព្រោះសាលាដំបូង និងតុលាការកំពូលមានលទ្ធភាពក្នុងការសំរេចអំពី

សុពលភាពនៃការស្នើសុំពិនិត្យធម្មនុញ្ញភាពនេះ ហើយអាចមិនធ្វើការបញ្ជូនច្បាប់នេះទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្អែកលើមាត្រា ១៩ នៃព្រះរាជក្រមខាងលើ។

ភាពចន្លោះប្រហោងនេះធ្វើឱ្យមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញក្លាយជាការគ្រាន់តែចែងលើក្រដាស តែធាតុពិតប្រជាពលរដ្ឋមិនអាចលើកឡើងដោយពេញលេញនូវសិទ្ធិ សេរីភាពរបស់ខ្លួន ដើម្បីការពារខ្លួននៅចំពោះមុខតុលាការបានទេ។

---

**FIDH សូមផ្តល់អនុសាសន៍ដូចតទៅ:**

**សូមឱ្យអាជ្ញាធរកម្ពុជាលុបចោលនូវឃ្លា "ប្រសិនបើការស្នើសុំនេះសមហេតុផល" និង "លើកលែងតែខ្លួនយល់ឃើញថាការស្នើសុំនេះមិនសមហេតុផល" ក្នុងមាត្រា ១៩ នៃព្រះរាជក្រម ចុះថ្ងៃទី៨ មេសា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូចនេះមាត្រា ១៩ ខាងលើត្រូវកែប្រែទៅជា: *ភាគីនៅក្នុងរឿងក្តីមួយដែលយល់ឃើញថា ច្បាប់ដែលអនុវត្តដោយតុលាការ ឬ ដោយស្ថាប័នណាមួយរំលោភ លើសិទ្ធិសេរីភាព ជាមូលដ្ឋានរបស់ខ្លួន អាចលើកឡើងនូវអធម្មនុញ្ញភាពនៃច្បាប់នេះនៅចំពោះមុខតុលាការ។ សាលាដំបូងត្រូវតែបញ្ជូនសំណុំរឿងនេះទៅតុលាការកំពូលក្នុងរយៈពេលយ៉ាងយូរ១០ថ្ងៃ។***

***តុលាការកំពូលត្រូវតែធ្វើការពិនិត្យ និងសំរេចបញ្ជូនច្បាប់នេះទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ។***

---

## ជំពូកទី៣ៈ អង្គជំនុំជម្រះវិសាមញ្ញ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ

ក្រោយពីការចរចារយ៉ាងតឹងតែង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងមួយ[២៥] នៅថ្ងៃទី៦ មិថុនា ២០០៣ បង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

កិច្ចព្រមព្រៀងនេះត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជានៅថ្ងៃទី១៩ តុលា ២០០៤។ នៅមុនពេលចុះកិច្ចព្រមព្រៀងនេះ កម្ពុជាបានបង្កើតច្បាប់មួយចុះថ្ងៃទី១០ សីហា ២០០១ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះ[២៦]។ ដើម្បីអោយស្របទៅនឹងកិច្ចព្រមព្រៀងថ្ងៃទី៦ មិថុនា ២០០៣ ច្បាប់នេះត្រូវបានកែប្រែដោយច្បាប់មួយទៀត ចុះថ្ងៃទី ២៧ តុលា ២០០៤[២៧]។

អង្គជំនុំជម្រះវិសាមញ្ញដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងថ្ងៃទី៦ មិថុនា ២០០៣ និងច្បាប់ចុះថ្ងៃទី១០ សីហា ២០០១ គឺជាអង្គជំនុំជម្រះមួយដែលមានលក្ខណៈជារបៀប "កូនកាត់" ហើយមានសមត្ថកិច្ចជំនុំជម្រះតែលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្រោមរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ តែប៉ុណ្ណោះ ដែលក្នុងនោះមានបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

ដូចយើងបានដឹងហើយថា បទឧក្រិដ្ឋកម្មទាំងប៉ុន្មានខាងលើនេះត្រូវបានដាក់ក្រោមសមត្ថកិច្ចនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ហើយត្រូវបានឱ្យនិយមន័យនៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ទោះបីជាយ៉ាងនេះក៏ដោយ មិនមានវិវាទផ្ទៃកសមត្ថកិច្ចរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញនេះទេ ព្រោះមាត្រា ១១ វាក្យខ័ណ្ឌទី១ នៃលក្ខន្តិកៈទីក្រុងរ៉ូមចែងថាៈ *តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះតែលើបទឧក្រិដ្ឋដែលចាត់ចូលជាសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវបានប្រព្រឹត្តក្រោយពីការចូលជាធរមាននៃលក្ខន្តិកៈនេះ*។

---

[២៥] កិច្ចព្រមព្រៀង ចុះថ្ងៃទី៦ មិថុនា ២០០៣ ស្តីពីការជំនុំជម្រះជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យស្របទៅតាមច្បាប់កម្ពុជា។ ឯកសារអ.ស.ប A/RES/57/228B (២០០៣) ១៣ ឧសភា ២០០៣ "ដំណើរក្តី ខ្មែរក្រហម" ឧបសម្ព័ន្ធ។

[២៦] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដើម្បីជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុង កំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អនុម័តដោយរដ្ឋសភានៅថ្ងៃទី២ មករា ២០០១ ហើយត្រូវបានព្រឹទ្ធសភាផ្តល់ការយល់ព្រម នៅថ្ងៃទី១៥ មករា ២០០១។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស រកម ០៨០១/១២ ចុះថ្ងៃទី១០ សីហា ២០០១។

[២៧] ច្បាប់កែប្រែមាត្រា២, ៣, ៩, ១០, ១១, ១៤, ១៧, ១៨, ២០, ២១, ២២, ២៣, ២៤, ២៧, ២៩, ៣១, ៣៣, ៣៤, ៣៥, ៣៦, ៣៧, ៣៩, ៤០, ៤២, ៤៣, ៤៤, ៤៥, ៤៦, ៤៧ នៃច្បាប់ចុះថ្ងៃទី១០ សីហា ២០០១។ ច្បាប់នេះត្រូវបានអនុម័តដោយ រដ្ឋសភានៅថ្ងៃទី៥ តុលា ២០០៤ ត្រូវបានព្រឹទ្ធសភាផ្តល់នូវការយល់ព្រមទាំងស្រុងនៅថ្ងៃទី៨ តុលា ២០០៤ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម នស រកម ១០០៤/០០៦ ចុះថ្ងៃទី២៧ តុលា ២០០៤។

ដូចនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តក្រោមរបបកម្ពុជាប្រជាធិបតេយ្យនេះទេ។

ចំណែកអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានគេកំណត់យ៉ាងជាក់លាក់ថា មានសមត្ថកិច្ចជំនុំជម្រះតែទៅលើបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងពេលពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ តែប៉ុណ្ណោះ (មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៦ មិថុនា ២០០៣ មាត្រា ១ និង មាត្រា ២ នៃច្បាប់ចុះថ្ងៃទី១០ សីហា ២០០១ កែប្រែនៅថ្ងៃទី២៧ តុលា ២០០៤)។

ដូចនេះ សមត្ថកិច្ចទាក់ទងនឹងសម័យកាលនៃការប្រព្រឹត្តបទល្មើស រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និង អង្គជំនុំជម្រះវិសាមញ្ញមានការខុសគ្នាដាច់ស្រឡះ។ ប៉ុន្តែ ក្រៅពីសមត្ថកិច្ចទាក់ទងនឹងសម័យកាលនៃការប្រព្រឹត្តបទល្មើសនេះ ក៏នៅមានភាពខុសគ្នាជាមូលដ្ឋានរវាងតុលាការទាំងពីរនេះផងដែរ។

## ក. ភាពដូចគ្នានៃអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១- ការកំណត់បទល្មើស

ការកំណត់បទល្មើសដោយច្បាប់ចុះថ្ងៃទី១០ សីហា ២០០១ កែប្រែនៅថ្ងៃទី២៧ តុលា ២០០៤ ចំលងស្ទើរតែទាំងស្រុងតាមលក្ខន្តិកៈទីក្រុងរ៉ូម។

#### ១.ក. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានឱ្យនិយមន័យបទប្រល័យពូជសាសន៍ដូចតទៅ:

*មាត្រា៤: អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចជំនុំជម្រះរាល់ជនសង្ស័យថាបានប្រព្រឹត្តបទប្រល័យពូជសាសន៍ ដែលមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែលឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្តនៅក្នុងកំឡុងពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។*

*បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាបទល្មើសគ្មានអាជ្ញាយុកាល ហើយសំដៅលើអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា:*

*-ឃាតកម្មលើសមាជិកនៃក្រុម។*

*-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសត្តិបញ្ញារបស់សមាជិកនៃក្រុម។*

*-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខ័ណ្ឌ ដែលនាំឱ្យមានវិនាសអន្តរាយទាំងស្រុង ឬ មួយផ្នែកនៃក្រុម។*

*-វិធានការណ៍សំដៅរារាំងកំណើតទារកនៅក្នុងក្រុម។*

*-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត។*

*ម្យ៉ាងទៀត អំពើទាំងឡាយដូចរៀបរាប់ខាងក្រោមនេះ ក៏នឹងត្រូវផ្តន្ទាទោសដូចអំពើដែលបានរៀបរាប់ខាងលើដែរ:*

*-ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍*

*-ការសមគំនិតក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍*

*-ការចូលរួមក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍។"*

ដូចនេះ និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលចែងក្នុងមាត្រា ៤ ចំលងស្ទើរតែទាំងស្រុងតាមមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនេះ ក៏យកតាមនិយមន័យ ដែលចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ដែរ។

មាត្រា៤ ខាងលើបានចែងអំពីការផ្តន្ទាទោសផងដែរចំពោះការប៉ុនប៉ង ការសមគំនិត និងសហចារីនៃបទប្រល័យពូជសាសន៍។ ក៏ប៉ុន្តែ ច្បាប់ចុះថ្ងៃទី១០ សីហា ២០០១ មានភាពចន្លោះប្រហោងជាងលក្ខន្តិកៈទីក្រុងរ៉ូម ដោយមូលហេតុថា និយមន័យនៃការសមគំនិតដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់ខ្មែរមិនមានលក្ខណៈលំអិត ដូចមាត្រា ២៥ វាក្យខ័ណ្ឌទី៣ ចំនុច *ខ, គ* និង *ឯ* នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ។

ម្យ៉ាងវិញទៀត ច្បាប់ឆ្នាំ២០០១ មិនបានធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីការប៉ុនប៉ង ការឱ្យដៃ និងការប្រព្រឹត្តិបទល្មើសដោយជនល្មើសច្រើននាក់នោះទេ។ ផ្ទុយមកវិញ មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានឱ្យនិយមន័យយ៉ាងច្បាស់នូវរាល់សញ្ញាណខាងលើនេះ ក្នុងកថាខ័ណ្ឌទី៣ ចំនុច *ក, ឃ* និង *ច*។ ដូចគ្នានេះដែរ មាត្រា ៤ នៃច្បាប់ឆ្នាំ ២០០១ មិនបានចែងអំពីបទល្មើសញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តបទប្រល័យពូជសាសន៍នោះទេ ដែលអំពើទាំងនេះត្រូវបានមាត្រា ២៥ វាក្យខ័ណ្ឌទី៣ ចំនុច *ង* កំណត់ថាជាបទល្មើសមួយដាច់ដោយឡែក។

### ១.ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ច្បាប់ឆ្នាំ២០០១ ចែងពីការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា ៥។ មាត្រានេះចែងថា:

*"មាត្រា៥: អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចជំនុំជម្រះរាល់ជនសង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងកំឡុងពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។*

*បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាបទល្មើសគ្មានអាជ្ញាយុកាល ហើយសំដៅលើអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬ ជាប្រព័ន្ធសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលៈ*

*-ឃាតកម្ម*

*-ការសម្លាប់រង្គាល*

*-ការធ្វើឱ្យទៅជាទាសកម្ម*

*-ការនិរទេស ឬ ជម្លៀសប្រជាជនដោយការបង្ខំ*

*-ការដាក់ពន្ធនាគារ*

*-ការធ្វើទារុណកម្ម*

*-ការចាប់បង្ខំសេពសន្ថវៈ*

*-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជអំបូរ ឬសាសនា*

*-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត។"*

មាត្រា ៥ នេះ ចំលងតាមផ្នែកមួយនៃមាត្រា ៧ កថាខ័ណ្ឌ១ នៃលក្ខន្តិកៈទីក្រុងរ៉ូម[២៨]។ ម្យ៉ាងនិយមន័យនៃមាត្រា៥ ដែលយកគំរូតាមលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៃប្រទេសរ៉ូវ៉ាន់ដា ដោយទាមទារថា ការវាយលុកជាទូទៅប្រឆាំងនឹងប្រជាជនស៊ីវិលត្រូវតែធ្វើឡើង "ក្នុងហេតុផលជាតិសាសន៍ នយោបាយ ជាតិពន្ធុ ពូជអំបូរ ឬសាសនា"។ ចំណែកឯមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមវិញទាមទារឱ្យមានលក្ខខ័ណ្ឌបែបនេះតែក្នុងករណីអំពើធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ (កថាខ័ណ្ឌ១ វាក្យខ័ណ្ឌ ជ)។

ម្យ៉ាងទៀត កថាខ័ណ្ឌ២ នៃមាត្រា ៥ នៃច្បាប់ខ្មែរនេះ ចែងពីអំពើមួយចំនួន ដែលអាចចាត់ចូលថា ជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការជម្លៀសដោយបង្ខំ ការធ្វើទុក្ខបុកម្នេញ និងរាល់អំពើអមនុស្សធម៌ផ្សេងទៀត តែមិនបានបញ្ជាក់អំពីអត្ថន័យនៃពាក្យទាំងនេះ ទាំងនៅក្នុងមាត្រានេះ ទាំងនៅក្នុងមាត្រាផ្សេងទៀតនៃច្បាប់នេះ។

[២៨] សំរាប់អត្ថបទទាំងស្រុងនៃមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម សូមមើលនៅទំព័រ៥៨។

លក្ខន្តិកៈទីក្រុងរ៉ូមចែងបានច្បាស់លាស់ និងលំអិតជាងចំពោះបញ្ហាទាំងនេះ។ ដូចជាការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការជម្លៀសដោយបង្ខំ ការធ្វើទុក្ខបុកម្នេញ ត្រូវបានឱ្យនិយមន័យយ៉ាងច្បាស់នៅក្នុង មាត្រា ៧ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ *ខ គ ឃ* និង*ឆ*។ ចំពោះរាល់អំពើអមនុស្សជាតិផ្សេងទៀតត្រូវបានឱ្យនិយមន័យថា រាល់អំពើទាំងឡាយណា *"ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬ គ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់រូបកាយ ឬ ដល់សុខភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ"* (មាត្រា ៧ កថាខ័ណ្ឌ១ ចំនុច ដ នៃលក្ខន្តិកៈទីក្រុងរ៉ូម)។ ម្យ៉ាងទៀតច្បាប់ឆ្នាំ២០០១មិនបានឱ្យនិយមន័យការធ្វើទារុណកម្មដូចក្នុងមាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះឡើយ។ ដើម្បីកំណត់បទល្មើសនេះ ច្បាប់ឆ្នាំ២០០១ បែរជាយោងទៅលើមាត្រា ៥០០ នៃច្បាប់ព្រហ្មទណ្ឌខ្មែរ ឆ្នាំ១៩៥៥ ទៅវិញ (មាត្រា ៣ នៃច្បាប់ឆ្នាំ២០០១)[២៩]។

មាត្រា៥ នៃច្បាប់ឆ្នាំ២០០១ មិនបានចែងអំពីបណ្តាបទល្មើសមួយចំនួនដែលមានចែងក្នុងមាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដូចជាការបាត់ខ្លួនដោយបង្ខំ បទល្មើសទាក់ទងនឹងផ្លូវភេទក្រៅពីការរំលោភ និងបទល្មើស អាប៉ាថេតជាដើម។ បទល្មើសទាំងនេះក៏មិនមានចែងក្នុងមាត្រាណាមួយផ្សេងទៀតនៃច្បាប់នេះដែរ។

### ១.គ. ឧក្រិដ្ឋកម្មសង្គ្រាម

ដោយយោងទៅតាមមាត្រា ៦ នៃច្បាប់ឆ្នាំ២០០១ បទឧក្រិដ្ឋកម្មសង្គ្រាមអាចត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះវិសាមញ្ញ។ មាត្រានេះចែងថា:

*"មាត្រា៦: អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចជំនុំជម្រះនូវរាល់ជនសង្ស័យថាបានប្រព្រឹត្ត ឬ បញ្ជាឱ្យប្រព្រឹត្តអំពើរំលោភដ៏ធ្ងន់ធ្ងរប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៨ ហើយដែលអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងកំឡុងពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩។ អំពើទាំងនោះរួមមាន:*

*-ឃាតកម្ម*

*-ទារុណកម្ម ឬគ្រប់ប្រព្រឹត្តកម្មអមនុស្សធម៌*

*-អំពើបង្កដោយចេតនានូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពបុគ្គល ឬ ដល់សុខភាព*

*-ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដោយគ្មានហេតុផលសមរម្យខាងយោធា និងប្រព្រឹត្តឡើងដោយខុសច្បាប់ និងតាមទំនើងចិត្ត*

[២៩] ចំពោះការប្រៀបធៀបរវាងមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ១៩៥៥ និងនិយមន័យនៃការធ្វើទារុណកម្ម ដែលបានកំណត់ដោយមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម សូមមើលទំព័រ ៦៤។

*-អំពើបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិលឱ្យបម្រើក្នុងកងកំលាំងប្រដាប់អាវុធរបស់រដ្ឋដែលជាសត្រូវ*

*-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬ ជនស៊ីវិលក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង*

*-ការជម្លៀស ការបញ្ជូន ឬការឃុំឃាំងដោយខុសច្បាប់*

*-ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។ "*

មាត្រានេះចំលងតាមមាត្រា៨ កថាខ័ណ្ឌ១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ក៏ប៉ុន្តែមិនបានចំលងតាមទាំងស្រុងនោះទេ។

តាមពិតមាត្រា ៨ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ឃ នៃលក្ខន្តិកៈទីក្រុងរ៉ូមធ្វើការបញ្ចូលទំនៀមទំលាប់អន្តរជាតិទាក់ទងនឹងបទឧក្រិដ្ឋកម្មសង្គ្រាម។ មាត្រានេះចែងពីអំពើមួយចំនួន ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ដែលការចែងបែបនេះមិនត្រូវបានធ្វើឡើងទេនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

### ២- ការគ្មានអាជ្ញាយុកាលនៃបទល្មើស

ដោយយកគំរូតាមមាត្រា ២៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៤ និងមាត្រា ៥ នៃច្បាប់ឆ្នាំ២០០១ ចែងថា បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមានអាជ្ញាយុកាលទេ។ ក៏ប៉ុន្តែ ខុសពី មាត្រា ២៩ ច្បាប់ឆ្នាំ២០០១នេះមិនបានចែងពីការគ្មានអាជ្ញាយុកាលនៃបទឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។

## ខ. លក្ខណៈខុសគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១- ការដាក់បញ្ចូលអង្គជំនុំជម្រះវិសាមញ្ញទៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា

បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈពិសេស ដោយមានការចូលរួមពីចៅក្រមអន្តរជាតិ ក៏ប៉ុន្តែ អង្គជំនុំជម្រះនេះស្ថិតក្នុងប្រព័ន្ធយុត្តិធម៌ជាតិខ្មែរ ដោយហេតុថា ចំនួនចៅក្រមខ្មែរមានច្រើនជាងចៅក្រមអន្តរជាតិ។

ម្យ៉ាងទៀត ទោះបីជាមាត្រា ១២ នៃកិច្ចព្រមព្រៀងចុះថ្ងៃទី៦ មិថុនា ២០០៣ និងមាត្រា ៣៣ នៃច្បាប់ឆ្នាំ២០០១ បានចែងពីគោលការណ៍ឧត្តមភាពនៃស្តង់ដាអន្តរជាតិលើនីតិវិធីផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ ក៏គេនៅតែមានមន្ទិលសង្ស័យដែរថា ស្តង់ដាអន្តរជាតិនេះនឹងមិនត្រូវបានអនុវត្តដោយពេញលេញនោះទេ ដោយហេតុថា ចៅក្រមកម្ពុជាមិនមានបទពិសោធន៍គ្រប់គ្រាន់ក្នុងរឿងនេះ[៣០] ព្រមទាំងខ្វះនូវភាពឯករាជ្យ និងអព្យាក្រឹត្យ[៣១]។

---

[៣០] ប្រព័ន្ធយុត្តិធម៌កម្ពុជាបច្ចុប្បន្ននេះកំពុងតែជួបនូវកង្វះខាតផ្នែកធនធានមនុស្ស ដែលបង្កឡើងដោយរបបខ្មែរក្រហម។ សាលាភូមិន្ទចៅក្រមទើបតែបានបង្កើតឡើងនៅឆ្នាំ២០០២ប៉ុណ្ណោះ។

[៣១] លោក ភីធ័រ ឡឺប្រេច អតីតតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស នៅកម្ពុជាបានលើកឡើងនូវការខ្វះឯករាជ្យភាព និងអព្យាក្រឹត្យភាពនៃប្រព័ន្ធយុត្តិធម៌កម្ពុជា ព្រមទាំងបានលើកឡើងថា ចៅក្រមខ្មែរមានការពាក់ព័ន្ធនឹងរឿងនយោបាយៈ *"នៅក្នុងរយៈកាល ១០ឆ្នាំ*

សមត្ថកិច្ចតាមកាល នៃអង្គជំនុំជម្រះវិសាមញ្ញ និង តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបែងចែកគ្នាដាច់ស្រឡះ[៣២]។ ដូចនេះ បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញនេះមិនមានសមត្ថភាពក្នុងការអនុវត្តនីទូវសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋទាំងឡាយ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញនេះ តាមការចែងរបស់មាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមដែរ (សូមមើលគោលការណ៍នៃការបំពេញបន្ថែម)។

## ២- អធិបតេយ្យភាពនៃអង្គជំនុំជម្រះវិសាមញ្ញ និងគោលការណ៍នៃការបំពេញបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

អង្គជំនុំជម្រះវិសាមញ្ញ គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ បើយោងតាមច្បាប់ខ្មែរបច្ចុប្បន្ន មិនមានស្ថាប័នតុលាការណាមួយនៃប្រព័ន្ធយុត្តិធម៌កម្ពុជា មានសមត្ថកិច្ចក្នុងការជំនុំជម្រះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមទេ។ អាជ្ញាយុកាលបទល្មើសមួយចំនួននៃនីតិរួមត្រូវបានពន្យារពេលរហូតដល់៣០ឆ្នាំ ដើម្បីបំពេញតាមតំរូវការនៃការជំនុំជម្រះក្រុមខ្មែរក្រហម (មាត្រា ៣ នៃច្បាប់ឆ្នាំ២០០១)។

ក្នុងដំណើរការនៃការផ្តន្ទាទោសបទឧក្រិដ្ឋខាងលើនេះ លក្ខន្តិកៈទីក្រុងរ៉ូមមានការចែងខុសពីនេះ ពោលគឺគោរពតាមគោលការណ៍នៃការបំពេញបន្ថែម។ ដូចនេះ ក្នុងករណីទូទៅ រដ្ឋជាអ្នកមានសមត្ថកិច្ចក្នុងការជំនុំជម្រះលើរាល់បទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ បុព្វកថា វាក្យខ័ណ្ឌ១០ នៃលក្ខន្តិកៈនេះចែងថា:

*"តុលាការព្រហ្មទណ្ឌអន្តរជាតិ (...) ត្រូវជាការបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌជាតិ"*

មាត្រា ១ ចែងថា:

*"តុលាការព្រហ្មទណ្ឌអន្តរជាតិ (...) ត្រូវជាការបន្ថែមលើយុត្តាធិការព្រហ្មទ័ណ្ឌជាតិ"*

ដូច្នេះ មានតែក្នុងករណីដែលរដ្ឋពាក់ព័ន្ធមិនមានលទ្ធភាព ឬមិនមានឆន្ទៈក្នុងការជំនុំជម្រះរឿងនេះទេ ទើបតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ច ដោយយោងទៅលើមាត្រា ១៧:

---

*ចុងក្រោយនេះ អំណាចនីតិប្រតិបត្តិនៅតែបន្ត គ្រប់គ្រងអំណាចតុលាការ និងស្ថាប័នយុត្តាធិការផ្សេងៗមួយចំនួនទៀត(...)។ ឧបសគ្គចំបងក្នុងការបង្កើតឱ្យមានប្រព័ន្ធយុត្តិធម៌ឯករាជ្យគឺដោយសារតែគ្រប់ស្ថាប័នយុត្តិធម៌ទាំងអស់ដំណើរការដូចជាផ្នែកមួយនៃនីតិប្រតិបត្តិ។ ដំណើរការបែបនេះត្រូវបានគេ ប្រកាន់យកក្នុងកំឡុងរបបគ្រប់គ្រងនាទសវត្សរ៍ទី៨០ ហើយត្រូវបានចាក់ឫសយ៉ាងជ្រៅក្នុងសង្គមខ្មែរនាសម័យបច្ចុប្បន្ននេះ "*។ (របាយការណ៍របស់លោក ភីធ័រ ឡឺប្រេច តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពី *ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា* ចុះថ្ងៃទី២០ ធ្នូ ២០០៤, E/CN.4/2005/116 កថាខ័ណ្ឌទី២១)

[៣២] សូមមើលទំព័រទី ៣៥។

*"១. យោងតាមកថាខ័ណ្ឌទី១០ នៃបុព្វកថា និងមាត្រា ១ តុលាការត្រូវកំណត់ថា ករណីមួយមិនអាចទទួលយកបានទេបើ:*

*(ក) ករណីនេះត្រូវបានស៊ើបអង្កេត ឬ នាំយកមកជំនុំជម្រះដោយរដ្ឋដែលមានយុត្តាធិការលើករណីនោះរួចហើយ លើកលែងតែរដ្ឋនោះគ្មានឆន្ទៈ ឬ គ្មានលទ្ធភាពអនុវត្តការស៊ើបអង្កេត ឬ ការនាំយកមកជំនុំជម្រះដោយពិតប្រាកដ ។*

*(ខ) ករណីនេះត្រូវបានស៊ើបអង្កេតដោយរដ្ឋ ដែលមានយុត្តាធិការលើករណីនោះហើយ ហើយរដ្ឋនោះបានសម្រេចមិននាំយកជនពាក់ព័ន្ធនោះមកជំនុំជម្រះទេ លើកលែងតែសេចក្តីសម្រេចនោះកើតចេញពីលទ្ធផលនៃភាពគ្មានឆន្ទៈ ឬ អលទ្ធភាពរបស់រដ្ឋនោះក្នុងការនាំយកមកជំនុំជម្រះដោយពិតប្រាកដ ។*

*(គ) ជនពាក់ព័ន្ធត្រូវបានជំនុំជម្រះចំពោះអំពើដែលជាកម្មវត្ថុនៃពាក្យបណ្តឹងនោះរួចហើយ ហើយការជំនុំជម្រះដោយតុលាការមិនត្រូវបានអនុញ្ញាតឱ្យតាម កថាខ័ណ្ឌទី៣ នៃមាត្រា ២០ ទេ*[៣៣] *។*

*(ឃ) ករណីនោះមិនធ្ងន់ធ្ងរគ្រប់គ្រាន់ល្មមសម្រាប់ធ្វើយុត្តិកម្មសកម្មភាពបន្តទៀតដោយតុលាការ ។"*

តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចតែក្នុងករណីដែលរដ្ឋមិនមានឆន្ទៈ ឬ មិនមានលទ្ធភាពក្នុងការស៊ើបអង្កេត និងជំនុំជម្រះឧក្រិដ្ឋជនតែប៉ុណ្ណោះ ។

យោងតាមមាត្រា ១៧ កថាខ័ណ្ឌ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ការគ្មានឆន្ទៈសំដៅលើស្តង់ដានៃនីតិអន្តរជាតិទាក់ទង ជាអាទិ៍ នឹងការធានាឱ្យមានការជំនុំជម្រះប្រកបដោយសមធម៌ ។ ការខ្វះខាតឆន្ទៈក្នុងការជំនុំជម្រះអាចកើតឡើងក្នុងករណីដែលមាននីតិវិធីក្នុងការជំនុំជម្រះយឺតយូរហួសហេតុ ឬ ខ្វះភាពឯករាជ្យ និងអព្យាក្រឹត្យ (វាក្យ ខ័ណ្ឌ*ខ* និង *គ*) ។

---

[៣៣] មាត្រា២០ កថាខ័ណ្ឌ៣ ចែងថា: *គ្មានជនណាម្នាក់ដែលត្រូវបានជំនុំជម្រះដោយតុលាការមួយផ្សេងទៀតចំពោះការប្រព្រឹត្ត ដែលបានពិពណ៌នាផងដែរនៅក្នុងមាត្រា៦, ៧ ឬ ៨ ត្រូវជំនុំជម្រះដោយតុលាការទាក់ទងទៅលើការប្រព្រឹត្តិដូចគ្នាតែមួយទេ លើកលែងតែដំណើរការទាំងឡាយនៅក្នុងតុលាការមួយផ្សេងទៀតនោះ:*

*(ក) ត្រូវបានធ្វើឡើងសំរាប់គោលបំណងលាក់កំបាំងជនដែលពាក់ព័ន្ធពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ សំរាប់បទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការនៃតុលាការនោះ ឬ*

*(ខ) បើមិនដូច្នោះទេ ត្រូវបានធ្វើឡើងដោយគ្មានឯករាជ្យ ឬ ដោយគ្មានភាពឥតលំអៀង ស្របតាមបទដ្ឋាននៃ ដំណើរការត្រឹមត្រូវតាមច្បាប់ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយត្រូវបានធ្វើឡើងតាមរបៀបមួយដែល ក្នុងកាលៈទេសៈនានា មិនស្របតាមចេតនានាំខ្លួនជន ដែលពាក់ព័ន្ធនោះមករកយុត្តិធម៌ ។*

អសមត្ថភាពត្រូវបានគេឱ្យនិយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូមថា កើតឡើងដោយសារការដួលរលំទាំងស្រុង ឬជាសារវ័ន្តនៃប្រព័ន្ធយុត្តិធមិជាតិ ឬមួយ ដោយសារកង្វះខាតនូវសមត្ថភាពក្នុងការចាត់ការតាមនីតិវិធីអោយបានពេញលេញក្នុងការជំនុំជម្រះបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ( មាត្រា ១៧ កថាខ័ណ្ឌ៣) ។

ម្យ៉ាងវិញទៀត បើទោះបីជាឧក្រិដ្ឋជនណាមួយត្រូវបានកាត់ទោសដោយស្ថាប័នយុត្តាធិការជាតិចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមរួចហើយក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិអាចសើរើយករឿងនេះមកជំនុំជម្រះឡើងវិញបានដែរ ប្រសិនបើតុលាការនេះរកឃើញថា ដំណើរការនៃនីតិវិធីធ្វើឡើងដោយតុលាការជាតិ មិនត្រូវបានធ្វើឡើងត្រឹមត្រូវតាមនីតិអន្តរជាតិ ( មាត្រា ២០ កថាខ័ណ្ឌ៣) ។

## ៣- ការដាក់ដែនកំណត់ចំពោះជនដែលអាចត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ

ច្បាប់ឆ្នាំ២០០១ បានកំណត់ថា អង្គជំនុំជម្រះអាចធ្វើការចោទប្រកាន់ និងជំនុំជម្រះតែចំពោះ *"អតីតមេ ដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយផ្សេងទៀតដែលមានការទទួលខុសត្រូវថ្នាក់ខ្ពស់ ក្នុងរបបនេះ"* ប៉ុណ្ណោះ ( មាត្រា២) ។ ការកំណត់បែបនេះត្រូវបានធ្វើឡើងក្នុងគោលបំណងជៀសវាងមិនឱ្យមានអស្ថេរភាពនយោបាយក្នុងប្រទេសកម្ពុជា ។

ផ្ទុយទៅវិញ លក្ខន្តិកៈទីក្រុងរ៉ូមមិនមានចែងនូវដែនកំណត់ចំពោះជនដែលអាចត្រូវបានចោទប្រកាន់ និងជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិទេ លើកលែងតែចំពោះជនដែលមានអាយុក្រោម១៨ឆ្នាំ ក្នុងពេលដែលខ្លួនប្រព្រឹត្តបទល្មើស ( មាត្រា ២៦) ។ ក្រៅពីនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចធ្វើការចោទប្រកាន់ និងជំនុំជម្រះលើគ្រប់ជនទាំងឡាយណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាសមត្ថកិច្ចរបស់តុលាការ ទោះបីជនទោះជាចារីផ្ទាល់ ឬ ជាសហចារី ជាជនសមគំនិត ឬ ក៏មានការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋនេះក៏ដោយ ( មាត្រា ២៥ នៃលក្ខនិកៈក្រុងរ៉ូម)[៣៤] ។

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃមេបញ្ជាការកងទ័ព ឬ ជនទាំងឡាយដែលអនុវត្តមុខងារជាបញ្ជាការកងទ័ព ក៏អាចត្រូវបានចោទប្រកាន់ និងជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ( មាត្រា ២៨ នៃលក្ខន្តិកៈក្រុងរ៉ូម)[៣៥] ។

---

[៣៤] សូមមើលទំព័រទី ៥៣ ។

[៣៥] សូមមើលផ្នែកទី៤ ជំពូកទី៣ ។

មិនមានអភ័យឯកសិទ្ធិ ដែលទាក់ទងនឹងសម្បទារផ្លូវការនៃជនសង្ស័យ ដែលអាចត្រូវបានលើកឡើងនៅចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីឱ្យបានរួចផុតពីការចោទប្រកាន់នោះឡើយ បើទោះបីជនោះជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ឬ ភ្នាក់ងាររដ្ឋផ្សេងទៀតក៏ដោយ។ លើសពីនេះទៅទៀត មិនមានអភ័យឯកសិទ្ធិទាក់ទងនឹងសម្បទារផ្លូវការនៃបុគ្គលណាម្នាក់ ក្នុងនីតិជាតិ ឬ នីតិអន្តរជាតិ អាចត្រូវបានលើកឡើងជាឧបសគ្គក្នុងការអនុវត្តសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានឡើយ (មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម)[៣៦]។

វិធានដែលបានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនេះ បង្ហាញនូវភាពខុសគ្នាដាច់ស្រឡះរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញកម្ពុជា។

---

**FIDH សូមធ្វើការកត់សំគាល់ និងរំលឹកថាៈ**

**អង្គជំនុំជម្រះវិសាមញ្ញនៃកម្ពុជា ដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងតុលាការព្រហ្មទណ្ឌអន្តរជាតិមានការខុសគ្នាយ៉ាងខ្លាំង។ អង្គជំនុំជម្រះវិសាមញ្ញកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបញ្ចប់នូវនិទណ្ឌភាពនៃជន ដែលបានប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិនៅក្នុងអតីតកាល ចំណែកឯតុលាការព្រហ្មទណ្ឌអន្តរជាតិវិញមានគោលបំណងក្នុងការផ្តន្ទាទោសនូវរាល់បទឧក្រិដ្ឋអន្តរជាតិ ដែលត្រូវបានប្រព្រឹត្តក្រោយពីការចូលជាធរមាននៃលក្ខន្តិកៈទីក្រុងរ៉ូម។**

---

[៣៦] សូមមើលទំព័រទី៥៣។

# ផ្នែកទី៣៖ ការបញ្ចូលនិយមន័យនៃបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមទៅក្នុងនីតិកម្ពុជា

## សេចក្តីផ្តើម

មាត្រា៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមចែងថា មានបទឧក្រិដ្ឋចំនួន៤ ដែលជាសមត្ថកិច្ចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ឧក្រិដ្ឋកម្មទាំង៤នោះរួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មឈ្លានពាន។

នៅពេលតាក់តែងលក្ខន្តិកៈនេះ រដ្ឋដែលចូលរួមតាក់តែងយល់ឃើញថា ដោយយោងលើស្ថានភាពនយោបាយអន្តរជាតិបច្ចុប្បន្ន ការបញ្ចូលបទឧក្រិដ្ឋកម្មឈ្លានទៅក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមានសារៈសំខាន់ណាស់។ ក៏ប៉ុន្តែ រដ្ឋទាំងនោះមិនអាចព្រមព្រៀងគ្នាក្នុងការឱ្យនិយមន័យលើបទឧក្រិដ្ឋកម្មនេះ ព្រមទាំងលក្ខខ័ណ្ឌក្នុងការអនុវត្តសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិចំពោះបទឧក្រិដ្ឋនេះទេ។ បច្ចុប្បន្ននេះ ការជជែកពិភាក្សាគ្នាត្រូវបានធ្វើឡើងក្នុងសន្និបាតនៃរដ្ឋហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូម ដើម្បីឈានទៅរកការព្រមព្រៀងគ្នាមួយលើនិយមន័យរួមនៃបទឧក្រិដ្ឋឈ្លានពាននេះ ហើយដាក់ជូនរដ្ឋហត្ថលេខីអនុម័តនៅក្នុងសន្និសីទមួយដែលនឹងត្រូវរៀបចំឡើងនៅឆ្នាំ២០០៩ ដើម្បីសើរើឡើងវិញនូវលក្ខន្តិកៈទីក្រុងរ៉ូម (មាត្រា ៥ កថាខ័ណ្ឌ២, ១២១ និង១២៣ នៃលក្ខន្តិកៈចែងថា សន្និសីទបែបនេះនឹងត្រូវរៀបចំធ្វើឡើងក្នុងរយៈពេល៧ឆ្នាំ ក្រោយពីការចូលជាធរមាននៃលក្ខន្តិកៈ)។

លក្ខន្តិកៈទីក្រុងរ៉ូមមិនបានតំរូវឱ្យរដ្ឋហត្ថលេខីទទួលស្គាល់បទឧក្រិដ្ឋទាំង៤ខាងលើ ក្នុងនីតិកម្មជាតិរបស់ខ្លួនទេ។ ក៏ប៉ុន្តែ ការអនុវត្តកាតព្វកិច្ចរបស់រដ្ឋហត្ថលេខីចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងក្របខ័ណ្ឌគោលការណ៍ នៃការបំពេញបន្ថែម ដែលចែងក្នុងមាត្រា១ នៃលក្ខន្តិកៈនេះ កំណត់ឱ្យរដ្ឋហត្ថលេខីត្រូវតែកំណត់នូវនិយមន័យនៃបទឧក្រិដ្ឋទាំងនេះនៅក្នុងច្បាប់ជាតិរបស់ខ្លួន ព្រមទាំងសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងការផ្តន្ទាទោសបទឧក្រិដ្ឋទាំងនេះទៀតផង[៣៧]។

ក្រៅពីករណីអតីតមេដឹកនាំខ្មែរក្រហម កម្ពុជាមិនបានកំណត់ នៅក្នុងច្បាប់ព្រហ្មទណ្ឌទូទៅរបស់ខ្លួន អំពីបទឧក្រិដ្ឋកម្មទាំងបួនខាងលើនេះទេ។ ទាំងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ និងច្បាប់ព្រហ្មទណ្ឌអន្តរកាលមិនបានកំណត់ឱ្យបានច្បាស់លាស់អំពីការផ្តន្ទាទោសបទឧក្រិដ្ឋទាំងនេះទេ។

[៣៧] សូមមើលផ្នែកទី៣ និង ផ្នែកទី៥ ។

ដូចនេះ អាជ្ញាធរកម្ពុជាត្រូវតែបញ្ចូលក្នុងនីតិវិជ្ជមានរបស់ខ្លួននូវនិយមន័យនៃបទឧក្រិដ្ឋទាំងបួន ដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដើម្បីឱ្យតុលាការកម្ពុជាមានសមត្ថកិច្ចក្នុងការផ្តន្ទាទោសជនឧក្រិដ្ឋនៃបទល្មើសទាំងបួននេះ។ ប្រសិនបើមិនដូច្នោះទេ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងក្លាយទៅជាស្ថាប័នយុត្តាធិការតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទឧក្រិដ្ឋទាំងបួនខាងលើ ហើយកម្ពុជាមិនអាចលើកឡើងនូវឧត្តមភាពនៃសមត្ថកិច្ចរបស់ខ្លួនលើសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានឡើយ។

ដោយមើលឃើញនូវភាពចន្លោះប្រហោងនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើកំណែទំរង់យ៉ាងស៊ីជំរៅលើប្រព័ន្ធយុត្តិធម៌របស់ខ្លួន។ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមួយត្រូវបានគេកំពុងធ្វើការសិក្សា និងអាចនឹងដាក់ជូនអង្គនីតិបញ្ញត្តិធ្វើការអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។ នៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះ បទឧក្រិដ្ឋទាំងបួនដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមត្រូវបានឱ្យនិយមន័យ និងកំណត់នូវទោសទណ្ឌចំពោះជនដែលបានប្រព្រឹត្ត។

## ជំពូកទី១៖ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានឱ្យនិយមន័យ ជាលើកដំបូង នៅក្នុងអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទប្រល័យពូជសាសន៍។ ក្រោយពីសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ សហគមន៍អន្តរជាតិយល់ឃើញថា ជនដែលប្រព្រឹត្តបទប្រល័យពូជសាសន៍ចាំបាច់ត្រូវតែទទួលនូវការផ្តន្ទាទោស ក៏ប៉ុន្តែមិនមានតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាអចិន្ត្រៃយ៍ណាមួយ ត្រូវបានបង្កើតឡើងឡើយ។ ព្រះរាជាណាចក្រកម្ពុជាបានយកលិខិតូបករណ៍នៃការផ្តល់សច្ចាប័នដល់អនុសញ្ញានេះទៅដំកល់នៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ នាថ្ងៃទី១៤ តុលា ១៩៥០។

និយមន័យនៃបទប្រល័យពូជសាសន៍ត្រូវបានចែងក្នុងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដោយយកទាំងស្រុងតាមនិយមន័យដែលបានចែងក្នុងអនុសញ្ញាចុះថ្ងៃទី៩ ធ្នូ ១៩៤៨។ និយមន័យនេះក៏ត្រូវបានយកទៅបញ្ចូលក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសយូហ្គោស្លាវី និងប្រទេសរ៉ូវ៉ាន់ដាផងដែរ។ មាត្រា៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមចែងថា៖

*"មាត្រា ៦៖ អំពីអំពើប្រល័យពូជសាសន៍*

*សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ ពាក្យ "ប្រល័យពូជសាសន៍" សំដៅលើអំពីណាមួយក្នុងចំនោម អំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃ ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា:*

*(ក) ឃាតកម្មលើសមាជិកនៃក្រុម*

*(ខ) ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬ សត្តិបញ្ញារបស់សមាជិកនៃក្រុម*

*(គ) ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខ័ណ្ឌ ដែលនាំឱ្យមានវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែក នៃក្រុម*

*(ឃ) វិធានការណ៍សំដៅរារាំងកំណើតទារកនៅក្នុងក្រុម*

*(ង) ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត*

*(ខ) ការបង្កឱ្យមានការរងគ្រោះថ្នាក់ដល់រូបកាយ*

អ្នកតាក់តែងលក្ខន្តិកៈទីក្រុងរ៉ូមក៏បានបញ្ចូលគោលការណ៍នៃការផ្តន្ទាទោសចំពោះការញុះញង់ ដោយផ្ទាល់ និងជាសាធារណៈអោយប្រព្រឹត្តបទប្រល័យពូជសាសន៍ ដែលត្រូវបានចែងក្នុងមាត្រា ៣ នៃអនុសញ្ញាឆ្នាំ១៩៤៨។ មាត្រា ២៥ កថាខ័ណ្ឌ៣ វាក្យខ័ណ្ឌ *ង* នៃលក្ខន្តិកៈទីក្រុងរ៉ូមចែងថា:

*"ស្របតាមលក្ខន្តិកៈនេះ នឹងត្រូវទទួលខុសត្រូវ និងទទួលទណ្ឌកម្មជាលក្ខណ:បុគ្គលចំពោះបទល្មើស ដែល ស្ថិតនៅក្នុងយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនដែល:*

*(ង) ញុះញង់អ្នកដ៏ទៃដោយផ្ទាល់ និងជាសាធារណ:ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍"*

គោលការណ៍ខាងលើនេះត្រូវបានគេអនុវត្តជាលើកដំបូងនៅក្នុងដំណើរក្តីកាត់ទោសឧក្រិដ្ឋជនណាស៊ី ដោយ តុលាការយោធា Nuremberg នៅឆ្នាំ ១៩៤៥។ បទញុះញង់នេះត្រូវបានបង្កើតឡើងក្រោមរូបភាពជាឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ដើម្បីកាត់ទោស Julius Streicher ដែលបានសរសេរអត្ថបទជាច្រើនមានន័យប្រឆាំងទៅនឹងជន ជាតិជ្វីហ្វ។ បីឆ្នាំក្រោយមក អនុសញ្ញាឆ្នាំ១៩៤៨ ចែងថា បទញុះញង់ដោយផ្ទាល់ និងជាសាធារណៈអោយប្រព្រឹត្ត អំពើប្រល័យពូជសាសន៍នឹងត្រូវផ្តន្ទាទោសដូចជាការប្រព្រឹត្តិ ការសមគំនិត ការអោយដៃ និងការប៉ុនប៉ងប្រព្រឹត្តបទ ប្រល័យពូជសាសន៍ដែរ។ គោលការណ៍ដដែលនេះត្រូវបានគេយកទៅបញ្ចូលក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សំរាប់ប្រទេសយូហ្គោស្លាវី និងប្រទេសរ៉ូវ៉ាន់ដា។ សេចក្តីសំរេចមួយចំនួនរបស់តុលាការទាំងពីរនេះត្រូវបានធ្វើឡើង

ដោយផ្តោតជាសំខាន់លើការញុះញង់អោយប្រព្រឹត្តបទប្រល័យពូជសាសន៍[៣៨] ។ ក្រៅពីនេះ មានយុត្តិសាស្ត្រជាច្រើនដែលមានជំហរដូចគ្នា ទាក់ទងនឹងនិយមន័យនៃបទញុះញង់ខាងលើនេះ។ នេះបញ្ជាក់ថា "ការចូលរួមប្រព្រឹត្តបទល្មើស" នេះក្លាយទៅជាបទល្មើសមួយដាច់ដោយឡែកពីបទល្មើសដើម[៣៩] ។

## ក. បទប្រល័យពូជសាសន៍

ដូចដែលបានជំរាបជូនខាងលើរួចមកហើយថា បទប្រល័យពូជសាសន៍មិនត្រូវបានចែងក្នុងនីតិវិជ្ជមានខ្មែរទេ។ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមានគោលដៅបំពេញនូវកង្វះខាតនេះ ដោយបានឱ្យនិយមន័យបទប្រល័យពូជសាសន៍ដែលមានន័យដូចគ្នាទាំងស្រុងទៅនឹងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

### ១- នីតិវិជ្ជមាន

ថ្វីបើ នីតិព្រហ្មទណ្ឌទូទៅនៃប្រទេសកម្ពុជាទទួលស្គាល់ថា មានបទឧក្រិដ្ឋប្រល័យពូជសាសន៍ តែក្នុងករណីអតីតមេដឹកនាំខ្មែរក្រហម តែមានការចែងមួយចំនួននៅក្នុងនីតិព្រហ្មទណ្ឌខ្មែរ ដែលអាចឱ្យយុត្តាធិការនៃនីតិរួមលើកយកមកធ្វើជាអំណះអំណាងក្នុងការផ្តន្ទាទោសជនសង្ស័យពីបទប្រល័យពូជសាសន៍។

មានមូលដ្ឋានគតិយុត្តពីរដែលអាចឱ្យតុលាការលើកយកមកធ្វើជាអំណះអំណាងបាន គឺច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ កញ្ញា ១៩៩២ និងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥។ ច្បាប់ទាំងពីរនេះរួមគ្នាបង្កើតជានីតិវិជ្ជមាន ផ្នែកព្រហ្មទណ្ឌនៃប្រទេសកម្ពុជា លើកលែងតែក្នុងករណីដែលបានរៀបរាប់ខាងលើ[៤០] ។

អត្ថបទទាំងពីរនេះចែងអំពីអំពើមួយចំនួនដែលអាចកំណត់ថាជាបទប្រល័យពូជសាសន៍។ ឧទាហរណ៍ ទាំងច្បាប់ព្រហ្មទណ្ឌអន្តរកាល និងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ កំណត់ថាជាបទល្មើស អំពើមួយចំនួនដូចជា មនុស្សឃាត មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការរំលោភ ឬ ការរំលោភបំពានលើបូរណភាពរាងកាយនៃបុគ្គលជាដើម។

ច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងពីបទល្មើសមួយចំនួនដូចជា ឃាតកម្មដោយគិតទុកជាមុន (មាត្រា ៣១) អំពើមនុស្សឃាតដោយចេតនា (មាត្រា ៣២) បទរំលោភសេពសន្ថវៈ (មាត្រា ៣៣)។ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥

---

[៣៨] តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា, សំណុំរឿងទាក់ទងនឹងលោក Georges Ruggiu, លេខ ICTR-97-32-I សាលក្រមចុះថ្ងៃទី១ មិថុនា ២000 ហើយត្រូវបានសាលាឧទ្ធរត៌កល់ទុកជាបានការ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉ូវ៉ាន់ដា សំណុំរឿងទាក់ទងនឹងលោក Ferdinand Nahimana, Hassan Ngeze និង Jean-Bosco Barayagwiza, លេខ ICTR-99-52-T, សាលក្រមចុះថ្ងៃទី៣ ធ្នូ ២០០៣ ហើយសព្វថ្ងៃកំពុងចាត់ការដោយសាលាឧទ្ធរណ៍។

[៣៩] តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា សំណុំរឿង Akayesu ទំព័រទី១៤៨: *"ការញុះញង់គឺជាការចូលរួមក្នុងការប្រព្រឹត្តិបទល្មើសគឺជាបទល្មើសដែលនឹងត្រូវទទួលការផ្តន្ទាទោស"* ។

[៤០] សូមមើលផ្នែកទី២ ជំពូកទី១។

ចែងពីបទល្មើសផ្សេងទៀតដូចជា ការធ្វើទារុណកម្ម (មាត្រា ៥០០) និងបទល្មើសប្រឆាំងនឹងសាសនា ដូចជាការធ្វើឃាតព្រះសង្ឃជាដើម (មាត្រា ២០៩ ដល់២១៨)។ ដោយសារការចែងទាំងនេះមិនផ្ទុយនឹង "ស្មារតីនៃរដ្ឋធម្មនុញ្ញ" ដូចនេះការចែងទាំងនេះមានតំលៃជាច្បាប់ធរមាន (មាត្រា ១៥៨ នៃរដ្ឋធម្មនុញ្ញ)។ មិនតែប៉ុណ្ណោះ វាថែមទាំងជួយពង្រឹងការអនុវត្តន៍រដ្ឋធម្មនុញ្ញ ដោយធានានូវសេរីភាពខាងជំនឿសាសនាស្របទៅនឹងមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ព្រមទាំងផ្តន្ទាទោសរាល់អំពើធ្វើទារុណកម្ម ដែលស្របនឹងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។

កំរិតទោសធ្ងន់បំផុតនៃបទល្មើសទាំងនេះ គឺការជាប់ពន្ធនាគារអស់មួយជីវិត ស្របទៅនឹងការចែងក្នុង មាត្រា ៧៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

ថ្វីត្បិតតែការចែងទាំងប៉ុន្មានខាងលើមិនបានគ្របដណ្តប់លើបទប្រល័យពូជសាសន៍ទាំងមូល តែវាជាមូលដ្ឋានគតិយុត្តមួយដែលអាចត្រូវបានគេយកមកសំអាងដើម្បីផ្តន្ទាទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍។ ច្បាប់ឆ្នាំ ២០០១ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីកាត់ទោសអតីតមេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ ក៏បានលើកយកមាត្រាខាងលើមកធ្វើជាមូលដ្ឋានក្នុងការកាត់ទោសជនទាំងឡាយណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានលក្ខណៈទូទៅ និងមានលក្ខណៈជាប្រព័ន្ធ។

ជាទូទៅ ថ្វីបើច្បាប់ព្រហ្មទណ្ឌអន្តរកាល និងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ បានចែងពីបទល្មើសមួយចំនួនដូចជាមនុស្សឃាត ការធ្វើទារុណកម្ម ការរំលោភ ការលួច និងការបំផ្លិចបំផ្លាញជាដើម តែការចែងនេះមិនទាន់គ្រប់គ្រាន់សំរាប់កំណត់នូវលក្ខណៈពិសេសនៃបទប្រល័យពូជសាសន៍នៅឡើយទេ។

យោងតាមមាត្រា ២ នៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទប្រល័យពូជសាសន៍ និងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាអំពើទាំងឡាយណាដែលត្រូវបានប្រព្រឹត្តឡើងក្នុងចេតនាបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃមនុស្សមួយក្រុម ដោយហេតុផលខាងជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ ខាងសាសនា។ នីតិព្រហ្មទណ្ឌនៃប្រទេសកម្ពុជាបច្ចុប្បន្នថ្វីបើមានចែងអំពីបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងដោយបុគ្គល និង អំពើនីមួយៗដែលអាចផ្សំជាបទប្រល័យពូជសាសន៍ តែមិនបានចែងឱ្យបានច្បាស់អំពីបទប្រល័យពូជសាសន៍ទាំងមូលនោះទេ។ ម្យ៉ាងទៀត ច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏មិនបានចែងអំពីធាតុផ្សំអត្តនោម័តនៃបទល្មើសប្រល័យពូជសាសន៍ ដូចដែលមានចែងក្នុង មាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ។

| **និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងសេចក្តីព្រាង ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា កម២១១-១** | **និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុង លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦** |
|---|---|
| *បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាអំពើណាមួយ* | *ក្នុងគោលបំណងនៃលក្ខន្តិកៈនេះ បទឧក្រិដ្ឋ* |

| | |
|---|---|
| *ក្នុងចំនោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃក្រុម:*<br>*-ជាតិ*<br>*-ជាតិពន្ធុ*<br>*-ពូជសាសន៍*<br>*-សាសនា*<br>*អំពើទាំងនោះរួមមាន:*<br>*-ឃាតកម្មលើសមាជិកនៃក្រុម ។*<br>*-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិ្តបញ្ញារបស់សមាជិកនៃក្រុម ។*<br>*-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខ័ណ្ឌដែលនាំឱ្យមានវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែកនៃក្រុម ។*<br>*-វិធានការណ៍សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។*<br>*-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។* | *ប្រល័យពូជសាសន៍ គឺជាអំពើណាមួយក្នុងចំនោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃក្រុម:*<br>*-ជាតិ*<br>*-ជាតិពន្ធុ*<br>*-ពូជសាសន៍*<br>*-សាសនា*<br>*អំពើទាំងនោះរួមមាន:*<br>*-ឃាតកម្មលើសមាជិកនៃក្រុម ។*<br>*-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិ្តបញ្ញារបស់សមាជិកនៃក្រុម ។*<br>*-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខ័ណ្ឌ ដែលនាំឱ្យមានវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែកនៃក្រុម ។*<br>*-វិធានការណ៍សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។*<br>*-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។* |

ម្យ៉ាងទៀត យើងក៏សូមរំលឹកអំពីភាពមិនច្បាស់លាស់ចំពោះការអនុវត្តន៏ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ ដោយសារតែមានការបកស្រាយដោយគ្មានមូលដ្ឋានគ្រប់គ្រាន់លើមាត្រា ១៥៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា[៤១] ។ ដូចនេះអ្នកតំណាងរាស្ត្រកម្ពុជាមានកាតព្វកិច្ចក្នុងការបញ្ចូលធាតុផ្សំអត្តនោម័តនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ទៅក្នុងច្បាប់ ជាតិដូចដែលមានចែងក្នុងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ។

[៤១] សូមមើលផ្នែកទី២ ជំពូកទី១

## ២- ច្បាប់ដែលកំពុងត្រូវបានធ្វើការសិក្សា

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីខ្មែរ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការសិក្សា បានឱ្យនិយមន័យលើបទឧក្រិដ្ឋប្រល័យពូជសាសន៍ក្នុងមាត្រា កម ២១១១-១។ និយមន័យនេះដូចគ្នាទាំងស្រុងទៅនឹងនិយមន័យ ដែលបានឱ្យក្នុងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

អ្នកតាក់តែងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះបានធ្វើការអត្ថាធិប្បាយលើមាត្រា កម ២១១១-១ ដែលស្ថិតក្នុង គន្ថីទី១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះថា: *"ការបង្ក្រាបបទឧក្រិដ្ឋដែលធ្ងន់ធ្ងរជាងគេ ពោល គឺឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ប្រមូលផ្តុំនៅ គន្ថីទី១ ផ្នែកទី២ ដែលមានចំណងជើងថា "បទល្មើសប្រឆាំងនឹងបុគ្គល" បានបញ្ជាក់ឱ្យឃើញច្បាស់នូវឆន្ទៈរបស់អ្នកតាក់តែងច្បាប់កម្ពុជាក្នុងការផ្តល់សារៈសំខាន់ពិសេសដល់បទប្បញ្ញត្តិនៃសន្ធិសញ្ញាក្រុងរ៉ូម ស្តីពីការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ "*។

អ្នកតាក់តែងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះបានបញ្ជាក់ផងទៀតថា ការចែងស្តីពីចេតនាក្នុងការបំផ្លាញក្រុមមនុស្សមួយក្រុម គឺជាការយកតាមគំនិតនៃមាត្រា ២ អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទប្រល័យពូជសាសន៍។ ដោយមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមក៏បានយកតាមមាត្រា ២ នៃអនុសញ្ញាឆ្នាំ១៩៤៨ ដែរនោះ និយមន័យដែលបានចែងក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីកម្ពុជាស្របទាំងស្រុងនឹងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

គេគួរធ្វើការកត់សំគាល់ថា អនុសញ្ញាឆ្នាំ១៩៤៨ កំណត់យក **"ស្ថេរភាព"** មកធ្វើជាលក្ខណៈវិនិច្ឆ័យនៃក្រុមមនុស្សដែលមានចែងក្នុងនិយមន័យបទប្រល័យពូជសាសន៍ (ទស្សនទានដែលមានលក្ខណៈវត្ថុវិស័យ)។ មូលហេតុ ដែលនាំឱ្យមានការជ្រើសរើសយកលក្ខណៈវិនិច្ឆ័យនេះ គឺដោយសារនៅក្នុងកំឡុងពេលជជែកពិភាក្សា ដើម្បីតាក់តែងអនុសញ្ញានេះ មានរដ្ឋមួយចំនួនចង់ដាក់បញ្ចូលគំនិតដែលថា "ក្រុមដែលកំណត់ដោយហេតុផលនយោបាយ"។ ប៉ុន្តែគំនិតនេះត្រូវបានច្រានចោលដោយសហភាពសូវៀត ដោយយកលេសថា វានាំឱ្យមានការប៉ះពាល់ដល់ស្ថេរភាព ដែលជាបុគ្គលិកលក្ខណៈចំបងរបស់ក្រុមទាំងនោះ។ តែមូលហេតុពិតប្រាកដនៃការច្រានចោលនេះ គឺដោយសារការភ័យ ខ្លាចថា ការដែលរដ្ឋាភិបាល "ស្របច្បាប់" ធ្វើការបង្ក្រាបក្រុមបះបោរប្រឆាំងរដ្ឋាភិបាល អាចនឹងត្រូវចាត់ចូលជាបទឧក្រិដ្ឋប្រល័យពូជសាសន៍នេះដែរ។ ការភ័យខ្លាចបែបនេះមានកាន់តែខ្លាំងចំពោះរបបផ្តាច់ការឯកបក្ស។ គោលការណ៍ស្ថេរភាពនេះត្រូវបានទទួលស្គាល់ និងអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉ូវ៉ាន់ដា ក្នុងសេចក្តីសំរេចឈ្មោះ *Akayesu*:

*"ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍សំដៅតែលើអំពើណា ដែលបានប្រព្រឹត្តទៅលើក្រុមមនុស្សដែលមានស្ថេរ ភាពបង្កើតឡើងជាលក្ខណៈអចិន្ត្រៃយ៍ ហើយដែលមនុស្សក្នុងក្រុមនេះជាសមាជិកក្រុមតាំងពីកំណើត ហើយមិនត្រូវបាន*

*រាប់ចូលជាក្រុមមនុស្សដែលមានចែងក្នុងនិយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ រាល់ក្រុមមនុស្សទាំងឡាយណា ដែលមិនមានស្ថេរភាព ហើយការចូលជាសមាជិកនៃក្រុមនេះត្រូវបានធ្វើឡើងដោយការស្ម័គ្រចិត្តផ្ទាល់របស់បុគ្គល*"[៤២]។

ទស្សនទាន ដែលមានលក្ខណៈវត្ថុវិស័យនេះ មិនគ្រប់គ្រាន់ទេសំរាប់កំណត់ក្រុមដែលអាចត្រូវបានចាត់ចូលក្នុងនិយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយហេតុថា គេមិនអាចផ្តល់ភស្តុតាងអំពីចំណងរវាងបុគ្គល និងក្រុមបានទេ ប្រសិនបើគ្មានធាតុប្រធានវិស័យ។ បញ្ហានេះបានចោទឡើងនៅក្នុងសេចក្តីសំរេច *Akayesu* ដដែលនេះ ព្រមទាំងនៅក្នុងសេចក្តីសំរេច *Jesilic* ដែលចេញដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសយូហ្គោស្លាវី[៤៣]។ នៅក្នុងសេចក្តីសំរេចទាំងនេះ ចៅក្រមបានសំរេចថា ចំណងទាក់ទងនឹងក្រុមមួយត្រូវកំណត់ដោយឆន្ទៈជាប្រធានវិស័យរបស់សមាជិកនិមួយៗនៃក្រុមនោះ ពោលគឺឆន្ទៈរបស់បុគ្គលម្នាក់ៗក្នុងការចូលជាសមាជិកក្រុមមួយ។

ម្យ៉ាងវិញទៀត ការជាប់ទាក់ទងនឹងក្រុមមួយ ឬ មិនមែន ច្រើនតែត្រូវបានកំណត់ដោយបុគ្គលដែលមិនមែនជាសមាជិករបស់ក្រុមនោះ ពោលគឺកើតឡើងពីឆន្ទៈនយោបាយរបស់ឧក្រិដ្ឋជនប្រល័យពូជសាសន៍។ ដូច្នេះ ការចែងរបស់មាត្រា ២ នៃអនុសញ្ញាឆ្នាំ១៩៤៨ និងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម មិនទាន់គ្រប់គ្រាន់សំរាប់ធ្វើការផ្តន្ទាទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍នៅឡើយទេ។ គេត្រូវតែយកមកពិចារណាផងដែរនូវធាតុផ្សំដែលមានលក្ខណៈប្រធានវិស័យ ដែលអាចឱ្យឧក្រិដ្ឋជនប្រល័យពូជសាសន៍យកមកធ្វើជាហេតុផលក្នុងការចាត់ជនណាមួយ ចូលទៅក្នុងក្រុមណាមួយ។ ម្យ៉ាងទៀត ទស្សនទានវត្ថុវិស័យនេះគឺជាការផាត់ចោលនូវរាល់ក្រុមដែលត្រូវបានកំណត់ ដោយលក្ខណៈវិនិច្ឆ័យវត្ថុវិស័យ។ ក្រុមណាក៏ដោយដែលត្រូវបានវិនិច្ឆ័យដោយផ្អែកលើលក្ខណៈប្រធានវិស័យ ហើយ ដែលជាទូទៅតែងតែមានលក្ខណៈនយោបាយ ថាជាក្រុមដែលត្រូវបំផ្លាញចោលទាំងស្រុង ឬ ដោយផ្នែក ត្រូវតែ ទទួលបាននូវការការពារដូចគ្នាទៅនឹងក្រុមមនុស្សដែលមានចែងនៅក្នុងមាត្រា ២ នៃអនុសញ្ញាឆ្នាំ១៩៤៨ និង មាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

---

[៤២] តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉ូវ៉ាន់ដា សំណុំរឿង *Jean Paul Akayesu* លេខ ICTR-96-4-T, សាលក្រមចុះ ថ្ងៃទី២ កញ្ញា ១៩៩៨ កថាខ័ណ្ឌ ៥១១។

[៤៣] តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសយូហ្គោស្លាវី សំណុំរឿង *Goran Jelisic* លេខ IT-95-10-T, សាលក្រមចុះថ្ងៃទី១៤ ធ្នូ ១៩៩៩ កថាខ័ណ្ឌ ៧០: *ថ្វីត្បិតតែការកំណត់នូវក្រុមសាសនាមួយដោយផ្អែកលើធាតុវត្ថុវិស័យអាចធ្វើទៅបាន ប៉ុន្តែបច្ចុប្បន្ននេះ ការព្យាយាមកំណត់នូវក្រុមជាតិ ជាតិពន្ធុ ឬពូជសាសន៍ ដោយផ្អែកទៅលើធាតុវត្ថុវិស័យគឺជាការព្យាយាមប្រកបដោយ ការប្រថុយប្រថាន ហើយម្យ៉ាងទៀតលទ្ធផលដែលចេញពីការកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបែបនេះអាចនឹងមិនឆ្លុះបញ្ចាំងអំពីទស្សនវិស័នៃបុគ្គលទាំងឡាយចំពោះក្រុមនេះ។ វាជាការមួយសមហេតុផល ដែលធ្វើការកំណត់នូវក្រុមជាតិ ជាតិពន្ធុ ឬពូជសាសន៍ណាមួយដោយផ្អែកលើទស្សនវិស័យរបស់បុគ្គលទាំងឡាយដែលចង់ធ្វើការបែងចែកក្រុមនេះឱ្យដាច់ពី ក្រុមផ្សេងទៀត។ ដូច្នេះ អង្គជំនុំជម្រះសំរេច ធ្វើការកំណត់ក្រុមជាតិ ជាតិពន្ធុ ឬពូជសាសន៍ ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យ ប្រធានវិស័យៈ គឺការដែលសង្គមមួយស្អប់ខ្ពើមក្រុមមួយដោយសារមូលហេតុ ជាតិ ជាតិពន្ធុ ឬពូជសាសន៍ខុសពីគេ ដែលយើង អាចធ្វើការកំណត់បានថាតើប្រជាជនដែលត្រូវទទួលរងនូវការធ្វើទុក្ខបុកម្នេញ គឺជាក្រុមជាតិ ជាតិពន្ធុ ឬពូជសាសន៍មួយ ក្នុងក្រសែភ្នែកជនដែលបានប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញនេះ ឬក៏មិនមែន។ ជំហរនេះដូចគ្នាទៅនឹងជំហររបស់ អង្គជំនុំជម្រះក្នុងសេចក្តីសំរេច ទាក់ទងទៅនឹងការសិក្សាលើបណ្តឹងប្រឆាំងនឹង*Dragon Nikoli* *ក្នុងក្របខ័ណ្ឌនៃមាត្រា ៦១*"។

ការលំបាកក្នុងការកំណត់បទល្មើសដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថាជាបទប្រល័យពូជសាសន៍ តាមន័យនៃមាត្រា ២ នៃអនុសញ្ញាឆ្នាំ១៩៤៨ បង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ការឱ្យនិយមន័យលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយផ្អែកលើគោលការណ៍ស្ថេរភាព មិនមានលក្ខណៈសុក្រឹត្យឡើយ។

ទាក់ទងនឹងបញ្ហានេះ យើងអាចសិក្សាលើឧទាហរណ៍នៃច្បាប់បារាំង។ ច្បាប់បារាំងឱ្យនិយមន័យលើប្រភេទនៃក្រុមជនរងគ្រោះបានពេញលេញជាងអនុសញ្ញាឆ្នាំ១៩៤៨ និងលក្ខន្តិកៈទីក្រុងរ៉ូម។ ច្បាប់នេះបានឱ្យនិយមន័យ ក្រុមជនរងគ្រោះ ដោយបន្ថែមលក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈប្រធានវិស័យ ក្នុងគោលដៅចាត់ បញ្ចូលក្រុមផ្សេងទៀតដែលត្រូវបង្កើតឡើងតាមលក្ខណៈនយោបាយ សេដ្ឋកិច្ច អាជីព សង្គម ឬ ភេទ។ មាត្រា ២១១-១ នៃក្រមព្រហ្មទណ្ឌថ្មីរបស់បារាំងចែងថា:

*"ត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍ រាល់អំពើទាំងឡាយដូចមានចែងខាងក្រោម ដែលត្រូវបានប្រព្រឹត្តឡើង ឬបញ្ជាឱ្យគេប្រព្រឹត្តក្នុងផែនការណ៍បំផ្លាញទាំងស្រុង ឬ ដោយផ្នែកណាមួយ នៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាមួយ ឬ ក្រុមណាមួយផ្សេងទៀតដែលត្រូវបានកំណត់ដោយលក្ខណៈប្រធានវិស័យ។ អំពើទាំងនោះរួមមាន:*

*-មនុស្សឃាត*

*-ការប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរាងកាយ ឬ សតិបញ្ញា*

*-ការដាក់ក្រុមមួយឱ្យស្ថិតក្នុងលក្ខ័ណ្ឌដែលនាំឱ្យមានការវិនាសអន្តរាយទាំងស្រុង ឬ ដោយផ្នែកណាមួយនៃក្រុមនោះ*

*-ការរារាំងកំណើតទារក*

*-ការជម្លៀសកុមារដោយបង្ខំ*

ហេតុនេះ អ្នកតាក់តែងច្បាប់បារាំងបានដាក់បញ្ចូលក្នុងនិយមន័យនៃក្រុមជនរងគ្រោះ *"ក្រុមណាមួយដែលត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យប្រធានវិស័យផ្សេងទៀត"*។ និយមន័យនេះស្របទៅនឹងគំនិត ដ៏ត្រឹមត្រូវ ក្នុងការបង្ក្រាបអំពើប្រល័យពូជសាសន៍។

និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលចែងក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ស្របទៅនឹងនិយមន័យដែលមានចែងក្នុងមាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ក៏ប៉ុន្តែ និយមន័យនេះនៅមិនទាន់គ្រប់គ្រាន់ទេ ដោយមូលហេតុថា អ្នកតាក់តែងសេចក្តីព្រាងក្រមនេះបានប្រកាន់យកគោលការណ៍ស្ថេរភាពក្នុងការឱ្យនិយមន័យបទប្រល័យពូជសាសន៍ ហើយម្យ៉ាងទៀត វាជាការចាំបាច់ក្នុងការផ្តន្ទាទោសផងដែរចំពោះជនដែលបានប្រព្រឹត្តបទល្មើស

នេះដោយហេតុផលនយោបាយ ។ លក្ខន្តិកៈទីក្រុងរ៉ូមមិនបានហាមឃាត់កម្ពុជាមិនឱ្យកំណត់យកនិយមន័យទូលំទូលាយជាងចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះទេ ។ ផ្ទុយទៅវិញ យោងទៅលើវាក្យស័ព្ទដែលបានប្រើក្នុងមាត្រា ៦ ( ស្របតាមគោលដៅនៃលក្ខន្តិកៈនេះ ឧក្រិដ្ឋប្រល័យពូជសាសន៍ គឺវាល់អំពើទាំងឡាយណា...) លក្ខន្តិកៈទីក្រុងរ៉ូមទុកលទ្ធភាពឱ្យមានការឱ្យនិយមន័យប្លែកពីនេះ ។

---

**FIDH សូមផ្តល់នូវអនុសាសន៍ដូចតទៅ:**

**ដោយយោងទៅលើអ្វីដែលបានរៀបរាប់ខាងលើ សូមឱ្យអាជ្ញាធរកម្ពុជាធ្វើការកែប្រែមាត្រា កម ២១១១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីទៅជា:**

***"មាត្រា កម ២១១១-១: ធាតុផ្សំនៃបទប្រល័យពូជសាសន៍***

***បទប្រល័យពូជសាសន៍ គឺជាអំពើណាមួយក្នុងចំនោមនៃអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ សាសនា ឬ <u>ក្រុមណាមួយដែលត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យប្រធានវិស័យផ្សេងទៀត</u>:***

***១-ឃាតកម្មលើសមាជិកនៃក្រុម ។***
***២-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិបញ្ញារបស់សមាជិកនៃក្រុម ។***
***៣-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខ័ណ្ឌ ដែលនាំឱ្យវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែកនៃក្រុម ។***
***៤-វិធានការណ៍សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។***
***៥-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។***

---

## ខ. ការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍

មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ។ យោងតាមមាត្រានេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចក្នុងការជំនុំជម្រះរាល់រូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើសដែលមានចែងក្នុងមាត្រា៥ នៃលក្ខន្តិកៈ ព្រមទាំងជនសមគំនិត ជនដែលប៉ុនប៉ងប្រព្រឹត្តបទល្មើស ព្រមទាំងជនដែលបានឱ្យដៃក្នុងការប្រព្រឹត្តបទល្មើសទាំងនេះ ។ នីតិកម្មនៃប្រទេសកម្ពុជាក៏បានកំណត់ផងដែរនូវការផ្តន្ទាទោស ចំពោះបទល្មើស

ប៉ុនប៉ង ( មាត្រា ៣១, ៣២, ៣៣, ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៧៧ ដល់៨១ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥) និងការសមគំនិត ( មាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៨៣ ដល់៨៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥)[៤៤]។

ម្យ៉ាងវិញទៀត មាត្រា ២៥ កថាខ័ណ្ឌ៣ វាក្យខ័ណ្ឌ *ង* នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងអំពីការផ្តន្ទាទោសចំពោះការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ក្នុងឋានៈជាបទល្មើសស្វយ័ត។ ការចែងបែបនេះ បង្ហាញពីលក្ខណៈពិសេសនៃបទល្មើសប្រល័យពូជសាសន៍នេះ ដោយហេតុថា ការញុះញង់បែបនេះគឺជាបទល្មើសដាច់ដោយឡែកមួយ ដោយមិនចាំបាច់កំណត់ថាតើវានាំឱ្យមានការប្រព្រឹត្តបទល្មើសនោះដែរ ឬ អត់នោះទេ។

### ១- នីតិកម្មរបស់កម្ពុជាស្តីពីការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍

ច្បាប់ព្រហ្មទណ្ឌអន្តរកាលកំណត់ថា ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមគឺជាបទល្មើស ដែលនឹងត្រូវផ្តន្ទាទោស ( មាត្រា ៥៩, ៦០ និង៦១) ។

មាត្រា ២២៥ និង ៣០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ បានចែងជាពិសេសថាការញុះញង់ឱ្យមានការស្អប់ខ្ពើម និងការប្រមាថមើលងាយរវាងក្រុមមនុស្សដែលស្ថិតក្នុងឋានៈផ្សេងគ្នាក្នុងសង្គម ឬ ដែលមានជំនឿសាសនា ខុសគ្នាព្រមទាំងការញុះញង់ឱ្យមានសង្គ្រាមស៊ីវិល ទាំងនេះគឺជាបទល្មើសដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់។

ប៉ុន្តែនៅក្នុងនីតិរដ្ឋមាននៃប្រទេសកម្ពុជា មិនមានការចែងណាមួយដែលកំណត់ថា ការញុះញង់ដោយផ្ទាល់និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺជាបទល្មើសនោះឡើយ។

នីតិរដ្ឋមានកម្ពុជាធ្វើការបែងចែករវាងការញុះញង់ និងការសមគំនិត។ មាត្រា ៥៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចែងអំពីការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋដោយបានសំរេចផលថា:

*"នឹងត្រូវផ្តន្ទាទោសពីបទសមគំនិត ក្នុងអំពើដែលចាត់ថាជាបទឧក្រិដ្ឋតាមបទប្បញ្ញត្តិនេះ ជនទាំងឡាយណាដែល តាមរយៈសន្ទរកថា តាមការស្រែក ឬការគំរាមកំហែង បន្ទរឡើងក្នុងកន្លែងនានា ឬក្នុងទីប្រជុំជន សាធារណៈ តាមការសរសេរ ការបោះពុម្ព គំនូរ ចម្លាក់ វិចិត្រកម្ម និម្មិតរូប រូបភាព ឬគ្រប់ការគាំទ្រនៃការសរសេរ សំដី ឬរូបភាព ដែលដាក់លក់ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ តាមផ្ទាំងបដា ឬប័ណ្ណប្រកាស ដែលតាំងឱ្យ*

[៤៤] សូមមើលខាងក្រោម។

*សាធារណៈជនឃើញ តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សន៍ បានបង្កដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ ប្រព្រឹត្តអំពើដូចពោលខាងលើនេះ បើការញុះញង់នោះបានសំរេចផល ។*

*លក្ខន្តិកៈនេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ ។ "*

យោងតាមមាត្រានេះ ច្បាប់ព្រហ្មទណ្ឌអន្តរកាលបែងចែកការញុះញង់ជាពីរ គឺការញុះញង់ដោយបានសំរេចផល និងការញុះញង់ដែលនាំឱ្យមានត្រឹមតែការប៉ុនប៉ងប្រព្រឹត្តបទល្មើស ។ ការញុះញង់ដោយបានសំរេចផលត្រូវបានចាត់ទុកថាជាបទល្មើស ឬ ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ហើយនឹងត្រូវផ្តន្ទាទោសដូចការប្រព្រឹត្តបទល្មើសដែរ ។ ចំណែកឯការញុះញង់ ដែលនាំឱ្យមានត្រឹមតែការប៉ុនប៉ងប្រព្រឹត្តបទល្មើស នឹងត្រូវចាត់ទុកថាជាបទល្មើសមជ្ឈិម ហើយនឹងត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី១ ទៅ៥ឆ្នាំ ( មាត្រា ៦០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ។

ផ្ទុយមកវិញ ការសមគំនិតត្រូវបានឱ្យនិយមន័យនៅក្នុងមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលថាៈ

*"ជនណាដែលបានផ្តល់មធ្យោបាយសំរាប់ប្រព្រឹត្តបទល្មើស ដែលបានបញ្ជាឱ្យគេប្រព្រឹត្តបទល្មើស ដែលបានសំរួលដល់ការប្រព្រឹត្តបទល្មើស នឹងត្រូវចាត់ទុកថាជាអ្នកសមគំនិត ហើយត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសនោះដែរ ។"*

ដូច្នេះ ក្នុងច្បាប់ខ្មែរ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសគឺជាបទល្មើសមួយផ្សេងពីបទសមគំនិត ។ ការញុះញង់ដែលបង្កឱ្យមានត្រឹមតែការប៉ុនប៉ងប្រព្រឹត្តបទល្មើសក៏នឹងត្រូវចាត់ទុកថា ជាបទល្មើសដែរ ។

ដូចនេះ ច្បាប់ព្រហ្មទណ្ឌអន្តរកាលហាក់ដូចជាកំណត់ថា ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសគឺជាបទល្មើសស្វយ័ត្ត ។ ដោយហេតុថា បទប្រល័យពូជសាសន៍ គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរ គេគួរតែចែងអំពីការញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ផ្សេងពីការញុះញង់ក្នុងនីតិរួម ដូចអ្វីដែលបានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ។

### ២- សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី បានចែងអំពីការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនៅក្នុងមាត្រា កម ៤១៣៣-២ ដោយប្រើពាក្យថា "ការញុះញង់" ។ មាត្រានេះចែងថាៈ

*អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋតាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា កម ៤១៣៣-១ ត្រូវផ្តន្ទាទោសៈ*

*១. ដាក់ពន្ធនាគារពីប្រាំមួយខែ ទៅពីរឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល ទៅបួនលានរៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធិភាពទេ ។*

*២. ដាក់ពន្ធនាគារពីពីរឆ្នាំ ទៅប្រាំឆ្នាំ និងពិន័យជាប្រាក់ពីបួនលានរៀល ទៅដប់លានរៀល ប្រសិនបើការញុះញង់នេះមានប្រសិទ្ធិភាព លើកលែងតែបទប្បញ្ញត្តិនៃមាត្រា កម ១១២១-៤ នៃក្រមនេះ ។*

មាត្រា កម ៤១៣៣-១ ដែលត្រូវបានលើកឡើងក្នុងមាត្រា កម ៤១៣៣-២ខាងលើនេះចែងថា:

*មាត្រា កម ៤១៣៣-១: លក្ខខ័ណ្ឌនៃអត្ថិភាពនៃការញុះញង់*

*ដើម្បីអនុវត្តជំពូកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះបានប្រព្រឹត្ត:*

*១. ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬ នៅក្នុងពេលប្រជុំជាសាធារណៈ*

*២. ដោយសំនេរ ឬ គំនូរតាមប្រភេទណាក៏ដោយដែលត្រូវផ្សព្វផ្សាយនៅក្នុងសាធារណជន ឬ តាំងឱ្យសាធារណជនមើល*

*៣. ដោយគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍សំរាប់សាធារណជន ។*

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីបានកំណត់ថា ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស គឺជាបទល្មើសមួយ ដោយមិនមានធ្វើការបែងចែកថា តើការញុះញង់នោះនាំឱ្យមានការប្រព្រឹត្តបទល្មើសដែរឬអត់នោះទេ។ ដូចនេះ ការចែងក្នុងសេចក្តីព្រាងនេះមានការធូរស្រាលជាងអត្ថបទច្បាប់ជាធរមាន។

ដោយបទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាបទល្មើសធ្ងន់ធ្ងរ គេគួរតែផ្តន្ទាទោសការញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឱ្យបានធ្ងន់ធ្ងរដែរ ពោលគឺការញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ត្រូវចាត់ទុកថាជាបទ ឧក្រិដ្ឋ មិនមែនជាបទមជ្ឈិម។ ប៉ុន្តែ ការចែងនេះត្រូវតែចែងនៅក្នុងមាត្រាមួយដាច់ដោយឡែកពីការញុះញង់ទូទៅ ហើយកំណត់ឱ្យបានច្បាស់ថាជាការញុះញង់ឱ្យប្រព្រឹត្តបទប្រល័យពូជសាសន៍។

ម្យ៉ាងទៀត បើយើងមើលមាត្រា ១៧ កថាខ័ណ្ឌ១ វាក្យខ័ណ្ឌ ឃ និងមាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម យើងអាចចោទជាសំនួរថា តើការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយមិនបង្កឱ្យ

មានការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អាចនឹងត្រូវជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ ប្រសិនបើតុលាការនេះចាត់ទុកការញុះញង់នេះមិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់។ មាត្រាខាង លើនេះចែងថាៈ

*"១. យោងតាមកថាខ័ណ្ឌទី១០នៃបុព្វកថា និងមាត្រា១ តុលាការកំណត់ថា ករណីមួយមិនអាចទទួលយកបានទេបើៈ*

*(ឃ) ករណីនោះមិនធ្ងន់ធ្ងរគ្រប់គ្រាន់ល្មមសម្រាប់ធ្វើយុត្តិកម្មសកម្មភាពបន្តទៀតដោយតុលាការ។"*

ដូចនេះ ប្រទេសកម្ពុជាដែលជាប្រទេសហត្ថលេខីនៃអនុសញ្ញាឆ្នាំ១៩៤៨ គួរតែចែងឱ្យបានច្បាស់អំពីផ្តន្ទាទោសការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ទោះបីជាការញុះញង់បានសំរេច ផល ឬមិនបានសំរេចផលក៏ដោយ។

សារុបសេចក្តីមក ថ្វីត្បិតតែនីតិកម្មនៃប្រទេសកម្ពុជាបានចែងអំពីការញុះញង់ឱ្យប្រព្រឹត្តបទល្មើស គឺជាបទល្មើសស្វយ័ត្ យ ប៉ុន្តែមិនមានការចែងណាមួយឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់អំពីការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ ទាំងក្នុងច្បាប់ជាធរមាន ទាំងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។

---

**FIDH សូមផ្តល់អនុសាសន៍ដូចតទៅៈ**

**បញ្ចូលក្នុងសេចក្តីព្រាងព្រហ្មទណ្ឌថ្មី មាត្រាមួយទៀត គឺមាត្រា កម ៤១៣៣-៣ ដែលចែងអំពីការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍[៤៥]។ មាត្រានេះនឹងចែងថាៈ**

***"មាត្រា កម ៤១៣៣-៣ ការញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍***

***ការញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តាមមធ្យោបាយណាមួយក្នុងចំនោមមធ្យោបាយដែលមានចែងក្នុងមាត្រា កម ៤១៣៣-១ នឹងត្រូវផ្តន្ទាទោសៈ***

***១. ដាក់ពន្ធនាគារយ៉ាងច្រើន៣០ឆ្នាំ ប្រសិនបើការញុះញង់នាំឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍***

[៤៥] ការបញ្ចូលមាត្រា កម ៤១៣៣-៣ថ្មី ដូចដែលបានស្នើសុំនេះ នាំឱ្យមាត្រា កម ៤១៣៣-៣ ចាស់ ដែលទាក់ទងទៅនឹង "ការញុះញង់ឱ្យមានការរើសអើង" នឹងត្រូវប្តូរទៅជាមាត្រា កម ៤១៣៣-៤, មាត្រា កម ៤១៣៣-៤ ចាស់ ស្តីពី "ការញុះញង់តាមរយៈសារពត៌មាន" នឹងត្រូវប្តូរទៅជាមាត្រា កម ៤១៣៣-៥ ហើយមាត្រា កម ៤១៣៣-៥ ចាស់ ស្តីពី "ការដាក់ទោសបន្ថែម" នឹងត្រូវប្តូរទៅជាមាត្រា កម ៤១៣៣-៦។

***២. ដាក់ពន្ធនាគារពី២ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ រៀល ទៅ ៤ ០០០ ០០០ រៀល ប្រសិនបើការញុះញង់នោះមិនបង្កឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍"***

## ជំពូកទី២: បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងក្នុងមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ហើយត្រូវបានរាប់បញ្ចូលក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូចនេះ រដ្ឋហត្ថលេខីចាំបាច់ត្រូវដាក់បញ្ចូលឧក្រិដ្ឋកម្មនេះទៅក្នុងនីតិកម្មជាតិរបស់ខ្លួន ដើម្បីឱ្យតុលាការជាតិមានសមត្ថកិច្ចជំនុំជម្រះឧក្រិដ្ឋជននៃបទឧក្រិដ្ឋនេះ។

ច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្នរបស់កម្ពុជាមិនបានចែងពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ដូច្នេះ ឧក្រិដ្ឋកម្មនេះនឹងមិនត្រូវបានផ្តន្ទាទោសទេ។ ប៉ុន្តែនីតិរួមបានចែងអំពីការផ្តន្ទាទោសនូវបណ្តាអំពើមួយចំនួនដែលអាចជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាអំពើមនុស្សឃាត (មាត្រា ៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល) អំពើរំលោភ (មាត្រា ៣៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល) អំពើពេស្យាកម្មដោយបង្ខំ (មាត្រា ៣ ច្បាប់ចុះថ្ងៃទី១៦ មករា ១៩៩៦ ស្តីអំពីការផ្តន្ទាទោសអំពើចាប់ជំរិត ការជួញដូរ និងការធ្វើអាជីវកម្មលើផ្លូវភេទ និងមាត្រា ៤៥ និង៤៦ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)។

ទោះជាយ៉ាងនេះក៏ដោយ ការចែងខាងលើនេះមិនទាន់គ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របទៅនឹងការចែងរបស់មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ។ មាត្រា ៧ នេះចែងថា:

***១. សំរាប់គោលបំណងនៃលក្ខន្តិកៈនេះ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះកាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬ ជាប្រព័ន្ធសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល:***

*(ក) ឃាតកម្ម។*

*(ខ) ការសម្លាប់រង្គាល។*

*(គ) ការធ្វើឱ្យទៅជាទាសកម្ម។*

*(ឃ) ការនិរទេស ឬជម្លៀសប្រជាជនដោយការបង្ខំ។*

*(ង) ការដាក់ពន្ធនាគារ ឬការដកហូតសេរីភាពខាងរាងកាយ ដោយបំពានលើវិធានជាមូលដ្ឋាននៃនីតិអន្តរជាតិ ។*

*(ច) ការធ្វើទារុណកម្ម ។*

*(ឆ) ការចាប់បង្ខំសេពសន្ថវៈ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការមានគភ៌ដោយបង្ខំ ការធ្វើឱ្យគ្មានកូនដោយបង្ខំ ឬការបំពានផ្លូវភេទក្នុងទម្រង់ទ្រាយផ្សេងទៀត ដែលមានភាពធ្ងន់ធ្ងរប្រហែលគ្នានេះ ។*

*(ជ) ការធ្វើទុក្ខបុកម្នេញលើក្រុម ឬ សមូហភាពជាក់លាក់ណាមួយដោយមូលហេតុនយោបាយ ពូជអំបូរ ជាតិសាសន៍ ជាតិពន្ធុ វប្បធម៌ សាសនា ឬយេនឌ័រ ដូចបានកំណត់និយមន័យក្នុងកថាខណ្ឌទី៣ ឬ លើមូលដ្ឋាន ផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាសាកលថាមិនអាចអនុញ្ញាតឱ្យធ្វើបានតាមច្បាប់អន្តរជាតិនៅក្នុងទំនាក់ទំនង ជាមួយអំពើណាមួយដែលបានចែងក្នុងកថាខណ្ឌនេះ ឬ បទល្មើសព្រហ្មទណ្ឌណាមួយ ដែលស្ថិតក្នុងយុត្តាធិការតុលាការ ។*

*(ឈ) ការបាត់ខ្លួនមនុស្សដោយបង្ខំ ។*

*(ញ) បទល្មើសអាប៉ាថេដ ។*

*(ដ) អំពើអមនុស្សធម៌ស្រដៀងគ្នាផ្សេងទៀត ដែលមានលក្ខណៈជាអន្តរជាតិ ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬ គ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់រូបរាងកាយ ឬ ដល់សុខភាពខាងបញ្ញាស្មារតី ឬ សុខភាពខាងរូបកាយ ។"*

### *២. សំរាប់គោលបំណងនៃកថាខណ្ឌទី១នេះ*

*(ក) "ការវាយលុកជាទូទៅសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល" មានន័យថា ដំណើរការនៃការប្រព្រឹត្តិមួយពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើជាច្រើនដូចមានចែងក្នុងកថាខណ្ឌទី១ ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់ ស្របតាម ឬ ស្ថិតក្នុងការធ្វើឱ្យជឿនលឿនទៅមុខរបស់រដ្ឋមួយ ឬ គោលនយោបាយចាត់តាំងដើម្បីប្រព្រឹត្តការវាយប្រហារបែបនេះ ។*

*(ខ) "ការសំលាប់រង្គាល"គឺជាការដាក់លក្ខខណ្ឌលើជីវិតដោយចេតនាដែលក្នុងចំណោមនោះមានការដកហូតសិទ្ធិទទួលបានអាហារនិងថ្នាំពេទ្យក្នុងករិតមួយដែលប្រុងនឹងនាំដល់មានការបំផ្លិចបំផ្លាញផ្នែកមួយ នៃប្រជាពលរដ្ឋ ។*

*(គ) "ការធ្វើឱ្យទៅជាទាសកម្ម" មានន័យថា ការប្រើអំណាចណាមួយ ឬ អំណាចទាំងអស់ដែលមានជាប់នឹងសិទ្ធិកម្មសិទ្ធិទៅលើជនម្នាក់ និងរួមទាំងការប្រើសិទ្ធិនេះក្នុងដំណើរការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ។*

*(ឃ) "ការនិរទេស ឬជម្លៀសប្រជាជនដោយការបង្ខំ" មានន័យថា ការផ្លាស់ទីកន្លែងរបស់ជនដែល ពាក់ព័ន្ធ ដោយបង្ខំដោយការបណ្តេញ ឬ ដោយអំពើបង្ខិតបង្ខំផ្សេងទៀតចេញពីតំបន់ដែលពួកគេមានវត្តមាននៅ ដោយស្រប ច្បាប់ ដោយគ្មានមូលដ្ឋានដូចបានអនុញ្ញាតក្នុងច្បាប់អន្តរជាតិ ។*

*(ង) "ការធ្វើទារុណកម្ម" មានន័យថា ការធ្វើឱ្យមានការចុកចាប់ ឬការរងគ្រោះជាទំងន់ដោយចេតនា ទោះបីជាដល់រូបកាយក្តី ឬដល់បញ្ញាស្មារតីក្តី ទៅលើជនដែលនៅក្នុងការឃុំឃាំង ឬក្រោមការត្រួតត្រារបស់ជន ជាប់ចោទ លើកលែងតែចំពោះការណីទារុណកម្ម គេមិនត្រូវរាប់បញ្ចូលការចុកចាប់ ឬការរងគ្រោះដែលកើតចេញពី ការដាក់ទណ្ឌកម្មស្របច្បាប់ដែលមានជាប់នឹងអំពើនោះ ឬដែលមានជាយថាហេតុទេ ។*

*(ច) "ការមានគភ៌ដោយបង្ខំ" មានន័យថា ការបង្ខាំងដោយខុសច្បាប់នូវស្ត្រីដែលត្រូវធ្វើឱ្យមានគភ៌ដោយ បង្ខំ ដោយមានចេតនាចង់ឱ្យមានការប៉ះពាល់ដល់សមាសភាពជាតិពន្ធនៃពលរដ្ឋណាមួយ ឬ ការអនុវត្តការបំពានដ៏ធ្ងន់ធ្ងរដ៏ ទៃទៀតលើច្បាប់អន្តរជាតិ ។ ក្នុងករណីណាក៏ដោយ មិនត្រូវយកនិយមន័យនេះទៅបកស្រាយឱ្យមានឥទ្ធិពលលើច្បាប់ ជាតិពាក់ព័ន្ធនឹងដំណើរការមានគភ៌ឡើយ ។*

*(ឆ) "ការធ្វើទុក្ខបុកម្នេញ" មានន័យថាការដកហូតសិទ្ធិជាមូលដ្ឋានដោយចេតនា និងយ៉ាងធ្ងន់ធ្ងរដែលផ្ទុយ នឹងច្បាប់អន្តរជាតិ ដោយមូលហេតុនៃអត្តសញ្ញាណនៃក្រុម ឬសមូហភាព ។*

*(ជ) "បទល្មើសអាប៉ាថេដ" មានន័យថា អំពើអមនុស្សធម៌ដែលមានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងអំពើ ទាំងឡាយណាដែលពោលនៅក្នុងកថាខ័ណ្ឌទី១ ដែលបានប្រព្រឹត្តក្នុងបរិបទនៃរបបគ្រប់គ្រងជាស្ថាប័ន នៃការសង្កត់ សង្កិន ជាលក្ខណៈប្រព័ន្ធ និងការគ្របសង្កត់របស់ក្រុមពូជសាសន៍មួយទៅលើក្រុមពូជសាសន៍មួយ ឬច្រើន ដ៏ទៃទៀត ហើយដែលបានប្រព្រឹត្តក្នុងចេតនាទុករបបនោះ ។*

*(ឈ) "ការបាត់ខ្លួនមនុស្សដោយបង្ខំ" មានន័យថា ការចាប់ខ្លួន ការឃុំឃាំង ឬការចាប់ពង្រត់មនុស្ស ដោយ មានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមរបស់រដ្ឋ ឬ អង្គការនយោបាយ បន្ទាប់មកមានការបដិសេធមិនទទួលដឹង ឮអំពីការដកហូតសេរីភាពនោះ ឬមិនផ្តល់ពត៌មានអំពីជោគវាសនា ឬ ទីសំចតនៃជនទាំងនោះ ដោយមានចេតនាដក ពួកគេចេញពីការការពារតាមផ្លូវច្បាប់ក្នុងរយៈពេលពន្យារយូរមួយ ។*

***៣. សម្រាប់គោលបំណងនៃលក្ខន្តិកៈនេះ ពាក្យ "ជែនឌ័រ" ត្រូវបានយល់ថា សំដៅលើភេទទាំងពីរ បុរសនិងស្ត្រីនៅក្នុងបរិបទនៃសង្គម ។ពាក្យ "ជែនឌ័រ" មិនបានបង្ហាញអត្ថន័យណាមួយផ្សេងពីខាងដើមនេះទេ ។***

ដើម្បីបំពេញនូវចន្លោះប្រហោងនេះ អ្នកតាក់តែងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីបានស្នើឡើងនូវនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា កម ២១២១-១។ អ្នកតាក់តែងសេចក្តីព្រាងនេះបានសរសេរក្នុងសេចក្តីអត្ថាធិប្បាយរបស់ខ្លួនថា "*និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ គឺជាការបញ្ចូលមាត្រា ៧នៃលក្ខន្តិកៈ ទីក្រុងរ៉ូមស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិមកក្នុងច្បាប់ខ្មែរ*"។ ប៉ុន្តែ នៅពេលដែលគេធ្វើការសិក្សាលំអិត លើនិយមន័យក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីថ្មីនេះ គេសង្កេតឃើញមានការខ្វះចន្លោះមួយចំនួន។ ឃ្លា "*ឬ លើមូលដ្ឋានផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាសាកលថាមិនអាចអនុញ្ញាតឱ្យធ្វើបានតាមច្បាប់អន្តរជាតិនៅក្នុងទំនាក់ទំនងជាមួយអំពើណាមួយដែលបានចែងក្នុងកថាខណ្ឌនេះ ឬ បទល្មើសព្រហ្មទណ្ឌណាមួយដែលស្ថិតក្នុងយុត្តាធិការតុលាការ*" និង "*ដល់សុខភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ*" មិនបានចែងក្នុងមាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនោះទេ។ មាត្រានេះចែងថាៈ

*"បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាបទឧក្រិដ្ឋដែលអំពើណាមួយចែងខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលៈ*

*១-ឃាតកម្ម។*

*២-ការសម្លាប់រង្គាល។*

*៣-ការធ្វើឱ្យទៅជាទាសកម្ម។*

*៤-ការនិរទេស ឬជម្លៀសប្រជាជនដោយការបង្ខំ។*

*៥-ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ។*

*៦-ការធ្វើទារុណកម្ម។*

*៧-ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មផ្លូវភេទ ពេស្យាចារដោយបង្ខំ ការធ្វើឱ្យមានគភ៌ដោយបង្ខំ ការធ្វើឱ្យគ្មានកូនដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហឹង្សាខាងផ្លូវភេទ ដែលមានទំងន់ដូចគ្នា។*

*៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពជាក់លាក់ណាមួយដោយមូលហេតុនយោបាយ ពូជអំបូរ ជនជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ។*

*៩-ការបាត់ខ្លួនដោយបង្ខំ។*

*១០-ការប្រកាន់ពូជសាសន៍*

*១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀតដែលបង្កឱ្យការឈឺចាប់យ៉ាងខ្លាំង ឬ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ។*

ម្យ៉ាងទៀត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងបទល្មើសអាប៉ាថេដ ដែលមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រា ៧ លក្ខន្តិកៈទីក្រុងរ៉ូម ហើយដែលនិយមន័យត្រូវបានកំណត់យ៉ាងច្បាស់នៅវាក្យខ័ណ្ឌ *ខ ឧ* និង *ជ* នៃ កថាខ័ណ្ឌ២ មាត្រាដដែល មិនត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់ខ្មែរឡើយ។ ចំណែកឯនិយមន័យនៃអំពើទារុណកម្ម ដែលមានចែងក្នុងវាក្យខ័ណ្ឌ *ង* នៃកថាខ័ណ្ឌ២ មាត្រា ៧ លក្ខន្តិកៈទីក្រុងរ៉ូម មានភាពទូលំទូលាយជាងនិយមន័យដែលមានចែងក្នុងមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ១៩៥៥ (ការអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ នេះនៅតែមានភាពស្រពិចស្រពិលនៅឡើយ ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ)។

## ក. ការប៉ះពាល់ដល់សុខភាពផ្លូវកាយនិងខាងសតិបញ្ញា

មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងថា អំពើអមនុស្សធម៌ដែលនាំឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬប៉ះពាល់ដល់ "សុខភាពខាងផ្លូវកាយឬខាងសតិបញ្ញា" គឺជាធាតុផ្សំចំបងនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ដូចនេះ លក្ខន្តិកៈទីក្រុងរ៉ូមមានគោលដៅពង្រីកនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឱ្យកាន់តែទូលាយថែមទៀត ព្រមទាំងផ្តល់នូវតំលៃនៃការប៉ះពាល់ដល់សុខភាពផ្លូវកាយនិងខាងសតិបញ្ញាឱ្យស្មើនឹងការបំពារបំពានលើបូរណភាពរាងកាយរបស់បុគ្គល។

ការប៉ះពាល់ដល់សុខភាពផ្លូវកាយ ឬ ខាងសតិបញ្ញាមានអត្ថន័យខុសពីការប៉ះពាល់ដល់បូរណភាពលើរូបរាងកាយឬបូរណភាពលើផ្លូវចិត្តដែលមិនមានចែងក្នុងមាត្រាកម២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីទេ។ ការប៉ះពាល់ដល់សុខភាពខាងសតិបញ្ញាអាចកើតមានឡើង ទោះបីជាមិនមានការប៉ះពាល់ដល់បូរណភាពលើរូបរាងកាយ ក៏ដោយ។ ដូចគ្នានេះដែរ ការប៉ះពាល់ដល់សុខភាពផ្លូវកាយអាចកើតមានឡើង ទោះបីជាគ្មានការប៉ះពាល់ដល់បូរណភាពលើផ្លូវកាយ។

អ្នកតាក់តែងមាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមិនបានចែងថា ការប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវកាយឬខាងសតិបញ្ញាគឺជាធាតុផ្សំចំបងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ។ ការខកខានមិនបានចែងបែបនេះនាំឱ្យការបង្រាបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមានភាពទូលំទូលាយ និងពេញលេញនោះទេបើ យើងធ្វើការប្រៀបធៀបទៅនឹងការចែងនៃលក្ខន្តិកៈទីក្រុងរ៉ូម។ ហេតុនេះហើយ គេចាំបាច់ត្រូវបញ្ចូលនិយមន័យនៃអំពើទាំងនេះទៅក្នុងមាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។

## ខ. ការចាំបាច់ក្នុងការបញ្ជាក់ឱ្យបានច្បាស់ក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនូវអត្ថន័យនៃបណ្តាអំពើមួយចំនួនដែលជាធាតុផ្សំចំបងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ច្បាប់ព្រហ្មទណ្ឌនៃប្រទេសកម្ពុជាមិនមានចែងអំពីនិយមន័យនៃអំពើសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអាប៉ាថេត ដែលសុទ្ធសឹងតែជាធាតុផ្សំចំបងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ ដើម្បីឱ្យស្របទៅនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និយមន័យនៃអំពើទាំងបីខាងលើនេះត្រូវតែមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន។

ដូចនេះ គេត្រូវតែបញ្ចូលនិយមន័យនៃអំពើទាំងនេះទៅក្នុងមាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ដោយយកគំរូតាមមាត្រា ៧ កថាខ័ណ្ឌ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលបានចែងស្របនឹងនីតិអន្តរជាតិ។ មាត្រា ៣ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា និងមាត្រា ៥ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវីបានយកតាមគំរូលក្ខន្តិកៈទីក្រុងរ៉ូម។

ម្យ៉ាងវិញទៀត មាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងអំពីចេតនានៃការធ្វើទុក្ខបុកម្នេញមានភាពទូលាយជាងអ្វីដែលមានចែងនៅក្នុងអត្ថបទច្បាប់អន្តរជាតិមុនៗ (មាត្រា៦ *គ* នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិនីរម៉ឺប៊ែរ មាត្រា ៣ និង៥ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងពីរដែលបានចែងខាងលើ)។ ដូចនេះ គេគួរតែបញ្ចូលនូវការកំណត់ អំពីចេតនា ឱ្យបានទូលំទូលាយជាងនេះទៅក្នុងច្បាប់ខ្មែរ ទាក់ទងនឹងនិយមន័យនៃការធ្វើទុក្ខបុកម្នេញ។ ផ្ទុយទៅវិញ មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងថា *ការធ្វើទុក្ខបុកម្នេញ* ត្រូវតែបានប្រព្រឹត្ត *"នៅក្នុងទំនាក់ទំនងជាមួយអំពើណាមួយដែលបានចែងក្នុង [កថាខ័ណ្ឌ២ នៃមាត្រា ៧ នៃលក្ខន្តិកៈ ទីក្រុងរ៉ូមនេះ] ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលស្ថិតក្នុងយុត្តាធិការតុលាការ"*។ គេអាចនិយាយ បានម្យ៉ាងទៀតថា ការធ្វើទុក្ខបុកម្នេញ ដែលមិនទាក់ទងនឹងអំពើ ដូចមានចែងខាងលើនេះ មិនគ្រប់គ្រាន់ក្នុងការកំណត់បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ វាត្រូវតែមានទំនាក់ទំនងទៅនឹងអំពើផ្សេងទៀតដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬទៅនឹងឧក្រិដ្ឋកម្មដែលស្ថិតក្នុងសមត្ថកិច្ចតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមិនបានចែងអំពីលក្ខ័ណ្ឌបែបនេះទេ។ ដូចនេះវាជាចំនុចវិជ្ជមានមួយនៃមាត្រាខាងលើនេះ។

ដូចគ្នានេះដែរ ទាក់ទងនឹងអំពើទារុណកម្ម និយមន័យនៃមាត្រា ១ អនុសញ្ញាចុះថ្ងៃទី១០ ធ្នូ ១៩៨៤ ស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម និងទោស ឬអំពើឃោរឃៅ អមនុស្សធម៌ និងមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៥ មានភាពចង្អៀតជាងនិយមន័យនៃមាត្រា ៧ លក្ខន្តិកៈទីក្រុងរ៉ូម។

និយមន័យដែលមានចែងក្នុងមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមខុសពីនិយមន័យដែលចែងក្នុងមាត្រា ១ នៃអនុសញ្ញាចុះថ្ងៃទី១០ ធ្នូ ១៩៨៤ ដែលបានចែងថា ជនដែលប្រព្រឹត្តអំពើទារុណកម្មត្រូវតែជាភ្នាក់ងារក្នុងមុខងារសាធារណៈ ឬជាបុគ្គលផ្សេងទៀតដែលប្រព្រឹត្តអំពើទាំងនេះក្នុងឋានៈផ្លូវការរបស់ខ្លួន ឬបានញុះញង់ ឬបានផ្តល់នូវការព្រមព្រៀងដោយច្បាស់លាស់ ឬដោយមិនច្បាស់លាស់។

ម្យ៉ាងវិញទៀត និយមន័យដែលមានចែងក្នុងមាត្រា ៧ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ង មានភាពទូលំទូលាយជាងនិយមន័យដែលមានចែងក្នុងមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ ទាក់ទងនឹងគោលបំណងនៃការធ្វើទារុណកម្ម។ មាត្រា ៥០០ បានចែងថា ការធ្វើទារុណកម្មត្រូវតែធ្វើឡើងដើម្បីសួរចំលើយ។ មាត្រា ៥០០ បានចែង ថា: *"ជនណាធ្វើទារុណកម្មអ្នកដទៃ ដើម្បីឱ្យអ្នកនោះឈឺចាប់ជាខ្លាំង ហើយធ្លាយប្រាប់ពត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមជ្ឈឹមកម្មណាមួយក្តី ដើម្បីសងសឹក ឬដោយអំពើចិត្តព្រៃរបស់ខ្លួនក្តី ជននោះត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី។"*

ប៉ុន្តែលក្ខន្តិកៈទីក្រុងរ៉ូមបានចែងកាន់តែចង្អៀតជាងមាត្រា ៥០០ ទៅទៀត ទាក់ទងនឹងជនដែលប្រព្រឹត្តអំពើទារុណកម្ម ព្រោះថាមាត្រា ៧ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ង បានចែងថា ជនរងគ្រោះត្រូវតែស្ថិតក្នុងការគ្រប់គ្រងរបស់ជនប្រព្រឹត្តអំពើទារុណកម្ម។

លើសពីនេះទៅទៀត យើងសូមធ្វើការរំលឹកទៀតថា ការអនុវត្តន៍មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ នៅតែមានភាពមិនច្បាស់លាស់ ដោយសារតែមានការបកស្រាយដោយគ្មានមូលដ្ឋាន លើមាត្រា ១៥៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៤៦]។

---

**FIDH សូមផ្តល់នូវអនុសាសន៍ដូចតទៅ:**

**ធ្វើការកែប្រែមាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ដើម្បីបន្ថែមអំពើអមនុស្សធម៌ ដែលបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬការប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវកាយឬខាងសតិបញ្ញា ចូលទៅក្នុងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។**

[៤៦] សូមមើលផ្នែកទី២ ជំពូកទី១។

បន្ថែមកថាខ័ណ្ឌ២ ដល់មាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ដោយឱ្យនិយមន័យលើពាក្យ "ការសម្លាប់រង្គាល" "អំពើទារុណកម្ម" "អំពើធ្វើទុក្ខបុកម្នេញ" និង "អំពើអាប៉ាថេត" ដូចដែលបានចែងក្នុងមាត្រា ៧ កថាខ័ណ្ឌ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ហើយស្របទៅនឹងនីតិអន្តរជាតិ ។

មាត្រា កម ២១២១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនឹងចែងយ៉ាងដូច្នេះ

*"បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាបទឧក្រិដ្ឋដែលអំពើណាមួយចែងខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលៈ*

*១-ឃាតកម្ម ។*

*២-ការសម្លាប់រង្គាល ។*

*៣-ការធ្វើឱ្យទៅជាទាសកម្ម ។*

*៤-ការនិរទេស ឬជម្លៀសប្រជាជនដោយការបង្ខំ ។*

*៥-ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។*

*៦-ការធ្វើទារុណកម្ម ។*

*៧-ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មផ្លូវភេទ ពេស្យាចារដោយបង្ខំ ការធ្វើឱ្យមានគភ៌ដោយបង្ខំ ការធ្វើឱ្យគ្មានកូនដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហឹង្សាខាងផ្លូវភេទ ដែលមានទំងន់ដូចគ្នា ។*

*៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពជាក់លាក់ណាមួយដោយមូលហេតុនយោបាយ ពូជអំបូរ ជនជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ។*

*៩-ការបាត់ខ្លួនដោយបង្ខំ ។*

*១០-ការប្រកាន់ពូជសាសន៍*

*១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀតដែលបង្កឱ្យការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។*

*សំរាប់គោលបំណងនៃកថាខ័ណ្ឌទីខាងលើនេះ*

*១- "ការសំលាប់រង្គាល" គឺជាការដាក់លក្ខខ័ណ្ឌលើជីវិតដោយចេតនា ដែលក្នុងចំណោមនោះមានការដកហូតសិទ្ធិទទួលបានអាហារនិងថ្នាំពេទ្យ ក្នុងគោលគំនិតមួយដែលប្រុងនឹងនាំដល់មានការបំផ្លិចបំផ្លាញផ្នែកមួយនៃប្រជាពលរដ្ឋ ។*

*២- "ការធ្វើទារុណកម្ម" មានន័យថា ការធ្វើឱ្យមានការចុកចាប់ ឬការរងគ្រោះជាទំងន់ដោយចេតនា ទោះបីជាផ្លូវកាយក្តី ឬផ្លូវបញ្ញាស្មារតីក្តី ទៅលើជនដែលនៅក្នុងការឃុំឃាំង ឬក្រោមការត្រួតត្រារបស់ជនជាប់ចោទ លើកលែងតែចំពោះការណ៍ទារុណកម្ម គេមិនត្រូវរាប់បញ្ចូលការចុកចាប់ ឬការរងគ្រោះដែលកើតចេញពីការដាក់ទណ្ឌកម្មស្របច្បាប់ដែលមានជាប់នឹងអំពើនោះ ឬដែលមានជាយថាហេតុទេ ។*

*៣- "ការធ្វើទុក្ខបុកម្នេញ" មានន័យថាការដកហូតសិទ្ធិជាមូលដ្ឋានដោយចេតនា និងយ៉ាងធ្ងន់ធ្ងរដែលផ្ទុយនឹងច្បាប់អន្តរជាតិ ដោយមូលហេតុនៃអត្តសញ្ញាណនៃក្រុម ឬសមូហភាព ។*

*៤- "បទល្មើសអាប៉ាថេដ" មានន័យថា អំពើអមនុស្សធម៌ដែលមានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងអំពើទាំងឡាយណាដែលពោលនៅក្នុងកថាខ័ណ្ឌទី១ ដែលបានប្រព្រឹត្តក្នុងបរិបទនៃរបបគ្រប់គ្រងជាស្ថាប័ននៃការសង្កត់សង្កិន ជាលក្ខណៈប្រព័ន្ធ និងការគ្របសង្កត់របស់ក្រុមពូជសាសន៍មួយទៅលើក្រុមពូជសាសន៍មួយ ឬច្រើន ដទៃទៀត ហើយដែលបានប្រព្រឹត្តក្នុងចេតនាទុករបបនោះ ។"*

---

## ជំពូកទី៣: ឧក្រិដ្ឋកម្មសង្គ្រាម

ឧក្រិដ្ឋកម្មសង្គ្រាម ជាទូទៅត្រូវបានគេឱ្យនិយមន័យថាជាការរំលោភធ្ងន់ធ្ងរលើច្បាប់ និងទំនៀមទំលាប់ស្តីពីសឹកសង្គ្រាម ។ ឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងឧបករណ៍គតិយុត្តអន្តរជាតិជាច្រើន ដូចជាអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងពិធីសារបន្ថែមទី១ឆ្នាំ១៩៧៧ ។

លក្ខន្តិកៈទីក្រុងរ៉ូមបានឱ្យនិយមន័យឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងមាត្រា ៨ ហើយបានចែងថា ឧក្រិដ្ឋកម្មនេះស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងសមត្ថកិច្ចរបស់តុលាការនៃបណ្តាប្រទេសជាសមាជិកលក្ខន្តិកៈស្របទៅតាមគោលការណ៍នៃការបំពេញបន្ថែម ។

ដូចគ្នានឹងករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ នីតិកម្មជាតិនៃប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យតុលាការជាតិអាចជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ដើម្បីឱ្យស្របទៅនឹងកាតព្វកិច្ចអន្តរជាតិដែលកម្ពុជាបានព្រមព្រៀង ។

ផ្ទុយទៅវិញ នីតិវិជ្ជមានរបស់កម្ពុជាមិនបានចែងអំពីការផ្តន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាមទេ ។

មាត្រា កម ២១៣១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីបានចែងអំពីការផ្តន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាមដែលនេះគឺជាចំនុចវិជ្ជមានមួយ។ ក៏ប៉ុន្តែ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះមិនបានចែងគ្រប់ធាតុផ្សំចំបងនៃឧក្រិដ្ឋកម្មសង្គ្រាមដូចដែលមានចែងក្នុងមាត្រា ៨ នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ។

## ក. ការកំណត់អំពីការបង្ក្រាបឧក្រិដ្ឋកម្មសង្គ្រាមក្នុងនីតិវិជ្ជមានកម្ពុជា

### ១- ប្រភពពីនីតិកម្ពុជា

មានអត្ថបទច្បាប់ចំនួនបី នៃនីតិវិជ្ជមានកម្ពុជា ដែលអាចអនុញ្ញាតឱ្យមានការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាម ប៉ុន្តែការចែងនៃអត្ថបទទាំងនោះមិនបានពេញលេញទេ។ អត្ថបទច្បាប់ទាំងនោះរួមមាន ច្បាប់ព្រហ្មទណ្ឌអន្តរកាល ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ និងក្រមយុត្តិធម៌យោធាឆ្នាំ១៩៥៤ (អត្ថបទពីរចុងក្រោយនេះស្ថិតនៅជាធរមានដោយ ផ្អែកយោងលើមាត្រា ១៥៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៤៧]។

ដូចយើងបានឃើញរួចមកហើយថា ការចែងនៃអត្ថបទច្បាប់ទាំងបីនេះអាចឱ្យមានការផ្តន្ទាទោសចំពោះតែអំពើមួយចំនួនដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះ ដូចជាអំពើមនុស្សឃាត ការធ្វើទារុណកម្ម ឬការបំពារបំពានបូរណភាពលើរូបរាងកាយនៃបុគ្គលជាដើម តែមិនមែនជាការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាមទាំងមូលនោះទេ។

ក្រមយុត្តិធម៌យោធាឆ្នាំ១៩៥៤បានឱ្យនិយមន័យ និងកំណត់អំពីការផ្តន្ទាទោសនូវអំពើមួយចំនួនផ្សេងទៀត ដូចជាអំពើហឹង្សាលើយោធារបួស និងការលួចទ្រព្យសម្បត្តយោធារបួស ឬស្លាប់ជាដើម[៤៨]។

[៤៧] សូមមើលផ្នែកទី២ ជំពូកទី១។

[៤៨] មាត្រា ១៨៤ នៃក្រមយុត្តិធម៌យោធាកំណត់ថាជាបទល្មើសរាល់ "អំពើហឹង្សាលើយោធារបួស ឬមានជំងឺ បាត់បង់សមត្ថភាពការពារខ្លួន" ប្រព្រឹត្តដោយ យោធា ឬស៊ីវិល។ មាត្រា ២០២ នៃក្រមដដែលនេះចែងអំពីការផ្តន្ទាទោសចំពោះការលួច ឬការប្លន់ទ្រព្យសម្បត្តិរបស់យោធារបួស មានជំងឺ ឬស្លាប់ ឬមួយការប្រព្រឹត្តិអំពើហឹង្សាប្រព្រឹត្តដោយយោធាឬជនស៊ីវិល ។មាត្រា២០៣និង២០៥ក៏បានកំណត់ផងដែរ ថាជាបទល្មើសរាល់អំពើលួចទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់កងទ័ព ឬជាកម្មសិទ្ធិរបស់"ប្រជាជនស៊ីវិលដែលផ្តល់កន្លែងឱ្យកងទ័ពស្នាក់នៅ"។ នីតិរួមទាក់ទងនឹងអំពើហិង្សា (មាត្រា ៤៩៥ ដល់៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥)។ អំពើមនុស្សឃាត (មាត្រា ៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល) អំពីឃាតកម្មគិតទុកជាមុន (មាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល) និងការប៉ុនប៉ងប្រព្រឹត្តបទល្មើស (មាត្រា ៣១ ៣២ ៣៤ ៤៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៧៧ ដល់៨១ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥) អាចអនុវត្តបានក្នុងករណីដែលមានចែងក្នុងមាត្រាទាំងនេះ។

## ២- ការប្រៀបធៀបជាមួយនឹងលក្ខន្តិកៈទីក្រុងរ៉ូម

ច្បាប់ជាធរមាននៃប្រទេសកម្ពុជា ដែលយើងទើបតែបានលើកឡើងខាងលើនេះមិនបានគ្របដណ្តប់លើគ្រប់ធាតុផ្សំចំបង៧របស់ឧក្រិដ្ឋកម្មសង្គ្រាមដូចអ្វីដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ។ ម្យ៉ាងវិញទៀត បទល្មើសមួយចំនួនដូចជាមនុស្សឃាត អំពើទារុណកម្ម មនុស្សឃាតគិតទុកជាមុន អំពើរំលោភសេពសន្ថវៈ អំពើហឹង្សា ឬការបំផ្លិចបំផ្លាញ ដែលមានចែងក្នុងនីតិរូម មិនអាចឱ្យយើងកំណត់បទឧក្រិដ្ឋកម្មសង្គ្រាម ដែលមានលក្ខណៈពិសេសដាច់ដោយឡែកពីនីតិរូម ពោលគឺវាត្រូវបានប្រព្រឹត្តឡើងនៅក្នុងជម្លោះប្រដាប់អាវុធ ឬដោយមានទំនាក់ទំនងទៅនឹងជម្លោះនេះ។ អំពើដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានប្រព្រឹត្តឡើងដោយកម្លាំងប្រដាប់អាវុធនៃភាគីម្ខាងប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធ ឬ ជនស៊ីវិលនៃភាគីម្ខាងទៀតនៃជម្លោះ និយាយឱ្យចំគឺអំពើប្រព្រឹត្តឡើងប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលត្រូវបាន"ការពារ"ដោយអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងពិធីសារបន្ថែម ទី១ ឆ្នាំ១៩៧៧។

ច្បាប់ខ្មែរបច្ចុប្បន្នអនុញ្ញាតឱ្យធ្វើការផ្តន្ទាទោសតែចំពោះអំពើមួយៗដាច់ពីគ្នា ដែលមិនគ្របដណ្តប់លើឧក្រិដ្ឋកម្មសង្គ្រាមទាំងមូល។ មិនមានច្បាប់ជាធរមានណាមួយដែលមានចែងអំពីនិយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាម ដើម្បីឱ្យតុលាការអាចធ្វើការផ្តន្ទាទោសចំពោះឧក្រិដ្ឋជនសង្គ្រាមបានពេញលេញនោះទេ។

តុលាការព្រហ្មទណ្ឌអន្តរជាតិមិនត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះអំពើមួយៗដាច់ពីគ្នា ដែលប្រព្រឹត្តឡើងក្នុងនាមបុគ្គលផ្ទាល់ខ្លួននោះទេ។ តុលាការនេះមានសមត្ថកិច្ចជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមដរាបណាបទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តឡើង "ក្នុងក្របខ័ណ្ឌនៃផែនការណ៍ ឬនយោបាយណាមួយ ឬជាផ្នែកមួយនៃការប្រព្រឹត្តិក្នុងទំហំដ៏ធំធេងនៃបទល្មើសព្រហ្មទណ្ឌបែបនេះ" (មាត្រា ៨ កថាខ័ណ្ឌ១ នៃលក្ខន្តិកៈទីក្រុងរ៉ូម)។

ដូចនេះ នីតិកម្មនៃប្រទេសកម្ពុជាគួរតែត្រូវបានកែប្រែដើម្បីឱ្យស្របទៅនឹងគោលការណ៍ដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដើម្បីតុលាការកម្ពុជាមានសមត្ថកិច្ចជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម។ បើមិនដូច្នោះទេ កម្ពុជានឹងត្រូវចាត់ទុកថាគ្មានសមត្ថភាពក្នុងការជំនុំជម្រះ ហើយសមត្ថកិច្ចនេះនឹងត្រូវផ្ទេរទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។

## ខ. ឧក្រិដ្ឋកម្មសង្គ្រាមក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីថ្មីបានឱ្យនិយមន័យ និងកំណត់អំពីការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងមាត្រា កម ២១៣១-១ និងកម ២១៣១-២។ មាត្រានេះចែងថា:

*មាត្រា កម ២១៣១-១: ធាតុផ្សំនៃបទឧក្រិដ្ឋសង្គ្រាម*

*បទឧក្រិដ្ឋសង្គ្រាម គឺអំពើណាមួយដូចមានចែងខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៨:*

*១-ឃាតកម្ម ។*

*២-ទារុណកម្ម ឬគ្រប់ប្រព្រឹត្តកម្មអមនុស្ស រួមបញ្ចូលទាំងការពិសោធន៍ជីវសាស្ត្រ ។*

*៣-អំពើបង្កដោយចេតនានូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបូរណភាពបុគ្គល ឬសុខភាព ។*

*៤-ការបំផ្លាញ ឬការកេងយកនូវទ្រព្យសម្បត្តិ ដោយគ្មានហេតុផលត្រឹមត្រូវខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត ។*

*៥-អំពើបង្ខំឈ្លើយសឹក ឬជនស៊ីវិលឱ្យបម្រើក្នុងកងកំលាំងប្រដាប់អាវុធរបស់រដ្ឋដែលជាសត្រូវ ។*

*៦-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិលក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង*

*៧-ការជម្លៀស ការបញ្ជូន ឬការឃុំឃាំងដោយខុសច្បាប់ ។*

*៨-ការចាប់ជាចំណាប់ខ្មាំង ។*

*មាត្រា កម ២១៣១-២: បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត*

*អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើអំពើនោះត្រូវបានប្រព្រឹត្ត ក្នុងឱកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬមិនមែនអន្តរជាតិ:*

*១-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬអាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍*

*២-អំពើវាយប្រហារ ឬទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយ ទៅលើទីក្រុង ភូមិ កន្លែងរស់នៅ ឬអាគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា*

*៣-អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬ សម្ភារៈដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។*

*៤-អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនាដល់ប្រជាជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។*

*៥-អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីជៀសវាងនូវប្រតិបត្តិការយោធាទៅលើអាគារខ្លះ តំបន់ខ្លះនៃដែនដី ឬ កងកំលាំងយោធាខ្លះ ។*

*៦-អំពើបំផ្លាញ ឬធ្វើឱ្យខូចខាតដោយចេតនា នូវអាគារសម្រាប់សាសនា សប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ ។*

*៧-អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ខាងផ្នែកយោធាដែលសង្ឃឹមទុក ។*

*៨-ការលួចប្លន់នូវសម្បត្តិសាធារណៈ ឬឯកជន ។"*

អ្នកតាក់តែងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីនេះបានសរសេរនៅក្នុងសេចក្តីអត្ថាធិប្បាយរបស់ខ្លួនថា មាត្រា កម ២១៣១-១ និងកម ២១៣១-២ ចំលងតាមនិយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាមដែលមានចែងនៅក្នុងមាត្រា ៨ កថាខ័ណ្ឌ ២ វាក្យខ័ណ្ឌ ក និងខ នៃលក្ខន្តិកៈទីក្រុងរ៉ូម ។

ក៏ប៉ុន្តែបន្ទាប់ពីការសិក្សាលំអិតលើមាត្រាទាំងពីរនេះ យើងសង្កេតឃើញមានភាពចន្លោះប្រហោងក្នុងការឱ្យនិយមន័យក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីខាងលើ ។

## ១- ការប្រៀបធៀបមាត្រា កម២១៣១-១នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ជាមួយមាត្រា៨ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ក នៃលក្ខន្តិកៈទីក្រុងរ៉ូម

### ១-ក. ឃ្លា "*ការបំផ្លាញ ឬ ការកេងយកនូវទ្រព្យសម្បត្តិ* "

ឃ្លានេះធ្វើការបែងចែកដាច់ពីគ្នារវាងការបំផ្លិចបំផ្លាញ និងការកេងយកនូវទ្រព្យសម្បត្តិអ្នកដ៏ទៃ។ ពាក្យទាំងពីរនេះមានន័យមិនដូចគ្នាទេ។ ការកេងយកទ្រព្យសម្បត្តិអ្នកដ៏ទៃមិនសុទ្ធតែនាំឱ្យមានការបំផ្លិចបំផ្លាញទ្រព្យ ដែលជាកម្មសិទ្ធិនោះទេ ហើយបើមានការបំផ្លិចបំផ្លាញទ្រព្យអ្នកដ៏ទៃហើយគេមិនអាចយកទ្រព្យនោះមកធ្វើជាកម្មសិទ្ធិបានទៀតទេ។

ការប្រើឈ្នាប់ "ឬ" នៅក្នុងឃ្លាខាងលើនេះនាំឱ្យមាត្រា កម ២១៣១-១ មានអត្ថន័យទូលាយជាងមាត្រា ៨ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ក នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលប្រើឈ្នាប់ "និង" ។

នេះគឺជាចំនុចវិជ្ជមានរបស់សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីក្នុងការបង្ក្រាបឧក្រិដ្ឋកម្មសង្គ្រាម ។

### ១-ខ. ពាក្យ "ជនស៊ីវិល" នៃមាត្រា កម២១៣១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី និងពាក្យ "ជនដែលទទួលបានការការពារ" នៃមាត្រា៨ កថាខ័ណ្ឌ២នៃលក្ខន្តិកៈទីក្រុងរ៉ូម

ពាក្យថា "ជនដែលទទួលបានការការពារ" ដែលប្រើនៅក្នុងមាត្រា ៨ កថាខ័ណ្ឌ ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម សំដៅលើជនដែលត្រូវបានការពារដោយអនុសញ្ញាក្រុងហ្សឺណែវចំនួនបី ចុះថ្ងៃទី១២ សីហា ១៩៤៩ គឺអនុសញ្ញាស្តី

ពីការការពារទាហានរបួស និង ទាហានមានជំងឺក្នុងកំឡុងពេលធ្វើបេសកកម្ម អនុសញ្ញាស្តីពី ការការពារទាហាន របួស ទាហានមានជំងឺ និងទាហានលង់ទឹកដោយលិចកប៉ាល់ ក្នុងកំឡុងពេលធ្វើបេសកកម្ម តាមសមុទ្រ និង អនុសញ្ញាស្តីពី ការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម។

អនុសញ្ញាទាំងនេះការពារជាពិសេសជនទាំងឡាយដែលមិនចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធគ្នា រួមទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានដាក់អាវុធចុះចាញ់ ទាហានមានរបួសឬជំងឺ និងរាល់ជនស៊ីវិលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ភាគីណាមួយនៃជម្លោះ ឬ ក្រោមការគ្រប់គ្រងនៃមហាអំណាចបរទេសដែលកាន់កាប់ ដែនដីមួយ ព្រមទាំងរាល់បុគ្គលិកដែលបំរើការក្នុងវិស័យសុខាភិបាល និងសាសនាក្នុងកងកម្លាំងប្រដាប់អាវុធនៃ ភាគីជម្លោះដែលត្រូវបានទទួលឱ្យស្នាក់នៅលើទឹកដីអព្យាក្រឹត្យណាមួយ។

មាត្រា កម ២១៣១-១ ប្រើពាក្យថា "ជនស៊ីវិល" ជំនួសពាក្យ "ជនដែលទទួលបានការការពារដោយអនុសញ្ញាក្រុងហ្សឺណែវ" ដែលបានប្រើក្នុងមាត្រា ៨ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ក នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ការប្រើពាក្យនេះនាំឱ្យនិយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាមក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមានភាពចង្អៀតជាងនិយមន័យ ដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម។

---

**FIDH សូមផ្តល់នូវអនុសាសន៍ដូចតទៅ:**

**សូមឱ្យអាជ្ញាធរខ្មែរធ្វើការកែប្រែមាត្រា កម ២១៣១-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ដោយជំនួសពាក្យ "ជនស៊ីវិល" ដោយពាក្យ "ជនដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ"វិញ។**

---

## ២- ការប្រៀបធៀបមាត្រា កម២១៣១-២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ជាមួយមាត្រា៨ កថាខ័ណ្ឌ២(ខ)នៃលក្ខន្តិកៈទីក្រុងរ៉ូម

### ២-ក. មាត្រា៨ កថាខ័ណ្ឌ២(ខ)នៃលក្ខន្តិកៈទីក្រុងរ៉ូម

មាត្រា ៨ កថាខ័ណ្ឌ ២ នៃលក្ខន្តិកៈទីក្រុងរ៉ូមធ្វើការបែងចែកដាច់ពីគ្នារវាងឧក្រិដ្ឋកម្មសង្គ្រាមក្នុងករណីជម្លោះប្រដាប់អាវុធអន្តរជាតិ និងករណីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ។ មាត្រានេះបានចែងយ៉ាងលំអិត នៅ

ក្នុងវាក្យខ័ណ្ឌ ខ អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាមក្នុងករណីជម្លោះប្រដាប់អាវុធអន្តរជាតិ និងក្នុងវាក្យខ័ណ្ឌ គ និង ង អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាមក្នុងករណីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ។

ប្រសិនបើរដ្ឋណាមួយជាសមាជិកនៃលក្ខន្តិកៈទីក្រុងរ៉ូមមិនធ្វើការផ្តន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាម ដូចដែលបានចែងក្នុងមាត្រា ៨ កថាខ័ណ្ឌ ២ នៃលក្ខន្តិកៈនេះទេនោះ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងយកសំណុំរឿងនេះមកធ្វើការជំនុំជម្រះ ដោយផ្អែកលើគោលការណ៍នៃការបំពេញបន្ថែម។ ក្នុងករណីនេះ រដ្ឋជាសមាជិកនោះមិនមានសិទ្ធិជំទាស់នឹងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងការជំនុំជម្រះបទឧក្រិដ្ឋកម្មសង្គ្រាមនេះឡើយ។ ដើម្បីឱ្យខ្លួនមានសមត្ថកិច្ចពេញលេញក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនេះ រដ្ឋជាសមាជិកត្រូវតែបញ្ចូលនិយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាមដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ទៅក្នុងនីតិកម្មជាតិរបស់ខ្លួន។

## ២-ខ. មាត្រា កម ២១៣១-២ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

ដូចដែលយើងបានឃើញខាងលើរួចមកហើយថា អ្នកតាក់តែងសេចក្តីព្រាងក្រមនេះបានសរសេរនៅក្នុងសេចក្តីអត្ថាធិប្បាយរបស់ខ្លួនថា មាត្រា កម ២១៣១-២ បានឱ្យនិយមន័យឧក្រិដ្ឋកម្មសង្គ្រាមដោយយកតាម មាត្រា ៨ កថាខ័ណ្ឌ ២ វាក្យខ័ណ្ឌ *ខ* នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ក៏ប៉ុន្តែ នៅពេលដែលយើងធ្វើការសិក្សាលំអិតទៅលើ មាត្រានេះ យើងសង្កេតឃើញថា ការចំលងតាមនេះបានធ្វើឡើងតែមួយផ្នែកប៉ុណ្ណោះ។ មានធាតុផ្សំចំបងៗមួយចំនួននៃឧក្រិដ្ឋកម្មសង្គ្រាម ដែលមានចែងក្នុងមាត្រា ៨ កថាខ័ណ្ឌ ២ វាក្យខ័ណ្ឌ *ខ* នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលមិនត្រូវបាន ចែងក្នុងមាត្រា កម ២១៣១-២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីទេ ដូចជា "*ការដឹកនាំដោយ ចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ឬប្រឆាំងនឹងឯកត្តជនស៊ីវិលដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូស្តរាយគ្នា*"[៤៩] "*ការដឹកនាំដោយចេតនា នូវការវាយប្រហារប្រឆាំងនឹងវត្ថុស៊ីវិល ដែលនោះជាវត្ថុដែលមិន មែនជាចំណុចគោលដៅខាងយោធា*"[៥០] "*ការសម្លាប់ ឬ ការធ្វើរបួសដល់យុទ្ធជនដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ ឬ ជនដែលគ្មានមធ្យោបាយការពារខ្លួនតទៅទៀតដែលបានចុះចាញ់ព្រមតាមខ្លួន*"[៥១] "*ការប្រើប្រាស់មិនសមស្របនូវ ទង់ផ្លាកសង្គ្រាម ទង់ជាតិ សញ្ញាសំគាល់យោធា និងឯកសណ្ឋានសត្រូវ ឬ ឯកសណ្ឋានរបស់អង្គការសហប្រជាជាតិ ក៏ដូចជានិមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបណ្តាលឱ្យមានការស្លាប់ ឬ គ្រោះថ្នាក់ដល់ មនុស្សយ៉ាងធ្ងន់ធ្ងរ*"[៥២] "*ការបញ្ជូនផ្លាស់ទីកន្លែងដោយផ្ទាល់ ឬដោយប្រយោលនូវកម្លាំងដែលកំពុងកាន់កាប់ផ្នែកខ្លះ នៃពលរដ្ឋស៊ីវិលរបស់ខ្លួនផ្ទាល់ចូលទៅក្នុងទឹកដី ដែលខ្លួនចូល*

[៤៩] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), *i.*

[៥០] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), *ii.*

[៥១] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), *vi.*

[៥២] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), *vii.*

*កាន់កាប់ ឬ ការនិរទេស ឬ ការបញ្ជូនផ្លាស់ទីពលរដ្ឋខ្លះ ឬ ទាំងអស់នៃទឹកដីដែលបានចូលកាន់កាប់ទៅក្នុងទឹកដីនោះ ឬចេញក្រៅទឹកដីនោះ"*[៥៣] *"ការប្រកាសថានឹងមិនផ្តល់ ការត្រាប្រណីណាមួយឡើយ"*[៥៤] *"ការប្រកាសលុបចោល ពន្យារពេល ឬមិនទទួលយក នៅក្នុងតុលាការ នូវសិទ្ធិ និងសកម្មភាពទាំងឡាយរបស់ពលរដ្ឋនៃភាគីបច្ចាមិត្ត"*[៥៥] *"ការបង្ខំឱ្យពលរដ្ឋនៃភាគី បច្ចាមិត្តចូលរួមក្នុងប្រតិបត្តិការ សឹកសង្គ្រាមដឹកនាំធ្វើឡើងប្រឆាំងនឹងប្រទេសរបស់ពួកគេផ្ទាល់ ទោះបីជាពួកគេ បានបំរើការប្រទូស្តរាយ មុនការចាប់ផ្តើមសង្គ្រាមក៏ដោយ"*[៥៦] *"ការប្រើប្រាស់ជាតិពុល ឬ អាវុធជាតិពុល"*[៥៧] *"ការប្រើប្រាស់គ្រាប់កាំភ្លើង ដែលអាច រីក ឬ ផ្ទុះ បែកនៅក្នុងខ្លួនមនុស្សបានយ៉ាងងាយ ដូចជាគ្រាប់កាំភ្លើង ដែលមានស្រទាប់ស្រោបពីក្រៅយ៉ាងរឹងមាំ តែមិនមានស្រោបត្រង់បណ្តូលវាទាំងមូល ឬ ដែលមានច្រៀក ដោយស្នាមវះ"*[៥៨] *"ការប្រើប្រាស់អាវុធ កាំភ្លើងផ្លោង ព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកដែលមាន លក្ខណៈបណ្តាលឱ្យគ្រោះថ្នាក់ដ៏លើសលុប ឬ គ្រោះថ្នាក់ ដែលមិនចាំបាច់ ឬ ដែលមិនរើសមុខ យ៉ាងជាប់នៅក្នុងការបំពានច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធដោយ លក្ខខ័ណ្ឌថា អាវុធ កាំភ្លើងផ្លោង ព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកនោះ គឺជាកម្មវត្ថុនៃការហាមឃាត់ដ៏ទូលំទូលាយមួយ ហើយត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធនៃច្បាប់លក្ខន្តិកៈនេះ ដោយការធ្វើវិសោធនកម្ម អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធដូចមានចែងក្នុង មាត្រា១២១ និង១២៣"*[៥៩] *"ការប្រព្រឹត្តិអំពើចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការមានគភ៌ ដោយបង្ខំដូចមានកំណត់និយមន័យនៅកថាខ័ណ្ឌ ទី២ (ច) នៃមាត្រា ៧ វណ្ណកម្មដោយបង្ខំ ឬ ការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងៗទៀត ក៏បង្កើតជាការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវដែរ"*[៦០] *"ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល ឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ បុគ្គលិកពេទ្យ ដោយការប្រើប្រាស់និម្មិតសញ្ញាដោយឡែកៗ នៃអនុសញ្ញាទីក្រុងហ្សឺណែវស្របតាមច្បាប់អន្តរជាតិ "*[៦១] *"ការកេណ្ឌ ឬ ការបញ្ចូលកុមារក្រោមអាយុដប់ប្រាំឆ្នាំឱ្យចូលបំរើកងទ័ពជាតិ ប្រើប្រាស់ពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងការប្រទូស្តរាយគ្នា"*[៦២] ។

[៥៣] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (viii.)

[៥៤] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (xii.)

[៥៥] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (xiv.)

[៥៦] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (xv.)

[៥៧] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (xvii.)

[៥៨] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (xix.)

[៥៩] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ), (xx.)

[៦០] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ). (xxii.)

[៦១] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ). (xxiv.)

[៦២] មាត្រា ៨ កថាខ័ណ្ឌទី២ (ខ). (xxvi.)

អំពើទាំងឡាយខាងលើនេះក៏ត្រូវបានចែងផងដែរក្នុងអនុសញ្ញាក្រុងហ្សឺណែវ ហើយម្យ៉ាងទៀតការចែងនេះមិនផ្ទុយនឹងស្មារតីនៃច្បាប់ខ្មែរជាធរមានឡើយ ដោយហេតុថា ច្បាប់ជាធរមាននៃកម្ពុជាបច្ចុប្បន្នមានការចែងអំពីការផ្តន្ទាទោសនូវបណ្តាអំពើមួយចំនួនដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាម ដូចជា អំពើរំលោភសេពសន្ថវៈ អំពើទាសកម្មផ្លូវភេទ ការមានគភ៌ដោយបង្ខំ អំពើពេស្យាកម្មដោយបង្ខំ ការបង្ខំមិនឱ្យមានកូន ឬអំពើហឹង្សាធ្ងន់ធ្ងរលើផ្លូវភេទផ្សេងៗទៀត។

ម្យ៉ាងទៀត មាត្រា កម ២១៣១-២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី កំណត់ការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបានប្រព្រឹត្ត "ក្នុងកំឡុងជម្លោះប្រដាប់អាវុធជាអន្តរជាតិ ឬមិនមែនអន្តរជាតិ"។

ក៏ប៉ុន្តែ ថ្វីបើមាត្រានេះបានចែងអំពីការផ្តន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាមក្នុងករណីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ តែអំពើល្មើសដែលជាធាតុផ្សំចំបងនៃឧក្រិដ្ឋកម្មនេះមិនត្រូវបានចែងឱ្យបានច្បាស់ដូចដែលបានធ្វើក្នុង មាត្រា ៨ កថាខ័ណ្ឌ ២ (គ) និង(ង) នៃលក្ខន្តិកៈទីក្រុងរ៉ូមទេ។ ដូចនេះគេគួរតែបន្ថែមធាតុផ្សំទាំងនេះទៅក្នុង មាត្រា កម ២១៣១-២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។

---

**FIDH សូមផ្តល់អនុសាសន៍ដូចតទៅ:**

**ដោយយោងទៅលើអ្វីដែលបានរៀបរាប់ខាងលើ កម្ពុជាគួរតែធ្វើការកែប្រែមាត្រា កម ២១៣១-២ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ដោយធ្វើការបន្ថែមធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាម ដូចដែលមានចែងក្នុងមាត្រា ៦ កថាខ័ណ្ឌ ២ (ខ), (គ) និង(ង) នៃលក្ខន្តិកៈទីក្រុងរ៉ូម ហើយដែលមិនមានចែងក្នុងមាត្រា កម ២១៣១-២ បច្ចុប្បន្ន។ មាត្រានេះគួរតែចែងថា:**

***" មាត្រា កម ២១៣១-២: បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត***

***អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើអំពើនោះត្រូវបានប្រព្រឹត្តក្នុងឱកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ:***

***១-ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ឬប្រឆាំងនឹងឯកត្តជនស៊ីវិល ដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូស្តរាយគ្នា។***

***២-ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងវត្ថុស៊ីវិល ដែលនោះជាវត្ថុដែលមិនមែនជាចំណុចគោលដៅខាងយោធា។***

*៣-ការសម្លាប់ ឬការធ្វើរបួសដល់យុទ្ធជនដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ ឬជនដែលគ្មានមធ្យោបាយការពារខ្លួនតទៅទៀត ដែលបានចុះចាញ់ព្រមតាមខ្លួន*

*៤-ការប្រើប្រាស់មិនសមស្របនូវទង់ផ្លាកសង្គ្រាម ទង់ជាតិ សញ្ញាសំគាល់យោធា និងឯកសណ្ឋានសត្រូវ ឬឯកសណ្ឋានរបស់អង្គការសហប្រជាជាតិ ក៏ដូចជានិមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបណ្តាលឱ្យមានការស្លាប់ ឬគ្រោះថ្នាក់ដល់មនុស្សយ៉ាងធ្ងន់ធ្ងរ ។*

*៥-ការបញ្ជូនផ្លាស់ទីកន្លែងដោយផ្ទាល់ ឬដោយប្រយោលនូវកម្លាំងដែល កំពុងកាន់កាប់ផ្នែកខ្លះនៃពលរដ្ឋស៊ីវិលរបស់ខ្លួនផ្ទាល់ចូលទៅក្នុងទឹកដីដែលខ្លួនចូលកាន់កាប់ ឬការនិរទេស ឬការបញ្ជូនផ្លាស់ទីពលរដ្ឋខ្លះ ឬទាំងអស់នៃទឹកដីដែលបានចូលកាន់កាប់ទៅក្នុងទឹកដីនោះ ឬចេញក្រៅទឹកដីនោះ ។*

*៦-ការប្រកាសថានឹងមិនផ្តល់ការត្រាប្រណីណាមួយឡើយ។*

*៧-ការប្រកាសលុបចោល ពន្យារពេល ឬមិនទទួលយកនៅក្នុងតុលាការ នូវសិទ្ធិ និងសកម្មភាពទាំងឡាយរបស់ពលរដ្ឋនៃភាគីបច្ចាមិត្ត ។*

*៨-ការបង្ខំឱ្យពលរដ្ឋ នៃភាគីបច្ចាមិត្ត ចូលរួមក្នុងប្រតិបត្តិការសឹកសង្គ្រាមដឹកនាំធ្វើឡើងប្រឆាំងនឹងប្រទេសរបស់ពួកគេផ្ទាល់ ទោះបីជាពួកគេបានបំរើការប្រទូស្តរាយមុនការចាប់ផ្តើមសង្គ្រាមក៏ដោយ ។*

*៩-ការប្រើប្រាស់ជាតិពុល ឬអាវុធជាតិពុល ។*

*១០-ការប្រើប្រាស់គ្រាប់កាំភ្លើងដែលអាចរីក ឬផ្ទុះបែកនៅក្នុងខ្លួនមនុស្សបានយ៉ាងងាយ ដូចជាគ្រាប់កាំភ្លើងដែលមានស្រទាប់ស្រោបពីក្រៅយ៉ាងរឹងមាំតែមិនមានស្រោបត្រង់បណ្តូលវាទាំងមូល ឬដែលមានច្រៀកដោយស្នាមវះ ។*

*១១-ការប្រើប្រាស់អាវុធ កាំភ្លើងផ្លោង ព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកដែលមាន លក្ខណៈបណ្តាលឱ្យគ្រោះថ្នាក់ដ៏លើសលុប ឬគ្រោះថ្នាក់ដែលមិនចាំបាច់ ឬដែលមិនរើសមុខ យ៉ាងជាប់នៅក្នុង ការបំពានច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធដោយលក្ខខ័ណ្ឌថា អាវុធ កាំភ្លើងផ្លោង ព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកនោះគឺជាកម្មវត្ថុនៃការហាមឃាត់ដ៏ទូលំទូលាយមួយ ហើយត្រូវបានដាក់បញ្ចូលក្នុង ឧបសម្ព័ន្ធនៃច្បាប់លក្ខន្តិកៈនេះដោយការធ្វើវិសោធនកម្ម អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធដូចមានចែងក្នុង មាត្រា១២១ និង១២៣ ។*

*១២-ការប្រព្រឹត្តិអំពើថោកទាប ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការមានគភ៌ដោយបង្ខំ ដូចមានកំណត់និយមន័យនៅកថាខ័ណ្ឌទី២ (ច) នៃមាត្រា ៧ វណ្ណកម្មដោយបង្ខំ ឬការបំពានផ្លូវភេទក្នុង ទ្រង់ទ្រាយផ្សេងៗទៀត ក៏បង្កើតជាការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវដែរ ។*

*១៣-ការដឹកនាំដោយ ចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល ឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ បុគ្គលិកពេទ្យ ដោយការប្រើប្រាស់និមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញា ទីក្រុងហ្សឺណែវស្របតាមច្បាប់អន្តរជាតិ ។*

*១៤-ការកេណ្ឌ ឬការបញ្ចូលកុមារក្រោមអាយុដប់ប្រាំឆ្នាំឱ្យចូលបំរើកងទ័ពជាតិ ប្រើប្រាស់ពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធរាយគ្នា ។*

*១៥-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬអាវុធ ដែលស្លាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍ ។*

*១៦-អំពើវាយប្រហារ ឬទម្លាក់គ្រាប់បែកដោយចេតនាតាមមធ្យោបាយណាក៏ដោយ ទៅលើទីក្រុង ភូមិកន្លែងរស់នៅ ឬអាគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា ។*

*១៧-អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬសម្ភារៈដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។*

*១៨-អំពើបង្កគ្រោះទុរិភិក្សដោយចេតនាដល់ប្រជាជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។*

*១៩-អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីជៀសវាងនូវប្រតិបត្តិការយោធាទៅលើអាគារខ្លះ តំបន់ខ្លះនៃដែនដី ឬកងកំលាំងយោធាខ្លះ ។*

*២០-អំពើបំផ្លាញ ឬធ្វើឱ្យខូចខាតដោយចេតនា នូវអាគារសម្រាប់សាសនា សប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ ។*

*២១-អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ខាងផ្នែកយោធាដែលសង្ឃឹមទុក ។*

*២២-ការលួចប្លន់នូវសម្បត្តិសាធារណៈ ឬឯកជន ។"*

*ក្នុងករណីជម្លោះយោធាដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ នឹងត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាម អំពើណាមួយក្នុងចំនោមអំពើដែលមានរៀបរាប់ខាងក្រោម ប្រព្រឹត្តប្រឆាំងនឹងជនទាំងឡាយណាដែលមិនបានចូលរួមសកម្មក្នុងការប្រយុទ្ធរាយ រួមទាំងសមាជិកនៃពលទាហានដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ និងអ្នកដែលមិនស្ថិតនៅក្នុងទីលានប្រយុទ្ធដោយមានជំងឺ របួស ការឃុំឃាំង ឬដោយមូលហេតុផ្សេងទៀតៈ*

*១-ការប៉ះពាល់ដល់អាយុជីវិត និងដល់បូរណភាពខាងរាងកាយ ជាពិសេសអំពើមនុស្សឃាតគ្រប់រូបភាពទាំងអស់ ការធ្វើកាយវិកល ការប្រព្រឹត្តិដោយឃោរឃៅ និងអំពើទារុណកម្ម ។*

២-ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេសការប្រព្រឹត្តិដែលនាំឱ្យមានភាពអាម៉ាស់ និងអស់តម្លៃជាមនុស្ស ។

៣-ការចាប់ជាចំណាប់ខ្មាំង ។

៤-ការកាត់ទោស និងការអនុវត្តន៍ទោសដោយគ្មានសាលក្រមកាត់ទោសចេញដោយតុលាការ ដែលត្រូវបានបង្កើតឡើងជាប្រក្រតី ដែលផ្តល់ការធានាខាងតុលាការ ដែលជាទូទៅត្រូវបានទទួលស្គាល់ថាមានភាពសំខាន់ខានមិនបាន ។

ក្នុងករណីជម្លោះយោធាដែលមិនមានចរិកលក្ខណៈជាអន្តរជាតិ ក៏នឹងត្រូវចាត់ទុកផងដែរថាជាឧក្រិដ្ឋកម្មសង្គ្រាម អំពើណាមួយក្នុងចំនោមអំពើដែលមានរៀបរាប់ខាងក្រោមៈ

១-ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ឬ ប្រឆាំងនឹងឯកត្តជនស៊ីវិលដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូស្តរាយគ្នា ។

២-ការដឹកនាំដោយ ចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារ ឧបករណ៍ សម្ភារៈសុខាភិបាល ឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ បុគ្គលិកពេទ្យ ដោយការប្រើប្រាស់និមិ្មតសញ្ញាដោយខ្សែក១នៃអនុសញ្ញា ទីក្រុងហ្សឺណែវ ស្របតាមច្បាប់អន្តរជាតិ ។

៣-ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងមន្ត្រី ប៉ុស្តិ៍ទីតាំង ឧបករណ៍ សម្ភារៈ ឬយានជំនិះពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព ស្របតាមធម្មនុញ្ញសហប្រជាជាតិ ដរាបណាពួកគេមានសិទ្ធិទទួលបានការការពារ ដែលមានឱ្យដល់ពលរដ្ឋស៊ីវិល ឬវត្ថុស៊ីវិល តាមច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ ។

៤-ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអាគារដែលប្រើប្រាស់សម្រាប់គោលបំណង សាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសប្បុរសធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និងទីកន្លែង ដែលមានអ្នកជំងឺ និងអ្នករបួសប្រមូលផ្តុំ ដោយទីកន្លែងនោះមិនមែនជាចំនុចគោលដៅយោធា ។

៥-ការចូលលួចប្លន់ទីក្រុង ឬកន្លែងណាមួយ ទោះបីជាធ្វើឡើងដោយការវាយតប់ក៏ដោយ ។

៦-ការប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការមានគភ៌ដោយបង្ខំ ដូចមានកំណត់និយមន័យក្នុងមាត្រា ៧ កថាខ័ណ្ឌ២ (ច) វណ្ណកម្មដោយបង្ខំ និងអំពើបំពានផ្លូវភេទក្នុងទ្រង់ទ្រាយណាផ្សេងទៀត ក៏បង្កើតបានជាការបំពានយ៉ាងធ្ងន់ធ្ងរលើមាត្រា៣រួម នៃអនុសញ្ញាក្រុងហ្សឺណែវទាំងបួនដែរ ។

៧-ការកេណ្ឌ និងបញ្ចូលកុមារក្រោមអាយុ១៥ឆ្នាំ ឱ្យចូលក្នុងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬប្រើប្រាស់ពួកគេឱ្យបំរើការយ៉ាងសកម្មក្នុងការប្រទូស្តរាយ ។

*៨-ការដាក់បញ្ជាឱ្យពលរដ្ឋស៊ីវិលផ្លាស់ទីលំនៅ ដោយសារមូលហេតុពាក់ព័ន្ធនឹងជម្លោះនោះ លើកលែងតែមានការពាក់ព័ន្ធនឹងសុវត្ថិភាពនៃពលរដ្ឋស៊ីវិល ឬមានមូលហេតុមកពីភាពចាំបាច់ខាងយោធាតម្រូវឱ្យធ្វើដូច្នោះ ។*

*៩-ការសម្លាប់ ឬការធ្វើឱ្យរងរបួសដល់ពលទាហានដែលក្បត់ ។*

*១០-ការប្រកាសថានឹងមិនផ្តល់ការត្រាប្រណីណាមួយឡើយ ។*

*១១-ការដាក់ជនដែលស្ថិតនៅក្នុងអំណាចនៃភាគីមួយទៀតនៃជម្លោះឱ្យរងការធ្វើកាយវិកល ឬការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬខាងវិទ្យាសាស្ត្រណាមួយ ដែលមិនត្រូវបានធ្វើយុត្តិកម្មដោយការព្យាបាលវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឬការដេកពេទ្យដល់ជនពាក់ព័ន្ធនោះ ដែលមិនធ្វើឡើងក្នុងប្រយោជន៍របស់ជននោះ និងដែលបណ្តាលឱ្យ ជននោះស្លាប់ ឬធ្វើឱ្យជននោះរងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់សុខភាព ។*

*១២-ការបំផ្លាញ ការរឹបអូសយកទ្រព្យសម្បត្តិរបស់បច្ចាមិត្ត លើកលែងតែការបំផ្លាញ ឬការរឹបអូសយកនោះត្រូវទាមទារបញ្ជារឱ្យធ្វើដោយសារភាពចាំបាច់នៃជម្លោះនោះ ។*

## ជំពូកទី៤៖ ការអនុវត្តគោលការណ៍បំពេញបន្ថែម

នៅក្នុងនីតិរួមកម្ពុជា មានឧបសគ្គចំបងចំនួនពីរចំពោះការអនុវត្តគោលការណ៍បំពេញបន្ថែម គឺការលើកលែងទោស និងទោសទណ្ឌដែលអាចដាក់លើជនប្រព្រឹត្តអំពើឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ។

### ក. ការលើកលែងទោស៖ ឧបសគ្គចំពោះការអនុវត្តន៍គោលការណ៍បំពេញបន្ថែម

មាត្រា ១៧ កថាខ័ណ្ឌ១ វាក្យខ័ណ្ឌ ក នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងថា តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានសមត្ថកិច្ចក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមទេ ប្រសិនបើសំណុំរឿងនៃឧក្រិដ្ឋកម្មនេះ "*កំពុងស្ថិតក្រោមការស៊ើបអង្កេត ឬការជំនុំជម្រះដោយតុលាការនៃរដ្ឋដែលមានសមត្ថកិច្ច លើរឿងនេះ លើកលែងតែក្នុងករណីដែលរដ្ឋនេះមិនមានឆន្ទៈ ឬមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការស៊ើបអង្កេត ឬជំនុំជម្រះរឿងនេះ*" ។

បើយោងទៅលើប្រភេទនៃបទឧក្រិដ្ឋដែលជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីឱ្យជំនុំជម្រះបទឧក្រិដ្ឋទាំងនេះ ដោយតុលាការជាតិនៃរដ្ឋមួយត្រូវបានចាត់ទុកថាមានប្រសិទ្ធិភាព ដរាបណាតែការលើកលែងទោសមិនត្រូវបានគេយកមកអនុវត្ត បើមិនដូច្នោះទេ រដ្ឋនេះនឹងត្រូវចាត់ទុកថាមិនមានឆន្ទៈ ឬសមត្ថភាពក្នុងការ ជំនុំជម្រះ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចក្នុងការយករឿងនេះមកជំនុំជម្រះស្របតាមមាត្រា ១៧ កថាខ័ណ្ឌ១ (ក) ។

#### ១- អំពីច្បាប់ខ្មែរ

##### ១-ក. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅដែលធ្វើឡើងលើអំពើណាមួយមានអានុភាពប្រតិសកម្ម ដោយលុបបំបាត់ចោលទាំងស្រុងនូវលក្ខណៈជាបទល្មើសនៃអំពើនោះ ។ ការលើកលែងទោសជាទូទៅនេះមានអានុភាពរំលត់បណ្តឹងអាជ្ញា និងលុបចោលនូវទោសដែលបានប្រកាសដោយតុលាការ ។

មាត្រា ៩០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖

"*រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។*"

ដូចនេះ មានតែរដ្ឋសភាទេដែលមានអំណាចផ្តល់ការលើកលែងទោសជាទូទៅតាមរយៈច្បាប់ ។

ការលើកលែងទោសជាទូទៅក៏ត្រូវបានចែងនៅក្នុងមាត្រា១៩៥ ១៩៦ និង១៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ ។ មាត្រា ១៩៥ ចែងថា:

*" ការលើកលែងទោសត្រូវតែបានកំណត់ដោយច្បាប់ ។ ការលើកលែងទោសមានអនុភាពរំលត់បណ្តឹងអាជ្ញាទាក់ទងនឹងបទល្មើសមួយចំនួន ដែលមានកំណត់នៅក្នុងច្បាប់ដែលលើកលែងទោស និងលុបចោលជាស្ថាពរនូវការទោសចំបង ឬបន្ទាប់បន្សំដែលត្រូវបានប្រកាសឡើងស្របទៅតាមលក្ខខ័ណ្ឌនៃច្បាប់ ។ ក៏ប៉ុន្តែ ប្រសិនបើទោសនោះ ជាទោសពិន័យ ហើយទណ្ឌិតបានបង់ពិន័យនោះរួចទៅហើយផង តុលាការមិនត្រូវសងប្រាក់ពិន័យនោះទោទណ្ឌិតវិញទេ ។*

*ព្រះរាជក្រមនេះនឹងលើកលែងទោសឱ្យតែបទល្មើសណា ដែលត្រូវបានប្រព្រឹត្តមុនថ្ងៃប្រកាសឱ្យប្រើព្រះរាជក្រមនេះតែប៉ុណ្ណោះ ។"*

ការលើកលែងទោសជាទូទៅមានអានុភាពតែទៅលើបណ្តឹងអាជ្ញាដែលត្រូវបានរំលត់ និងទោសចំបង ឬ ទោសបន្ទាប់បន្សំ ដែលត្រូវបានលុបចោលតែប៉ុណ្ណោះ តែមិនប៉ះពាល់ដល់ការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឡើយ[៦៣] ។ ជនរងគ្រោះដោយសារបទល្មើសដែលត្រូវបានលើកលែងទោសជាទូទៅ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីទាមទារសំណងជំងឺចិត្តដែលបង្ករឡើងដោយបទល្មើសនេះ ប៉ុន្តែមិនមានទោសព្រហ្មទណ្ឌណាមួយ អាចនឹងត្រូវសំរេចដាក់លើជនល្មើសឡើយ ។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី បានចែងអំពីការលើកលែងទោសជាទូទៅនៅក្នុងមាត្រា កម ១២៥៣-១ មាត្រា កម ១២៥៣-២ និងមាត្រា កម ១២៥៣-៣ ដូចតទៅ:

*" មាត្រា កម ១២៥៣-១: អានុភាពនៃការលើកលែងទោស*

*ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញ លុបបំបាត់ចោលនូវទណ្ឌកម្ម ដែលពាក់ព័ន្ធនឹងច្បាប់លើកលែងទោស ។*

*ទោសមិនអាចអនុវត្តបានទេ ។*

*ទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់ដោយថាហេតុ ។*

*ប៉ុន្តែចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយមិនអាចទារសំណងពីរដ្ឋបានទេ ។*

*មាត្រា កម ១២៥៣-២: ការលើកលែងទោស និងការដកការព្យួរទោស*

[៦៣] មាត្រា ១៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៥

*កាលបើការព្យួរទោសពីមុនត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅនេះបង្កើតឡើងវិញនូវការព្យួរទោស ។*

*មាត្រា កម ១២៥៣-៣: ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោស*

*លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃច្បាប់ការលើកលែងទោសជាទូទៅ មិនមានឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ ។*

សារុបសេចក្តីមក ថ្វីបើការលើកលែងទោសជាទូទៅមិនមានអានុភាពលុបចោលនូវសំណងជំងឺចិត្តខាងផ្នែករដ្ឋប្បវេណី តែវានាំឱ្យមាននិទណ្ឌភាពខាងផ្នែកព្រហ្មទណ្ឌ ។

ដោយយោងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គេគួរតែចែងនៅក្នុងនីតិរូមកម្ពុជាថា ការលើកលែងទោសជាទូទៅមិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្មខាងលើនេះឡើយ ។

### **១-ខ. ការអនុគ្រោះទោស**

ការអនុគ្រោះទោស ថ្វីត្បិតតែវាមានផលវិបាកមិនធ្ងន់ធ្ងរដូចជាការលើកលែងទោសជាទូទៅ តែវាអាចនាំឱ្យជនដែលត្រូវបានសំរេចថាមានពិរុទ្ធរួចពីទោសទាំងស្រុង ឬមួយផ្នែក ឬទទួលទោសស្រាលជាងទោស ដែលបានកំណត់ដោយសេចក្តីសម្រេចរបស់តុលាការ ។

នៅប្រទេសកម្ពុជា ការអនុគ្រោះទោស គឺជាអំណាចឆន្ទានុសិទ្ធិរបស់ព្រះមហាក្សត្រ។ មាត្រា ២៧ នៃរដ្ឋ-ធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា:

*" ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។ "*

ក្រឹត្យលេខ២៨ ចុះថ្ងៃទី២០ មិថុនា ១៩៨៨ ស្តីពីលក្ខណ្ឌនៃការស្នើសុំលើកលែងទោស ឬបន្ថយទោស និងសារាចរណ៍ណែនាំលេខ២៨២ ចុះថ្ងៃទី២៤ កុម្ភៈ ១៩៩៤ បានចែងបញ្ជាក់អំពីរបបគតិយុត្តនៃការបន្ធូរបន្ថយ និងការលើកលែងទោសនេះ ។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីក៏បានចែងផងដែរអំពីការអនុគ្រោះទោស នៅក្នុងមាត្រា កម ១២៥២-១ និងមាត្រា កម ១២៥២-២:

*" មាត្រា កម ១២៥២-១: អានុភាពនៃការអនុគ្រោះទោស*

*ការអនុគ្រោះទោសដូចដែលមានចែងនៅក្នុងមាត្រា២៧ នៃរដ្ឋធម្មនុញ្ញលើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោស ។*

*មាត្រា កម ១២៥២-២: ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស*

*លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យ ការអនុគ្រោះទោសមិនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ ។"*

ដូចគ្នានឹងករណីលើកលែងទោសជាទូទៅដែរ គេគួរតែចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌខ្មែរថា ការលើកលែងទោសមិនអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ ។

## ២- ការប្រៀបធៀបច្បាប់ខ្មែរទៅនឹងលក្ខន្តិកៈទីក្រុងរ៉ូម

លក្ខន្តិកៈទីក្រុងរ៉ូមមិនបានចែងអំពីនិយមន័យនៃការលើកលែងទោសជាទូទៅ ឬ វិធានការណ៍ប្រហាក់ប្រហែល ហើយក៏មិនបានធ្វើការយោងទៅលើអត្ថបទគតិយុត្តណាមួយស្តីពីការលើកលែងទោសជាទូទៅនេះទេ។ បញ្ហាលើកលែងទោសជាទូទៅនេះ គឺជាបញ្ហានយោបាយ។ ពាក្យថា "ការលើកលែងទោសជាទូទៅ" មិនមានចែងទាល់តែសោះនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម។ ប៉ុន្តែ បើយើងអានមាត្រា ១៧ កថាខ័ណ្ឌ២ (ក) និងមាត្រា ២០ កថាខ័ណ្ឌ៣ (ក) ដែលកើតចេញអំពីការសម្របសម្រួលខាងនយោបាយយើងអាចសង្កេតឃើញថា រដ្ឋជាសមាជិកហាក់ដូចជាមានចេតនាចែងអំពីការលើកលែងទោសជាទូទៅនេះ ដោយមិនប្រើពាក្យចំៗ។

មាត្រា ១៧ កថាខ័ណ្ឌ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងថា:

*"២. ដើម្បីកំណត់អំពីភាពគ្មានឆន្ទៈក្នុងករណីជាក់លាក់មួយ តុលាការត្រូវពិចារណាដោយសំអាងលើគោលការណ៍នៃដំណើរការសមរម្យដែលបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ថាតើចំណុចមួយឬច្រើន ដូចតទៅ នេះកើតមានដើម្បីអាចអនុវត្តបានឬទេ :*

*(ក) ករណីទាំងនោះបាន ឬកំពុងដំណើរការ ឬសេចក្តីសម្រេចថ្នាក់ជាតិបានធ្វើឡើងក្នុងគោលបំណងបិទបាំងជនពាក់ព័ន្ធពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការដូចមានចែងក្នុងមាត្រា ៥ (...)"*

ការចែងក្នុងមាត្រានេះមានន័យថា ក្នុងករណីដែលរដ្ឋមួយមិនមានឆន្ទៈជំនុំជម្រះឧក្រិដ្ឋជន ដែលបានប្រព្រឹត្ត បទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ឬ ប្រកាសថាខ្លួនមានសមត្ថកិច្ចជំនុំជម្រះក្នុងគោលបំណង ធ្វើយ៉ាងណាឱ្យឧក្រិដ្ឋជនរួចផុតពីសំណាញ់យុត្តិធម៌តុលាការព្រហ្មទណ្ឌអន្តរជាតិអាចនឹងមានសមត្ថកិច្ចក្នុងការ ជំនុំជម្រះលើបទឧក្រិដ្ឋកម្មនេះ ។

មាត្រា ២០ កថាខ័ណ្ឌ៣ នៃលក្ខន្តិកៈទីក្រុងរ៉ូមចែងថា:

*" គ្មានជនណាម្នាក់ ដែលត្រូវបានជំនុំជម្រះនៅក្នុងតុលាការមួយទៀត ចំពោះបទល្មើសព្រហ្មទណ្ឌដែលបាន ពិពណ៌នាផងដែរនៅក្នុងមាត្រា៦ ៧ ឬ៨ ត្រូវជំនុំជម្រះដោយតុលាការទាក់ទងទៅលើការប្រព្រឹត្តិដូចគ្នាតែមួយទេ លើក លែងតែដំណើរការទាំងឡាយនៅក្នុងតុលាការមួយផ្សេងទៀតនោះ:*

*(ក) ត្រូវបានធ្វើឡើងសំរាប់គោលបំណងលាក់បាំងជនដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ សំរាប់ បទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការនៃតុលាការ ។"*

យោងតាមមាត្រានេះ យើងអាចសន្និដ្ឋានបានថា ប្រសិនបើរដ្ឋមួយអនុវត្តការលើកលែងទោសជាទូទៅ ឬ វិធានការណ៍ប្រហាក់ប្រហែល រដ្ឋនោះនឹងត្រូវចាត់ទុកថាមិនមានឆន្ទៈក្នុងការផ្តន្ទាទោសឧក្រិដ្ឋជន ឬ ក៏មានឆន្ទៈក្នុង ការធ្វើយ៉ាងណាឱ្យឧក្រិដ្ឋជននោះរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។

---

**FIDH សូមផ្តល់នូវអនុសាសន៍ដូចតទៅ:**

**កម្ពុជាគួរធ្វើការកែប្រែមាត្រា ២៧ និងមាត្រា ៩០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយចែងបន្ថែមថាការ អនុគ្រោះទោស និងការអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅមិនអាចធ្វើទៅបានទេក្នុងករណីឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ មាត្រាទាំងពីរនេះគួរត្រូវបានចែងដូច តទៅ:**

***" មាត្រា ២៧:***

***លើកលែងតែក្នុងករណីដែលមានចែងក្នុងកថាខ័ណ្ឌខាងក្រោម ព្រះមហាក្សត្រមានព្រះរាជសិទ្ធិក្នុងការបន្ធូរបន្ថយ ទោស និងលើកលែងទោស ។***

*ក្នុងករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ការបន្ធូរបន្ថយទោស និងការលើកលែងទោសមិនអាចធ្វើទៅបានទេ ។*

*មាត្រា ៩០:*

*រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។*

*រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែឬលុបចោលពន្ធដារ ។*

*រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។*

*លើកលែងតែក្នុងករណីដែលមានចែងខាងក្រោមនេះ រដ្ឋសភាអនុម័តច្បាប់ស្តីការលើកលែងទោសជាទូទៅ ។*

*ច្បាប់ស្តីពីការលើកលែងទោសជាទូទៅនេះមិនអាចអនុម័តបានទេក្នុងករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។*

*រដ្ឋសភាអនុម័តយល់ព្រមឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។*

*រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។*

*ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។*

*រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។"*

កម្ពុជាក៏គួរតែធ្វើការកែប្រែផងដែរនូវមាត្រា កម ១២៥២-១ និង កម ១២៥៣-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ថ្មី ដោយធ្វើការបន្ថែមថា ការអនុគ្រោះទោស និង ការលើកលែងទោសជាទូទៅមិនអាចអនុវត្តបានទេនៅក្នុងករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម។ មាត្រាទាំងពីរនេះនឹងចែងដូចតទៅ:

*" មាត្រា កម ១២៥២-១: អានុភាពនៃការអនុគ្រោះទោស*

*លើកលែងតែក្នុងករណីដែលមានចែងក្នុងកថាខ័ណ្ឌខាងក្រោម ការអនុគ្រោះទោសដូចដែលមានចែងនៅក្នុង មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញលើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តន៍ទោស ។*

*នៅក្នុងករណីនៃបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមការអនុគ្រោះទោស មិនអាចធ្វើទៅបានទេ ។*

*មាត្រា កម ១២៥៣-១: អានុភាពនៃការលើកលែងទោស*

*លើកលែងតែក្នុងករណីដែលមានចែងក្នុងកថាខ័ណ្ឌខាងក្រោម ការលើកលែងទោសជាទូទៅដូចមានចែងក្នុង មាត្រា ៩០ នៃរដ្ឋធម្មនុញ្ញ លុបបំបាត់ចោលនូវទណ្ឌកម្ម ដែលពាក់ព័ន្ធនឹងច្បាប់លើកលែងទោស ។*

*ទោសមិនអាចអនុវត្តបានទេ ។*

*ទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់ជាយថាហេតុ ។*

*ប៉ុន្តែចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយមិនអាចទារសំណងពីរដ្ឋបានទេ ។*

*នៅក្នុងករណីនៃបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ការលើកលែងទោសមិនអាចធ្វើទៅបានទេ ។"*

---

## ខ.បញ្ហាទាក់ទងនឹងទោសទណ្ឌ

នៅពេលដែលបុគ្គលណាមួយត្រូវបានកាត់ឱ្យជាប់ទោសពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិ ឬ ឧក្រិដ្ឋកម្មសង្គ្រាម ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ បុគ្គលនោះត្រូវទទួលទោសស្របតាមការចែង ក្នុងមាត្រា ៧៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលបានចែងថាៈ

*" មាត្រា ៧៧: អំពីទណ្ឌកម្មដែលអាចយកទៅអនុវត្តបាន*

*១.លើកលែងតែក្នុងករណីដែលមានចែងក្នុងមាត្រា ១១០ តុលាការអាចដាក់ទណ្ឌកម្មលើជន ដែលមានពិរុទ្ធពី បទព្រហ្មទណ្ឌក្រោមមាត្រា៥ នៃលក្ខន្តិកៈនេះ នូវទណ្ឌកម្មមួយក្នុងចំណោមទណ្ឌកម្មទាំងឡាយដូចតទៅនេះ :*

*( ក) ទោសពន្ធនាគារ តាមចំនួនឆ្នាំដែលបានកំណត់ ដែលមិនលើសពីចំនួនទោសអតិបរិមា៣០ឆ្នាំ ឬ*

*(ខ) ទោសពន្ធនាគារអស់មួយជីវិត បើត្រូវបានធ្វើយុត្តិកម្មដោយស្ថានទំងន់ទោសដ៏ធ្ងន់ធ្ងរនៃបទល្មើសព្រហ្មទណ្ឌ ព្រមទាំងកាលៈទេសៈឯកត្តបុគ្គលរបស់ពិរុទ្ធជន*

*២. តុលាការអាចដាក់ទណ្ឌកម្មបន្ថែមលើទោសពន្ធនាគារនូវៈ*

*(ក) ការផាកពិន័យជាប្រាក់ តាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាននៃនីតិវិធីនិងភស្តុតាង*

*(ខ) ការដកហូតផលពីការលក់ទ្រព្យ ការដកហូតទ្រព្យសម្បត្តិ និងទ្រព្យធន ដែលបានមកដោយផ្ទាល់ ឬមិនផ្ទាល់ពីបទល្មើសព្រហ្មទណ្ឌនោះ ដោយមិនមានអគតិធមិចំពោះសិទ្ធិរបស់តតិយភាគីដែលសុចរិតឡើយ ។*

បច្ចុប្បន្ននេះ ដូចដែលយើងបានឃើញរួចមកហើយថា នីតិកម្មនៃប្រទេសកម្ពុជាមិនបានចែងអំពីការបង្ក្រាបអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ ឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។ មានតែអំពើល្មើសមួយចំនួនដែលអាចជាធាតុផ្សំនៃបទឧក្រិដ្ឋខាងលើប៉ុណ្ណោះដែលនឹងត្រូវទទួលនូវការផ្តន្ទាទោស។ ទោសដែលអាចដាក់លើជនដែលបានប្រព្រឹត្តអំពើល្មើសទាំងនេះ គឺការជាប់ពន្ធនាគារពី២០ឆ្នាំ ដល់អស់មួយជីវិត សំរាប់បទល្មើសឧក្រិដ្ឋ ដែលបានប្រព្រឹត្តដោយមានស្ថានទម្ងន់ទោស ស្របតាមច្បាប់ស្តីពីស្ថានទម្ងន់ទោសទាក់ទងនឹងទោសឧក្រិដ្ឋ[៦៤] ។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីកំណត់អំពីការផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដោយកំណត់ទោសដាក់ពន្ធនាគារអស់មួយជីវិតដល់រូបវ័ន្តបុគ្គល ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ (មាត្រា កម ២១១១-២ កម ២១២១-២ កម ២១៣១-៣) និងការពិន័យជាប្រាក់ពី៥០ លានរៀល ទៅ៥០០ លានរៀល (មាត្រា កម ២១១១-៥, កម ២១២១-៥ កម ២១៣១-៦)។ ឧក្រិដ្ឋជនក៏អាច នឹងត្រូវទទួលទោសបន្ទាប់បន្សំផ្សេងទៀតផងដែរ (មាត្រា កម ២១១១-៤ កម ២១២១-៤, កម ២១៣១-៥ ចំពោះរូបវ័ន្តបុគ្គល មាត្រា កម ២១១១-៥ កម ២១២១-៥ កម ២១៣១-៦ ចំពោះនីតិបុគ្គល)។

---

**FIDH សូមផ្តល់នូវអនុសាសន៍ដូចតទៅ:**

**សូមឱ្យទោសទណ្ឌដែលយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលមានចែងក្នុងមាត្រា កម ២១១១-២, កម ២១១១-៤, កម ២១១១-៥, កម ២១២១-២, កម ២១២១-៤, កម ២១២១-៥, កម ២១៣១-៣, កម ២១៣១-៥, កម ២១៣១-៦ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី**

[៦៤] ច្បាប់ស្តីពីស្ថានទម្ងន់ទោសទាក់ទងនឹងបទឧក្រិដ្ឋ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ ២០០៧។

**ស្របទៅនឹងមាត្រា ៧៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម និងសូមធ្វើការគាំទ្រទាំងស្រុងឱ្យ អ្នកតំណាងរាស្ត្រខ្មែរធ្វើការអនុម័តមាត្រាទាំងនេះ។**

# ផ្នែកទី៤ : គោលការណ៍ទូទៅនៃនីតិ

## សេចក្តីផ្តើម

គោលការណ៍ទូទៅនៃនីតិគឺជា "បំណែកស្រាយខាងគតិយុត្តិដ៏ខ្ពស់មួយ ដែលគេសន្មត់ថា កើតមានមុនបទដ្ឋានគតិយុត្តិ"[៦៥] ។

គោលការណ៍នេះនាំអោយកើតមានវិធានវិជ្ជមានផងបំពេញបន្ថែមអោយវិធានវិជ្ជមានផង និងអាចឈានដល់មានការការពារវិធានវិជ្ជមាននេះទៀតផង។ ជាទូទៅគោលការណ៍ទាំងនេះទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ ហើយគោលការណ៍ ដែលត្រូវបានគេស្គាល់ជាងគេគឺសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ ដែលយើងនឹងលើកយកមកអធិប្បាយនៅខាងក្រោយ[៦៦] ។

ទោះបីជានៅគ្រាដំបូងគោលការណ៍ ទាំងនោះមិនត្រូវបានគេសរសេរជាលាយលក្ខណ៍អក្សរ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទាំងអស់ក៏ដោយក៏យុត្តិសាស្ត្រជាតិរបស់ប្រទេសនីមួយៗបានខំប្រឹងលើកបង្ហាញ នូវគោលការណ៍ទាំងនេះហើយជាញឹកញាប់អ្នកតាក់តែងច្បាប់ថ្នាក់ជាតិបានបញ្ចូលគោលការណ៍ទាំងអស់នេះ ទៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួនផងដែរ។

តែផ្ទុយទៅវិញជាទូទៅនៅប្រទេសកម្ពុជា យុត្តិសាស្ត្រស្ទើរតែគ្មានទាល់តែសោះ ជាពិសេសក្នុងវិស័យឧក្រិដ្ឋកម្មអន្តរជាតិ។ ចំណែកឯបញ្ញត្តិច្បាប់ស្តីពីបញ្ហានេះទៀតសោតក៏នៅមានភាពខ្វះចន្លោះច្រើន។ ហេតុដូច្នេះ ជាទូទៅចំពោះឧក្រិដ្ឋកម្មទាំងនេះ គេចាំបាច់ត្រូវតែយោងទៅលើលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានចែងនូវគោលការណ៍ទូទៅនៃនីតិអន្តរជាតិ មួយចំនួននៅក្នុងជំពូកទី ៣។

លក្ខន្តិកៈទីក្រុងរ៉ូមជាពិសេសមាត្រា ២៥ ដល់ ៣៣ បានចែងនូវវិធាននានាដែលកំណត់អំពីការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗព្រមទាំងអំពីមូលហេតុផ្សេងៗដែលនាំអោយមានការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់ពួកគេផងដែរ។

ម្យ៉ាងវិញទៀត សូម្បីតែវិធាននានា ដែលចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមក៏នៅមានភាពខ្វះចន្លោះឬជួនកាលរហូតដល់មានភាពមិនស៊ីសង្វាក់គ្នាថែមទៀតផង។ ដូចនេះ វាតោងទាមទារឱ្យអ្នកតាក់តែងច្បាប់បង្កើតបទបញ្ញត្តិថ្មីៗសម្រាប់បំពេញបន្ថែម ឬ ធ្វើការកែសំរួលបទបញ្ញត្តិដែលមានស្រាប់ ប្រសិនបើគ្មានយុត្តិសាស្ត្រជាតិនោះទេ។

---

[65] H. Motulsky, "នីតិធម្មជាតិនៅក្នុងការអនុវត្តន៍យុត្តិសាស្ត្រ : ការគោរពសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ នៅក្នុងនីតិវិធីរដ្ឋប្បវេណី", *Mélanges Roubier*, 1961, ទំព័រ ១៧៥ និងបន្តបន្ទាប់។

[៦៦] សូមអានផ្នែកទី VII ។

# ជំពូក១ : ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗៈមាត្រា២៥នៃលក្ខន្តិកៈទីក្រុងរ៉ូម

## ក. អវត្តមាននៃការទទួលស្គាល់ថា មានការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល

កថាខ័ណ្ឌ១របស់មាត្រា២៥នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងថា : "តុលាការគឺមានសមត្ថកិច្ចចំពោះរូបវ័ន្តបុគ្គលទាំងឡាយអនុលោមតាមបញ្ញត្តិរបស់លក្ខន្តិកៈនេះ"។

រីឯការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គលវិញមិនត្រូវបានចែងនៅក្នុងលក្ខន្តិកៈនេះទេស្របតាមបំណងប្រាថ្នារបស់រដ្ឋជាភាគីមួយចំនួនដែលបានលើកឡើងនៅពេលតាក់តែងអត្ថបទនេះ[៦៧]។

មាត្រា ៩ និង បន្តរបន្ទាប់ នៃលក្ខន្តិកៈរបស់តុលាការយោធាអន្តរជាតិនើរីមប៊ែរ (Tribunal militaire international de Nuremberg) បានទទួលស្គាល់គោលការណ៍នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់អង្គការទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋ។

ប៉ុន្តែ គោលការណ៍នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គលនៅតែត្រូវបានបដិសេធដោយអ្នកតាក់តែងលក្ខន្តិកៈទីក្រុងរ៉ូម ដោយហេតុថា ការទទួលខុសត្រូវប្រភេទនេះមិនទាន់ត្រូវបានគេទទួលយកនៅឡើយទេ នៅក្នុងប្រព័ន្ធយុត្តិធម៌ធំៗភាគច្រើន ហើយជាទូទៅ គឺដោយសារមូលហេតុនយោបាយ និងសេដ្ឋកិច្ច។

តែអវត្តមាននៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនេះ មិនមានលក្ខណៈដាច់ខាតនោះទេ ព្រោះថាលក្ខណៈវិនិច្ឆ័យនៃបទល្មើស ចំពោះការចូលរួមជាមួយគ្នា និងការរួមគំនិតគ្នា ត្រូវបានកំណត់ ដើម្បីអាចផ្តន្ទាទោសបុគ្គលទាំងឡាយ ដែលបានប្រព្រឹត្តជាក្រុម ដែលមានលក្ខណៈដូចគ្នាទៅនឹងអង្គការ ដែលប្រព្រឹត្តបទល្មើស។

ច្បាប់ព្រហ្មទណ្ឌខ្មែរ ដែលមានជាធរមានក៏មិនបានចែងផងដែរអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល។ តាមការពិត បទបញ្ញត្តិសម័យអន្តរកាល និងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ មិនបានលើកបង្ហាញពីបញ្ហានេះទេ។ មាត្រា ១ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ បានចែងយ៉ាងច្បាស់តែចំពោះការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗ ប៉ុណ្ណោះ។ មាត្រានេះបានចែងដូចតទៅៈ

> "ច្បាប់បញ្ញត្តិថាត្រូវទុកអំពើខ្លះរបស់*មនុស្ស* ថាជាបទល្មើស ហើយបទល្មើសនេះត្រូវតែបានទទួលទោស ព្រោះថាបទល្មើសនោះ អាចធ្វើអោយសង្គម មនុស្សរកករល្អក់បាន"។

[៦៧] ជាឧទាហរណ៍ ប្រទេសបារាំងមានបំណងចង់អោយ នីតិបុគ្គល អាចត្រូវបានគេប្តឹង ដូចជាក្រុមហ៊ុនពាណិជ្ជកម្មឯកជនជាដើម លើកលែងតែអង្គការសាធារណៈ មិនមែនរដ្ឋាភិបាល និងគ្មានគោលបំណងរកប្រាក់ចំណេញ។

ផ្ទុយទៅវិញ សេចក្តីព្រាងក្រមព្រហ្មទណ្ឌខ្មែរថ្មី ដែលបានរៀបចំឡើងដោយគណៈកម្មការព្រហ្មទណ្ឌ រួមសហការជាមួយក្រុមអ្នកច្បាប់បារាំង នៅក្នុងមាត្រា កម ១១២៣-១ និង កម ១១២៣-២ ដែលមានលំនាំតាមច្បាប់បារាំង បានចែងអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល។ មាត្រា កម ១១២៣-១ បានចែង ថា ៖

*"ក្នុងករណីដែលមានចែងដោយច្បាប់នីតិបុគ្គលលើកលែងតែរដ្ឋចេញអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ពីបទល្មើសដែល ប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ"*[៦៨] ។

ដោយឈរលើមូលដ្ឋានរបស់មាត្រានេះ មាត្រា កម ២១១១-៥, កម ២១២១-៥ និង កម ២១៣១-៦ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ នូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល ចំពោះបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

ដូច្នេះចំពោះបញ្ហានេះ គេត្រូវតែយល់ដឹងអំពីគោល ជំហរដ៏រឹកចំរើនរបស់សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។

---

**អេហ្វ អ៊ី ដេ អាស សន្និដ្ឋានថា ៖**

**ជាការមួយដែលមានលក្ខណៈវិជ្ជមាន ចំពោះ ករណីដែលថា សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នៅ ក្នុងមាត្រា កម ១១២៣-១, កម ២១១១-៥, កម ២១២១-៥ និង កម ២១៣១-៦ បានចែងនូវការទទួលខុសត្រូវ ខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល ចំពោះ បទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាមទោះបីជាលក្ខន្តិកៈទីក្រុងរ៉ូមមិនបានលើកឡើងពីបញ្ហានេះក៏ដោយ និង ជួយជំរុញអោយមានការអនុម័ត មាត្រាទាំងនេះ ដោយអំណាចនីតិ បញ្ញត្តិខ្មែរ។**

---

## ខ. ទំរង់ផ្សេងៗនៃការចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិមួយ

កថាខ័ណ្ឌ ២ និង ៣ នៃមាត្រា ២៥ របស់លក្ខន្តិកៈទីក្រុងរ៉ូម បានកំណត់នូវទំរង់ផ្សេងៗ នៃការចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិមួយ ដែលមានលក្ខណៈគ្រប់គ្រាន់អាចអោយមានការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗ។

---

*៦៨.* មាត្រា កម ១១២៣-១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌខ្មែរថ្មី បានយកតាមមាត្រា ១២១-២ នៃក្រមព្រហ្មទណ្ឌបារាំងថ្មី ដែលបានចែងថា *"នីតិបុគ្គលទាំងឡាយ លើកលែងតែរដ្ឋចេញ ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ទៅតាមការបែងចែករបស់មាត្រា ១២១-៤ ដល់ ១២១-៧ និងនៅក្នុងករណី ដែលមាន ចែងដោយច្បាប់ ឬបទបញ្ជា ចំពោះបទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាង ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលទាំងនេះ"*។

### ១-ការសមគំនិត

បុគ្គលដែលប្រព្រឹត្តបទឧក្រិដ្ឋមួយ ដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមទោះបីដោយម្នាក់ឯងក្តីឬមានការចូលរួមជាមួយបុគ្គលម្នាក់ទៀត ឬតាមរយៈ បុគ្គលម្នាក់ទៀតក្តី ត្រូវមានការទទួលខុសត្រូវ ផ្ទាល់ខ្លួន ខាងព្រហ្មទណ្ឌ ( មាត្រា ២៥ កថាខ័ណ្ឌ ៣ *ក.* នៃ លក្ខន្តិកៈទីក្រុងរ៉ូម) ។

ការបញ្ជាការញុះញង់ ឬ ការលោងលោមអោយប្រព្រឹត្តបទឧក្រិដ្ឋនេះ ឬ ការផ្តល់ជំនួយ ឬ ការជួយឧបត្ថម្ភ ក្រោមរូបភាព ផ្សេងៗទៀត ដែលជួយសំរួលដល់ការប្រព្រឹត្តបទឧក្រិដ្ឋនេះ ត្រូវបានចាត់ ទុកថាជាការសមគំនិតដែលអាចនាំអោយមាន ការទទួលខុសត្រូវខាងព្រហ្មទណ្ឌផងដែរ ( មាត្រា ២៥ កថាខ័ណ្ឌ ៣ *ខ* និង *គ* ) ។ ករណីទាំងអស់នេះត្រូវបានពិចារណា ទៅលើយុត្តិសាស្ត្រពីមុន របស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ សំរាប់រ៉ូវ៉ាន់ដា និងអតីតយូហ្គោស្លាវី (Tribunaux pénaux internationaux pour le Rwanda et l’ex-Yougoslavie) ។

ការសមគំនិត ត្រូវបានអោយនិយមន័យដោយមាត្រា ៦៩ នៃបទបញ្ញត្តិសម័យអន្តរកាល តាមខ្លឹមសារដូចខាង ក្រោម :

*"ជនណាដែលបានផ្តល់មធ្យោបាយ សំរាប់ប្រព្រឹត្តបទល្មើស ដែលបានសំរួលដល់ការប្រព្រឹត្តបទល្មើសនឹងត្រូវចាត់ទុកថាជាអ្នកសមគំនិត ហើយត្រូវផ្តន្ទា ទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសនោះដែរ"*។

ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ នៅក្នុងមាត្រា ៨៣ ដល់ ៨៨ បានបញ្ជាក់អោយកាន់តែច្បាស់នូវនិយមន័យ និងរបបគតិយុត្តិនៃការសមគំនិត ជាពិសេស គឺបានបន្ថែមនូវធាតុផ្សំ *អត្តនោម័ត*។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នៅក្នុងមាត្រា កម ១១២១-៤ និង ១១២១-៥ បានចែងនិយមន័យនេះឡើងវិញ ដោយធ្វើការបែងចែកអ្នកផ្តើមគំនិតចេញពីជនសមគំនិត។ ដូចនេះអ្នកផ្តើមគំនិតគឺជាជនទាំងឡាយណា ដែលបានផ្តល់ការ ណែនាំអោយប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈឹម ឬ បង្កអោយមានការប្រព្រឹត្តអំពើទាំងនេះ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ឬ ដោយការ រំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។ ជនសមគំនិតត្រូវបានគេអោយនិយមន័យថាជា ជនណាដែលជួយសំរួលដល់ ការប៉ុនប៉ង ឬការសំរេចបទឧក្រិដ្ឋ ឬ មជ្ឈឹមដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន "ដោយចេតនា"។ ការបែងចែកនេះ គឺយកតាមលំនាំ ដែលបានអនុវត្តដោយវាក្យខ័ណ្ឌ *ខ* និង *គ* នៃ មាត្រា ២៥ កថាខ័ណ្ឌ ៣ របស់លក្ខន្តិកៈទីក្រុងរ៉ូម។ ដូច្នេះសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីបានផ្តល់ដល់ប្រជាពលរដ្ឋ និងចៅក្រម នូវនិយមន័យនៃការសមគំនិតមួយដែលមានលក្ខណៈពេញលេញ ស្របតាមលក្ខន្តិកៈទីក្រុងរ៉ូម។

នីតិវិជ្ជមានគួរតែទទួលយកមាត្រា កម ១១២១-៤ និង កម ១១២១-៥ ទាំងនេះ ដែលមានកំណត់និយមន័យនៃការសមគំនិតយ៉ាងច្បាស់លាស់ ជាជាង ទៅធ្វើការស្វែងរកនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ នូវធាតុផ្សំ *អត្ត*

*នៅម៉ត* ដែលប្រជាពលរដ្ឋមិនមានការពេញចិត្តទេនោះដោយហេតុថា អត្ថបទនេះនៅមានការអនុវត្តមិនទាន់ច្បាស់លាស់នៅឡើយ[៦៩] ។

---

**ជាលទ្ធផល អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរ អោយធ្វើការអនុម័តបទបញ្ញត្តិ មាត្រា កម ១១២១-៤ និង កម ១១២១-៥ នៃ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។**

---

## ២- ការប៉ុនប៉ង

តាមលក្ខណៈសំខាន់របស់វា ជនដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែង នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដោយអំពើទាំងឡាយ ដែលនាំអោយមានការចាប់ផ្តើមអនុវត្ត ប៉ុន្តែ បទឧក្រិដ្ឋនោះមិនបានសំរេចទេ ដោយសារតែកាលៈទេសៈផ្សេងៗក្រៅពីឆន្ទៈរបស់ខ្លួន ត្រូវមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ( មាត្រា ២៥ កថាខ័ណ្ឌ ៣ *ច.* នៃលក្ខន្តិកៈទីក្រុងរ៉ូម) ។

ផ្ទុយទៅវិញ ជនណាដែលបានបោះបង់ការប្រព្រឹត្តបទឧក្រិដ្ឋ ឬ បានបញ្ឈប់តាមមធ្យោបាយផ្សេងៗ មិនអាចត្រូវបានគេផ្តន្ទាទោស ចំពោះការប៉ុនប៉ងរបស់ខ្លួនឡើយ ប្រសិនបើជននោះបានបញ្ឈប់ទាំងស្រុង និងដោយឆន្ទៈនូវបទឧក្រិដ្ឋ ( មាត្រា ២៥ កថាខ័ណ្ឌ ៣ *ច.* នៃលក្ខន្តិកៈទីក្រុងរ៉ូម) ។

និយមន័យនៃការប៉ុនប៉ង មានចែងនៅក្នុងមាត្រា ៧៧ ដល់ ៧៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ ដែលបានចែងដូចតទៅនេះ :

"មាត្រា ៧៧ - ជនណាមានបំណងនឹងប្រព្រឹត្តបទ ល្មើស ជននោះត្រូវមានទោស ប្រសិនបើការប៉ុនប៉ង នោះត្រូវបានធ្វើឡើងតាមរយៈការចាប់ផ្តើមធ្វើនូវអំពើល្មើសណាមួយ ហើយអំពើនោះមិនបានសំរេចទៅវិញ ដោយសារមានកាលៈទេសៈអ្វីមួយមកបង្អាក់អោយវានសម្រេច ខុសពីឆន្ទៈនៃចារី ។

មាត្រា ៧៨ - ការរៀបចំបម្រុងនឹងប្រព្រឹត្តបទ ល្មើស មិនទាន់ទុកជាការចាប់ផ្តើមប្រតិបត្តិបានទេ។

មាត្រា ៧៩ - បំណងនឹងប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ត្រូវទុកដូចជាបានប្រព្រឹត្តបទឧក្រិដ្ឋនោះដែរ" ។

ការចែងនេះ គឺមានលក្ខណៈដូចគ្នានឹងនិយមន័យ ដែលបានកំណត់នៅក្នុងវាក្យខ័ណ្ឌ *ច.* កថាខ័ណ្ឌ ៣ នៃមាត្រា ២៥ របស់លក្ខន្តិកៈទីក្រុងរ៉ូម ។

---

[៦៩] សូមមើលផ្នែកទី២ ជំពូកទី ១។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នៅក្នុងមាត្រា កម ១១២១-៣ បានចែងឡើងវិញនូវនិយមន័យនៃការ ប៉ុនប៉ង ដែលបាន កំណត់ដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥។

---

**ជាលទ្ធផល អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរ អោយធ្វើការអនុម័តបទបញ្ញត្តិ មាត្រា កម ១១២១-៣ នៃសេចក្តីព្រាងក្រម ព្រហ្មទណ្ឌថ្មី។**

---

## ជំពូក២ៈ អភ័យឯកសិទ្ធិ : មាត្រា ២៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម

អភ័យឯកសិទ្ធទាំងឡាយ មានមុខងាររារាំងចៅក្រមក្នុងស្រុកមិនឱ្យមានសមត្ថកិច្ចជំនុំជម្រះ ឬ ចេញនូវវិធានការណ៍បង្ខិតបង្ខំផ្សេងៗ ចំពោះរឿងក្តីណាមួយ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏គេឃើញមានការបែងចែករវាងអភ័យឯកសិទ្ធជាតិ និងអភ័យឯកសិទ្ធិអន្តរជាតិដែរ។ អភ័យឯកសិទ្ធជាតិ ឬ ក្នុងស្រុក កើតឡើងពីបទបញ្ញត្តិនៃច្បាប់ជាតិ។ ដូច្នេះវាត្រូវបានគោរពតែនៅក្នុងក្របខណ្ឌ័របស់ច្បាប់នេះប៉ុណ្ណោះ។ រីឯអភ័យឯកសិទ្ធិអន្តរជាតិវិញ មានប្រភពពីនីតិអន្តរជាតិ។ ហេតុនេះវាតម្រូវឱ្យប្រពន្ធ័តតិយុត្តិជាតិទាំងមូលត្រូវគោរពតាម។ ក្នុងន័យនេះ បញ្ហាអភ័យឯកសិទ្ធិក្នុងស្រុក គឺជាបញ្ហាដែលកើតមានឡើង តែទៅលើបុគ្គលទាំងឡាយណាដែលទទួលបាននូវអភ័យឯកសិទ្ធតិច ឬ ច្រើនពីច្បាប់ខ្មែរប៉ុណ្ណោះជាអាទិ៍ : ព្រះមហាក្សត្រ សមាជិកសភា សមាជិករាជរដ្ឋាភិបាល។ ចំណែកឯអភ័យឯកសិទ្ធិអន្តរជាតិវិញ វាទាក់ទងនឹងអ្នកដឹកនាំព្រមទាំងអ្នកការទូតបរទេស ដែលត្រូវបានគេប្តឹងនៅប្រទេសកម្ពុជា។ លក្ខន្តិកៈទីក្រុងរ៉ូម ដែលបានចែងអំពីបញ្ហា អភ័យឯកសិទ្ធ នៅក្នុងមាត្រា ២៧ និង ២៨ មិនបានបញ្ញត្តិឱ្យបានច្បាស់លាស់ទេថា បញ្ហាខាងលើនេះត្រូវតែដោះស្រាយនៅក្នុងច្បាប់ជាតិដែលយកលំនាំតាម ឬ យ៉ាងណា។ តាមការពិត អភ័យឯកសិទ្ធ ទាំងជាតិ ទាំងអន្តរជាតិ សុទ្ធតែមិនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ (មាត្រា ២៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម)។ ដូច្នេះ នៅក្នុងករណីដែលវាមាននៅចំពោះមុខយុត្តាធិការជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងប្រើប្រាស់បុព្វសិទ្ធិយុត្តាធិការ ចំពោះបុគ្គលទាំងឡាយដែលពាក់ព័ន្ធ។ ប៉ុន្តែការបកស្រាយរបៀប នេះហាក់ដូចជាផ្ទុយទៅនឹងគោលគំនិតរបស់លក្ខន្តិកៈទីក្រុងរ៉ូម ដែលមានមូលដ្ឋានយ៉ាងច្បាស់ លើគំនិតនៃការបំពេញ បន្ថែមអោយគ្នារវាងយុត្តាធិការជាតិនិងយុត្តាធិការអន្តរជាតិ[៧០]។ ដូច្នេះ វាមិនមានលក្ខណៈគ្រប់គ្រាន់ទេ ដែលគ្រាន់តែមានការយល់ព្រមអោយផ្ទេរបុគ្គលទាំងអស់ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងករណី ដែលបុគ្គលទាំងនេះមានអភ័យឯកសិទ្ធិនៅចំពោះមុខយុត្តាធិការជាតិ។ សរុបសេចក្តីទៅ យើងឃើញថាវាមានការលំបាកណាស់ ដែលរដ្ឋាភិបាលមួយយល់ព្រមផ្ទេរបុគ្គលម្នាក់ ដែលមានអភ័យឯកសិទ្ធិក្នុងស្រុក ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញជូនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិជាអាទិ៍ មានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលជាបុគ្គលម្នាក់ *"ដែលមិនអាចរំលោភបំពានបាន"* (មាត្រា៧ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា) ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយរំលោភ ទៅលើបទដ្ឋានរបស់ប្រទេសខ្លួននោះ។

ដូច្នេះ នៅក្នុងផលប្រយោជន៍របស់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ វាចាំបាច់ណាស់ដែលថា នៅក្នុងករណីនៃបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម អភ័យឯកសិទ្ធិមិនអាចត្រូវបានលើកឡើង នៅចំពោះមុខយុត្តាធិការជាតិបានឡើយ ទោះបីជាវាជាអភ័យឯកសិទ្ធិក្នុងស្រុក ឬ អភ័យឯកសិទ្ធិអន្តរជាតិក៏ដោយ។

[៧០] វាក្យខ័ណ្ឌ ១០ នៃបុព្វកថារបស់លក្ខន្តិកៈទីក្រុងរ៉ូម និង មាត្រា ១ នៃលក្ខន្តិកៈ។ សូមមើលនៅខាងដើមផងដែរ (ទំព័រ ៩ និង ៣៥)។

## ក. អភ័យឯកសិទ្ធិក្នុងស្រុក

### ១- អភ័យឯកសិទ្ធិរបស់អង្គព្រះមហាក្សត្រ

យោងតាមខ្លឹមសាររបស់មាត្រា៧ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា *"អង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបានឡើយ"* ដែលមានន័យថា ព្រះអង្គមានអភ័យសិទ្ធិទាំងស្រុង។

ជាធម្មតា អ្នកច្បាប់នៅក្នុងប្រទេស បានធ្វើការបញ្ជាក់អំពីអភ័យឯកសិទ្ធិនេះ ដោយបានលើកបង្ហាញនូវវាក្យខ័ណ្ឌ ទីមួយ នៃ មាត្រា ៧ ដដែល ដែលបានចែង ថា *"ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែ ទ្រង់មិនកាន់អំណាចឡើយ"*។ ការបកស្រាយនេះមិនត្រូវបានអះអាងបញ្ជាក់ដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទេថា ប្រសិនបើព្រះមហាក្សត្របានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នោះទ្រង់នឹងទទួលបាននូវអភ័យឯកសិទ្ធិដាច់ខាត[៧១]។

ហេតុនេះ នៅក្រោមរូបភាពរាជានិយមផ្សេងទៀត វិសោធនកម្មរដ្ឋធម្មនុញ្ញមានលក្ខណៈចាំបាច់ នៅក្នុងន័យនៃការទទួលស្គាល់អវត្តមានអភ័យឯកសិទ្ធិរបស់អង្គព្រះមហាក្សត្រ ចំពោះបទឧក្រិដ្ឋទាំងឡាយ ណាដែលជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**អោយធ្វើវិសោធនកម្មមាត្រា៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការអនុម័តទៅលើការតាក់តែង ដូចតទៅនេះ :**

***"មាត្រា ៧ :***

***ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។ លើកលែងតែបទបញ្ញត្តិនៃវាក្យខ័ណ្ឌខាងក្រោយនេះអង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបានឡើយ។ នាំអោយមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ព្រះមហាក្សត្រ ចំពោះបទឧក្រិដ្ឋទាំងឡាយដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ"។***

---

[៧១] ការបកស្រាយរបៀបនេះ ត្រូវបានធ្វើឡើងជាពិសេសដោយ អ្នកតំណាងរាស្ត្រ ខៀវ សន : សូមមើលការកត់ចំណាំខាងដើមត្រង់លេខ ៤ ទំព័រទី១៣។

## ២- អភ័យឯកសិទ្ធិសភា

មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បានចែងដូចតទៅ :

"តំណាងរាស្ត្រមាន*អភ័យឯកសិទ្ធិសភា* ។ តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬ ឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួនការឃាត់ខ្លួន ឬ ការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភាវៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច។

សេចក្តីសំរេចនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភា ខាងមុខ ដើម្បីអនុម័ត តាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួនការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិន បើរដ្ឋសភាបានបញ្ចេញមតិអោយផ្អាកតាមមតិភាគច្រើន បីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល" (អក្សរទ្រេត គឺត្រូវបានបន្ថែម)។

ចំពោះ សមាជិកព្រឹទ្ធសភា មាត្រា ១០៤ បានចែងដូចតទៅ :"សមាជិកព្រឹទ្ធសភាមាន*អភ័យឯកសិទ្ធិសភា*។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបាន ចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំ ខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគ ច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាកប្រសិនបើព្រឹទ្ធសភាបានបញ្ចេញ មតិអោយផ្អាក តាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល" *(អក្សរទ្រេត គឺត្រូវបានបន្ថែម)*។

បទបញ្ញត្តិរដ្ឋធម្មនុញ្ញទាំងនេះ បានហាមឃាត់ការប្តឹងសមាជិកសភាណាមួយ ដោយគ្មានការអនុញ្ញាតិជាមុនពីសំណាក់សភារបស់គេ ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានសមត្ថកិច្ច ដោយរាប់បញ្ចូលជាឧទាហរណ៍ផងដែរចំពោះករណីនៃការញុះញង់ដោយផ្ទាល់ និងជាសាធារណៈអោយប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលកើតមានឡើងនៅពេលពិភាក្សារបស់សភា ។

សេចក្តីសំរេចរបស់គ្នាគេ តាមសំលេងភាគច្រើនពីរភាគបី គឺមានការចាំបាច់សំរាប់អនុញ្ញាតិអោយមានពាក្យបណ្តឹង ។ ផ្ទុយទៅវិញនៅក្នុងករណីបទល្មើសជាក់ស្តែង ការបោះឆ្នោតតាមសំលេងបីភាគបួនរបស់សភាអាចរារាំងការប្តឹងពួកគេ នៅចំពោះមុខយុត្តាធិការខ្មែរ ។

ដូច្នេះក្នុងផលប្រយោជន៍របស់យុត្តិធម៌ វាចាំបាច់អោយមានការធ្វើវិសោធនកម្មបទបញ្ញត្តិរដ្ឋធម្មនុញ្ញទាំងនេះ ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍:**

**អោយធ្វើវិសោតនកម្មមាត្រា ៨០ និង ១០៤ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុម័តការតាក់តែង ដូចតទៅ :**

***"មាត្រា ៨០ :***

***លើកលែងតែបទបញ្ញត្តិ នៃវាក្យខ័ណ្ឌចុងក្រោយ បង្អស់របស់មាត្រានេះ តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។***

***តំណាងរាស្ត្របណាក៏ដោយ មិនអាចត្រូវបានចោទ ប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញ មុខងាររបស់ខ្លួនសោះឡើយ ។***

***ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំ ខ្លួនសមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច ។***

***សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័ត តាមមតិ ភាគច្រើនពីរភាគបី នៃសមា ជិករដ្ឋសភាទាំងមូល ។ លើកលែងតែ បទបញ្ញត្តិនៃវាក្យខ័ណ្ឌចុងក្រោយ បង្អស់របស់មាត្រានេះ ក្នុងករណីទាំងអស់ខាងលើ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិនបើរដ្ឋសភាបានបញ្ចេញមតិអោយ ផ្អាកតាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។***

*ចំពោះបទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកៈ ទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់សមាជិករដ្ឋសភាត្រូវតែមានដោយគ្មានលក្ខខណ្ឌណាមួយដែលបានចែងនៅក្នុងវាក្យខ័ណ្ឌ ខាងដើមរបស់មាត្រានេះ អាចត្រូវបានលើកឡើងនោះទេ"។*

*"មាត្រា ១០៤ :*

*លើកលែងតែបទបញ្ញត្តិនៃវាក្យខ័ណ្ឌចុងក្រោយបង្អស់របស់មាត្រានេះ សមាជិកព្រឹទ្ធសភាមាន អភ័យឯកសិទ្ធិសភា។*

*សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបាន សំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។*

*ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពី គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូន ព្រឹទ្ធសភា ឬជូនគណៈ កម្មាធិការអចិន្ត្រៃយ៍ របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច។ សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។ លើកលែងតែបទបញ្ញត្តិនៃវាក្យខ័ណ្ឌចុងក្រោយ បង្អស់របស់មាត្រានេះ ក្នុងករណីទាំងអស់ខាងលើ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិ អោយផ្អាកតាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិក ព្រឹទ្ធសភា ទាំងមូល។ ចំពោះបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងលក្ខន្តិកៈ ទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វានាំអោយមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់សមាជិកព្រឹទ្ធសភា ដោយគ្មានលក្ខខណ្ឌណាមួយ ដែលបានចែងនៅក្នុងវាក្យខ័ណ្ឌខាងដើមរបស់មាត្រានេះអាចត្រូវបានលើកឡើងនោះទេ"។*

---

### ៣- អវត្តមាននអភ័យឯកសិទ្ធិ ចំពោះសមាជិករដ្ឋាភិបាល

មាត្រា១២៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថាៈ *"សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។ ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច។ រដ្ឋសភាសំរេច ក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល"*។ គ្មានអភ័យឯកសិទ្ធិយុត្តាធិការណាមួយ និងគ្មាន

បុព្វសិទ្ធិយុត្តាធិការណាមួយ ដូចដែលមាន ជាឧទាហរណ៍ នៅក្នុងប្រទេសបារាំង ជាមួយនឹងតុលាការយុត្តិធម៌របស់សាធារណៈរដ្ឋ (la Cour de Justice de la République) ត្រូវបានចែងសំរាប់សមាជិករដ្ឋាភិបាលកម្ពុជា ទេ[៧២] ។

វាក្យខ័ណ្ឌ២ នៃ បទបញ្ញត្តិរដ្ឋធម្មនុញ្ញបានបន្ថែមទៅលើនីតិវិធីរបស់នីតិរូមនូវលទ្ធភាពរបស់រដ្ឋសភា ក្នុងការប្តឹងតុលាការ នីតិរូម ចំពោះបទឧក្រិដ្ឋ បទមជ្ឈឹម ឬ កំហុសធ្ងន់ធ្ងរដែលបានប្រព្រឹត្តដោយសមាជិករដ្ឋាភិបាល នៅក្នុងការបំពេញមុខងាររបស់ខ្លួន ។

---

**អេហ្វ អ៊ី ដេ អាស សន្និដ្ឋាន :**

**ថាអវត្តមានអភ័យឯកសិទ្ធិឬបុព្វសិទ្ធិយុត្តាធិការ ចំពោះសមាជិករដ្ឋាភិបាល គឺជាការមួយដែលមានលក្ខណៈវិជ្ជមាន ។**

---

## ខ- អភ័យឯកសិទ្ធិអន្តរជាតិ

វិស័យអភ័យឯកសិទ្ធិអន្តរជាតិត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញាមួយចំនួន ជាពិសេស សន្ធិសញ្ញានៃច្បាប់ការទូត ដូចជាអនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូត និងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៩ ស្តីពីបេសកកម្មការទូតពិសេស និងដោយនីតិអន្តរជាតិដែលមានប្រភពពីទំនៀមទំលាប់ ។ នីតិទំនៀមទំលាប់អន្តរជាតិមានការរីកចំរើនយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ ១៩៤៥ ចំពោះអវត្ត មានអភ័យឯកសិទ្ធិ នៅពេលដែលបទឧក្រិដ្ឋ ដែលគេបានប្តឹងស្ថិតនៅក្នុងប្រភេទនៃបទឧក្រិដ្ឋអន្តរជាតិ[៧៣] ។

តាមការពិត នៅក្នុងវិស័យបទឧក្រិដ្ឋអន្តរជាតិគោលការណ៍នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗ គឺមានសារសំខាន់ណាស់ ។ គោលការណ៍នេះបានកើតមានឡើងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការយោធានីរឹមប៊ែរ

---

៧២. នៅខែមករា ឆ្នាំ ២០០៤ ប្រធានគណៈបក្សសម រង្ស៊ី លោក សម រង្ស៊ី បានដាក់ពាក្យបណ្តឹងមួយប្រឆាំងនឹងលោកនាយករដ្ឋ មន្ត្រី ហ៊ុន សែន ចំពោះការសមគំនិតមនុស្សឃាតដោយចេតនានៅក្នុងក្របខ័ណ្ឌនៃការផ្ទុះគ្រាប់បែកមួយនៅពេលមានការធ្វើបាតុកម្មដែលបានរៀបចំឡើងដោយគណៈបក្សរបស់គាត់ នៅក្នុងខែ មិនា ឆ្នាំ ១៩៩៧ ។ តុលាការក្រុងភ្នំពេញ បានបដិសេធការស្នើសុំរបស់គាត់ ។ លោក សម រង្ស៊ី បានប្តឹងឧទ្ធរណ៍ ។ សាលាឧទ្ធរណ៍ ដែលចៅក្រមនៃតុលាការកំពូលបានធ្វើការសំរេច ដូចគ្នា បានប្រកាន់យកនៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៥ គោលជំហរនៃសេចក្តីសំរេច របស់តុលាការដំបូង ។ ចៅក្រមសាលាឧទ្ធរណ៍មួយរូបដែលទទួលបន្ទុករឿងក្តីនេះ បាន ប្រកាសនៅក្រោយពេលសវនាការបាន បញ្ចប់ថា : "សេចក្តីសំរេច របស់តុលាការក្រុង មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។ សំណុំឯកសារនៃពាក្យបណ្តឹងដែលបានធ្វើឡើង ដោយមេធាវី ឱ្យរបស់ សម រង្ស៊ី ឧមិនមានភស្តុតាង គ្រប់គ្រាន់ សំរាប់អោយមានការប្តឹងទេ" ។ ការនេះមានន័យថាពាក្យបណ្តឹងប្រភេទនេះ អាចទទួលយកបាននៅ ចំពោះមុខតុលាការទាំងឡាយ ។

៧៣. សូមមើលអត្ថបទរបស់ អេហ្វ អ៊ី ដេ អាស លេខ ៣២ លេខ ពិសេស "យុត្តិធម៌អន្តរជាតិ" ចុះថ្ងៃទី ១៤ កុម្ភៈ ឆ្នាំ ២០០០ ទំព័រ ២៤ ។

ដែលក្រោយមកទៀត ត្រូវបានលើកឡើងបញ្ជាក់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ និងគណៈកម្មការនីតិអន្តរជាតិរបស់អង្គការ សហប្រជាជាតិ។ នីតិទំនៀមទំលាប់អន្តរជាតិ ត្រូវបានបង្កើតឡើងយ៉ាងប្រាកដ តាមន័យនេះ។

ជាលទ្ធផល ការនេះរួមបញ្ចូលអវត្តមានអភ័យឯកសិទ្ធិចំពោះភ្នាក់ងារសាធារណៈទាំងអស់ដូចជា ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ព្រមទាំងរដ្ឋមន្ត្រីនានាផង នៅក្នុងករណីបទឧក្រិដ្ឋអន្តរជាតិ។

លក្ខន្តិកៈទីក្រុងរ៉ូម បានចែងនៅក្នុងមាត្រា ២៧ អំពីអវត្តមានអភ័យឯកសិទ្ធិយុត្តាធិការ។ ផ្ទុយទៅវិញ មាត្រា ៩៨ កថាខ័ណ្ឌ ១ បានចែងនូវអភ័យឯកសិទ្ធិក្នុងការអនុវត្តសំណើកិច្ចសហប្រតិបត្តិការ ដែលតម្រូវអោយរដ្ឋទទួលសំណើរ អនុវត្តផ្ទុយពីកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ដែលពាក់ព័ន្ធនឹងអភ័យឯកសិទ្ធិរបស់រដ្ឋ ឬ អភ័យឯកសិទ្ធិការទូតរបស់បុគ្គល ឬ ទ្រព្យសម្បត្តិរបស់តតីយរដ្ឋមួយ ប្រសិនបើបានទទួលជាមុននូវកិច្ចសហប្រតិបត្តិកាពីតតីយរដ្ឋនេះ ដើម្បីអោយមានការបោះបង់អភ័យឯកសិទ្ធិ។

មាត្រា ៩៨ កថាខ័ណ្ឌ ១ មិនបានរារាំងដល់ការផ្តើម អោយមានពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិទេ។ វាគ្រាន់តែបានបង្ហាញថា តុលាការមិនអាចស្នើសុំអោយរដ្ឋអនុវត្តកិច្ចបង្ខំណាមួយ ទៅលើបុគ្គលមួយចំនួន ដែលបានការពារដោយបទបញ្ញត្តិរបស់សន្ធិសញ្ញាបានឡើយ។ ដូច្នេះ វាគ្មានអភ័យឯកសិទ្ធិយុត្តាធិការទេ ប៉ុន្តែ មានអភ័យឯកសិទ្ធិក្នុងការអនុវត្ត។

ដូច្នេះ ឋានានុក្រមយុត្តាធិការជាតិត្រូវចែង អោយបានច្បាស់លាស់ នូវភាពសមហេតុសមផលនេះ។ ការចែងនេះ ជាការចាំបាច់សំរាប់ការអនុវត្តអោយបានល្អ នូវគោលការណ៍បំពេញបន្ថែមអោយគ្នា រវាងតុលាការអន្តរជាតិ និងយុត្តាធិការជាតិ។ វាមានសារសំខាន់ណាស់ ដើម្បីអោយប្រជាពលរដ្ឋ អាចធ្វើការប្តឹងជនទាំងឡាយ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាសមត្ថកិច្ចរបស់លក្ខន្តិកៈទីក្រុងរ៉ូម នៅចំពោះមុខយុត្តាធិការជាតិ។

ចំពោះស្ថានភាពបច្ចុប្បន្នរបស់ច្បាប់ខ្មែរទោះបីជាមានការទទួលស្គាល់ធម្មនុញ្ញភាពនៃសិទ្ធិមនុស្សដែលបានកំណត់នៅក្នុងនីតិអន្តរជាតិ និង មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏សិទ្ធិនេះ មិនទាន់អនុញ្ញាតិ អោយប្រជាពលរដ្ឋ ខ្មែរលើកឡើង ដោយផ្ទាល់នូវបទបញ្ញត្តិនីតិអន្តរជាតិទាំងនេះ នៅចំពោះមុខយុត្តាធិការជាតិនៅឡើយទេដរាបណាអ្នកតាក់តែងច្បាប់មិនបានចូលធ្វើអន្តរាគមន៍ ដើម្បីបញ្ចូលកាតព្វកិច្ចអន្តរជាតិ ដែលពាក់ព័ន្ធនឹង វិស័យនេះទេនោះ (មាត្រា ៣១ វាក្យខ័ណ្ឌចុង ក្រោយនៃរដ្ឋធម្មនុញ្ញ)[៧៤]។

ចំពោះអវត្តមានអភ័យឯកសិទ្ធិ មានករណីលើកលែងតែមួយគត់ គឺមាត្រា ២៩ នៃច្បាប់វិសោធនកម្មឆ្នាំ ២០០១ ដែលបាន ចែង នៅក្នុងក្របខ័ណ្ឌនៃការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ថា *"តួនាទី ឬឋានៈរបស់*

៧៤. សូមមើលផ្នែកទី២ ជំពូកទី២។

*ជនសង្ស័យ មិនអាចជួយជននេះអោយរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឬជួយ បន្ថយទណ្ឌកម្មដល់ជននេះបានឡើយ"*។

ដូច្នេះ ការចែងនៅក្នុងច្បាប់ទូទៅនូវនីតិអន្តរជាតិ ដែលទាក់ទងនឹងអវត្តមានអភ័យឯកសិទ្ធិ ចំពោះករណីបទឧក្រិដ្ឋអន្តរជាតិ និងជាពិសេសនៅក្នុងករណីនៃបទឧក្រិដ្ឋដែលបានចែងដោយលក្ខន្តិកៈទីក្រុងរ៉ូម វាមានលក្ខណៈចាំបាច់សំរាប់អនុញ្ញាតិ អោយប្រជាពលរដ្ឋខ្មែរធ្វើការប្តឹងជនល្មើស។

ដូច្នេះ វាហាក់ដូចជាមានការចាំបាច់ណាស់ក្នុងការបន្ថែមទៅក្នុងបទបញ្ញត្តិដែលមានស្រាប់នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នូវបទបញ្ញត្តិដែលទាក់ទងនឹងអវត្តមានអភ័យឯកសិទ្ធិ។ ការតាក់តែងសេចក្តីព្រាងក្រមថ្មីអនុញ្ញាតិអោយមានការដាក់បញ្ចូលបទបញ្ញត្តិប្រភេទនេះទៅក្នុងគន្ថីទី ១ នៃភាគទី ២ ដែលស្តីពីបទល្មើសប្រឆាំងនឹងបុគ្គល។ គន្ថីនេះទាក់ទងទៅនឹងបទល្មើស ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ វាមានមាតិកាចំនួន ៣ៈ មាតិកា ទីមួយស្តីពី បទល្មើសប្រល័យពូជសាសន៍ មាតិកាទីពីរ ស្តីពីឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ និងមាតិកាទីបីស្តីពីឧក្រិដ្ឋកម្មសង្គ្រាម។

ដូច្នេះ យើងសូមស្នើទៅអាជ្ញាធរខ្មែរអោយបញ្ចូលបទបញ្ញត្តិដែលទាក់ទងនឹងអវត្តមានអភ័យឯកសិទ្ធិ ចំពោះបទឧក្រិដ្ឋ ទាំងឡាយដែលបានចែងដោយលក្ខន្តិកៈទីក្រុងរ៉ូម នៅក្នុងទំរង់ជាមាតិកាទីបួនដែលមានចំណងជើងថា "អវត្តមានអភ័យ ឯកសិទ្ធិ ចំពោះបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម" ទៅក្នុងគន្ថីទី ១ នៃភាគទី ២ ដែលមានមាតិកាចំនួន ៣ រួចហើយ។ នៅក្នុងមាតិកាទី ៤ ថ្មី នេះ យើងសូមស្នើមាត្រាចំនួនពីរ គឺ កម ២១៤១-១ និង កម ២១៤១-២ ដោយធ្វើការចុះលេខ អោយសមស្របទៅតាមប្រព័ន្ធនៃការចុះលេខរបស់សេចក្តីព្រាងក្រម។

---

### អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :

**អោយបញ្ចូលទៅក្នុងគន្ថីទី ១ នៃភាគទី ២ នៃសេច ក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នូវមាតិកាទី ៤ និងមាត្រា ចំនួនពីរ គឺ កម ២១៤១-១ និង កម ២១៤១-២ ដែលបានចែងយ៉ាងច្បាស់មួយផ្នែក នូវអវត្តមាន អភ័យឯកសិទ្ធិយុត្តាធិការ ចំពោះបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម ដែលបានកំណត់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម និងមួយផ្នែកទៀតនូវអវត្តមានអភ័យឯកសិទ្ធិអនុវត្តដើម្បីចាប់ខ្លួន និង/ឬ ដើម្បីផ្ទេរបុគ្គលទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ លើកលែងតែមានបទបញ្ញត្តិសន្ធិសញ្ញាចែងផ្ទុយពីនេះ នៅក្នុងករណីនេះ វាអាស្រ័យទៅតាមការយល់ឃើញដោយឯករាជ្យរបស់តុលាការ។ មាតិកាទី ៤ និងមាត្រា ទាំងអស់ដែលបានស្នើសុំអោយធ្វើការបញ្ចូល មានចែងដូចតទៅ :**

*"មាតិកាទី ៤ : អវត្តមានអភ័យឯកសិទ្ធិ ចំពោះ បទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម*

ជំពូកទី ១ : ជំពូកទោល

*មាត្រា កម ២១៤១-១ : អវត្តមានអភ័យឯកសិទ្ធិយុត្តាធិការ*

*គ្មានអភ័យឯកសិទ្ធិណាមួយ អាចត្រូវបានលើកឡើង នៅចំពោះមុខយុត្តាធិការខ្មែរបានទេ ចំពោះបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ។*

*មាត្រា កម ២១៤១-២ : អវត្តមានអភ័យឯកសិទ្ធិ អនុវត្ត*

*គ្មានអភ័យឯកសិទ្ធិណាមួយ អាចត្រូវបានលើកឡើង ដើម្បីរារាំងដល់ការបង្ខិតបង្ខំបុគ្គលណាមួយ ដែលត្រូវបាន ចោទ នៅចំពោះមុខយុត្តាធិការខ្មែរ ពីបទល្មើសណាមួយ ក្នុងចំណោមបទល្មើសទាំងឡាយ ដែលបានចែងនៅក្នុង មាត្រា កម ២១៤១-១ ឬ រារាំងដល់សំណើ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានឡើយ លើកលែងតែវាជាកាតព្វកិច្ច ដែលមានចែងយ៉ាងច្បាស់នៅក្នុងសន្ធិសញ្ញា ចំពោះតតីយរដ្ឋចែងផ្ទុយពីនេះ ។ នៅក្នុងករណីនេះ វាអាស្រ័យទៅលើការយល់ឃើញដោយឯករាជ្យ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ" ។*

## ជំពូក ៣ : ការទទួលខុសត្រូវរបស់មេបញ្ជាការកងទ័ព និងថ្នាក់លើផ្សេងៗទៀត : មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម

### ក. សេចក្តីកត់សំគាល់បឋម

ការប្រព្រឹត្តបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ជាទូទៅត្រូវមានការជាប់ពាក់ពន្ធ័ទៅនឹងការរៀបចំខាងនយោបាយ ខាងយោធា ឬ ខាងសារពតិមានដោយមានរចនាសម្ព័ន្ធជាឋានានុក្រម។ ក្រៅពី វត្តមាននៃទំនាក់ទំនងជាឋានានុក្រម និង ឥទ្ធិពលរបស់វានៅក្នុងការប្រព្រឹត្តបទល្មើសទាំងនេះ វាតម្រូវឱ្យមាន ទន្ទឹមគ្នានឹងអ្នកប្រព្រឹត្តផ្ទាល់ នូវជនល្មើសពិសេសមួយប្រភេទទៀត ដែលស្ថិតនៅថ្នាក់លើនៃឋានានុក្រមខាងស៊ីវិល ឬ ខាងយោធា។

ដោយយល់ពីបញ្ហានេះហើយទើបមាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់មេបញ្ជាការកងទ័ព និងថ្នាក់លើផ្សេងៗទៀត។ ចំពោះបញ្ហាដែលទាក់ទងទៅនឹងការទទួលខុសត្រូវរបស់មេបញ្ជាការកងទ័ព បទបញ្ញត្តិនេះបានយកគំនិតតាមអនុសញ្ញាក្រុងឡាអេឆ្នាំ ១៩០៧ និងតាមមាត្រា ៧ នៃលក្ខន្តិកៈតុលាការយោធាអន្តរជាតិនីរមប៊េរ ព្រមទាំងមាត្រា ៨៦ (២) និង ៨៧ នៃពិធីសារបន្ថែមទី I របស់អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើផ្សេងៗទៀត លក្ខន្តិកៈបានយកលំនាំតាមបទបញ្ញត្តិរបស់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងពីរ[៧៥] ដែលបានធ្វើអោយមានការរីកចំរើន ដោយយុត្តិសាស្ត្ររបស់ពួកគេ។

### ខ. ដែនអនុវត្តរបស់មាត្រា២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម

មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម តាមផ្លូវច្បាប់ អនុវត្តទៅលើស្ថានភាព នៃការនៅស្មៀមរបស់ថ្នាក់លើទោះបីជាវាមាន លក្ខណៈវិជ្ជមាន (ការអត់អោនចំពោះការប្រព្រឹត្តរបស់អ្នកនៅក្រោមឱវាទ) ឬ អវិជ្ជមាន (ការធ្វើមិនដឹងមិនលឺ ដោយចេតនា ឬ ដោយអចេតនា នូវការប្រព្រឹត្តរបស់អ្នកនៅក្រោមឱវាទ) ក៏ដោយ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ដោយអ្នក នៅក្រោមឱវាទរបស់ខ្លួន។

បទបញ្ញត្តិនេះអាចដោះស្រាយខាងព្រហ្មទណ្ឌផងដែរនូវស្ថានភាពមួយដែលទំនាក់ទំនងឋានានុក្រម បានចងថ្នាក់លើ និងអ្នកក្រោមឱវាទ ដែលជាជនល្មើសនៃបទឧក្រិដ្ឋអន្តរជាតិ។ តាមទំនាក់ទំនងដ៏សាមញ្ញនេះ ថ្នាក់លើមិនអាចត្រូវបានគេចាត់ទុកថា ជាចារី ឬ សហចារីនៃបទល្មើសទេ។ ផ្ទុយទៅវិញ តាមបទបញ្ញត្តិដដែលនេះ ថ្នាក់លើគ្រាន់

៧៥. មាត្រា ៧ (៣) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌសំរាប់អតីត យូហ្គោស្លាវី និងមាត្រា ៦ (៣) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់រវ៉ាន់ដា។

តែត្រូវបានគេដាក់កាតព្វកិច្ចអោយ ដាក់ទោសអ្នកនៅក្រោមឱវាទរបស់ខ្លួន ឬ រារាំងគេមិនអោយប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិតែប៉ុណ្ណោះ[៧៦] ។

កាតព្វកិច្ចក្នុងការប្រុងប្រយ័ត្ន និង ចាត់វិធានការណ៍នេះមានការខុសប្លែកគ្នាទៅតាមចរិតលក្ខណៈស៊ីវិល ឬ យោធារបស់ថ្នាក់លើ ។

ការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលមិនមែនជាយោធាមានលក្ខណៈពិបាកនឹងលើកបង្ហាញជាងការទទួលខុសត្រូវរបស់មេបញ្ជាការកងទ័ព ដែលការទទួលខុសត្រូវរបស់គាត់ត្រូវបានគេកំណត់យ៉ាងច្បាស់លាស់ ដោយសាររចនាសម្ព័ន្ធនៃការចាត់តាំងយោធា និងភាពចាំបាច់នៃការគោរពអោយបានល្អនូវវិន័យយោធា។ មេបញ្ជាការកងទ័ពត្រូវមានការទទួលខុសត្រូវ ចំពោះបទល្មើសដែលបានប្រព្រឹត្តដោយកូនទាហានរបស់ខ្លួនប្រសិនបើ "*គាត់បានដឹង ឬ គួរតែបានដឹងដោយយោងទៅតាមកាលៈទេសៈ* " ថាបទល្មើសនឹងត្រូវបានប្រព្រឹត្ត ហើយប្រសិនបើគាត់មិនបានចាត់វិធានការណ៍ដែលចាំបាច់សំរាប់បង្កា ឬ បង្ក្រាបការប្រព្រឹត្តបទល្មើសទេ ( មាត្រា ២៨ កថាខ័ណ្ឌ ១ *ក.* នៃលក្ខន្តិកៈទីក្រុងរ៉ូម) ។

អ្នកថ្នាក់លើមិនមែនយោធាត្រូវមានការទទួលខុសត្រូវចំពោះបទល្មើស ដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមឱវាទរបស់ខ្លួន នៅពេលដែលបទល្មើសមានការពាក់ព័ន្ធទៅនឹងសកម្មភាពដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួនដោយគេបានដឹង ឬគេមិនចង់យកចិត្តទុកដាក់ទៅលើព័ត៌មានដែលបានបញ្ជាក់យ៉ាងច្បាស់ថាអ្នកនៅក្រោមឱវាទកំពុងប្រព្រឹត្ត ឬ ប្រុងនឹងប្រព្រឹត្តបទល្មើសទាំងនេះ ហើយគេមិនបានចាត់វិធានការណ៍នានា ដែលចាំបាច់សំរាប់ទប់ស្កាត់ ឬ បង្ក្រាបការប្រតិបត្តិ ឬ មិនបានប្ដឹងតុលាការដែលមានសមត្ថកិច្ច ( មាត្រា ២៨ កថាខ័ណ្ឌ ១ *ខ* នៃលក្ខន្តិកៈទីក្រុងរ៉ូម) ។ ការលំបាកក្នុងការបង្ហាញ ភស្តុតាងមានកម្រិតខ្ពស់ ពីព្រោះគេត្រូវបង្ហាញថាថ្នាក់លើបាន ដឹងពីការប្រព្រឹត្តបទល្មើស ឬ ធ្វើមិនដឹងមិនឮ ចំពោះការកើតមានឡើងនូវបទល្មើស ។

## ឥ. អត្ថប្រយោជន៍របស់មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម

ថ្នាក់លើខាងស៊ីវិល ក៏ដូចជាខាងយោធា ត្រូវមានការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌ ប្រសិនបើ "គេបានបញ្ជា ញុះញង់ ឬជំរុញអោយប្រព្រឹត្តបទល្មើស" ( មាត្រា ២៥ កថាខ័ណ្ឌ ៣ *ខ.* នៃ លក្ខន្តិកៈ) ។ អនុលោមភាពស្រដៀងគ្នាខាងគតិយុត្តិ យើងអាចចាត់ទុកភាពនៅស្ងៀមជាវិជ្ជមាន (ជាអាទិ៍ ការអត់អោន) របស់ថ្នាក់លើ ខាង

៧៦. ជាទូទៅ កាតព្វកិច្ចរបស់ថ្នាក់លើ ដើម្បីរារាំងការប្រព្រឹត្តបទល្មើស ដោយអ្នកនៅក្រោមឱវាទរបស់ខ្លួន ត្រូវបានប្រកាសដោយតុលាការជាតិ។ ឧទាហរណ៍ គំរូមួយនៅក្នុងវិស័យនេះ គឺសេចក្ដីសំរេច *យ៉ាម៉ាស៊ីតា* បានប្រកាសថាៈ "ច្បាប់សង្គ្រាមតំរូវអោយមន្ត្រីយោធា នៅក្នុងឋានៈជាអ្នកបញ្ជានូវកាតព្វកិច្ចជាវិជ្ជមានមួយនៃការចាត់វិធានការណ៍តាមអំណាចរបស់ខ្លួន និងទៅតាមកាលៈទេសៈដើម្បីត្រួតពិនិត្យអ្នក ដែលស្ថិតនៅក្រោមការបញ្ជារបស់ខ្លួនទាំងអស់ ក្នុងគោលបំណងបង្កាជាមុននូវអំពើទាំងឡាយ ដែលជាការរំលោភបំពានលើច្បាប់សង្គ្រាម" រឿងក្ដី *យ៉ាម៉ាស៊ីតា* តុលាការកំពូលរបស់សហរដ្ឋអាមេរិក ចេញថ្ងៃទី ៤ កុម្ភៈ ១៩៤៦/ I.L.R., សៀវភៅទី ១៣ លេខ ១១៥ ទំព័រ ២៦៩ និងបន្តបន្ទាប់ ។

ស៊ីវិល ឬខាងយោធា ថាជាការជំរុញ ដោយតុណ្ហីភាពអោយមានការរំលោភបំពាន ដែលញ៉ាំងឱ្យមានការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌ។បំណកស្រាយខាងលើនេះគ្រាន់តែជាកម្មវត្ថុនៃការប៉ុនប៉ង និង ការចង់បានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានលើកឡើងជាច្រើនលើកច្រើនសារ[៧៧] ថា : គោលការណ៍នៃការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌ ត្រូវមានអានុភាពលប់លើគោលការណ៍នៃការទទួលខុសត្រូវរបស់មេបញ្ជាការកងទ័ព និង ថ្នាក់លើប្រសិនបើការទទួលខុសត្រូវទាំងពីនេះកើតឡើងព្រមគ្នា។

ម៉្យាងទៀត ភាពនៅស្ងៀមជាវិជ្ជមាននេះ មានលក្ខណៈស្រដៀងគ្នាទៅនឹង កិច្ចវិជ្ជមាននៃការសមគំនិត (មាត្រា ២៥ កថាខ័ណ្ឌ ៣ គ នៃលក្ខន្តិកៈទីក្រុងរ៉ូម) ដែលអាចនាំអោយមានការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌរបស់ថ្នាក់លើ ខាងស៊ីវិល ឬខាងយោធា។ ដូច្នេះមាត្រា ២៨ ត្រូវបានប្រើ នៅពេលដែលការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌមិនអាចលើកបង្ហាញបាន។ ថ្វីដ្បិតតែវាកំរកើតមានក៏ដោយ ក៏ភាពមិនអាចលើកបង្ហាញបាននេះអាចកើតមានឡើង នៅក្នុងករណីនៃភាពស្ងាត់ស្ងៀមជាអវិជ្ជមានរបស់ថ្នាក់លើខាងស៊ីវិល។

## ឃ. ច្បាប់កម្ពុជា

នៅក្នុងច្បាប់កម្ពុជា ការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌ មានចែងក្នុងមាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ ដែលបានចែងថា: *"ជនទាំងពួងណា មានសតិជាល្អ មានវិចារណញាណ ស្គាល់ល្អ អាក្រក់ ជនទាំងពួងនោះត្រូវមានភារៈទទួល ខុសត្រូវ តាមច្បាប់ព្រហ្មទណ្ឌ ចំពោះបទល្មើស ដែលខ្លួនប្រព្រឹត្ត ចំពោះបទឧក្រិដ្ឋ ឬមជ្ឈិម ដែលខ្លួនសមគំនិត និង ចំពោះ បំណងជាឧក្រិដ្ឋ ឬបំណងជាមជ្ឈិមខ្លះ ដែលខ្លួនបានធ្វើអោយ ប្រកបនឹងលក្ខខណ្ឌ ដូចដែលមានបញ្ញត្តិក្នុងច្បាប់"*។ យើងបានដឹង រួចមកហើយ នូវនិយមន័យនៃការសមគំនិត និងការប៉ុនប៉ង ដែលបានផ្តល់អោយដោយនីតិវិជ្ជមាន[៧៨] ។

### ១- ថ្នាក់លើខាងយោធា

ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់ថ្នាក់លើខាងយោធា បានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ២៣៧, ២៣៨ និង ២៤២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥[៧៩] ។ មាត្រាទាំងអស់នេះ មានចែងដូចតទៅ : "មាត្រា ២៣៧ អ្នករាជ

---

[៧៧] រឿងក្តី ការ៉ាហ្ស៊ីក និង ម្ល៉ាឌីក (Affaires Karadzic et Mladic) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោ ស្លាវី, រឿងក្តីលេខ IT-95-5-R61 និងលេខ IT-95-18-R61 ចុះថ្ងៃទី ១១ កក្កដា ១៩៩៦ កថាខ័ណ្ឌ ៨៣ : *"លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ថ្នាក់លើ តាមមាត្រា ៧ កថាខ័ណ្ឌ ៣ នៃ លក្ខន្តិកៈ មានន័យថា លក្ខខណ្ឌដែលនាំអោយមានការធ្វើមិន ដឹងមិនលឺដែលជាបទល្មើស របស់ថ្នាក់លើត្រូវបានបំពេញ។ ផ្ទុយទៅវិញ តុលាការបានសន្និដ្ឋានថា ការទទួលខុសត្រូវនេះ អាចកំណត់បានយ៉ាងល្អ ដោយបទបញ្ញត្តិនៃកថាខ័ណ្ឌ ១ មាត្រា ៧ របស់លក្ខន្តិកៈ"* ដែលទាក់ទងនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗ។

៧៨. សូមអានទំព័រ ៩១។

៧៩. សូមមើលផងដែរនូវមាត្រា ២២៦, ២២៨, ២៣០, ២៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥។

ការអ្នកតំណាង អាជ្ញាធរសាធារណៈ ឆ្លៀតប្រើកងកម្លាំងដែលនៅក្រោមបង្គាប់ខ្លួន អោយប្រឆាំងនឹងការប្រតិបត្តិច្បាប់ បទបញ្ជា សេចក្តីសំរេចតុលាការ ដីកាតុលាការជាតិ ជាឱរាល់ទៅទៀត គឺប្រឆាំងនឹងគ្រប់សេចក្តីបង្គាប់ជា នីត្យានុកូល ដែលចេញមកពីអាជ្ញាធរជាធម្មានុរូប អ្នករាជការនោះត្រូវបានទោសឧក្រិដ្ឋថ្នាក់ទីមួយ។

មាត្រា២៣៨ បទបញ្ញត្តិក្នុងមាត្រាទាំងពីរខាងលើនេះនឹងអនុវត្តទៅលើអ្នករាជការ ឬ អ្នកតំណាងអាជ្ញាធរសាធារណៈ តែក្នុងលក្ខខណ្ឌដូចដែលមានគ្រោងទុកក្នុង មាត្រា១០០[៨០] ប៉ុណ្ណោះ វៀរលែងតែវិរុទ្ធជននោះបានជូនតឹកតាងពីអំពើដែលខ្លួនបានធ្វើ ឬ មិនបានធ្វើនោះ ព្រោះប្រតិបត្តិតាមបង្គាប់របស់ចៅហ្វាយនាយដែលខ្លួនត្រូវស្តាប់។ បើមានករណី យ៉ាងនេះ ទោសអាចត្រូវធ្លាក់បានតែទៅលើចៅហ្វាយនាយ ដែលជាអ្នកទទួលខុសត្រូវក្នុងការចាត់បង្គាប់នេះទៅវិញប៉ុណ្ណោះទេ។

មាត្រា ២៤២ នាកាល អ្នករាជការ ឬអ្នកតំណាង អាជ្ញាធរសាធារណៈ ដែលមានពិរុទ្ធជន បានធ្វើមុខការខ្លួនដោយរំលោភអំណាចនោះ មានសំអាងថា កាលខ្លួនប្រព្រឹត្តនោះ ខ្លួនបានធ្វើតែតាមបង្គាប់ចៅហ្វាយនាយ តាមលំដាប់ថ្នាក់របស់ខ្លួនប៉ុណ្ណោះទេ ហើយម្យ៉ាងទៀតថា សេចក្តីបង្គាប់នោះ ក៏មានកម្មវត្ថុត្រូវតាមមុខអំណាចចៅហ្វាយនាយនោះដែរ នោះទោសដែលបានគ្រោងទុកក្នុងមាត្រា២៤០នេះ ត្រូវអនុវត្តទៅលើចៅហ្វាយនាយ ជាម្ចាស់បង្គាប់នឹងអ្នករាជការ អ្នកតំណាង ដែលទទួលប្រតិបត្តិបង្គាប់ តាមលក្ខខណ្ឌស្តីពីការទទួលខុសត្រូវ ដូចមានសំដែង ក្នុងមាត្រា ១០០ នេះ"។

បទបញ្ញត្តិទាំងនេះ ដាក់ទោសថ្នាក់លើខាងយោធា ប្រសិនបើគេប្រព្រឹត្តយ៉ាងសកម្ម នូវអំពើមួយចំនួន ដែលបានកំណត់ថាជា បទល្មើស ប៉ុន្តែមិនបានបញ្ជាក់ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៅក្នុងករណីអកម្មទេ។

ផ្ទុយទៅវិញអកម្មរបស់ថ្នាក់លើ អាចលើកឡើងដើម្បីអោយមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដោយយោង ទៅតាម មាត្រា ៦៩ នៃបទបញ្ញត្តិ សម័យអន្តរកាលនិងមាត្រា ៨៣ ដល់ ៨៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ ដែលបានអោយនិយមន័យនៃការសមគំនិត។ ដូចដែលយើងបានកត់សំគាល់នៅខាងលើរួចហើយ[៨១] នឹងត្រូវបានផ្តន្ទាទោស ជាជនសមគំនិតជនណាដែល *"បានសំរួលដល់ការ ប្រព្រឹត្តបទល្មើស"* (មាត្រា ៦៩ នៃបទបញ្ញត្តិសម័យអន្តរកាល)។ ការអត់អោន របស់ថ្នាក់លើ ដែលធ្វើមិនដឹង ឬ មិនអើពើនឹងចាត់វិធានការណ៍នានា ដែលចាំបាច់សំរាប់បង្ការ ឬ បង្ក្រាបការប្រព្រឹត្តបទល្មើស ដោយអ្នកនៅក្រោមឱវាទ នឹងត្រូវចាត់ទុកដូចជាអំពើមួយ ដែលបានសំរួលដល់ការប្រព្រឹត្តបទល្មើសផងដែរ។

៨០. មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ បានចែងដូចតទៅ : "ក្នុងករណីដែលសេចក្តីបង្គាប់ជានីត្យានុកូល ហើយអ្នក បញ្ជាជាអាជ្ញាធរធម្មានុរូបនោះចៅក្រមត្រូវថ្លឹងមើលតាមការគួរ នូវភាពនៃការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការណ៍នោះ"។

៨១. សូមអានទំព័រ ៩១។

ផ្ទុយទៅវិញភាពនៅស្ងៀមជាអវិជ្ជមាន (ដែលអាច ជាការធ្វេសប្រហែសផងដែរ) របស់ថ្នាក់លើខាងយោធា មិនអាចផ្តន្ទាទោសបានទេតាមនីតិវិជ្ជមានរបស់ខ្មែរ។ លើសពីនេះទៅទៀត វាមិនមានចែងនៅ ក្នុងអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីទេ។ កង្វះខាតនេះគួរអោយសោកស្តាយណាស់ព្រោះថា ស្ថានភាពនេះ អាចកើតមានឡើងយ៉ាងពិតប្រាកដ នៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេសនៅពេលដែលមានឧក្រិដ្ឋកម្មសង្គ្រាម។

ជាលទ្ធផល យើងគួរតែយកលំនាំតាមមាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូមដើម្បីដាក់អោយមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់ថ្នាក់លើខាងយោធានៅក្នុងច្បាប់ខ្មែរ។

### ២- ថ្នាក់លើខាងស៊ីវិល

ដូចគ្នានឹងថ្នាក់លើខាងយោធាដែរ ភាពនៅស្ងៀមជាវិជ្ជមាន (ការអត់អោន) របស់ថ្នាក់លើខាងស៊ីវិល អាចចាត់ទុកជាការសមគំនិត។

ផ្ទុយទៅវិញ តាមច្បាប់ជាធរមាន និងតាមសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី និងដោយមិនមានអត្ថបទ ច្បាប់ព្រហ្មទណ្ឌណាមួយ ចែងនៅក្នុងន័យនេះ ភាពនៅស្ងៀមជាអវិជ្ជមាន (ការធ្វេសប្រហែសដោយចេតនា) របស់ជននេះ មិនអាចផ្តន្ទាទោសបានឡើយ ដូចគ្នានឹងករណីរបស់ថ្នាក់លើខាងយោធាដែរ។

ទោះបីជាវាមានការលំបាក ក្នុងការលើកបង្ហាញនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់ថ្នាក់លើខាងស៊ីវិល ដោយផ្អែកលើមូលដ្ឋាននៃមាត្រា ២៨ របស់លក្ខន្តិកៈទីក្រុងរ៉ូម ប៉ុន្តែដូចដែលយើងបានលើកឡើង នៅខាងលើរួចហើយក៏ដោយ ក៏អត្ថបទនេះនៅមានលក្ខណៈគ្រប់គ្រាន់ល្អជាងច្បាប់ខ្មែរដែលមានជាធរមានដដែល។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដោយយោងទៅលើ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលមានចែងដោយលក្ខន្តិកៈទីក្រុងរ៉ូម និង ទៅលើកំណែទំរង់យ៉ាងខ្លាំងក្លាទៅលើច្បាប់ព្រហ្មទណ្ឌ នាពេលបច្ចុប្បន្ន អោយធ្វើការបន្ថែមទៅលើបទបញ្ញត្តិ ដែលមានស្រាប់ នៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នូវមាត្រាចំនួនពីរគឺ កម ២១៥១-១ និង កម ២១៥១-២ ដែលទាក់ទងនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ថ្នាក់លើខាងយោធា និងខាងស៊ីវិល ដែលការតាក់តែងគឺយកលំនាំតាមឃ្លា ប្រយោគរបស់មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម។**

**មាត្រាដែលបានស្នើទាំងនេះ នឹងដាក់បញ្ចូលទៅក្នុង គន្ថីទី ១ នៃភាគទី ២ របស់សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ជាមាតិកាទី ៥ ថ្មី ដែលមានចំណងជើងថា "ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់ថ្នាក់លើ ចំពោះបទល្មើសប្រល័យពូជសាសន៍ ឬ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម"។ វានឹងមានចែងដូចតទៅនេះ :**

"មាតិកាទី ៥ : ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ របស់ថ្នាក់លើ ចំពោះបទល្មើស ប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋ កម្មសង្គ្រាម

## ជំពូកទី ១ : ជំពូកទោល

មាត្រា កម ២១៥១-១ : ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់មេបញ្ជាការកងទ័ពមេបញ្ជាការកងទ័ព ឬ ជនដែលបំពេញមុខងារពិតប្រាកដជាមេបញ្ជាការកងទ័ព ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសប្រល័យ ពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលបានប្រព្រឹត្តដោយកងកម្លាំង ដែលស្ថិតនៅក្រោមបញ្ជា និងការគ្រប់គ្រងពិតប្រាកដរបស់ខ្លួន ឬ ក្រោមអំណាចនិងការត្រួតត្រាពិតប្រាកដទៅតាមករណីនីមួយៗ នៅពេលដែលខ្លួនមិនបានត្រួតត្រាអោយបានត្រឹមត្រូវលើកងកម្លាំងទាំងនោះ ដូចជាករណីដែល :

-មេបញ្ជាការកងទ័ពនោះ ឬជននោះ ទោះជាបានដឹង ឬអាស្រ័យទៅតាមកាលៈទេសៈនៅ ពេលនោះ គួរបានដឹងថាកងកម្លាំងក្រោមបង្គាប់ខ្លួនកំពុងតែប្រព្រឹត្ត ឬប្រុងនឹងប្រព្រឹត្តបទល្មើសទាំងនេះ ។

-និងករណីដែលមេបញ្ជាការកងទ័ព ឬជននោះ ខកខានមិនបាន ចាត់វិធានការណ៍ចាំបាច់និងសមហេតុផល នៅក្នុងក្របខ័ណ្ឌនៃអំណាចរបស់ខ្លួនដើម្បីទប់ស្កាត់ ឬបង្ក្រាបការប្រព្រឹត្តរបស់កងកម្លាំងទាំងនោះ ឬ ដើម្បីប្រគល់បញ្ហានោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត និង នាំយកមកជំនុំជំរះ ។

មាត្រា កម ២១៥១-២ : ការទទួលខុសត្រូវខាង ព្រហ្មទណ្ឌ របស់ថ្នាក់ លើខាងស៊ីវិល

ថ្នាក់លើខាងស៊ីវិល ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលបានប្រព្រឹត្តដោយថ្នាក់ក្រោម ដែលស្ថិតនៅក្រោមអំណាច និងការត្រួតត្រាមានប្រសិទ្ធភាព របស់ខ្លួន នៅពេលដែលខ្លួនមិនបានធ្វើការត្រួតត្រាអោយបានត្រឹមត្រូវលើថ្នាក់ក្រោម នៅក្នុងករណីដែល :

ថ្នាក់លើបានដឹងថា ថ្នាក់ក្រោមប្រព្រឹត្ត ឬប្រុងនឹងប្រព្រឹត្តបទល្មើសទាំងនេះ ឬមិនបានអើពើ ដោយចេតនាចំពោះព័ត៌មានដែលបង្ហាញយ៉ាងច្បាស់ ។

បទល្មើសទាំងនេះ ទាក់ទងនឹងសកម្មភាពទាំងឡាយ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវ និង ការត្រួតពិនិត្យយ៉ាងពិតប្រាកដរបស់ខ្លួន ។

ថ្នាក់លើខាងស៊ីវិល មិនបានចាត់វិធានការណ៍ ចាំបាច់និងសមហេតុផល នៅក្នុងក្របខ័ណ្ឌនៃអំណាចរបស់ខ្លួនដើម្បីទប់ស្កាត់ ឬបង្ក្រាបការប្រព្រឹត្តរបស់ថ្នាក់ក្រោម ឬដើម្បីប្រគល់បញ្ហា ទៅអោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត និងនាំយកមកជំនុំជម្រះ" ។

# ជំពូក៤ : ភាពគ្មានអាជ្ញាយុកាលនៃបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម : មាត្រា ២៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម

## សេចក្តីផ្តើម

នីតិអន្តរជាតិមិនបានទទួលស្គាល់អាជ្ញាយុកាល ចំពោះបទឧក្រិដ្ឋអន្តរជាតិទេ។ ជាលទ្ធផលនៅក្នុងស្មាដៃរបស់ខ្លួន នៃការដាក់បញ្ចូលទៅក្នុងច្បាប់ ក្នុងស្រុកនៃកាតព្វកិច្ចអន្តរជាតិ រដ្ឋត្រូវគោរពតាមរបបគតិយុត្តិដដែល។

នៅក្នុងនីតិអន្តរជាតិ គោលការណ៍នៃភាពគ្មានអាជ្ញាយុកាលរបស់ឧក្រិដ្ឋកម្មសង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទល្មើសប្រល័យពូជសាសន៍ ត្រូវបានប្រកាសជាផ្លូវការនៅគ្រាដំបូងដោយអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីភាពគ្មាន អាជ្ញាយុកាលរបស់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានអនុម័តនៅថ្ងៃទី ២៦ វិច្ឆិកា ១៩៦៨ ដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចរបស់ខ្លួនលេខ ២៣៩១ (XXIII) ចុះថ្ងៃទី ២៦ វិច្ឆិកា ១៩៦៨ និងចូលជាធរមាននៅថ្ងៃទី ១១ វិច្ឆិកា ១៩៧0 និងដោយលក្ខន្តិកៈ ទីក្រុងរ៉ូម នៅក្នុង មាត្រា ២៩។

### ក. អនុសញ្ញារបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៦ វិច្ឆិកា ១៩៦៨

#### ១- ការអធិប្បាយអំពីអនុសញ្ញា

មាត្រា ១ របស់អនុសញ្ញា បានចែងដូចតទៅ :

"***មាត្រា១*** បទល្មើសខាងក្រោមនេះ សុទ្ធតែគ្មានអាជ្ញាយុកាល *ដោយមិនគិតពីកាលបរិច្ឆេទនៃការប្រព្រឹត្ត* :

***ក.*** ឧក្រិដ្ឋកម្មសង្គ្រាម ដូចដែលវាត្រូវបានកំណត់ និយមន័យនៅក្នុងលក្ខន្តិកៈតុលាការយោធាអន្តរជាតិនរឹមប៊ែរ ចុះថ្ងៃទី ៨ សីហា ១៩៤៥ និងអះអាងបញ្ជាក់ដោយសេចក្តីសំរេចលេខ ៣ (I) និង ៩៥ (I) នៃមហាសន្និបាតរបស់អង្គការ សហប្រជាជាតិ ចុះថ្ងៃ ទី ១៣ កុម្ភៈ ១៩៤៦ និង ១១ ធ្នូ ១៩៤៦ ជាពិសេស "បទល្មើសធ្ងន់ធ្ងរ" ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ សីហា ១៩៤៩ ដើម្បីការពារជនរងគ្រោះដោយសារសង្គ្រាម។

***ខ.*** ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទោះបីជាវាត្រូវបានប្រព្រឹត្តនៅពេលមានសង្គ្រាម ឬ នៅពេលមានសន្តិភាពក៏ដោយ ដូចដែលវាត្រូវបានចែងនៅក្នុងលក្ខន្តិកៈតុលាការយោធាអន្តរជាតិនរឹមប៊ែរ ចុះថ្ងៃទី ៨ សីហា ១៩៤៥ និងអះអាង បញ្ជាក់ដោយសេចក្តីសំរេចលេខ ៣ (I) និង ៩៥ (I) នៃមហា សន្និបាតរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃ ទី ១៣ កុម្ភៈ ១៩៤៦ និង ១១ ធ្នូ ១៩៤៦ ការដណ្តើមយក ដោយការវាយប្រហារប្រដាប់អាវុធ ឬការកាន់កាប់ និងអំពើអមនុស្សធម៌ទាំងឡាយ ដែលកើតចេញពីនយោបាយរើសអើង (la politique d'*apartheid*) ព្រមទាំងបទល្មើសប្រល័យពូជសាសន៍ ដូចដែលវា បានអោយនិយមន័យ

នៅក្នុង អនុសញ្ញាឆ្នាំ ១៩៤៨ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសប្រល័យពូជសាសន៍ ទោះបីជាអំពើទាំងនេះ មិននាំអោយមានការរំលោភបំពានច្បាប់ក្នុងស្រុករបស់ប្រទេសដែលជាកន្លែងដែលវាត្រូវបានប្រព្រឹត្តក៏ដោយ" *(អក្សរទ្រេតត្រូវបានបន្ថែម)*។

ដោយបានចែងយ៉ាងដូច្នេះថា ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទល្មើសប្រល័យពូជសាសន៍ សុទ្ធតែគ្មានអាជ្ញាយុកាល *"ដោយមិនគិតពីកាលបរិច្ឆេទ នៃការប្រព្រឹត្តរបស់វា"* អនុសញ្ញាចុះថ្ងៃទី ២៦ វិច្ឆិកា ១៩៦៨ ប្រកាសពីអានុភាពប្រតិសកម្មនៃបទបញ្ញត្តិរបស់វា។

## ២- តំណែរបស់អនុសញ្ញានៅក្នុងច្បាប់ខ្មែរ

ប្រទេសកម្ពុជា មិនបានផ្តល់សច្ចាប័នដល់អនុសញ្ញារបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៦ វិច្ឆិកា ១៩៦៨ ទេ។ អនុសញ្ញានេះបានចូលជាធរមាន នៅថ្ងៃទី ១១ វិច្ឆិកា ១៩៧០ ហើយរហូតមកដល់សព្វថ្ងៃនេះ គឺ មានប្រទេសជាសមាជិកចំនួន៤៣ ដែលក្នុងនោះ គេមិនឃើញមានប្រទេសណាមួយ ដែលជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិនោះទេ លើកលែងតែសហព័ន្ធរុស្ស៊ី។

ផ្ទុយទៅវិញ នៅគ្រប់ករណីទាំងអស់ ភាពជោគជ័យតិចតួចរបស់អនុសញ្ញានេះមិនបានផ្តល់ចំលើយជាអវិជ្ជមានទាំងស្រុង ចំពោះបញ្ហាដែលចោទថា តើភាពគ្មានអាជ្ញាយុកាលនាំអោយមានជាបទដ្ឋាន ទំនៀមទំលាប់អន្តរជាតិ ឬក៏អត់នោះទេ។

## ៣- ភាពគ្មានអាជ្ញាយុកាល ជាបទដ្ឋានទំនៀមទំលាប់អន្តរជាតិ ?

ភាពស្ងៀមស្ងាត់នៃច្បាប់អន្តរជាតិធំៗ ដែលបានអនុម័តនៅក្រោយសង្គ្រាមលោក ចំពោះបញ្ហានេះ បាននាំអោយមានការបកស្រាយផ្សេងៗ។ វាបានធ្វើអោយមានការគិតផងដែរថាមានការយល់ដឹងយ៉ាងច្បាស់នៅលើឆាក នៃសហគមន៍អន្តរជាតិ នូវភាពគ្មានអាជ្ញាយុកាលរបស់បទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ក្នុងឋានៈជាបទដ្ឋានទំនៀមទំលាប់អន្តរជាតិ។

ទាំងលក្ខន្តិកៈតុលាការយោធានីរមប៊ែរ ទាំងលក្ខន្តិកៈយោធាតូក្យូ សុទ្ធតែមិនបានចែងអំពីបញ្ហានេះទេ។ អនុសញ្ញាដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ ខ្លួនឯងក៏មិនមានចែងអ្វីទាល់តែសោះ ចំពោះបញ្ហានេះ។

មានតែច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ អាល្លឺម៉ង់ ចុះថ្ងៃទី ២០ ធ្នូ ១៩៤៥ ប៉ុណ្ណោះ ដែលបានលើកឡើងពីបញ្ហានេះ។ មាត្រា ២ កថាខ័ណ្ឌ ៥ របស់ច្បាប់នេះ បានចែងថា បុគ្គលទាំងឡាយដែលត្រូវបានគេចោទប្រកាន់ ពីបទឧក្រិដ្ឋណាមួយក្នុងចំណោមបទឧក្រិដ្ឋទាំងឡាយ ដែលបានចែងដោយបញ្ញត្តិច្បាប់មិនអាចទទួលយកផល

ប្រយោជន៍ពី អាជ្ញាយុកាលបានទេ ចំពោះអំឡុងពេលពីថ្ងៃទី ៣០ មករា ១៩៣៣ រហូតដល់ថ្ងៃទី ១ កក្កដា ១៩៤៥ ប៉ុន្តែ គួរកត់សំគាល់ថា ខ្លឹមសាររបស់បទបញ្ញត្តិនេះ មានការពិភាក្សាគ្នាយ៉ាងខ្លាំងក្លា។

អនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ សីហា ១៩៤៩ ព្រមទាំងពិធីសារបន្ថែមទាំងពីររបស់វា ចុះថ្ងៃទី ៨ មិថុនា ១៩៧៧ បានចែងអំពីការបង្ក្រាបឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែ មិនបានបញ្ជាក់អំពីអាជ្ញាយុកាលរបស់វាទេ។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សំរាប់អតីតយូហ្គោស្លាវី និងសំរាប់រ៉ូវ៉ាន់ដាមិនមានចែងបទបញ្ញត្តិណាមួយ ដែលទាក់ទងនឹងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោសទេ។

ដូច្នេះ នីតិអន្តរជាតិបានចែងពីការជំនុំជម្រះ និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាម ឧក្រិដ្ឋជនប្រល័យពូជសាសន៍ និង ឧក្រិដ្ឋជនប្រឆាំងនឹងមនុស្សជាតិដោយ មិនមានលើកឡើងនូវបញ្ហាអាជ្ញាយុកាល។

## ខ. ស្ថានភាពរបស់ច្បាប់កម្ពុជា

យើងបានឃើញពីខាងដើមរួចមកហើយថា នីតិវិជ្ជមានរបស់ខ្មែរមិនបានចែងអំពី ការបង្ក្រាបបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមទេ។

ផ្ទុយទៅវិញ ច្បាប់វិសោធនកម្មឆ្នាំ ២០០១ ស្តីអំពីការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម បញ្ញត្តិនូវភាពគ្មានអាជ្ញាយុកាលរបស់បទល្មើសប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ដូចគ្នានេះដែរ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី តាមរយៈមាត្រា កម ២១១១-១ ដល់ កម ២១៣១-៦ បានអោយនិយមន័យ និងបង្ក្រាបឧក្រិដ្ឋកម្មទាំងអស់នេះ ហើយសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងមាត្រា កម ១២១-៨ បានចែងថា :

*"បទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មិនមានអាជ្ញាយុ កាលកំណត់ទេ"*។

---

**អេហ្វ អ៊ី ដេ អាស សន្និដ្ឋាន :**

**ថាជាការមួយដែលមានលក្ខណៈវិជ្ជមាន ចំពោះ បញ្ហាដែលថា សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងមាត្រា កម១២១-៨បានចែងថា បទល្មើសប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមមិនមានអាជ្ញាយុកាលកំណត់ និងជួយជំរុញអោយមានការអនុម័តមាត្រានេះ ដោយអង្គនីតិបញ្ញត្តិខ្មែរ។**

---

# ជំពូក៥ : មូលហេតុនៃការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ : មាត្រា ៣១ នៃលក្ខន្តិកៈទីក្រុងរ៉ូម

## ក. ការអធិប្បាយអំពីមាត្រា ៣១ និងការបកស្រាយរិះគន់

មាត្រា ៣១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ធ្លាប់ជាកម្មវត្ថុនៃការចរចារគ្នាយ៉ាងខ្លាំង ដោយសារឆន្ទៈរបស់រដ្ឋទាំងឡាយចង់ធ្វើយ៉ាងណាអោយវាមានលក្ខណៈលំអិតតាមតែអាចធ្វើទៅបាន ចំពោះមូលហេតុនៃការរួចខ្លួនពិការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។ មាត្រានេះបានចែងដូចតទៅ :

**"មាត្រា ៣១ : មូលហេតុនៃការរួចខ្លួនពីការ ទទួលខុសត្រូវខាងព្រហ្មទណ្ឌ**

១. ក្រៅពីមូលហេតុផ្សេងៗទៀតនៃការរួចខ្លួនពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលមានចែងក្នុងលក្ខន្តិកៈនេះ ជនម្នាក់មិនត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ប្រសិនបើនៅខណៈពេលប្រព្រឹត្ត :

ក. ជននោះមានជំងឺវិបត្តិស្មារតី ឬមានការចុះអន់ ខ្សោយខាងស្មារតី ដែលធ្វើអោយជននោះមិនមានការយល់ដឹង ពីភាពខុសច្បាប់ ឬប្រភេទនៃការ ប្រព្រឹត្តរបស់ខ្លួន ឬមិនអាចគ្រប់គ្រងការប្រព្រឹត្ត របស់ខ្លួន អោយស្របតាមការតម្រូវរបស់ច្បាប់បាន។

ខ. ជននោះស្ថិតក្នុងស្ថានភាពស្រវឹង ដែលធ្វើអោយ ជននោះមិនមានការយល់ដឹងលើភាពខុសច្បាប់ ឬ ប្រភេទនៃការប្រព្រឹត្តរបស់ខ្លួន ឬមិនអាចគ្រប់គ្រង ការប្រព្រឹត្តរបស់ខ្លួន អោយស្របតាមការតម្រូវ របស់ច្បាប់បាន លើកលែងតែជននោះបានស្រវឹង ដោយឆន្ទៈ នៅក្នុងកាលៈទេសៈដែលជននោះបានដឹង ដោយការស្រវឹងថា គេអាចធ្វើអោយការប្រព្រឹត្ត របស់ខ្លួនក្លាយជាបទឧក្រិដ្ឋណាមួយ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ហើយគេមិនយកចិត្តទុកដាក់នឹងហានិភ័យនេះទេ។

គ. ជនណាដែលធ្វើអំពើសមហេតុផល ដើម្បីការពារខ្លួន ឬការពារជនម្នាក់ទៀត ឬនៅក្នុងករណីឧក្រិដ្ឋកម្មសង្គ្រាម ការពារទ្រព្យដែល មានលក្ខណៈចាំបាច់ សំរាប់ការចិញ្ចឹមជីវិតរបស់ជននោះ ឬរបស់ជនដទៃទៀត ឬទ្រព្យដែលចាំបាច់ សំរាប់ការបំពេញបេសកកម្មយោធា ប្រឆាំងនឹងការប្រើប្រាស់កងកំលាំងខុសច្បាប់ និងដែលប្រុងនឹងកើតមានឡើងដោយមានលក្ខណៈសមាមាត្រទៅនឹង កំរិតនៃគ្រោះថ្នាក់ចំពោះ ជននោះ ឬចំពោះជនដទៃទៀត ឬចំពោះទ្រព្យដែលបានការពារនោះ។ ការដែលជននោះបានចូលរួមនៅ ក្នុងប្រតិបត្តិការការពារ ដែលបានធ្វើឡើងដោយកងកំលាំងប្រដាប់អាវុធ តែមួយគត់មិនអាចធ្វើជាមូលហេតុនៃការរួចខ្លួន ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌបានឡើយ នៅក្នុងអត្ថន័យរបស់វាក្យខ័ណ្ឌនេះ។

ឃ. ការប្រព្រឹត្តដែលតុលាការចោទថាជាបទល្មើសនោះ ត្រូវបានធ្វើឡើងក្រោមការបង្ខិតបង្ខំ ឬការគំរាមកំហែងដល់អាយុជីវិតដែល ប្រុងនឹងកើតមានឡើង ឬ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរនិងជាបន្តបន្ទាប់ ឬ ប្រុងនឹងកើតមានឡើងចំពោះបូរណភាពរូបរាងកាយរបស់ខ្លួនផ្ទាល់ក្តី ឬ របស់ជនដទៃក្តី ហើយប្រសិនបើជននោះបានប្រព្រឹត្តក្នុងស្ថានភាពចាំបាច់ និងមានលក្ខណៈសមហេតុផល ដើម្បីបញ្ចៀសការគំរាមកំហែងនេះនៅក្នុងលក្ខខណ្ឌដែលថាជននោះមិនមានចេតនាបង្កអោយមានព្យសនកម្មធំជាងការដែលខ្លួនចង់ ចៀសវាងនោះទេ។ ការគំរាមកំហែងនេះអាច :

i). បានធ្វើឡើងដោយជនផ្សេងទៀត

ii). បានបង្កឡើង ដោយកាលៈទេសៈផ្សេងៗ ទៀត ក្រៅពីឆន្ទៈរបស់ខ្លួន។

២. តុលាការត្រូវប្រកាសពីបញ្ហា ថាតើមូលហេតុនៃ ការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងនៅក្នុង លក្ខន្តិកៈនេះ អាចអនុវត្តបានដែរ ឬ អត់ចំពោះករណីដែលបានប្តឹងមកខ្លួន។

៣. នៅពេលជំនុំជំរះ តុលាការអាចពិចារណាទៅលើ មូលហេតុណាមួយ នៃការរួចពីការទទួលខុសត្រូវ ក្រៅពីមូលហេតុទាំងឡាយ ដែលមានចែងនៅក្នុង កថាខ័ណ្ឌ ១ ប្រសិនបើមូលហេតុនេះ មានប្រភព ចេញមកពីច្បាប់ដែលអាចអនុវត្តបានដែលមានចែង នៅក្នុងមាត្រា ២១។ នីតិវិធីទាក់ទងទៅនឹងការ ពិចារណាលើមូលហេតុនេះ មានចែងនៅក្នុងវិធាននីតិវិធី និងភស្តុ តាង"។

វាក្យខ័ណ្ឌពីរខាងដើម គឺ *ក.* និង *ខ.* នៃកថាខ័ណ្ឌទី ១ បានចែងពីជំងឺ ស្ថានភាពស្រវឹង និង ការចុះអន់ថយខាងស្មារតី ជាមូលហេតុនៃការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

វាក្យខ័ណ្ឌ *គ.* បានកំណត់និយមន័យនៃការការពារជាធម្មានុរូប ភាពអាសន្ន និងស្ថានភាពចាំបាច់ដែលយើងឃើញមានទាំងនៅក្នុងនីតិអន្តរជាតិ ទាំងនៅក្នុងបទដ្ឋានគតិយុត្តិជាតិហើយដែលការអនុវត្តរបស់វាគួរអោយកត់សម្គាល់ រាប់តាំងពីនៅក្នុងបទដ្ឋានគតិយុត្តិអន្តរជាតិបុរាណ រហូតដល់បទដ្ឋានគតិយុត្តជាតិ និង ជាពិសេសតាមរយៈការអោយនិយមន័យផ្សេងៗគ្នា ចំពោះបញ្ហាទាំងនេះ។

លក្ខណៈពិសេសមួយទៀតរបស់បទបញ្ញត្តិនេះ ស្ថិតនៅក្នុងការកំណត់ភាពចាំបាច់ខាងយោធា ជាធាតុផ្សំមួយ ដែលនាំអោយ មានការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។ មូលហេតុនៃការរួចផុតពីការទទួលខុសត្រូវនេះ ត្រូវបានលើកឡើង នៅពេលតាក់តែងលក្ខន្តិកៈទីក្រុងរ៉ូម ដោយអ្នកតំណាងក្រសួងការពារជាតិ របស់ប្រតិភូផ្សេងៗ ជាច្រើន។ ប្រសិនបើ នៅក្នុងច្បាប់ជាតិភាគច្រើន ការការពារធម្មានុរូប ភាពអាសន្ន និងស្ថានភាពចាំបាច់ សុទ្ធតែ ជាមូលហេតុនៃការមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋនៃនីតិរួម វាហាក់ដូចជាមានលក្ខណៈផ្ទុយទៅនឹងភាពសមហេតុផល ដែលសន្និដ្ឋានថា បទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម អាចត្រូវបានប្រព្រឹត្តដើម្បីការពារខ្លួន ឬ ការពារអ្នកដទៃ។ គំនិត ដែលទាមទារអោយមានភាពសមាមាត្រ នៃការឆ្លើយតបទៅនឹងការគំរាមកំហែង មិនអាចធ្វើទៅបាន ប្រកបដោយភាពសមហេតុផលនោះទេ ចំពោះបទឧក្រិដ្ឋទាំងនេះ។

ចំពោះបញ្ហានេះ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម គណៈកម្មការនីតិអន្តរជាតិបានក្រើនរំលឹកថា *"ការលើកឡើងនូវភាព ចាំបាច់ខាងយោធា ឬភាពចាំបាច់នៃសង្គ្រាម ដើម្បីអោយរួចផុតពីការគោរពកាតព្វកិច្ច ដែលមានអោយច្បាស់ជាងនេះទៅទៀត ដើម្បីចៀសវាងកុំអោយភាពចាំបាច់នៃសង្គ្រាម បង្កអោយមានការឈឺចាប់ ដែលយើងចង់លុបចោលជាស្ថាពរនោះជាការមួយមិនច្បាស់លាស់"*[៨២]។ យើងគួរតែគាំទ្រសេចក្តីប្រកាស ដែលបានបង្កើតឡើងដោយ

៨២. គណៈកម្មការនីតិអន្តរជាតិ, *សៀវភៅកំណត់ប្រចាំឆ្នាំរបស់ គណៈកម្មការនីតិអន្តរជាតិ,* ឆ្នាំ ១៩៨០.II, ផ្នែកទី ២ ទំព័រ ៤៥។

បែលហ្ស៊ិកចំពោះបញ្ហានេះ នៅក្នុងខណៈដែលគេផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូម ហើយដែលសេចក្តីប្រកាសនេះមានខ្លឹមសារដូចតទៅ : *"ដោយយោងទៅតាមមាត្រា ២១.១.ខ. នៃលក្ខន្តិកៈដោយយោងទៅលើវិធានច្បាប់មនុស្សធម៌អន្តរជាតិ ដែលវាមិនអាចកែប្រែបានទេ រដ្ឋាភិបាលបែលហ្ស៊ិកយល់ឃើញថា មាត្រា ៣១.១.គ. នៃលក្ខន្តិកៈអាចត្រូវបានអនុវត្ត ឬត្រូវបានបកស្រាយស្របតាមវិធានទាំងនេះ"*។

ចំណែកឯវាក្យខ័ណ្ឌ *ឃ.* កថាខ័ណ្ឌទី ១ នៃមាត្រា ៣១ ត្រូវបានតាក់តែងឡើង ដោយមានលក្ខណៈលាយឡំចូលគ្នា រវាងទស្សនៈព្រហ្មទណ្ឌថ្នាក់ជាតិនៃការបង្ខិតបង្ខំ ការគំរាមកំហែង ការការពារធម្មានុរូប និងស្ថានភាពចាំបាច់។

ម៉្យាងទៀត ដោយចាត់ទុកការបង្ខិតបង្ខំជាមូលហេតុនៃការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងមិនមែនជាមូលហេតុនៃ ការបន្ធូរបន្ថយទោសនោះទេ លក្ខន្តិកៈទីក្រុងរ៉ូមទំនងជាអ្នកការពារសិទ្ធិក្នុងការការពារខ្លួន តាមផ្លូវតុលាការ ជាងតុលាការព្រហ្មទណ្ឌអន្តរជាតិ សំរាប់រវ៉ាន់ដា និងអតីតយូហ្គោស្លាវី[៨៣] ។

ផ្ទុយទៅវិញ ដោយយោងទៅលើប្រភេទរបស់វា ដំណោះស្រាយនៃយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិហាក់ដូចជាមាន លក្ខណៈត្រូវគ្នាជាមួយនឹងបទឧក្រិដ្ឋ ដែលមានចែងដោយលក្ខន្តិកៈទីក្រុងរ៉ូម។

## ខ. ស្ថានភាពច្បាប់កម្ពុជា

បទបញ្ញត្តិដែលទាក់ទងជាសំខាន់ទៅនឹងបញ្ហានេះមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ ពិសេសនៅក្នុងមាត្រា ៩៦ ដល់ ៩៨ ដែលទាក់ទងទៅនឹងការបង្ខិតបង្ខំ និងស្ថានភាពចាំបាច់ និងនៅក្នុងមាត្រា ១០១ ដល់ ១០៤ ដែលទាក់ទង នឹងការការពារធម្មានុរូប។

មាត្រា ៩៦ និង ៩៧ បានចែងដូចតទៅ :

"មាត្រា ៩៦ - កាលបើមានភស្តុតាងថា *មានកម្លាំងអ្វី មួយបានបង្ខំជនណាម្នាក់ អោយប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលមិនអាចទប់ទល់នឹងកម្លាំង នោះបាន* ក៏ប្រព្រឹត្តបទល្មើសនោះទៅ។ ជនអ្នកប្រព្រឹត្តបទល្មើសនេះ មិនត្រូវអោយទទួលខុសចំពោះអំពើដែលខ្លួនប្រព្រឹត្តនោះឡើយ។

មាត្រា ៩៧ - កម្លាំងដែលមកបង្ខំនោះគឺអ្វី ? - កម្លាំងនោះ គឺគ្រោះថ្នាក់ដែលបណ្តាលអោយមាន អាសន្នយ៉ាងធំបំផុត។ ពាក្យថាអាសន្នយ៉ាងធំបំផុត បានន័យថា គ្រោះថ្នាក់ យ៉ាងធំបំផុត នឹងត្រូវធ្លាក់មកលើអ្នកណាម្នាក់ ក្នុងពេលជាបន្ទាន់ ក្រៃពេក *មិនអាចនឹងចៀសបានដោយងាយ ហើយអ្នកមានគ្រោះនោះនឹងដោះខ្លួន អោយរួចពីគ្រោះនោះបាន ក៏លុះតែបាន ប្រព្រឹត្តបទ*

៨៣. រឿងក្តី អែរដឺម៉ូវិក (Affaire Erdemovic) តុលាការព្រហ្ម ទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី សភាទី II ចុះថ្ងៃទី ៥ មិនា ១៩៩៨ : *"សាលាដំបូងបានផ្តល់អានុភាពដល់សាលដីកា របស់សាលាឧទ្ធរណ៍ ដែលបានសំរេចថា* "ការបង្ខិតបង្ខំ មិនមែនជាអំណះអំណាងការពារខ្លួន ដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់អោយមានការរួចខ្លួនទាំងស្រុងរបស់ទាហានមួយរូប ដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង/ឬ ឧក្រិដ្ឋកម្មសង្គ្រាមដែលនាំអោយមានការសំលាប់មនុស្សដែល មិនមានទោសភ័យនោះទេ"។ *ការបង្ខិតបង្ខំអាចចូលធ្វើអន្តរា គមន៏តែក្នុងឋានៈជាស្ថានសំរាលទោសប៉ុណ្ណោះ"* (កថាខ័ណ្ឌ ១៧)។

*ល្មើសណាមួយទើបរួច* ម្យ៉ាងទៀតគ្រោះថ្នាក់នោះ កាលកើតមក ក៏មិនមែនកើតមកពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះ ដែរ និងមិនមែនខ្លួនចារីនោះជាអ្នកបង្កបង្កើត បណ្តាលអោយមានគ្រោះថ្នាក់នោះដែរ" (អក្សរទ្រេត ត្រូវបានបន្ថែម)។

និយមន័យខ្មែរនៃការបង្ខិតបង្ខំ ឬ ស្ថានភាពចាំបាច់ដែលក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ មិនបានធ្វើការបែងចែកអោយបានច្បាស់ រវាងទស្សនៈទាំងពីរនេះទេ គឺ មានលក្ខណៈទូលំទូលាយជាង និយមន័យដែលបាន ផ្តល់អោយដោយលក្ខន្តិកៈទីក្រុងរ៉ូម។ ការនេះធ្វើអោយនិយមន័យនៃការបង្ខិតបង្ខំ និងស្ថានភាពចាំបាច់ ហាក់ដូចជាមិនសក្តិសមជាមូលហេតុនៃការរួចផុតពីការ ទទួលខុសត្រូវខាងព្រហ្មទណ្ឌក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។

តាមការពិត វាគ្រាន់តែអាចជាមូលហេតុនៃការកាត់បន្ថយទោសប៉ុណ្ណោះ។ វាមិនអាចជាចំលើយ ដែលអាចទទួលយកបានចំពោះការប្រព្រឹត្តបទល្មើសធំៗ ឬបទល្មើសសង្គ្រាម។

មាត្រា ១០១ ដល់ ១០៣ បានចែងដូចតទៅ ៖

"មាត្រា ១០១ - កាលណាបើការចាំបាច់តម្រូវ អោយសម្លាប់ កាប់ ឬវាយ ជនណាម្នាក់ ដើម្បីការពារខ្លួនឯង ឬខ្លួនអ្នកដទៃ ដោយធម្មានុរូប នោះ អំពើសម្លាប់ កាប់ វាយនេះ មិនចូលជាឧក្រិដ្ឋកម្ម ឬទោសកម្មទេ។

មាត្រា ១០២ - កិច្ចការពារខ្លួនឯង ឬការពារអ្នក ដទៃ នឹងទុកជាធម្មានុរូបបាន លុះតែមានការរំលោភ ពីគេមកមុន គឺថាគេវាយកាប់ ដោយអយុត្តិធម៌ជាមុន។ កិច្ចការពារនេះត្រូវធ្វើអោយតំណាលនឹងការរំលោភ *ហើយលៃអោយល្មមគ្រប់គ្រាន់* នឹងចៀសវាងអន្តរាយបានតែប៉ុណ្ណោះ។

មាត្រា ១០៣ - បើអំពើ ដែលបានធ្វើក្នុងកិច្ចការពារ ជាធម្មានុរូបនេះ *បណ្តាលអោយមានអន្តរាយដល់ អ្នករំលោកហួសប្រមាណពេក* នោះអ្នកសម្លាប់ កាប់ វាយ ដើម្បីកិច្ចការពារនោះ នៅតែត្រូវទទួលខុស ក្នុងបទព្រហ្មទណ្ឌខ្លះដែរ ក៏ប៉ុន្តែត្រង់ខនេះ ចៅក្រមត្រូវថ្លឹងមើល តាមការណ៍គួរផង" (អក្សរទ្រេតត្រូវបានបន្ថែម)។

បើនិយាយអោយចំនិយមន័យនៃការពារធម្មានុរូបដែលអោយដោយ ក្រមព្រហ្មទណ្ឌខ្មែរមិនបាននិយាយពីភាពចាំបាច់ខាងយោធាដែលមានចែងនៅក្នុងមាត្រា ៣១ កថាខ័ណ្ឌ ១ *គ.* នៃលក្ខន្តិកៈទីក្រុងរ៉ូមទេ។

ដូច្នេះ និយមន័យនេះមានលក្ខណៈ ចង្អៀតជាងនិយមន័យដែលបានកំណត់ដោយលក្ខន្តិកៈទីក្រុងរ៉ូម។ ដូចដែលយើងបានលើកឡើង ពីខាងលើរួចមកហើយ វាមិនមានភាពត្រឹមត្រូវទេ ដែលធ្វើការបកស្រាយខ្លឹមសារ មាត្រា ១០១ និង ១០២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ ចំពោះការអនុវត្តន៏នូវការការពារជាធម្មានុរូបថាជាមូលហេតុនៃការ រួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ ឧក្រិដ្ឋកម្ម សង្គ្រាម។

តាមការពិត ដោយយោងទៅលើប្រភេទនៃបទល្មើសដែលបានប្រព្រឹត្តតប វាតែងតែមាននូវ *"ផលវិបាក ហួសប្រមាណ"* ដែលមិនអាចចៀសបាន ហើយការឆ្លើយតបទៅនឹងការឈ្លានពាននឹងបង្កអោយមានជាចាំបាច់ នូវអំពើមួយ *"ដែលមិនមានលក្ខណៈចាំបាច់និងគ្រប់គ្រាន់ល្មម"*។

នៅទីបញ្ចប់ យើងគួរតែកត់សំគាល់ថា សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី បានយកលំនាំតាមស្ទើរតែទាំងស្រុង នូវនិយមន័យ នៃការបង្ខិតបង្ខំ ស្ថានភាព ចាំបាច់ និងការការពារធម្មានុរូប ដែលបានកំណត់ ដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៥ ប៉ុន្តែ បានធ្វើការបែងចែកយ៉ាងច្បាស់នូវស្ថានភាពចាំបាច់ពីការបង្ខិតបង្ខំ។ មាត្រា កម ១១២១-៨ នៃ សេចក្តីព្រាង ទាក់ទងទៅនឹងការការពារធម្មានុរូប មាត្រា កម ១១២១-១០ បានអោយនិយមន័យស្ថានភាពចាំបាច់ និង មាត្រា កម ១១២១-១១ ស្តីពីការបង្ខិតបង្ខំ។

ដូច្នេះនិយមន័យរបស់មូលហេតុទាំងឡាយនៃការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដូចដែលមានចែងនៅក្នុងក្រម ព្រហ្មទណ្ឌឆ្នាំ ១៩៥៥ គឺនៅតែមានលក្ខណៈទូលាយជាង និយមន័យដែលបានកំណត់ ដោយ លក្ខន្តិកៈទីក្រុងរ៉ូម ប៉ុន្តែ ផ្ទុយទៅវិញ មិនបានដោះស្រាយនូវបញ្ហាដែលយើងបានលើកឡើង ដែលទាក់ទងទៅនឹងបទបញ្ញត្តិនៃក្រម ដែលមានជាធរមាន។ នៅក្នុងឱកាសនៃកំណែទំរង់ដ៏ខ្លាំងក្លាលើវិស័យច្បាប់ព្រហ្មទណ្ឌខ្មែរ យើងគួរតែអនុម័តយកបទបញ្ញត្តិទាំងឡាយណា ដែលល្អសំរាប់ដោះស្រាយបញ្ហានេះ នៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**អោយបញ្ចូលទៅក្នុង ជំពូកទី ២ មាតិកាទី ២ គន្ថីទី ១ ភាគទី ១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី នូវ មាត្រា កម ១១២១-១០ និង កម ១១២១-១២ ថ្មី និងមាត្រា កម ១១២១-១៤ ដែលបានចែងយ៉ាងច្បាស់ថា ស្ថានភាពចាំបាច់ ការការពារធម្មានុរូប និង ការបង្ខិតបង្ខំមិនអាចជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ចំពោះ បទល្មើស ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ផ្ទុយទៅវិញ ការបង្ខិតបង្ខំ អាចជាមូលហេតុនៃការបន្ធូរបន្ថយទោស ចំពោះបទឧក្រិដ្ឋទាំងនេះ។**

**ភាគទី ១ ដែលបានស្នើអោយដាក់បញ្ចូលនូវមាត្រា កម ១១២១-១០, កម ១១២១-១២ និង កម ១១២១-១៤ គឺទាក់ទងនឹង "គោលការណ៍ជាមូល ដ្ឋាន" ហើយជំពូកទី ២ ស្តីអំពី "មូលហេតុផ្សេងៗនៃការមិន ទទួលខុសត្រូវ ឬ នៃការបន្ធូរបន្ថយការទទួលខុសត្រូវ"។**

**មាត្រា កម ១១២១-១០ និង កម ១១២១-១២ ថ្មី និង មាត្រា កម ១១២១-១៤ មានចែងដូច តទៅ :**

*"មាត្រា កម ១១២១-១០ : ភាពមិនអាចទទួលយកបាននូវការការពារធម្មានុរូប នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋសង្គ្រាម*

*ការការពារធម្មានុរូប មិនអាចត្រូវបានលើកឡើងបានឡើយ នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។*

*មាត្រា កម ១១២១-១២:ភាពមិនអាចទទួលយកបាននូវស្ថានភាពចាំបាច់នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ស្ថានភាពចាំបាច់មិនអាចត្រូវបានលើកឡើងបានឡើយ នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។*

*មាត្រា កម ១១២១-១៤ : ការប្រព្រឹត្តបទល្មើស ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ក្រោមឥទ្ធិពលនៃកម្លាំង ឬការបង្ខិតបង្ខំ។ កម្លាំង ឬការបង្ខិតបង្ខំ មិនអាចត្រូវបានលើកឡើងបានឡើយ នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។*

*ផ្ទុយទៅវិញ នៅពេលដែលបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានប្រព្រឹត្តនៅក្រោមឥទ្ធិពលនៃកម្លាំង និង ការបង្ខិតបង្ខំ តាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រា កម ១១២១-១៣ តុលាការអាចអនុញ្ញាតិអោយជនជាប់ចោទ ទទួលបាននូវផលប្រយោជន៍ពិស្ថានសំរាលទោស ដោយអនុលោមទៅតាម មាត្រា កម ១២២២-១ និង កម ១២២២-៣" ។*

ជាលទ្ធផល បន្ទាប់ពីបានធ្វើការបញ្ចូលរួច មាត្រា កម ១១២១-១០ ដែលពីដើមមានចំណងជើងថា "ស្ថានភាពចាំបាច់" បានក្លាយជា មាត្រា កម ១១២១-១១។ មាត្រា កម ១១២១-១១ ពីដើម បានក្លាយជាមាត្រា កម ១១២១-១៣។ មាត្រា កម ១១២១-១២ ដែលពីដើមមានចំណងជើងថា "ការមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌ" បានក្លាយជា មាត្រា កម ១១២១-១៥។

# ជំពូក៦ : បញ្ជាថ្នាក់លើ និងសេចក្តីបង្គាប់របស់ច្បាប់ : មាត្រា៣៣នៃលក្ខន្តិកៈទីក្រុងរ៉ូម

## សេចក្តីផ្តើម

មាត្រា ៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូមដែលមានចំណងជើងថា "បញ្ជាថ្នាក់លើ និងសេចក្តីបង្គាប់របស់ច្បាប់ " បានចែងពីស្ថានភាពរបស់អ្នកប្រតិបត្តិដែលបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយក្នុងចំណោមបទឧក្រិដ្ឋទាំងឡាយ ដែលបានកំណត់ដោយលក្ខន្តិកៈដោយគោរពតាមបញ្ជារបស់ថ្នាក់លើ។ ទំនាក់ទំនងខាងឋានានុក្រម ចារិកក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងក្រោមឱវាទដែលត្រូវបានអោយនិយមន័យ ដោយយោងទៅ តាម តុលាការព្រហ្មទណ្ឌអន្តរ ជាតិសំរាប់អតីតយូហ្គោស្លាវី ថាជាការត្រួតត្រាពិតប្រាកដលើអ្នកប្រតិបត្តិ ដោយថ្នាក់លើដែល ជាអ្នកចេញបញ្ជា[៨៤]។ អង្គដែលមានឋានានុក្រមនេះ មិនមែនចាំបាច់តែជាអង្គរបស់រដ្ឋនោះទេ។ លក្ខន្តិកៈទីក្រុងរ៉ូមបានបញ្ជាក់ថា បញ្ជាអាចចេញដោយ "រដ្ឋាភិបាល ឬ ដោយថ្នាក់លើ ជាយោធា ឬជាស៊ីវិល"។ ដូច្នេះ តាមការពិត ឋានានុក្រមអាចត្រូវកំណត់ដោយគ្រប់អង្គទាំងអស់ដែលមានការចាត់តាំងត្រឹមត្រូវ។

### ក. ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់អ្នកប្រតិបត្តិ

ការហាមឃាត់នូវការប្រតិបត្តិបញ្ជាខុសច្បាប់ មានប្រភពចេញពីច្បាប់សង្គ្រាម *(jus in bello)*។ គោលការណ៍នេះ ត្រូវបានលើកឡើងជាលើកដំបូង ដោយលក្ខន្តិកៈតុលាការយោធាអន្តរជាតិនីរឹមប៊ែរ នៅក្នុងមាត្រា ៨ ដែលបានចែងថា : "ការដែលថាជនជាប់ចោទ បានប្រព្រឹត្តដោយធ្វើតាម ការណែនាំរបស់រដ្ឋាភិបាល ឬរបស់ថ្នាក់លើ មិនបានដោះលែងជននោះ អោយរួចផុតពីការទទួលខុសត្រូវទេ ប៉ុន្តែអាចចាត់ទុកថាជាមូលហេតុនៃការបន្ធូរបន្ថយទោស ប្រសិនបើតុលាការសំរេចថា វាជាការមួយដែលមានលក្ខណៈត្រឹមត្រូវតាមយុត្តិធម៌"[៨៥]។ គោលការណ៍នីរឹមប៊ែរ មានឥទ្ធិពលផ្ទាល់ ទៅលើការតាក់តែងលក្ខន្តិកៈដែលបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិវិសាមញ្ញទាំងពីរ។ លក្ខន្តិកៈទាំងនេះបានលើកឡើងនូវគោលការណ៍នៃការទទួលខុសត្រូវផ្ទាល់ខ្លួនខាងព្រហ្មទណ្ឌ និងបានចែងពីស្ថានភាពរបស់អ្នកប្រតិបត្តិ។ មាត្រា ៧ កថាខ័ណ្ឌ ៤ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សំរាប់រ៉ូវ៉ាន់ដាបានចែងថា *"ការដែលថា ជនជាប់ចោទម្នាក់បានប្រព្រឹត្ត ដោយអនុវត្តតាមបញ្ជារបស់រដ្ឋាភិបាល ឬ របស់ថ្នាក់លើ មិនបានធ្វើអោយ ជននោះរួចពីការទទួលខុសត្រូវខាង*

---

៨៤. តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី សភាទី I, *ដឺឡាលិក (Delalic), មុយស៊ិក (Mucic), ដឺលិក (Delic), ឡង់ហ្សូ (Landzo)*, IT-96-21-T ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៨។

៨៥. សេចក្តីសំរេចនៃនីរឹមប៊ែរ ទំព័រ ២៣៥ ដល់ ២៣៦ : បទបញ្ញត្តិ របស់មាត្រា ៨ *"មានលក្ខណៈសមស្របទៅនឹងនីតិវិធីរបស់រដ្ឋទាំងឡាយ។ បញ្ជាដែលអោយទាហានម្នាក់សំលាប់ ឬធ្វើទារុណកម្ម ដោយរំលោភបំពានទៅលើនីតិអន្តរជាតិស្តីពីសង្គ្រាម មិនអាចយកមកធ្វើជាមូលហេតុសំអាងថា ត្រឹមត្រូវ ចំពោះអំពើហឹង្សាទាំងនេះបានទេ"*។

*ព្រហ្មទណ្ឌទេ ប៉ុន្តែអាចត្រូវបានចាត់ទុកថាជាមូលហេតុ នៃការបន្ធូរបន្ថយទោសប្រសិនបើតុលាការអន្តរជាតិយល់ឃើញថា វាជាការមួយដែលមានលក្ខណៈត្រឹមត្រូវតាមយុត្តិធម៌"។*

### ខ. ការអធិប្បាយអំពីមាត្រា ៣៣ និងការបកស្រាយរិះគន់

មាត្រា ៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម បានយកលំនាំតាមលក្ខណៈវិនិច្ឆ័យដែលបានបង្កើតឡើងដោយលទ្ធិ (doctrine) និងយុត្តិសាស្ត្ររឹមប៉ែរ ៖ អ្នកប្រតិបត្តិត្រូវឆ្លើយតបទៅនឹងអំពើរបស់ខ្លួន នៅពេលដែលការបញ្ជា ខាងស៊ីវិល ឬខាងយោធា មានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ ហើយជននោះបានដឹងពីភាពខុសច្បាប់នេះ។

ផ្ទុយទៅវិញ មាត្រា ៣៣ កថាខ័ណ្ឌ ១ បានចែងនូវលក្ខខណ្ឌទាំងឡាយដែលអ្នកប្រតិបត្តិ ត្រូវរួចខ្លួនពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។ លក្ខខណ្ឌទាំងនេះត្រូវមានរួមគ្នា ហើយមានទាំងអស់ចំនួន ៣ ៖ នៅពេលដែលអ្នកប្រតិបត្តិ មានកាតព្វកិច្ច តាមផ្លូវច្បាប់ ត្រូវគោរពបញ្ជា (មាត្រា ៣៣ កថា ខ័ណ្ឌ ១ *ក.*) ដែលគេមិនដឹងថា បញ្ជានេះខុសច្បាប់ (មាត្រា ៣៣ កថាខ័ណ្ឌ ១ *ខ.*) ហើយដែលបញ្ជា នេះ មិនមានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ទេ (មាត្រា ៣៣ កថាខ័ណ្ឌ ១ *គ.*) អ្នកប្រតិបត្តិនេះ មិនមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋ ដែលគេបានប្រព្រឹត្តនោះទេ។

កថាខ័ណ្ឌ ២ នៃមាត្រា ៣៣ បានចែងថា ៖

> "បទបញ្ជាអោយប្រព្រឹត្តបទល្មើស ប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺមានលក្ខណៈខុសច្បាប់ យ៉ាងជាក់ច្បាស់"។

បទបញ្ញត្តិនេះ បានបញ្ជាក់ថា នៅក្នុងករណីបទ ល្មើសប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិ បើបទបញ្ជាមានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ អ្នកប្រតិបត្តិត្រូវទទួលខុសត្រូវជាចាំបាច់ ព្រោះថា លក្ខខណ្ឌ មួយក្នុងចំណោមលក្ខខណ្ឌទាំងឡាយនៃការរួចផុតពីការទទួលខុសត្រូវ (លក្ខខណ្ឌដែលមានចែងនៅវាក្យ ខ័ណ្ឌ *គ.* នៃកថាខ័ណ្ឌ ១) មិនត្រូវបានបំពេញ។

នៅចុងបញ្ចប់យើងគួរកត់សំគាល់ថា មាត្រា៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម មិនមានចែងចំពោះឧក្រិដ្ឋកម្មសង្គ្រាមទេ ដែលជាការខ្វះខាតមួយយ៉ាងធ្ងន់ធ្ងរ។ មាត្រានេះមានចែងតែអំពីបទល្មើសប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតែប៉ុណ្ណោះ។

ការមិនមានចែងនេះ បង្ហាញពីការព្រមព្រៀងរវាងទស្សនៈពីរដែលមានលក្ខណៈប្រឆាំងគ្នា នៅពេលតាក់តែងលក្ខន្តិកៈ។ ប្រតិភូសហរដ្ឋអាមេរិកបានព្យាយាមបញ្ចុះបញ្ចូល ប្រតិភូដទៃៗទៀតអំពីអត្ថិភាពនៃបទបញ្ជារបស់ថ្នាក់លើ អោយប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ដែលអាចមិនមានលក្ខណៈខុសច្បាប់យ៉ាងជាក់ច្បាស់ទេ។ ផ្ទុយទៅវិញ ចក្រភព

អង់គ្លេស អាល្លឺម៉ង់ និង នូវែលហ្សេឡង់ បានអះអាងថា នៅគ្រប់ករណីទាំងអស់ បទបញ្ជាថ្នាក់លើទាំងនេះ មិនអាចជាមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌបានទេ ហើយមានតែការបង្ខិតបង្ខំការភាន់ច្រឡំលើអង្គហេតុ និងការភាន់ច្រឡំលើអង្គច្បាប់ប៉ុណ្ណោះ ដែលអាចជាមូលហេតុនៃការរួចពីការទទួលខុសត្រូវ។ ការពន្យល់បកស្រាយរបស់ក្រុមទីពីរមានការឆ្លើយតបយ៉ាងខ្លាំងទៅ នឹង ស្ថានភាពបច្ចុប្បន្នរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

ជាអកុសល ការសំរុះសំរួលនាំអោយឈានទៅដល់ ការអនុម័តទៅលើ ទស្សនៈរបស់សហរដ្ឋអាមេរិក ការណ៏នេះអាចពន្យល់បកស្រាយបាន ដោយការព្រួយបារម្ភរបស់រដ្ឋាភិបាលអាមេរិក នូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ទាហានគេនៅក្នុងពិភពលោក។ ភាពខ្វល់ខ្វាយនេះមិនសូវសំខាន់ទេចំពោះបទល្មើសប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីព្រោះបទឧក្រិដ្ឋដែលទាមទារអោយមានការរៀបចំយ៉ាងសកម្មពីសំណាក់អាជ្ញាធរជាន់ខ្ពស់ទាំងនេះ មិនអាចជាផលវិបាកនៃការភាន់ច្រឡំធម្មតាក្នុងការវិនិច្ឆ័យនោះឡើយ។

សរុបសេចក្តីទៅ ដោយអនុញ្ញាតិអោយមានការរួចផុតយ៉ាងទូលំទូលាយ ពីការទទួលខុសត្រូវរបស់អ្នកប្រតិបត្តិ ជាពិសេសនៅ ក្នុងករណីឧក្រិដ្ឋកម្មសង្គ្រាម មាត្រា ៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូមមិនមានលក្ខណៈ សមស្របទៅនឹងយុត្តិសាស្ត្រអន្តរជាតិ ដែលមានពីមុនមកនោះទេ។

## ឥ. ស្ថានភាពច្បាប់កម្ពុជា

ច្បាប់ព្រហ្មទណ្ឌខ្មែរ មិនមានចែងពីការបង្ក្រាប បទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមទេ លើកលែងតែនៅក្នុងក្របខ័ណ្ឌពិសេសរបស់តុលាការវិសាមញ្ញ ដែលទទួលបន្ទុកជំនុំជម្រះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[៨៦]។ ដូច្នេះ នៅក្នុងករណីនៃការប្រព្រឹត្ត បទឧក្រិដ្ឋទាំងនេះដោយអ្នកប្រតិបត្តិបញ្ហានៃការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ មិនឃើញមានចែងនៅក្នុងនីតិវិជ្ជមានទេ។

ផ្ទុយទៅវិញ យើងគួររំលឹកផងដែរថាសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី មានបញ្ញត្តិការបង្ក្រាបការប្រព្រឹតបទល្មើសទាំងនេះ (មាត្រា កម ២១១១-១ ដល់មាត្រា កម ២១៣១-៦)[៨៧]។ គួរអោយកត់សំគាល់ផងដែរថា មាត្រា កម ១១២១-៧ ដែលទាក់ទងទៅនឹងការអនុញ្ញាតិដោយច្បាប់ ឬ ដោយអាជ្ញាធរបានចែងពីស្ថានភាពរបស់អ្នកប្រតិបត្តិ ចំពោះបទឧក្រិដ្ឋទាំងនេះ។ មាត្រា កម ១១២១-៧ បានចែងដូចតទៅ :

"បុគ្គលណាដែលបានប្រព្រឹត្តអំពើ ដែលបានបញ្ញត្តិ ឬ អនុញ្ញាតិតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ ។

៨៦. សូមមើលផ្នែកទី ២ ជំពូកទី ៣។

៨៧. សូមមើលទំព័រ ៥០។

បុគ្គលដែលប្រព្រឹត្តអំពើតាមបញ្ជារបស អាជ្ញាធរស្របច្បាប់បុគ្គលនេះមិនប្រព្រឹត្តបទល្មើសទេលើកលែងតែអមពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ស្តែង។

ប៉ុន្តែចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុង*បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម មិនអាចលើកលែងអោយផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ខ្លួនទេ* ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១. ជនល្មើសនេះ បានប្រព្រឹត្តបទល្មើសដែលបញ្ញត្តិ អនុញ្ញាត ឬហាមឃាត់ដោយច្បាប់ជាធរមាន។

២. ជននេះ បានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់" (អក្សរទ្រេតត្រូវបានបន្ថែម)។

តាមខ្លឹមសាររបស់មាត្រានេះ អ្នកប្រតិបត្តិនៅតែមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌដដែល នៅក្នុងករណីបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដោយគេមិនអាចរួចផុតបានឡើយ។

ដូច្នេះមាត្រា កម ១១២១-៧ មានភាពខុសប្លែកខ្លាំងពីខ្លឹមសារនៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលមិនត្រឹមតែបានកំណត់អំពីរបបគតិយុត្តិនៃការរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមួយដែលមានលក្ខណៈអនុគ្រោះសម្រាប់អ្នកប្រតិបត្តិនៅក្នុងបទឧក្រិដ្ឋទាំងអស់នេះប៉ុណ្ណោះទេ តែថែមទាំងបានចែងអំពីលទ្ធភាពផ្តន្ទាទោសអ្នកប្រតិបត្តិ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម សង្គ្រាមដែលបង្ករឱ្យមានការខូចខាតច្រើនក្រៃលែង។

តាមការពិត ដោយគ្រាន់តែយោងតាមខ្លឹមសារដ៏ច្បាស់លាស់របស់មាត្រា កម ១១២១-៧ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ហើយមិនចាំបាច់ទាំងធ្វើការបែងចែកភាពខុសគ្នារវាងបទឧក្រិដ្ឋទាំងអស់នោះផង អ្នកប្រតិបត្តិ ដែលបានប្រព្រឹត្តបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ ឧក្រិដ្ឋកម្មសង្គ្រាម មិនអាចរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ខ្លួនឡើយ ទោះបីជានៅក្នុងករណីណាក៏ដោយ។ យើងមិនអាចយល់ច្បាស់ជាងនេះទៀតបានទេ។

---

**អេហ្វ អ៊ី ដេ អាស សន្និដ្ឋាន :**

**ថាជាករណីមួយវិជ្ជមាន ចំពោះការដែលថា សេចក្តី ព្រាងក្រមព្រហ្មទណ្ឌថ្មី នៅក្នុងមាត្រា កម ១១២១-៧ បានហាមឃាត់ការរួចផុតពីការទទួល ខុសត្រូវខាងព្រហ្មទណ្ឌទាំងអស់ របស់អ្នកប្រតិបត្តិ ចំពោះបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ទោះបីជាលក្ខន្តិកៈទីក្រុងរ៉ូម បានចែង យ៉ាងទូលាយ**

នូវការរួចផុតពីការទទួលខុសត្រូវនេះក៏ដោយ និងជួយជំរុញអោយមានការអនុម័តនូវមាត្រានេះ ដោយអំណាចនីតិប្រតិបត្តិខ្មែរ។

## ផ្នែកទី៥ ៖ កិច្ចសហប្រតិបត្តិការរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងប្រទេសកម្ពុជា

### ជំពូកទោល ៖ សំណើសុំបញ្ចូលមាតិកាមួយស្តីពីកិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិទៅក្នុងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ

អនុលោមតាមបទបញ្ញត្តិរបស់លក្ខន្តិកៈទីក្រុងរ៉ូម និងជាពិសេសបទបញ្ញត្តិនៃជំពូកទី IX ព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងការស៊ើបអង្កេតនិងការជំនុំជំរះ ដែលតុលាការនេះបានដឹកនាំចំពោះបទឧក្រិដ្ឋទាំងឡាយ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន (មាត្រា ៨៦)។ ដូចនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវចែងនៅក្នុងច្បាប់ជាតិ របស់ខ្លួននូវបទបញ្ញត្តិទាំងឡាយណាដែលចាំបាច់សំរាប់បំពេញកាតព្វកិច្ចនេះ។ កំណែទំរង់យ៉ាងខ្លាំងក្លានៃក្រមនីតិវិធីព្រហ្មទណ្ឌគួតែជាឱកាសមួយដ៏ល្អសំរាប់ចែងបទបញ្ញត្តិទាំងនេះ។ តែផ្ទុយទៅវិញ នៅក្នុងការតាក់តែងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលសព្វថ្ងៃស្ថិតនៅក្រោមការសិក្សារបស់រាជរដ្ឋាភិបាល មិនមានចែងនូវបញ្ញត្តិណាមួយចំពោះបញ្ហានេះទេ។ជាលទ្ធផល វាហាក់ដូចជាចាំបាច់ក្នុងការបន្ថែមទៅលើបទបញ្ញត្តិ ដែលមានស្រាប់នៅក្នុងសេចក្តីព្រាងក្រមនូវបទបញ្ញត្តិទាំង ឡាយដែលទាក់ទងទៅនឹងកាតព្វកិច្ចនានាដែលតម្រូវដោយលក្ខន្តិកៈទីក្រុងរ៉ូម។ ការតាក់តែងសេចក្តីព្រាងក្រមអាច អនុញ្ញាតអោយមានការដាក់បញ្ចូលកាតព្វកិច្ច ដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ ទៅក្នុងគន្ថី ដែលស្តីពីនីតិវិធីដោយឡែក។ វាគឺជាគន្ថីទី ៩។

គន្ថីនេះមានបីមាតិកា ៖ មាតិកាទីមួយស្តីពីបទបញ្ញត្តិទាក់ទងនឹងបុគ្គលដែលមានចែងនូវរបបបត្យាប័ន មាតិកា ទីពីរស្តីពីការបាត់បង់លិខិតស្នាម ការបកស្រាយ និងការកែសំរួលសេចក្តីសំរេច ហើយមាតិកាទីបីស្តីពីបទល្មើសព្រមទាំងការចោទប្រកាន់ និងការជំនុំជម្រះបទល្មើសយោធា។

ម៉្យាងវិញទៀតការអនុវត្តន៍វិធានការមួយចំនួនទាក់ទងនឹងការជួលជុលសំណងដែលសម្រេចដោយតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃកាតព្វកិច្ចរបស់ព្រះរាជាណាចក្រ ក្នុងការសហការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ហេតុដូច្នេះយើងគួរតែបញ្ចូលទៅក្នុងក្របខ័ណ្ឌនេះនូវបទបញ្ញត្តិ ទាំងឡាយដែលពាក់ព័ន្ធ[៨៨]។ តាមន័យនេះ អនុសាសន៍របស់យើងដែលបានលើកឡើងនៅក្នុងផ្នែកទី V របស់របាយការណ៍នេះនឹងមិនមាននៅក្នុងផ្នែកទី VII ទេ។

---

៨៨. ចំពោះការសិក្សាទូទៅ លើការជួសជុលការខូចខាត ដល់ជនរងគ្រោះ សូមមើលផ្នែកទី ៥។

**ដូច្នេះ អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរ អោយបញ្ចូលបទបញ្ញត្តិស្តីពីកិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយ យោង ទៅតាមមាត្រា ៩៥ កថាខ័ណ្ឌ ២, មាត្រា ៩៧ កថា ខ័ណ្ឌ ៣ វាក្យខ័ណ្ឌ *ឃ*. មាត្រា ៩៨, ៩៩, ៧៥, ៨០, ៨៦ ដល់ ១០២ (ជំពូកទី IX) មាត្រា ១០៣, ១០៥, ១០៦, ១០៨, ១០៩, ១១០ របស់លក្ខន្តិកៈទីក្រុងរ៉ូម ក្រោមទំរង់ជាមាតិកាមួយដែលមានចំណងជើងថា "កិច្ចសហប្រតិបត្តិការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ" ដោយ បន្ថែម ទៅលើមាតិកាចំនួនបីដែលមានស្រាប់នៅក្នុងគន្ថីទី ៩។**

**ជាលទ្ធផលនៃការដាក់បញ្ចូល មាតិកាទី ១ ស្តីពី "កិច្ចសហប្រតិបត្តិការជាមួយនឹង តុលាការព្រហ្ម ទណ្ឌអន្តរជាតិ" មាតិកាទី ១ ពីដើម របស់សេចក្តី ព្រាងក្រម ដែលមានចំណងជើងថា "បទបញ្ញត្តិទាក់ ទងនឹងបុគ្គល" បានក្លាយ ទៅជាមាតិកាទី ២។ មាតិកាទី ២ ពីដើម ដែលមានចំណងជើងថា "ការបាត់បង់លិខិតស្នាម ការបកស្រាយ និងការ កែសំរួល សេចក្តីសំរេច" បានក្លាយទៅជាមាតិកាទី ៣។ មាតិកាទី ៣ ពីដើម ដែលមានចំណងជើងថា "បទបញ្ញត្តិ ទាក់ទងនឹងបទល្មើស" បានក្លាយជាមាតិកាទី ៤។ មាត្រាទាំងឡាយ ដែលពីមុនត្រូវបានបង់លេខ ជា កម ៩១១-១ ដល់ កម ៩៣១-៨ នឹងត្រូវបាន បង់លេខជាថ្មីគឺ កម ៩២១-១ ដល់ កម ៩៤១-៨ ដោយយោងទៅតាមប្រព័ន្ធ នៃការបង់លេខរបស់ សេចក្តីព្រាង ដែលលេខក្នុងខ្ទង់ទីមួយបញ្ជាក់ពីគន្ថី ក្នុងខ្ទង់ទីពីរជាមាតិកា និងទីបីជាជំពូក។ មាតិកាដែលស្នើអោយធ្វើការបញ្ចូល មានចែងដូច តទៅ :**

## "គន្ថីទី ៩ : នីតិវិធីដោយឡែក

### មាតិកាទី ១ : កិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ

***ជំពូកទី ១ : កិច្ចសហប្រតិបត្តិការខាងយុត្តាធិការ***

**ផ្នែកទី ១ : ការជួយគ្នាទៅវិញទៅមកខាងតុលាការ**

**មាត្រា កម ៩១១-១**

ដើម្បីអនុវត្តលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានផ្តល់សច្ចាប័ននៅថ្ងៃទី ៧ មករា ២០០២ ព្រះរាជាណាចក្រកម្ពុជាចូលរួមនៅក្នុងការបង្ក្រាបបទល្មើស និងសហការជាមួយយុត្តាធិការនេះតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងមាតិកានេះ។

បទបញ្ញត្តិបន្តបន្ទាប់នេះ អាចអនុវត្តបានទៅលើគ្រប់បុគ្គលទាំងអស់ដែលត្រូវបានចោទប្រកាន់ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ ត្រូវបានផ្តន្ទាទោសដោយតុលាការនេះដោយសារមូលហេតុ នៃអំពើដែលបង្កអោយ

មានបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងអត្ថន័យរបស់មាត្រា ៦ ដល់ ៨ និង មាត្រា ២៥ នៃលក្ខន្តិកៈ ។

## មាត្រា កម ៩១១-២

សំណើជួយគ្នាទៅវិញទៅមកដែលធ្វើឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានធ្វើទៅកាន់អាជ្ញាធរដែលមានសមត្ថកិច្ច ដោយយោងទៅតាមមាត្រា ៨៧ របស់លក្ខន្តិកៈដើម ឬថតចម្លងមានបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់ជាមួយនូវឯកសារបញ្ជាក់ទាំងអស់ ។

ដោយយោងតាមមាត្រា ៨៧ របស់លក្ខន្តិកៈ អាជ្ញាធរមានសមត្ថកិច្ចបញ្ជូនសំណើជួយគ្នាទៅវិញទៅមក និងឯកសារ បញ្ជាក់ទាំងអស់ទៅអោយរដ្ឋមន្ត្រីក្រសួងយុត្តិធមិ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធមិត្រួតពិនិត្យមើលភាពត្រឹមត្រូវរបស់សំណើ ហើយបញ្ជូនទៅអោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅទីក្រុងភ្នំពេញដែលជាអ្នករក្សាទុក ។ ក្នុងករណីប្រញាប់ ឯកសារទាំងអស់នេះអាចត្រូវបានផ្ទេរដោយផ្ទាល់និងតាមគ្រប់មធ្យោបាយទៅអោយចៅក្រមរូបនេះ ។ បន្ទាប់មកទៀតឯកសារទាំងនេះនិងត្រូវផ្ទេរទៅតាមទំរង់ដែលបានចែងនៅក្នុងវាក្យខ័ណ្ឌខាងលើ ។

## មាត្រា កម ៩១១-៣

សំណើជួយគ្នាទៅវិញទៅមក ត្រូវបានប្រតិបត្តិដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ដោយសភា ស៊ើបសួរអមសាលាឧទ្ធរណ៍ដែលជាអ្នកសម្រេចលើការស្នើ។ អគ្គព្រះរាជអាជ្ញា និង សភាស៊ើបសួរអមសាលាឧទ្ធរណ៍ធ្វើសកម្មភាពលើដែនដីជាតិទាំងមូលដោយមានវត្តមានរបស់ព្រះរាជអាជ្ញាអមតុលាការព្រហ្មទណ្ឌអន្តរជាតិ ប្រសិនបើអាចធ្វើទៅបាន ឬ វត្តមានរបស់បុគ្គលផ្សេងទៀត ដែលបានលើកបង្ហាញនៅក្នុងសំណើរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

កំណត់ហេតុដែលបានធ្វើឡើង នៅក្នុងការប្រតិបត្តិសំណើត្រូវបានបញ្ជូនទៅអោយតុលាការព្រហ្មទណ្ឌអន្តរជាតិដោយអាជ្ញាធរមានសមត្ថកិច្ចអនុលោមតាមមាត្រា ៨៧ នៃលក្ខន្តិកៈ។

ក្នុងករណីប្រញាប់ ឯកសារថតចម្លងដែលបានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមរបស់កំណត់ហេតុ អាចបញ្ជូនដោយផ្ទាល់ និងតាមគ្រប់មធ្យោបាយទៅអោយតុលាការព្រហ្មទណ្ឌអន្តរជាតិ។ បន្ទាប់មកទៀត កំណត់ហេតុ និងត្រូវបញ្ជូនតាមបែបបទ ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌខាងដើម។

## មាត្រា កម ៩១១-៤

ការប្រតិបត្តិនៅលើដែនដី របស់ព្រះរាជាណាចក្រកម្ពុជានូវវិធានការថែរក្សា ដែលបានចែងនៅក្នុង *ង.* កថាខ័ណ្ឌ ១ នៃមាត្រា ៩៣ របស់លក្ខន្តិកៈត្រូវបានរៀបចំ ដោយចំណាយតាមថវិការ របស់រតនាគារជាតិ និងតាមបែបបទដែលបានចែង ដោយក្រមនីតិវិធីរដ្ឋប្បវេណីថ្មី នៅក្នុងមាត្រា ៥៦២ ដល់ ៥៧១ ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ រយៈពេល អតិបរមារបស់វិធានការនេះ ត្រូវបានកំណត់ត្រឹម (ពីរឆ្នាំ)។ វាអាចបន្តបានតាមលក្ខខណ្ឌដែលមុនការផុតកំណត់របស់ រយៈពេលនេះ តាមការស្នើសុំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

យោងតាមមាត្រា ៨៧ នៃលក្ខន្តិកៈ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បញ្ជូនទៅអោយអាជ្ញាធរមានសមត្ថកិច្ច នូវគ្រប់បញ្ហាទាំងអស់ដែលទាក់ទង ទៅនឹងការអនុវត្តវិធានការទាំងនេះ ដើម្បីធ្វើការពិភាក្សាផ្សេងៗ ស្របតាមមាត្រា ៩៣ កថាខ័ណ្ឌ ៣ និងមាត្រា ៩៧ នៃ លក្ខន្តិកៈ។

## ផ្នែកទី ២ : ការចាប់ខ្លួន និងការប្រគល់ខ្លួន

មាត្រា កម ៩១១-៥ ក្នុងគោលបំណងរបស់ផ្នែកនេះ ពាក្យ *"ប្រគល់ខ្លួន"* សំដៅលើទង្វើដែលរដ្ឋមួយប្រគល់មនុស្សម្នាក់ទៅ អោយតុលាការ ព្រហ្មទណ្ឌអន្តរជាតិដោយអនុវត្តតាមលក្ខន្តិកៈ។

មាត្រា កម ៩១១-៦

សំណើសុំចាប់ខ្លួន ដែលបានធ្វើឡើងដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបញ្ជូនច្បាប់ដើម និងភ្ជាប់ជាមួយឯកសារ បញ្ជាក់ទាំងអស់ទៅអោយអាជ្ញាធរមានសមត្ថកិច្ច ដោយយោងទៅតាមមាត្រា ៨៧ នៃលក្ខន្តិកៈ ដែលជាអ្នកបញ្ជូនឯកសារ ទាំងអស់នេះ ទៅអោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្រោយពីបានត្រួតពិនិត្យ ពីភាពត្រឹមត្រូវរបស់រួចហើយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បញ្ជូនវាទៅអោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

នៅក្នុងករណីបន្ទាន់ សំណើទាំងអស់នេះ អាចត្រូវបានបញ្ជូនដោយផ្ទាល់និងតាមគ្រប់មធ្យោបាយ ទៅអោយព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចតាមដែនដីបានផងដែរ។ បន្ទាប់មកទៀត វាត្រូវបានបញ្ជូនតាមទំរង់ដែលបានចែងនៅក្នុងវាក្យខ័ណ្ឌខាងដើម។

មាត្រា កម ៩១១-៧ បុគ្គលដែលបានចាប់តាមការសុំអោយចាប់ខ្លួនត្រូវតែប្រគល់ទៅអោយព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចតាមដែនដី ក្នុងរយៈពេលម្ភៃបួនម៉ោង។ នៅក្នុងអំឡុងពេលនេះ បទបញ្ញត្តិរបស់ មាត្រា កម ៣២៣-៣ និង កម ៣២៣-៤ នៃក្រមនេះ អាចអនុវត្តបានចំពោះរូបគេ។

ក្រោយពីធ្វើការផ្ទៀងផ្ទាត់លើអត្តសញ្ញាណរួចហើយ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ជននេះ តាមភាសាដែលគេចេះ ថា ខ្លួនគេគឺជាកម្មវត្ថុនៃការសុំចាប់ខ្លួនដើម្បីប្រគល់ទៅអោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយថានៅក្នុងរយៈពេលប្រាំថ្ងៃ យ៉ាងយូរ ជននេះត្រូវតែបង្ហាញខ្លួនទៅចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ព្រះរាជ អាជ្ញាត្រូវប្រាប់ជននេះ ផងដែរថា គេអាចមានមេធាវីជួយការពារតាមការជ្រើសរើសរបស់គេ ឬ បើមិនដូច្នោះទេ តាមការចាត់តាំង នៅក្នុងលក្ខខណ្ឌដែលបានចែងដោយច្បាប់លក្ខន្តិកៈមេធាវី ហើយអាចត្រូវបានជូនដំណឹងជាបន្ទាន់ និងតាមគ្រប់មធ្យោបាយ។ ព្រះរាជអាជ្ញាត្រូវណែនាំដល់ជននោះផងដែរថា គេអាចជួបសម្ភាស ភ្លាមៗតែម្តងជាមួយនឹងមេធាវីតាមការចាត់តាំង។ និទ្ទេសនៃការជូនដំណឹងទាំងអស់នេះ ត្រូវសរសេរនៅក្នុង កំណត់ហេតុដែលត្រូវបញ្ជូនអោយបានឆាប់ទៅអោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ព្រះរាជអាជ្ញា ចេញបញ្ជាអោយឃុំខ្លួនជន ដែលគេទាមទារនៅក្នុងពន្ធនាគារ ឬមជ្ឈមណ្ឌលឃុំខ្លួន។

## មាត្រា កម ៩១១-៨

ប្រសិនបើមានការទាមទារ ជនដែលគេទាមទារ ត្រូវបានបញ្ជូន និងដាក់ក្នុងពន្ធនាគារ ឬមជ្ឈមណ្ឌលឃុំខ្លួន ដែលស្ថិតនៅ ក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍។ ការផ្ទេរត្រូវធ្វើឡើងនៅក្នុងរយៈពេលប្រាំថ្ងៃយ៉ាងយូរ ដែលគិតចាប់ពីថ្ងៃបង្ហាញខ្លួន នៅចំពោះមុខព្រះរាជអាជ្ញាមក បើមិនដូច្នោះទេជនដែលគេទាមទារត្រូវតែបានដោះលែង ជាបន្ទាន់ តាមការសំរេចរបស់ប្រធានសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជូនដំណឹងតាមភាសាដែលគេចេះនូវការសុំចាប់ខ្លួនដើម្បីប្រគល់ ព្រមទាំងការចោទប្រកាន់នានា ដែលធ្វើឡើងប្រឆាំងនឹងជននេះ។

នៅពេលដែលជនដែលគេទាមទារបានធ្វើការស្នើសុំអោយមានមេធាវីជួយការពារខ្លួនរួចហើយ ហើយដែលមេធាវីនេះ ត្រូវបានកោះហៅយ៉ាងត្រឹមត្រូវអគ្គព្រះរាជអាជ្ញានឹងទទួលយកសេចក្តីប្រកាសរបស់គេ។

នៅក្នុងករណីផ្សេងទៀត ចៅក្រមនេះត្រូវរំលឹកដល់ជននេះ នូវសិទ្ធិក្នុងការជ្រើសរើសមេធាវី ឬស្នើសុំអោយមានការចាត់ តាំងមេធាវីសំរាប់រូបគេ។ មេធាវីដែលបានជ្រើសរើស ឬ ចំពោះករណីនៃការស្នើសុំអោយមានការចាត់តាំង ប្រធានគណៈមេធាវីត្រូវបានគេជូនដំណឹងតាមគ្រប់មធ្យោបាយ និងជាបន្ទាន់។ មេធាវីអាចមើលសំណុំឯកសារនៅ ហ្នឹងកន្លែង ហើយអាចធ្វើ ការទាក់ទងបានដោយសេរី និងដោយអាថិកំបាំង ជាមួយនឹងជនដែល គេទាមទារ។ អគ្គព្រះរាជអាជ្ញាទទួលយកសេចក្តីប្រកាសរបស់ជននេះ ក្រោយពីបានប្រាប់ថាគាត់មានសិទ្ធិមិនឆ្លើយ។ និទ្ទេសនៃការប្រាប់នេះ ត្រូវចុះនៅក្នុងកំណត់ហេតុ។

## មាត្រា កម ៩១១-៩

សភាស៊ើបសួរត្រូវទទួលយកនីតិវិធីអោយបានឆាប់។ ជនដែលគេទាមទារត្រូវបង្ហាញខ្លួននៅចំពោះមុខសភានេះក្នុង យៈពេល ៨ ថ្ងៃ គិតចាប់ តាំងពីថ្ងៃដែលបានបង្ហាញខ្លួន នៅចំពោះមុខអគ្គព្រះរាជអាជ្ញា។ តាមការស្នើសុំរបស់អគ្គព្រះរាជអាជ្ញា ឬ របស់ជនដែលគេទាមទារ រយៈពេលបន្ថែមចំនួន ៨ ថ្ងៃ អាចត្រូវបានអនុញ្ញាតិអោយ មុនមានការពិភាក្សាដេញដោល។ បន្ទាប់មកទៀត គឺមានការចោទសួរដែលត្រូវមានធ្វើកំណត់ហេតុ។

ការពិភាក្សាដេញដោល និងសាលដីកា ត្រូវធ្វើឡើងក្នុងសវនាការសាធារណៈ លើកលែងតែក្នុងករណីដែលតុលាការប្រកាសសវនាការជាអសាធារណៈ ដោយយោងទៅតាមមាត្រា កម ៥១៣-១ (ការផ្សព្វផ្សាយការពិភាក្សាដេញដោល និងសវនាការជាអសាធារណៈ) [ដែលបានធ្វើការកែប្រែ តាម អនុសាសន៍ ដែលបានផ្តល់អោយនៅក្នុងផ្នែកទី VII]។

តំណាងអយ្យការ និងជនដែលគេទាមទារត្រូវតែបានគេស្តាប់ចម្លើយរបស់ខ្លួនដែលជននេះអាចមាន មេធាវីជួយការពារ និងមានអ្នកបកប្រែភាសា ប្រសិនបើជាការគួរ។

**មាត្រា កម ៩១១-១០**

នៅពេលដែលសភាស៊ើបសួរពិនិត្យឃើញថា មិនមានការភាន់ច្រឡំជាក់ស្តែងទេ គាត់នឹងចេញបញ្ជាអោយប្រគល់ខ្លួនជន ដែលគេទាមទារ ហើយប្រសិនបើជននេះនៅក្រៅឃុំ នឹងបញ្ជាអោយឃុំខ្លួន។ គ្រប់បញ្ហាផ្សេងទៀតដែលស្ថិតនៅក្រោម អំណាចរបស់សភាស៊ើបសួរ ត្រូវបញ្ជូនទៅអោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនឹងត្រូវធ្វើការដោះស្រាយជាបន្ទាន់។ សភាស៊ើបសួរត្រូវសំរេចក្នុងរយៈពេលដប់ប្រាំថ្ងៃបន្ទាប់ពីការបង្ហាញខ្លួនរបស់ជន ដែលគេទាមទារនៅចំពោះមុខគាត់។ នៅក្នុងករណីមានបណ្តឹងសារទុក្ខ សភាព្រហ្មទណ្ឌរបស់តុលាការកំពូល ត្រូវសំរេចក្នុងរយៈពេលពីរខែ បន្ទាប់ពិតុលាការកំពូល បានទទួលសំណុំឯកសារ។

**មាត្រា កម ៩១១-១១**

ការដោះលែងអាចត្រូវបានស្នើសុំនៅគ្រប់ពេលទាំងអស់ ទៅកាន់សភាស៊ើបសួររបស់សាលាឧទ្ធរណ៍ ដែលនឹងចាត់នីតិវិធី ទៅតាមមាត្រា ៥៩ នៃលក្ខន្តិកៈ និងតាមនីតិវិធីដែលបានចែងដោយមាត្រា កម ៤១៣-២៨ និង បន្តបន្ទាប់នៃក្រមនេះ។

សភាស៊ើបសួរត្រូវសំរេចតាមសាលដីកា ដែលត្រូវធ្វើឡើងនៅក្នុងសវនាការសាធារណៈ និងមានសំអាងហេតុដោយយោងទៅតាមបទបញ្ញត្តិនៃកថា ខ័ណ្ឌ ៤ របស់មាត្រា ៥៩ ខាងលើ។

**មាត្រា កម ៩១១-១២**

សាលដីកា ដែលចេញដោយសភាស៊ើបសួរ ហើយទីកន្លែង និងកាលបរិច្ឆេទនៃការប្រគល់ជនដែលគេទាមទារប្រសិនបើមាន ព្រមទាំងរយៈពេលនៃការឃុំខ្លួន ត្រូវបញ្ជូនតាមគ្រប់មធ្យោបាយ ដោយអាជ្ញាធរមានសមត្ថកិច្ចទៅអោយតុលាការ ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីជ្រាបជាព័ត៌មាន ដោយយោងទៅតាមមាត្រា ៨៧ នៃលក្ខន្តិកៈ។

ជនដែលគេទាមទារត្រូវប្រគល់ក្នុងរយៈពេលមួយខែដោយគិតចាប់ពីថ្ងៃដែលសេចក្តីសំរេចនេះ បានចូលជាស្ថាពរបើមិន ដូច្នោះទេ ជននេះត្រូវបានដោះលែងជាបន្ទាន់ តាមសេចក្តីសំរេចរបស់ប្រធានសភាស៊ើបសួរ។

**មាត្រា កម ៩១១-១៣**

បទបញ្ញត្តិមាត្រា កម ៩១១-៦ ដល់ កម ៩១១-១២ អាចអនុវត្តបានផងដែរ ប្រសិនបើជនដែលគេទាមទារត្រូវបាន ចោទប្រកាន់ ឬជំនុំជម្រះនៅព្រះរាជាណាចក្រកម្ពុជា ចំពោះបទល្មើសផ្សេងៗទៀត ក្រៅពីបទល្មើសដែលបានលើកឡើងដោយ សំណើរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ផ្ទុយទៅវិញជនដែលគេបានឃុំខ្លួនតាមលក្ខខណ្ឌទាំងនេះ មិនអាចទទួលបាននូវការដោះលែងអោយមានសេរីភាព តាមមាត្រា កម ៩១១-៨ កម ៩១១-១១ និងវាក្យខ័ណ្ឌទី ២ នៃមាត្រា កម ៩១១-១២ បានឡើយ។

ចំពោះជននេះ នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបង្អង់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងនៃទោស ។

**មាត្រា កម ៩១១-១៤**

ដោយយោងទៅតាមមាត្រា ៨៩ នៃលក្ខន្តិកៈ ប្រសិនបើព្រះរាជាណាចក្រកម្ពុជាបានទទួលពីតុលាការព្រហ្មទណ្ឌអន្តរជាតិ នូវសំណើអោយប្រគល់ និងទទួលយកដោយរដ្ឋផ្សេងទៀត ដែលជាភាគីនៃលក្ខន្តិកៈ ឬមិនមែនជាភាគីនៃលក្ខន្តិកៈ សំណើធ្វើបត្យាប័នជននេះ ចំពោះការប្រព្រឹត្តដដែល ដែលបង្កអោយមានបទឧក្រិដ្ឋ ហើយដោយសារការនេះ តុលាការបានស្នើសុំ អោយប្រគល់ជននេះ ឬចំពោះការប្រព្រឹត្តមួយផ្សេងទៀត ខុសពីការប្រព្រឹត្តដែលបង្កអោយមានបទឧក្រិដ្ឋ ដែលនាំអោយតុលាការធ្វើការស្នើសុំត្រូវធ្វើឡើង តាមលក្ខខណ្ឌដែលបានកំណត់ដោយមាត្រា ៩០ នៃលក្ខន្តិកៈ ។

**មាត្រា កម ៩១១-១៥**

យោងតាមអត្ថន័យរបស់មាត្រា ៨៩ នៃលក្ខន្តិកៈ ការឆ្លងកាត់ទឹកដីប្រទេសកម្ពុជាត្រូវមានអនុញ្ញាតិ ដោយអាជ្ញាធរមានសមត្ថកិច្ច ដោយយោងតាមមាត្រា ៨៧ នៃលក្ខន្តិកៈ ។

**មាត្រា កម ៩១១-១៦**

នៅពេលដែលតុលាការសុំពង្រីកលក្ខខណ្ឌនៃការប្រគល់ខ្លួន ដែលបានអនុញ្ញាតិដោយអាជ្ញាធរកម្ពុជា សំណើត្រូវធ្វើទៅ កាន់អាជ្ញាធរមានសមត្ថកិច្ច ដោយយោងទៅតាមមាត្រា ៨៧ នៃលក្ខន្តិកៈ ដែលត្រូវបញ្ជូនជាមួយនឹងឯកសារសំអាង បញ្ជាក់ផ្សេងៗទៀត ព្រមទាំងសេចក្តីសន្និដ្ឋានរបស់សាម៉ីខ្លួន ទៅសភាស៊ើបសួររបស់សាលាឧទ្ធរណ៍ ។

ក្រោយពីបានពិនិត្យមើលឯកសារទាំងអស់ និងការពន្យល់បកស្រាយរបស់មេធាវីការពារជនដែលពាក់ព័ន្ធប្រសិនបើមានរួចហើយ ប្រសិនបើសភាស៊ើបសួរសន្និដ្ឋានថាពុំមានការភាន់ច្រឡំជាក់ស្តែងទេនោះ គាត់អនុញ្ញាតិលើការពង្រីកដែលបានសុំ ។

**មាត្រា កម ៩១១-១៧**

ជន ដែលជាកម្មវត្ថុនៃការចាប់ខ្លួនបណ្តោះអាសន្ន តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៩២ នៃលក្ខន្តិកៈ ប្រសិនបើ មានការយល់ព្រមពីជននេះ អាចត្រូវបានប្រគល់ទៅអោយតុលាការព្រហ្មទណ្ឌអន្តរជាតិ មុនធ្វើការស្នើសុំជាផ្លូវការទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអោយធ្វើការប្រគល់ខ្លួន ពីសំណាក់យុត្តាធិការអន្តរជាតិ ដោយយោងទៅតាមមាត្រា ៨៧ នៃលក្ខន្តិកៈ ។

សេចក្តីសំរេចប្រគល់ខ្លួនត្រូវធ្វើឡើងដោយសភាស៊ើបសួររបស់សាលាឧទ្ធរណ៍ក្រោយពីខ្លួនបានជូនដំណឹង ដល់ជនដែលពាក់ព័ន្ធពីសិទ្ធិក្នុងការទទួលបាននូវនីតិវិធីនៃការប្រគល់ខ្លួនជាផ្លូវការនិងទទួលបានការប្រមព្រៀងរួចហើយ ។ នៅក្នុងអំឡុងពេលនៃសវនកម្មរបស់សភាស៊ើបសួរជនដែលពាក់ព័ន្ធអាចត្រូវបានជួយការពារ ដោយមេធាវីម្នាក់តាមការជ្រើសរើសរបស់ខ្លួន ឬ ដោយមេធាវីចាត់តាំងតាមលក្ខខណ្ឌដែលបានចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និង មានអ្នកបកប្រែប្រសិនបើជាការគួរ ។

ជន ដែលជាកម្មវត្ថុនៃការចាប់ខ្លួនបណ្តោះអាសន្នតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៩២ នៃលក្ខន្តិកៈ ហើយដែល មិនបានយល់ព្រមប្រគល់ខ្លួនអោយតុលាការ អាចត្រូវបានដោះលែងអោយមានសេរីភាព ដោយយោងទៅតាមមាត្រា ៨៧ នៃលក្ខន្តិកៈ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចមិនបានទទួលនូវសំណើអោយធ្វើការប្រគល់ខ្លួនជាផ្លូវការទេ នៅក្នុងអំឡុងពេល ដែលបានកំណត់ដោយវិធាននីតិវិធី និងភស្តុតាង របស់យុត្តាធិការអន្តរជាតិនេះ ។

ការដោះលែងអោយមានសេរីភាព ត្រូវបានសំរេចដោយសភាស៊ើបសួរ តាមពាក្យសុំរបស់សាម៉ីខ្លួន។ សភាស៊ើបសួរ ត្រូវសំរេចក្នុងរយៈពេលប្រាំបីថ្ងៃ គិតចាប់តាំងពីថ្ងៃបង្ហាញខ្លួនរបស់ជន ដែលត្រូវបានចាប់ខ្លួន។

**មាត្រា កម ៩១១-១៨**

ប្រសិនបើជននោះយល់ព្រម ជនដែលត្រូវបានឃុំខ្លួននៅក្នុងទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានផ្ទេរទៅ អោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីត្រួតពិនិត្យលើអត្តសញ្ញាណ ឬស្តាប់ ឬដើម្បីបំពេញ កិច្ចការស៊ើបអង្កេតផ្សេងៗទៀត។ ការផ្ទេរត្រូវបានអនុញ្ញាតិដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ***ជំពូកទី ២ : ការដាក់ទោស និងវិធានការណ៍ជួសជុលការខូចខាត ដែលធ្វើឡើងដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ***

### **ផ្នែកទី ១ : ការដាក់ទោសពិន័យ និងការរឹបអូស ព្រមទាំងវិធានការណ៍ជួសជុលការ ខូចខាតរបស់ជនរងគ្រោះ**

**មាត្រា កម ៩១២-១**

នៅពេលដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការស្នើសុំ ការដាក់ទោសពិន័យ និងការរឹបអូស ឬសេចក្តីសំរេចដែលទាក់ទងនឹងការជួសជុល ដែលធ្វើឡើងដោយតុលាការនេះ ត្រូវបានអនុញ្ញាតិអោយតុលាការក្រុងភ្នំពេញ ដែលបានប្តឹងដោយ ព្រះរាជអាជ្ញា ឬដោយគ្រប់ភាគីសាម៉ីទាំងអស់។ នីតិវិធីនៅចំពោះមុខតុលាការក្រុងភ្នំពេញ ត្រូវគោរពតាមវិធាននៃក្រមនេះ។

តុលាការក្រុងត្រូវគោរពតាមសេចក្តីសំរេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយរួមបញ្ចូលទាំងបទបញ្ញត្តិ ដែលទាក់ទងនឹងសិទ្ធិរបស់តតិយជន។ ផ្ទុយទៅវិញ នៅក្នុងការអនុវត្តដីការឹបអូស តុលាការក្រុងអាចចេញវិធានការណ៍ នានាដើម្បីដកហូតវត្ថុដែលមានតំលៃជាទ្រព្យសម្បត្តិ ឬធនធាន ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានសំរេចអោយ រឹបអូស នៅពេលដែលដីកាសំរេចអោយរឹបអូសនេះទំនងជាមិនអាចអនុវត្តបាន។ តុលាការត្រូវស្តាប់ពិរុទ្ធជន ព្រមទាំងបុគ្គលទាំងអស់ ដែលមានសិទ្ធិលើវត្ថុ តាមដីកាចាត់អោយសួរជំនួស។ ជនទាំងនេះអាចតំណាងដោយមេធាវីបាន។

នៅពេលដែលតុលាការក្រុងពិនិត្យឃើញថា ការអនុវត្តដីការឹបអូស ឬដីកាជួសជុលការខូចខាត អាចបង្កអោយមាន ព្យសនកម្មដល់តតិយជនដែលសុច្ចរិត ដែលមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកានេះបានតុលាការត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីលើកបញ្ហាទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនឹងធ្វើការឆ្លើយតបភ្លាមៗ។

## មាត្រា កម ៩១២-២

ការអនុញ្ញាតិអោយមានការប្រតិបត្តិ ដែលធ្វើឡើងដោយតុលាការក្រុង ដោយយោងតាមមាត្រាខាងដើម តាមសេចក្តី សំរេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នឹងនាំអោយមានការផ្ទេរប្រាក់ពិន័យ និងវត្ថុដែលបានរឹបអូស ឬប្រាក់នៃការលក់ ទៅអោយតុលាការអន្តរជាតិ ឬទៅមូលនិធិសំរាប់ជនរងគ្រោះដែលមានចែងនៅមាត្រា ៧៩ នៃលក្ខន្តិកៈ។ វត្ថុ ឬចំនួនទឹក ប្រាក់ទាំងនេះអាចត្រូវបានប្រគល់ផងដែរ ទៅអោយជនរងគ្រោះ ប្រសិនបើតុលាការអន្តរជាតិបានសំរេច និងរៀបចំអោយមានការចាត់តាំង។ ការតវ៉ាទាំងអស់ដែលទាក់ទងនឹងការចាត់តាំងប្រាក់ពិន័យ វត្ថុ ឬប្រាក់នៃការលក់ ត្រូវបញ្ជូនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលនឹងដោះស្រាយបញ្ហាភ្លាមៗ។

## ផ្នែកទី ២ ៈការដាក់ទោសពន្ធនាគារ

## មាត្រា កម ៩១២-៣

ដោយអនុវត្តតាមមាត្រា ១០៣ នៃលក្ខន្តិកៈ នៅពេលដែលរាជរដ្ឋាភិបាលបានយល់ព្រមទទួលយកបុគ្គលម្នាក់ ដែលបានផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអោយជននេះអាចបញ្ចប់ទោសគុករបស់ខ្លួន នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ការផ្តន្ទាទោសដែលបានប្រកាស អាចអនុវត្តបានដោយផ្ទាល់ និងភ្លាមៗ ចំពោះទោស ដែលនៅសល់ ចាប់តាំងពីពេលផ្ទេរជននេះនៅលើដែនដីជាតិ។

លើកលែងតែបទបញ្ញត្តិរបស់លក្ខន្តិកៈ និងរបស់ផ្នែកនេះ ការដាក់ និងការអនុវត្តទោសត្រូវបានចែងដោយ បទបញ្ញត្តិនៃក្រមនេះ។

## មាត្រា កម ៩១២-៤

តាំងពីពេលមកដល់ដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា ជនដែលបានផ្ទេរត្រូវបានបង្ហាញខ្លួនទៅព្រះរាជអាជ្ញានៃកន្លែងមកដល់ ដែលជាអ្នកធ្វើការចោទសួរពីអត្តសញ្ញាណ និងធ្វើកំណត់ហេតុ។ ផ្ទុយទៅវិញ ប្រសិនបើការចោទសួរមិនអាចធ្វើទៅបានភ្លាម១ទេ ជននេះត្រូវបញ្ជូនទៅពន្ធនាគារ ឬមជ្ឈមណ្ឌលឃុំខ្លួន ដែលមិនត្រូវឃុំលើសពីម្ភៃបួនម៉ោងទេ។ នៅពេលផុត កំណត់រយៈពេលនេះ ជននេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ដោយប្រធានស្ថាប័ន។

តាមរយៈឯកសារ ដែលបង្ហាញពីការព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលទាក់ទងទៅនឹងការផ្ទេរសាមីខ្លួន ឯកសារថតចម្លង ដែលមានបញ្ជាក់ថាត្រឹមត្រូវនៃសេចក្តីសំរេចផ្តន្ទាទោស និងការជូន ដំណឹងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពីកាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តទោស និងពីថិរវេលាដែលនៅសល់ ព្រះរាជអាជ្ញាត្រូវចេញដីកាឃុំខ្លួនជន ដែលបានផ្តន្ទាទោសនេះ ជាបន្ទាន់។

## មាត្រា កម ៩១២-៥

ប្រសិនបើជន ដែលត្រូវបានផ្តន្ទាទោស បានដាក់ពាក្យសុំអោយនៅក្រៅឃុំ អោយមានសេរីភាពពាក់កណ្តាល អោយមាន ការកាត់បន្ថយទោស អោយបែងចែកទោសជាវគ្គ១ ឬអោយមានការព្យួរទោស អោយដាក់នៅក្រោមការតាមដានគ្រឿង អេឡិចត្រូនិច ឬការដោះលែងអោយមានសេរីភាពដោយមានលក្ខខណ្ឌ ពាក្យសុំនេះត្រូវធ្វើទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលនឹងបញ្ជូនបន្តទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវបញ្ជូនពាក្យសុំ រួមជាមួយនឹងឯកសារដែលពាក់ព័ន្ធទាំងអស់ ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងរយៈពេលមួយដ៏សមស្រប។តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវសំរេច ថាតើជនដែលត្រូវបាន គេផ្តន្ទាទោសអាច ឬមិនអាចទទួលបាននូវវិធានការណ៍ ទាំងនេះ។ នៅពេលដែលសេចក្តីសំរេចរបស់តុលាការអវិជ្ជមាន រាជរដ្ឋាភិបាលកម្ពុជាត្រូវបញ្ជាក់ទៅតុលាការថាខ្លួន យល់ព្រម ឬមិនយល់ព្រម ថែរក្សាជននេះ នៅលើទឹកដីរបស់ខ្លួន ឬចង់សុំអោយមានការផ្ទេរទៅរដ្ឋមួយទៀត ដែលតុលាការព្រហ្មទណ្ឌអន្តរជាតនឹងចាត់តាំង”។

# ផ្នែកទី៦: ការជួសជុលការខូចខាតដល់ជនរងគ្រោះ

## សេចក្តីផ្តើម

ជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្ររបស់យុត្តិធម៌អន្តរជាតិ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិមួយមានសមត្ថកិច្ច ដើម្បីចេញសេចក្តីសំរេចជួសជុលការខូចខាតរបស់ជនរងគ្រោះ។ នីតិវិធីនេះអនុញ្ញាតិអោយតុលាការអាចចាត់វិធានការណ៍រឹបអូស និងដកហូត ហើយកំណត់ពីគោលការណ៍នៃការជួសជុលការខូចខាត ដែលរួមមានការប្រគល់វត្ថុវិញ ការសងសំណង និងការផ្តល់នីតិសម្បទាអោយវិញ ដោយគ្មានព្រំដែនកំណត់។

ដូច្នេះ សមត្ថកិច្ចក្នុងការជួសជុលការខូចខាតបានធ្លាក់ទៅលើតុលាការព្រហ្មទណ្ឌអន្តរជាតិ។ នៅក្នុងករណីមួយចំនួន អាជ្ញាធរជាតិកម្ពុជា ឬបរទេស ដែលមានកាតព្វកិច្ចធ្វើការសហការជាមួយតុលាការនេះ អាចចាត់នីតិវិធីជួសជុលការខូចខាតផងដែរ។

ដូចនេះ ការជួសជុលការខូចខាតរបស់ជនរងគ្រោះ អាចពាក់ព័ន្ធនឹងអាជ្ញាធរកម្ពុជាតាមរបៀបពីរយ៉ាង :

- ដោយទន្ទឹមគ្នា ឬក្រោយ នីតិវិធីនៃការជួសជុល នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ ចំពោះមុខតុលាការបរទេស ប្រទេសកម្ពុជាត្រូវផ្តល់អានុភាពដល់សេចក្តីសំរេច ដែលបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីនេះ (ជំពូក I)។
- ដោយផ្ទាល់ពីព្រោះនីតិវិធីនៃការជួសជុលបានប្រព្រឹត្តទៅផងដែរ នៅចំពោះមុខតុលាការខ្មែរ (ជំពូក II)។

## ជំពូក១ : នីតិវិធីនៅចំពោះមុខ តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ តុលាការបរទេស

លក្ខន្តិកៈទីក្រុងរ៉ូមបានចែងថា អាជ្ញាធរកម្ពុជាត្រូវអនុវត្តសេចក្តីសំរេច និងដីកាជួសជុលការខូចខាត របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ លក្ខន្តិកៈនេះក៏បានបញ្ជាក់ផងដែរថា អាជ្ញាធរកម្ពុជាត្រូវអនុវត្តសេចក្តីសំរេច និងដីកាជួសជុលការខូចខាតនេះ ក្នុងក្របខ័ណ្ឌនៃ "នីតិវិធីដែលបានចែងដោយច្បាប់ជាតិ" (មាត្រា ៧៥ កថាខ័ណ្ឌ ៤ និង មាត្រា ១០៩ កថាខ័ណ្ឌ១)។ យើងអាចមានការងឿងឆ្ងល់ផងដែរ ពីកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការអនុវត្ត សេចក្តីសំរេច ដែលទាក់ទងនឹងនីតិវិធី នៃការជួសជុលការខូចខាត នៅចំពោះមុខតុលាការបរទេស។

## ក. កិច្ចសហប្រតិបត្តិការជាមួយ តុលាការព្រហ្មទណ្ឌអន្តរជាតិ និង ការអនុវត្តដីកាជួសជុលការខូចខាត

មាត្រា ៧៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានប្រកាសនូវគោលការណ៍នៃសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវការជួសជុលការខូចខាត។ "តុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើត ដោយខ្លួនឯង នូវគោលការណ៍ទាំងឡាយ ដែលអាចអនុវត្តបានចំពោះទំរង់ នៃការជួសជុលការខូចខាត ដូចជា ការប្រគល់វត្ថុអោយវិញ ការសងសំណង និងការផ្តល់នីតិសម្បទាឡើងវិញ ដែលត្រូវធ្វើ ឡើងចំពោះជនរងគ្រោះ ឬសិទ្ធិវន្តរបស់ជនរងគ្រោះ"។ តុលាការនេះ អាចកំណត់ពីកំរិតនៃការខូចខាតនៃការបាត់បង់ ឬនៃព្យសនកម្ម។ ដូច្នេះ តុលាការអាចសំរេចការជួសជុលការ ខូចខាត ដែលមានទំរង់ជាលក្ខណៈបុគ្គល និងរួម។ នៅក្នុងករណីដែលការជួសជុលបានធ្វើឡើងជាលក្ខណៈបុគ្គល តុលាការចេញដីកាប្រឆាំងនឹងជនដែលត្រូវបានផ្តន្ទាទោស (មាត្រា ៧៥ កថាខ័ណ្ឌ ២ របស់លក្ខន្តិកៈ និងមាត្រា ៩៨-២ របស់វិធាន នីតិវិធី និងភស្តុតាង)។ តុលាការអាចសំរេចផងដែរថា ប្រាក់សំរាប់ជួសជុលត្រូវតំកល់ នៅមូលនីធិសំរាប់ជនរងគ្រោះ ប្រសិនបើនៅពេលវិនិច្ឆ័យ ប្រាក់នោះមិនអាចប្រគល់ទៅអោយ ជនរងគ្រោះ ម្នាក់ៗដាច់ដោយឡែកពីគ្នាបាន។ ប្រាក់ដែលបានធ្វើការបែងចែករួចហើយ ត្រូវប្រគល់ទៅអោយជនរងគ្រោះ អោយបានឆាប់តាមតែអាចធ្វើទៅបាន។ នៅទីបញ្ចប់ តុលាការអាចសំរេចថា ប្រាក់សំរាប់ការជួសជុលត្រូវចែកចាយ ដោយឆ្លងតាមរយៈមូលនីធិសំរាប់ជនរងគ្រោះ នៅពេលដែលការជួសជុលជារួមមានលក្ខណៈសមស្របជាង ដោយយោងទៅលើ ចំនួនជនរងគ្រោះ កំរិតទំរង់ និងបែបបទនៃការជួសជុលការ ខូចខាត (មាត្រា ៧៩ របស់លក្ខន្តិកៈ និងមាត្រា ៩៨ របស់វិធាន នីតិវិធី និងភស្តុតាង)។ នៅក្នុងន័យនៃការជួសជុលការខូចខាត តុលាការអាចចាត់វិធានការថែរក្សា ដែលរដ្ឋទាំងឡាយមានកាតព្វកិច្ចប្រតិបត្តិតាម ដោយអនុវត្តនូវកាតព្វកិច្ចក្នុងការសហការ (ចំពោះកិច្ចសហប្រតិបត្តិការក្នុងវិធានការណ៍ថែរក្សា សូមមើលមាត្រា ៧៥ កថា ខ័ណ្ឌ ៤, មាត្រា ៥៧ កថាខ័ណ្ឌ ៣ វាក្យខ័ណ្ឌ *ង.* និង មាត្រា ៩៣ កថាខ័ណ្ឌ ១ វាក្យខ័ណ្ឌ *ង.* នៃលក្ខន្តិកៈទីក្រុងរ៉ូម និង មាត្រា ៩៩ របស់វិធាននីតិវិធី និង ភស្តុតាង)។

តុលាការអាចប្រកាសទោសដកហូតប្រាក់ចំណូល វត្ថុ និងធនធាន ដែលបានទាញយកដោយផ្ទាល់ ឬមិនផ្ទាល់ពីបទឧក្រិដ្ឋ (ចំពោះការអនុវត្តនីវិធានការណ៍ ដកហូត និងដីកាជួសជុលការខូចខាត សូមមើល មាត្រា ៧៥ កថាខ័ណ្ឌ ៥, មាត្រា ៧៧ កថាខ័ណ្ឌ ២ នៃលក្ខន្តិកៈ និងមាត្រា ២១៧ ដល់ ២១៩ និង ២២១-២ នៃវិធាននីតិវិធី និងភស្តុតាង)។

### ១- កាតព្វកិច្ចក្នុងការសហការដើម្បីការជួសជុលការខូចខាត

ការអនុវត្តវិធានការជួសជុលការខូចខាតមានប្រភពពីរបបនៃកិច្ចសហប្រតិបត្តិការរបស់រដ្ឋទាំងឡាយ នៅក្នុងក្របខ័ណ្ឌទូទៅនៃការអនុវត្តនីទោស ហើយមិនមែននៅក្នុងក្របខ័ណ្ឌនៃការជួសជុលការខូចខាតរបស់ជនរងគ្រោះទេ[៨៩]

៨៩. សូមមើលផ្នែកទី៥។

លើកលែងតែក្នុង ករណីដោយឡែកនៃការស្នើសុំអោយមានកិច្ចសហប្រតិបត្តិការសំរាប់អនុវត្តវិធាន ការណ៍ថែរក្សាដើម្បីធ្វើការរឹបអូស ( មាត្រា ៧៥ កថាខ័ណ្ឌ ៥ មាត្រា ៧៧ កថាខ័ណ្ឌ ២ មាត្រា ៧៩ កថាខ័ណ្ឌ ២ នៃលក្ខន្តិកៈ និង មាត្រា ២១៧ ដល់ ២១៩ និង ២២១-២ នៃវិធាននីតិវិធី និងភស្តុតាង) ។

មាត្រា ៧៥ កថាខ័ណ្ឌ ៤ របស់លក្ខន្តិកៈ បានផ្តល់អំណាចអោយតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងការស្នើសុំរដ្ឋជាភាគីទាំងឡាយ នូវវិធានការណ៍នៃកិច្ចសហប្រតិបត្តិការ ដែលមានចែងនៅក្នុងមាត្រា ៩៣ កថាខ័ណ្ឌ ១។ បទបញ្ញត្តិជាច្រើននៃកថាខ័ណ្ឌនេះ អនុញ្ញាតិអោយមានការអនុម័តវិធានការណ៍ជួសជុលដែលសក្តិសម : វាក្យខ័ណ្ឌ *ក* អនុញ្ញាតិអោយមានការកំណត់ទីតាំងទ្រព្យរបស់មនុស្សម្នាក់ វាក្យ ខ័ណ្ឌ *ដ "កំណត់អត្តសញ្ញាណ កំណត់ទីតាំង ប្រមូល ឬរឹបអូសផលពីបទឧក្រិដ្ឋ ទ្រព្យ ធនធាន និងឧបករណ៍នានា ដែលមានការជាប់ពាក់ព័ន្ធនឹង បទឧក្រិដ្ឋ ដើម្បីធ្វើការដក ហូតជាយថាហេតុ"* វាក្យ ខ័ណ្ឌ *ថ* បានពង្រីកកិច្ចសហប្រតិបត្តិការទៅលើ ជំនួយផ្សេងៗខាងផ្នែកច្បាប់របស់រដ្ឋ។ ម៉្យាងវិញទៀត មាត្រា ៩៦ នៃលក្ខន្តិកៈ បានបញ្ជាក់ពីខ្លឹមសាររបស់ការ សុំអោយមានកិច្ចសហប្រតិបត្តិការ។

កិច្ចសហប្រតិបត្តការ ដើម្បីជួសជុលការខូចខាតនេះ អាចបង្កើតនូវបញ្ហាពីរយ៉ាង។ ជាបឋម ចំពោះរដ្ឋទទួលសំណើ វិធានការណ៍ទាំងនេះអាចប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ឬ ផលប្រយោជន៍សំខាន់ ផ្សេងៗទៀតរបស់ខ្លួន។ តាមការពិត សន្ធិសញ្ញាទាំងឡាយ ដែលស្តីពីកិច្ចសហប្រតិបត្តិការខាងយុត្តាធិការអន្តរជាតិក្នុងវិស័យព្រហ្មទណ្ឌ ជាទូទៅតែងតែមានព្រំដែនកំណត់។ ប៉ុន្តែ សន្ធិសញ្ញាទាំងនោះមិនបានបង្កអោយមានឧបសគ្គ ដល់ការបំពេញកាតព្វកិច្ចក្នុងការសហការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិទេ។

បន្ទាប់មកទៀត អាជ្ញាធរជាតិអាចទទួលយកសំណើផ្សេងៗទៀត ដូចជាការស៊ើបអូសជាដើម ដែលធ្វើឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និងដោយរដ្ឋណាមួយដែលជាភាគី ឬមិនមែនជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម។ បញ្ហានេះ ត្រូវបានដោះស្រាយដោយម្រាតា ៩៣ កថាខ័ណ្ឌ ៩ *វាក្យខ័ណ្ឌ ក* នៃលក្ខន្តិកៈ ដែលធ្វើការបែងចែកជាពីរករណី :

- រដ្ឋទទួលសំណើជាប់កាតព្វកិច្ចអន្តរជាតិជាមួយតតីយរដ្ឋ ដែលអាចបង្កអោយមានឧបសគ្គដល់ការបំពេញកាតព្វកិច្ចរបស់ខ្លួន ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ។ នៅក្នុងករណីនេះ អាជ្ញាធរជាតិត្រូវខ្នះខ្នែង *"ឆ្លើយតបសំណើទាំងពីរ"* (មាត្រា ៩៣ កថាខ័ណ្ឌ ៩ *ក. i* នៃលក្ខន្តិកៈទីក្រុងរ៉ូម) ហើយចំពោះអ្នកតាក់តែងច្បាប់កម្ពុជាត្រូវបញ្ជាក់អោយបានច្បាស់ ថាតើអាជ្ញាធរមួយណា (ក្រសួងកិច្ចការបរទេស ឬក្រសួងយុត្តិធម៌) ដែលនឹងដឹកនាំការពិគ្រោះយោបល់ដោះស្រាយបញ្ហា ដែលជាកាតព្វកិច្ចមធ្យោបាយ (obligation de moyen) នេះ។

-យោងតាមមាត្រា ៩៣ កថាខ័ណ្ឌ ៩ *វាក្យខ័ណ្ឌ ក* ចំនុច *ii* ប្រសិនបើគេមិនអាចធ្វើទៅបានទេ បញ្ហានេះត្រូវបានដោះស្រាយ ដោយយោងតាមមាត្រា ៩០ នៃលក្ខន្តិកៈ។ ជាលទ្ធផល សេចក្តីសំរេចត្រូវគិតអំពី *"កត្តាដែលពាក់ព័ន្ធទាំងអស់ ដែលរួមមានដូចជា លំដាប់កាលបរិច្ឆេទរបស់សំណើ ផលប្រយោជន៍របស់[តតីយ] រដ្ឋ ហើយជា*

*ពិសេស ការដែលថាបទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួន និងសញ្ជាតិរបស់ជនរងគ្រោះ (...) និងលទ្ធភាពដែលថា [ តតិយ] រដ្ឋបានចាត់នីតិវិធី [ ដោយអនុវត្តតាមការស្នើសុំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ] "។*

## ២- ការតព្វកិច្ចអនុវត្តដីកាជួសជុលការខូចខាត

ការអនុវត្តន៍ដីកាជួសជុល របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវគោរពតាមគោលការណ៍ធំៗចំនួនពីរ : ទីមួយ គឺគោលការណ៍នៃអំណាចរបស់ដីកា (le principe de l'autorité des ordonnances) ដែលត្រូវទទួលស្គាល់ ជាដាច់ខាត និងទីពីរ គឺគោលការណ៍នៃកម្លាំងចាប់បង្ខំអោយអនុវត្តរបស់ដីកា (le principe de leur force exécutoire) ដោយយោងទៅនីតិវិធីជាតិ។

មាត្រា ៧៥ កថាខ័ណ្ឌ ៥ និង មាត្រា ១០៩ របស់លក្ខន្តិកៈ បានដាក់បង្ខំអោយរដ្ឋទាំងឡាយ ទទួលស្គាល់យ៉ាងដាច់ខាត នូវដីកា ជួសជុលការខូចខាត នៅក្នុងបទដ្ឋានក្នុងស្រុករបស់ខ្លួន។

មាត្រា ២១៩ នៃវិធាននីតិវិធី និងភស្តុតាងបានហាមឃាត់ដល់រដ្ឋជាភាគីទាំងឡាយធ្វើការកែប្រែដីកានេះនោះទេ។ ដូច្នេះ ប្រទេសកម្ពុជាមិនអាចដាក់ដីកានេះអោយនៅក្រោមនីតិវិធីនៃការត្រួតពិនិត្យបានទេ។ ដូចនេះ ជាលទ្ធផល ច្បាប់ក្នុងស្រុកត្រូវតែសំរបខ្លួនតាម។

ចំពោះលក្ខខណ្ឌទំរង់ ដែលមានចែងនៅក្នុងមាត្រា ២១៨ នៃវិធាននីតិវិធី និងភស្តុតាង ដែលអមជាមួយដីការបែបអូស អនុញ្ញាតិអោយរដ្ឋទាំងឡាយបញ្ជាក់ពីភាពត្រឹមត្រូវ និងអនុវត្តដីកាទាំងនេះអោយបានសមស្រប។ ម៉្យាងទៀត មាត្រានេះបានអនុញ្ញាតិអោយរដ្ឋទាំងឡាយរៀបចំអោយមានលក្ខណៈដូចគ្នា នូវនីតិវិធីនានាក្នុងការអនុវត្តដីកា។

វិធាននីតិវិធី និង ភស្តុតាងបានបញ្ជាក់អំពីនីតិវិធីនៃការចាត់វិធានការណ៍ និងកិច្ចសហប្រតិបត្តិការដើម្បីអនុវត្តដីកាទាំងនេះ។ ដូចជា មាត្រា ២១៧ នៃវិធានបានចែងពីលទ្ធភាពសំរាប់ចាងហ្វាងតុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើការស្នើសុំអោយមានកិច្ចសហប្រតិបត្តិការពីរដ្ឋទាំងឡាយ ដោយយោងទៅតាមជំពូកទី IX នៃលក្ខន្តិកៈទីក្រុងរ៉ូមទាំងស្រុង ហើយមិនមែនគ្រាន់តែតាមមាត្រា ៩៣ កថាខ័ណ្ឌ ១ នៃជំពូកនេះប៉ុណ្ណោះនោះទេ។ មាត្រា ៩៦-២ នៃវិធានបានបញ្ញត្តិពីសំណើអោយមានកិច្ចសហប្រតិបត្តិការ ដែលបានធ្វើឡើងទៅកាន់រដ្ឋនានា ចំពោះវិធានការផ្សព្វផ្សាយនីតិវិធីនៃការជួសជុលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

## ខ. កិច្ចសហប្រតិបត្តិការរវាងរដ្ឋនឹងរដ្ឋ

វិធាននៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋជាវិធានធម្មតា ទោះជាថ្នាក់ជាតិក្តី ឬថ្នាក់អន្តរជាតិក្តី ដែលឆ្លើយតបទៅនឹងគោលការណ៍នៃការបំពេញបន្ថែមអោយគ្នាទៅវិញទៅមក។ ផ្ទុយទៅវិញ យើងគួរតែធ្វើការកែលំអរបែប

បទទាំងអស់នេះអោយមានលក្ខណៈតែមួយវិញ។ អ្នកតាក់តែងច្បាប់កម្ពុជាអាចបង្ខំអាជ្ញាធរយុត្តាធិការ និងរដ្ឋាភិបាលអោយសំរួលវិធានការណ៍នានា មុនការជួសជុលការខូចខាត ដែលមានដូចជា វិធានការណ៍ថែរក្សាជាដើម និងមានកំណត់នូវការទទួលស្គាល់ដាច់ខាត ព្រមទាំងនីតិវិធីអនុវត្តសេចក្ដីសំរេចបរទេសណាមួយ ស្ដីពីការជួសជុល ការខូចខាត (une procédure d'exequatur simplifiée des jugements de réparation)។ នៅក្នុងករណីនេះ អនុសញ្ញាប្រ៊ុចសែល (la Convention de Bruxelles) ដែលស្ដីពីសមត្ថកិច្ចតុលាការ និងការអនុវត្តសេចក្ដីសំរេច ក្នុងវិស័យរដ្ឋប្បវេណី និងពាណិជ្ជកម្ម និងអនុសញ្ញាលុយហ្កាណូ (la Convention de Lugano) ដែលស្ដីពីសមត្ថកិច្ចតុលាការ និងការអនុវត្តសេចក្ដីសំរេចក្នុងវិស័យ រដ្ឋប្បវេណី និងពាណិជ្ជកម្ម អាចយកមកធ្វើជាសេចក្ដីយោងបាន។

## ជំពូក២ : នីតិវិធីនៅប្រទេសកម្ពុជា

យើងគួរចោទទៅលើបញ្ហាសមត្ថកិច្ចរបស់តុលាការ រដ្ឋប្បវេណីខ្មែរចំពោះការសំរេចលើបញ្ហានៃពាក្យសុំជួសជុលការខូចខាត ដែលបានធ្វើឡើងដោយជនរងគ្រោះណាម្នាក់ នៅពេលដែលបណ្ដឹងអាជ្ញាត្រូវបានធ្វើឡើងនៅចំពោះមុខតុលាការមួយផ្សេងទៀត។ស្ថានភាពចំនួនបីអាចលើកឡើងអាស្រ័យទៅតាមទីកន្លែងដែលបណ្ដឹងអាជ្ញានេះបានប្រព្រឹត្តទៅ: នៅប្រទេសកម្ពុជា នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ និងនៅចំពោះមុខតុលាការរបស់ប្រទេសណាមួយផ្សេងទៀត។

### ក. នីតិវិធីព្រហ្មទណ្ឌនៅប្រទេសកម្ពុជា

#### ១- ការកំណត់ពីសមត្ថកិច្ច

មាត្រា ៥-៤ នៃអនុសញ្ញាប្រ៊ុចសែល បានស្នើនូវដំណោះស្រាយដ៏សាមញ្ញមួយ ដែលតម្រូវអោយមានការផ្លាស់ប្ដូរច្បាប់ខ្មែរ តិចតួចប៉ុណ្ណោះ។ មាត្រានេះចែងថា ចុងចោទអាចត្រូវបានគេនាំមកបំភ្លឺ *"ប្រសិនបើជាបណ្ដឹងសុំជួសជុលការខូចខាត ឬបណ្ដឹងអោយប្រគល់សងវិញ ដែលមានមូលដ្ឋានលើបទល្មើស នៅចំពោះមុខតុលាការដែលបណ្ដឹងអាជ្ញាបានធ្វើឡើងដែលតាមច្បាប់តុលាការនេះអាចដោះស្រាយបណ្ដឹងរដ្ឋប្បវេណីបាន"*។ នីតិរដ្ឋមានកម្ពុជាមិនមានចែងនូវលទ្ធភាពនេះទេ ចំពោះករណីបណ្ដឹងរដ្ឋប្បវេណីដែលធ្វើនៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ មាត្រា កម ១៣១-៩ នៃសេចក្ដីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បានលើកឡើងនូវបញ្ហានេះ ដោយបានចែងថា :

> "បណ្ដឹងរដ្ឋប្បវេណីអាចធ្វើឡើង ប្រឆាំងទៅនឹងជនទាំងអស់ដែលត្រូវជួសជុលព្យសនកម្ម ដែលជាលទ្ធផលនៃបទល្មើសពោលគឺ :
>
> - ចារី និងសហចារីនៃបទល្មើស

- អ្នកសមគំនិត
- *អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី*" (អក្សរ ទ្រេតត្រូវបានបន្ថែម)។

នៅក្នុងករណីដែលបណ្តឹងរដ្ឋប្បវេណីធ្វើឡើងនៅចំពោះមុខតុលាការរដ្ឋប្បវេណីកម្ពុជា សារាចរលេខ ០៤-៨៤ របស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី ៨ កញ្ញា ១៩៨៤ ដែលស្តីពីនីតិវិធីរដ្ឋប្បវេណី បានចែងនៅក្នុង "កំណត់សំគាល់" II ចំណុច ២ នូវការចូល មកឆ្លើយបំភ្លឺរបស់ចុងចោទ ដោយបានចែងថា ៖

"II - ឧប្បត្តិហេតុនៅពេលជំនុំជំរះ

២- ការនាំតតីយជនជាដើមបណ្តឹង ឬ ចុងចោទនៃរឿងក្តីមកបំភ្លឺ

ដើម្បីជាផលប្រយោជន៍របស់ភាគីទាំងអស់នៅពេលពិភាក្សាដេញដោល ចៅក្រមអាចអោយតតីយជនចូលមកបំភ្លឺ ក្នុងនាមជាដើមបណ្តឹង ឬជាចុងចម្លើយ ដែលមានទំនាក់ទំនងជាមួយនឹងរឿងក្តី"។

ជាអកុសល សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីមិនបានយកលំនាំតាមបទបញ្ញត្តិរបស់សារាចរលេខ ០៤-៨៤ នេះទេ។ ដូច្នេះ យើងគួរតែបញ្ចូលបញ្ញត្តិនេះទៅក្នុងមាត្រា ៨៤ នៃសេចក្តីព្រាង ដែលទាក់ទងនឹងការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុបណ្តឹង។

### ២- ការពង្រីកសមត្ថកិច្ច

និយមន័យរបស់គោលការណ៍នៃការជួសជុលត្រូវយកលំនាំតាមការវិវត្តន៍របស់នីតិអន្តរជាតិ (ជាសំភារៈ ឬជាយុត្តិសាស្ត្រ) ដែលត្រូវបានចងជាក្រមដោយ *គោលការណ៍ជាមូលដ្ឋាន និងការណែនាំទាំងឡាយ ដែលទាក់ទងនឹងសិទ្ធិក្នុងការប្តឹង ឬជួសជុលការខូចខូតរបស់ជនរងគ្រោះពីការរំលោភបំពានយ៉ាងជាក់ស្តែងលើ នីតិអន្តរជាតិ ស្តីពីសិទ្ធិមនុស្ស និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើនីតិមនុស្សធម៌អន្តរជាតិ* ដែលបានអនុម័តនៅថ្ងៃទី ១០ វិច្ឆិកា ២០០៥ ដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។ អត្ថបទនេះ បានយកលំនាំដោយផ្ទាល់ ពីការតាក់តែងរបស់មាត្រា ៧៥ កថាខ័ណ្ឌ ១ នៃលក្ខន្តិកៈ ដូចដែលបានលើកឡើងនៅក្នុងការងារត្រៀមរៀបចំចងក្រង។

## ខ. នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ

ទន្ទឹមគ្នានឹងនីតិវិធី ដែលបើកចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិក្រោមលក្ខខណ្ឌនៃការភ្ជាប់បទឧក្រិដ្ឋទៅតុលាការជាតិ ដែលមានចែងនៅក្នុងច្បាប់ក្នុងស្រុក ជនរងគ្រោះត្រូវមានអំណាចស្នើសុំ នៅចំពោះមុខតុលាការកម្ពុជា អោយមានការជួសជុលព្យសនកម្ម ដែលមានប្រភពពីបទឧក្រិដ្ឋទាំងឡាយ ដែលគេបានស្គាល់។

ប្រសិនបើដីកាជួសជុលការខូចខាតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានធ្វើឡើងជាមុន សមត្ថកិច្ចរបស់តុលាការកម្ពុជា ចាំបាច់ត្រូវកំណត់តែលើការខូចខាតទាំងឡាយ ដែលដីការបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនេះមិនបានសំរេចអោយមានការជួសជុល ។

## គ. នីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខតុលាការរបស់តតិយរដ្ឋណាមួយ

គេត្រូវអនុវត្តតាមវិធានធម្មតានៃការជួយគ្នាទៅវិញទៅមកខាងយុត្តាធិការរដ្ឋប្បវេណី ជាពិសេសក្នុងការជូនដំណឹងជាលាយល័ក្ខអក្សរ និងការជូនដំណឹងតាមផ្លូវតុលាការ (en matière de notification et de signification) តាមគំរូរបស់អនុសញ្ញាក្រុងឡាអេ (la Convention de la Haye) ឆ្នាំ ១៩៦៥។ ផ្ទុយទៅវិញ ចំពោះការប្តឹងទៅតុលាការពីរ សំរាប់រឿងក្តីតែមួយ (la litispendance) និងការបញ្ចូលទៅក្នុងនីតិវិធីតែមួយនូវ រឿងក្តីពីរ ដែលមានទំនាក់ទំនងនឹងគ្នា (la connexité) យើងគួរតែអនុម័តនូវវិធាននៃកិច្ចសហប្រតិបត្តិការដ៏រឹងមាំ ដែលយកគំរូតាមមាត្រា ២១ និង ២២ របស់អនុសញ្ញាប្រ៊ុចសែល ។

បន្ទាប់មកទៀត វិធានការនៃកិច្ចសហប្រតបត្តិការជាក់ស្តែង រវាងយុត្តាធិការនិងយុត្តាធិការ ត្រូវតែមានចែងក្នុងច្បាប់ជាពិសេសចំពោះការផ្លាស់ប្តូរព័ត៌មានរវាងយុត្តាធិការទាំងឡាយ ។ នៅគ្រប់ករណីទាំងអស់ ប្រសិនបើសេចក្តីសំរេចរបស់តុលាការបរទេសបានធ្វើឡើងមុនសេចក្តីសំរេចរបស់តុលាការម្ពុជានោះ អាជ្ញាអស់ជំនុំត្រូវបញ្ឈប់នីតិវិធីតាមច្បាប់ម្ពុជា នៅក្នុងព្រំដែននៃការខូចខាត ដែលតុលាការបរទេសបានសំរេច ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**១- ចំពោះនីតិវិធីនៅចំពោះមុខតុលាការបរទេសណាមួយ ឬនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ**

**ក- ចំពោះកិច្ចសហប្រតិបត្តិការ ជាមួយនឹង តុលាការព្រហ្មទណ្ឌអន្តរជាតិ**

**អោយបញ្ចូលទៅក្នុងសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងគន្ថីទី ៧ ស្តីពីវិធានការណ៍ថែរក្សា នូវជំពូកទី ៤ ថ្មីមួយស្តីពីកិច្ចសហប្រតិបត្តិការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងគោលបំណងដកហូត ដើម្បីជួសជុលការខូចខាត (មាត្រា ៥៧ កថាខ័ណ្ឌ ៣ ខ. មាត្រា ៩៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម និងមាត្រា ៩០ នៃវិធាននីតិវិធី និងភស្តុតាង)។ ក្រៅពីមាត្រា ៥៧៣ ថ្មី ជំពូកទី ៤ ថ្មី មានមាត្រា ៥៧២ ថ្មី (សូមមើលអនុសាសន៍ខាងក្រោម) ។**

**ជាលទ្ធផល មាត្រា ៥៧២ ដើមនៃសេចក្តីព្រាងក្រមរដ្ឋប្បវេណី ដែលមានចំណងជើងថា "ការចូលជាធរមានរបស់ក្រម" បានក្លាយទៅជាមាត្រា ៥៧៤ ហើយគន្ថីទី ៨ ដែលមានចំណងជើងថា "អវសានបញ្ញត្តិ" ដែលមានមាត្រា ៥៧២ ពីមុន នឹងស្ថិតនៅបន្ទាប់ពីមាត្រា ៥៧៣ ថ្មី ។**

ជំពូកទី ៤ និង មាត្រា ៥៧៣ មានចែងដូចតទៅ :

*"គន្ថីទី ៧ : វិធានការណ៍ថែរក្សា*

*ជំពូកទី ៤ : កិច្ចសហប្រតិបត្តិការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ*

[មាត្រា ៥៧២ : សូមមើលអនុសាសន៍ខាងក្រោម]

*មាត្រា ៥៧៣ (វិធានការណ៍ថែរក្សា ដែលបានស្នើសុំដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីជួសជុលការខូចខាត)*

*ការអនុវត្តន៍នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នូវវិធានការណ៍ថែរក្សាដែលជាកម្មវត្ថុនៃការស្នើសុំអោយមានកិច្ចសហប្រតិបត្តិការ ដែលបានធ្វើឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចដែលមានចែងនៅក្នុងមាត្រា កម ៥១២-១ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ* [មាត្រាដែលបាន ស្នើឡើងដោយ អេហ្វ អ៊ី ដេ អាស សូមមើលខាងដើម] *ហើយដោយ អនុវត្តតាមមាត្រា ៩៣ កថាខ័ណ្ឌ ១ វាក្យខ័ណ្ឌ ជ. នៃលក្ខន្តិកៈទីក្រុងរ៉ូម ត្រូវប្រព្រឹត្តិទៅតាមការចំណាយរបស់រតនាគារជាតិ និងតាមបែបបទដែលមានចែងនៅក្នុងក្រមនេះ ដោយតុលាការមានសមត្ថកិច្ចក្រោយពេលដែលតុលាការនេះបានទទួល បណ្តឹងរបស់ព្រះរាជអាជ្ញាក្នុងគោលបំណងនេះ ឬ ដោយភាគីនៃរឿងក្តីប្រសិនបើម្ចាស់កម្មសិទ្ធិបានដឹងពីប្រភព ឬ ពិការប្រើប្រាស់ដោយបំពាន ។*

*ការលើកលែងទាំងស្រុង ឬ មួយផ្នែកនូវវិធានការថែរក្សា អាចស្នើសុំដោយជនទាំងឡាយដែលមានផលប្រយោជន៍ ។*

*ចាងហ្វាងតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវតែបានជូនដំណឹងជាមុនពីការលើកលែងនេះ ។*

*គោរអនុញ្ញាតិអោយអនុវត្តសេចក្តីសំរេចនៃការរឹបអូស ដែលបានធ្វើឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាការផ្តល់នូវសារៈសំខាន់ដល់វិធានការរឹបអូស និងនាំអោយមានការធានាដល់ការជួសជុលសំណង" ។*

-អោយធ្វើការកែប្រែមាត្រា ៥៣៧ នៃសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាលទ្ធផលនៃការតាក់តែងថ្មីរបស់មាត្រា ៥៧៣ នៃក្រមដដែល ដោយធ្វើការបន្ថែមនូវកថាខ័ណ្ឌទី ៦ ស្តីពីការទទួលបន្ទុក របស់រតនាគារជាតិ ចំពោះការចំណាយនានា ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តវិធានការណ៍ថែរក្សា។ កថាខ័ណ្ឌទី ៦ និងចុងក្រោយបង្អស់របស់មាត្រា ៥៣៧ មានចែងដូចតទៅ :

*"នៅពេលដែល ការស្នើសុំដើម្បីអោយមានការអនុវត្តន៍វិធានការណ៍ថែរក្សាត្រូវបានធ្វើឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ រាល់ការចំណាយទាំងអស់ជាបន្ទុករបស់រតនាគារជាតិ"*។

ខ- ចំពោះការទទួលស្គាល់ និងការអនុវត្តសេចក្តីសំរេច

- អោយបញ្ចូលទៅក្នុងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ត្រង់ជំពូកទី ៤ ថ្មី ដែលបានស្នើឡើងខាងលើ ស្តីពីកិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ នូវមាត្រា ៥៧២ ស្តីពីការទទួលស្គាល់សេចក្តីសំរេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងរបស់ប្រទេសផ្សេងៗទៀត ដែលជាភាគី ឬ មិនមែនជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម ។ មាត្រា ៥៧២ មានចែងដូចតទៅ :

*"មាត្រា ៥៧២ (ការទទួលស្គាល់សេចក្តីសំរេចរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ និង របស់រដ្ឋជាភាគី ឬមិនមែនជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ)*

*សេចក្តីសំរេចទាំងអស់ដែលផ្អែកលើមាត្រា ៧៥ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលទាក់ទងនឹងការជួសជុលការខូចខាត ដោយរាប់បញ្ចូលទាំងសេចក្តីសំរេចលើវិធានការណ៍បណ្តោះអាសន្ន និងថែរក្សា ឬ សេចក្តីសំរេច ដែលពាក់ព័ន្ធនឹងមូលនិធិសំរាប់ជនរងគ្រោះ ដែលបានចែងនៅក្នុងមាត្រា ៧៩ នៃលក្ខន្តិកៈស្តីពីប្រាក់ពិន័យ និងការរឹបអូសទោះបីជាបានធ្វើឡើងដោយតុលាការរបស់រដ្ឋណាមួយជាភាគីនៃលក្ខន្តិកៈ និងមានកម្លាំងអនុវត្តនៅក្នុងរដ្ឋនេះ ឬដោយតុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ត្រូវមានការទទួលស្គាល់ ជាដាច់ខាត ដោយយោងទៅតាម មាត្រា ១០៩ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ និងមាត្រា ២១៧ និង ២១៩ នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ វាត្រូវតែបានប្រកាសពីកម្លាំងអនុវត្ត ដោយប្រធានតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំរបស់ភាគីនៃរឿងក្តី ។*

*សេចក្តីសំរេចទាំងឡាយ ដែលបានធ្វើឡើងនៅក្នុងរដ្ឋណាមួយដែលជាភាគីនៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអាចមានកម្លាំងអោយអនុវត្តនៅលើទឹកដីរបស់ប្រទេសកម្ពុជាទេប្រសិនបើ :*

*- សេចក្តីសំរេចនោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ*

*- សេចក្តីសំរេចនោះទទួលបាន ដោយការក្លែងបន្លំ*

*- សេចក្តីសំរេចនោះមិនអាចផ្សះផ្សាបានជាមួយនឹងសេចក្តីសំរេចណាមួយ ដែលបានចេញដោយតុលាការកម្ពុជា ឬជាមួយសេចក្តីសំរេចណាមួយ ដែលចេញដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬជាមួយសេចក្តីសំរេចណាមួយរបស់តុលាការបរទេស ដែលមានអនុភាពនៅលើព្រះរាជាណាចក្រកម្ពុជា ។ សេចក្តីសំរេចដែលបានធ្វើឡើងនៅក្នុងរដ្ឋណាមួយ ដែលមិនមែនជាភាគីនៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវមានការទទួលស្គាល់ និងប្រកាសថា មានកម្លាំងអាចអនុវត្តបាន តាមលក្ខខណ្ឌរបស់នីតិរូម ឬសន្ធិសញ្ញាដែលអាចអនុវត្តបាន" ។*

អេហ្វ អ៊ី ដេ អាស សន្និដ្ឋាន :

**២**- ចំពោះនីតិវិធីនៅចំពោះមុខតុលាការខ្មែរ

- ទាក់ទងទៅនឹងមាត្រា កម ២១១១-១, កម ២១២១-១, កម ២១៣១-១ និង កម ២១៣១-២ [តាមការតាក់តែង ដែលបានស្នើជាអនុសាសន៍ ដោយ អេហ្វ អ៊ី ដេ អាស សូមមើលនៅខាងដើម ទំព័រ៣១, ៣៨, ៣៩, ៤២, ៤៤, ៤៥, ៤៦] នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ដែលបានបញ្ចូលបទឧក្រិដ្ឋទាំងឡាយ ដែលបានកំណត់ និងអោយនិយមន័យ ដោយមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ព្រមទាំងមាត្រា កម ១៣១-៩ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងពីការចូលមកបំភ្លឺរបស់ចុងចោទនៅចំពោះមុខតុលាការដែលបណ្តឹងអាជ្ញា បានធ្វើ ឡើង ចំពោះការជួសជុលការខូចខាត ឬការប្រគល់សងវិញ ដែលបានផ្អែកលើមូលដ្ឋាននៃបទល្មើស ថាជាការមួយ ដែលវិជ្ជមាន ។

នៅទីបញ្ចប់ អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ផងដែរ :

- អោយមានការបញ្ចូលទៅក្នុងមាត្រា ៨៤ នៃសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ស្តីពីការបន្ថែម និងការផ្លាស់ប្តូរកម្មវត្ថុរបស់ពាក្យសុំ នូវកថាខ័ណ្ឌទី២ថ្មី ស្តីពីការចូលបំភ្លឺរបស់ចុងចោទនៅចំពោះមុខតុលាការរដ្ឋប្បវេណីកម្ពុជា នៅពេលណាដែលមានបណ្តឹងអោយជួសជុលការខូចខាត ឬបណ្តឹងអោយប្រគល់សងវិញ ដែលផ្អែកលើមូលដ្ឋាន នៃបទឧក្រិដ្ឋមួយ ឬច្រើន ដែលមានចែងនៅក្នុងមាត្រា កម ២១១១-១, កម ២១២១-១, កម ២១៣១-១ និង កម ២១៣១-២ [ដូចដែល អេហ្វ អ៊ី ដេ អាស បានផ្តល់អនុសាសន៍អោយធ្វើវិសោធនកម្ម លើការតាក់តែង សូមមើលផ្នែកទី៣] នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ។ អត្ថបទតាក់តែងពីដើម របស់មាត្រា ៨៤ ត្រូវបានផ្លាស់ប្តូរដូចតទៅ :

*"មាត្រា ៨៤ ( ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុរបស់ពាក្យសុំ និងការចូលមកបំភ្លឺរបស់ចុងចោទ)*

*១. ចំពោះការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុរបស់ ពាក្យសុំ :*

*ក- ដើមបណ្តឹងអាចបន្ថែមកម្មវត្ថុណាមួយ ទៅក្នុងពាក្យសុំ ឬផ្លាស់ប្តូរកម្មវត្ថុដើមរបស់ពាក្យសុំ រហូតដល់ចុងបញ្ចប់នៃការ ពិភាក្សាដេញដោលដោយផ្ទាល់មាត់ ប្រសិនបើវាមិនមានការផ្លាស់ប្តូរមូលហេតុគតិយុត្តិ ដែលជាមូលដ្ឋានរបស់ពាក្យសុំពី មុនទៅក្នុងករណីដែលការបន្ថែម ឬការផ្លាស់ប្តូរនេះនឹងបង្កអោយមានការយឺតយ៉ាវយ៉ាងខ្លាំង នឹងមិនត្រូវបានអនុញ្ញាតិទេ ។*

*ខ- ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុរបស់ពាក្យសុំ ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ។*

*គ- ការសរសេរជាលាយល័ក្ខអក្សរ ដែលមានចែង នៅក្នុងវាក្យខ័ណ្ឌខាងលើ ត្រូវបញ្ជូនទៅអោយភាគីម្ខាងទៀត ។*

*ឃ-ប្រសិនបើការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុរបស់ពាក្យសុំ មិនមានលក្ខណៈសមស្របទៅនឹងការតំរូវរបស់យុត្តិធម៌ ទេ នោះចៅក្រមត្រូវចេញដីកាបដិសេធការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុរបស់ពាក្យសុំនេះ ។ ចៅក្រមអាចចេញដីកាបដិសេធនេះ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ។*

***២. ចំពោះការចូលមកបំភ្លឺរបស់ចុងចម្លើយ : ចុងចម្លើយ អាចត្រូវបានគេនាំមកឆ្លើយបំភ្លឺនៅមុខតុលាការរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងអោយជួសជុលការខូចខាត ឬបណ្តឹងអោយប្រគល់សងវិញ ដែលបានផ្អែកលើមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌរបស់នីតិរូបណាមួយ ឬ ដែលមានចែងនៅក្នុងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ" ។***

# ផ្នែកទី៧ ៈ ការថែរក្សាសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះការបង្ក្រាបបទឧក្រិដ្ឋទាំងឡាយ ដោយអនុវត្តនូវបទដ្ឋានអន្តរជាតិដែលមានលក្ខណៈសមស្រប

## សេចក្តីផ្តើម

លក្ខន្តិកៈទីក្រុងរ៉ូមជាមូលដ្ឋានគតិយុត្តិបំពេញបន្ថែមសម្រាប់តុលាការព្រហ្មទណ្ឌជាតិ (វាក្យខ័ណ្ឌ ១០នៃបុព្វកថា និងមាត្រា ១)។ រដ្ឋទាំងឡាយរក្សាសមត្ថកិច្ចរបស់ខ្លួន ក្នុងការបង្ក្រាបបទឧក្រិដ្ឋ ដែលមានចែងដោយលក្ខន្តិកៈ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត និងជំនុំជម្រះតែនៅក្នុងករណី ដែលរដ្ឋមិនមានឆន្ទៈ ឬ មិនមានសមត្ថភាពដឹកនាំអោយបានល្អបានប៉ុណ្ណោះ (មាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម)។ នៅក្នុងករណីនេះ តុលាការជាតិរបស់រដ្ឋដែលមិនមានសមត្ថភាព ត្រូវបោះបង់រឿងក្តីនោះចោលដោយអនុលោមតាម កាតព្វកិច្ចដែលមានចែងនៅក្នុងលក្ខន្តិកៈខាងលើ (មាត្រា ១៧ ដល់ ១៩)។

លើសពីនេះទៅទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវចាត់តាំងរដ្ឋដែលទទួលបន្ទុកអនុវត្តទោសដាក់ពន្ធនាគារ ហើយរដ្ឋនោះជារដ្ឋដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងការស៊ើបអង្កេត ព្រមទាំងការជំនុំជម្រះដើម្បីឱ្យចូលរួមនៅក្នុងការបង្ក្រាបបទឧក្រិដ្ឋ (មាត្រា ១០៣ នៃ លក្ខន្តិកៈ)។ តែនៅក្នុងករណី ដែលរដ្ឋចាត់តាំងនោះមិនឆ្លើយតបទៅនឹងការធានាជាអន្តរជាតិ ស្តីពីប្រព្រឹត្តកម្មទៅលើអ្នកជាប់ឃុំ និងអ្នកជាប់ពន្ធនាគារទេ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចសំរេចមិនចាត់តាំងរដ្ឋនេះអោយទទួលពិរុទ្ធជនបាន (មាត្រា ១០៣ កថាខ័ណ្ឌ ៣ *ខ*)។ ការណ៍នេះនឹងធ្វើអោយមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់រដ្ឋដែលពាក់ព័ន្ធមិនខាន ប្រសិនបើពលរដ្ឋរបស់ខ្លួនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួនហើយដែលទោសនោះត្រូវបង្ខំឱ្យយកទៅអនុវត្តនៅឯបរទេស។

## ជំពូក១ ៖ ការធានានានាដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ សម្រាប់រឿងក្តីមួយយុត្តិធម៌

ដើម្បីអោយកម្ពុជារក្សាសមត្ថកិច្ចរបស់ខ្លួនក្នុងការបង្ក្រាបបទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ប្រទេសកម្ពុជាចាំបាច់ត្រូវគោរពរាល់ការធានានានា ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិសម្រាប់ឱ្យរឿងក្តីមួយមានយុត្តិធម៌។ តាមពិត អសមត្ថកិច្ចរបស់រដ្ឋបណ្តាលមកពីបញ្ហានានាដូចជាបញ្ហាកង្វះលក្ខណៈសម្បត្តិផ្សេងៗ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានកត់សម្គាល់ជុំវិញបញ្ហានៃការធានានានា ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ សម្រាប់រឿងក្តីមួយយុត្តិធម៌ ( មាត្រា ១៧ កថាខ័ណ្ឌ ២ និងមាត្រា ២០ ) ។

បទដ្ឋានអន្តរជាតិក្នុងការធានានានាឱ្យរឿងក្តីមួយយុត្តិធម៌ ត្រូវបានរៀបរាប់ដោយសង្ខេបនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ។ ដោយសារតែខ្លួនជាសមាជិកនៃកតិកាសញ្ញា ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ១៩៩២ ផង និងការចូលជាធរមានរបស់លិខិតូបករណ៍នេះនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ១៩៩២ ផង ប្រទេសកម្ពុជាត្រូវគោរពកាតព្វកិច្ចទាំងឡាយដែលកើតចេញពីកតិកាសញ្ញានេះ។

លក្ខន្តិកៈទីក្រុងរ៉ូមក៏មានចែងផងដែរនូវបទបញ្ញត្តិដែលទាក់ទងនឹងការធានានានាឱ្យរឿងក្តីមួយយុត្តិធម៌។ ក្នុងន័យនេះ មាត្រា ៥៥ បានចែងជាអាទិ៍នូវការហាមឃាត់រាល់ការបង្ខិតបង្ខំ ឬ ការគំរាមកំហែង ការដាក់ទណ្ឌកម្ម និងការដាក់ទោស ឬ ប្រព្រឹត្តកម្មនានាដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ និងបាត់បង់តំលៃជាមនុស្ស ព្រមទាំងទទួលស្គាល់សិទ្ធិរបស់បុគ្គលក្នុងការមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង ក៏ដូចជាសិទ្ធិមិនសារភាពពីពិរុទ្ធភាព និងសិទ្ធិទទួលបានជំនួយពីមេធាវី ជាពិសេស នៅដំណាក់កាលចោទសួរ និងសិទ្ធិទទួលបាននូវអ្នកបកប្រែ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងផងដែរនូវការធានានានា ដែលចាំបាច់សម្រាប់ឱ្យរឿងក្តីមួយយុត្តិធម៌ ជាអាទិ៍៖ មាត្រា ៣១ បានចែងថា៖ *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"*។ ផ្ទុយទៅវិញ ដូចដែលបាន លើកឡើងពីខាងដើមរួចមកហើយ អនុសញ្ញាអន្តរជាតិជាច្រើន ស្តីពីសិទ្ធិមនុស្សដែលបានផ្តល់សច្ចាប័ន ដោយប្រទេសកម្ពុជា (ឬដែលប្រទេសកម្ពុជាយល់ ព្រមអោយមានការពាក់ព័ន្ធ តាមវិធីផ្សេងៗទៀត ដូចជាឧបាគមន៍ *(l'accession)* ជាដើម) រហូតមកដល់បច្ចុប្បន្ននេះ មិនទាន់បានបញ្ចូលទៅក្នុងច្បាប់ជាតិនៅឡើយទេទោះបីជាវាមានតំលៃរដ្ឋធម្មនុញ្ញក៏ដោយ ដោយយោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ[៩០] ។

៩០. សូមមើលផ្នែកទី២ ជំពូកទី២។

ម្យ៉ាងវិញទៀត មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានហាមឃាត់រាល់អំពើហឹង្សាលើរូបរាងកាយ រាល់ការបង្ខិតបង្ខំខាងស្មារតី ឬ រូបរាងកាយលើជនជាប់ឃុំ ព្រមទាំងបានចែងគោលការណ៍នៃការមិនទទួលយកចម្លើយសារភាព ដែលធ្វើឡើងតាមការបង្ខិតបង្ខំ និងគោលការណ៍សច្ចាធារណ៍នៃនិរទោស។ មាត្រា ៣៩ ចែងពីសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើបណ្តឹងប្រឆាំងនឹងអំពើខុសច្បាប់របស់ភ្នាក់ងារសេវាសាធារណៈរបស់រដ្ឋ និងបុគ្គលិករបស់គេ។ គួរបញ្ជាក់ផងដែរថា ការអនុវត្តអត្ថបទច្បាប់ ដែលមានមុនឆ្នាំ ១៩៧៩ នៅតែមានលក្ខណៈមិនទាន់ច្បាស់លាស់[៩១] សូម្បីតែវាមានចែងអំពីគោលការណ៍ទាំងអស់នេះក៏ដោយ។ រីឯអត្ថបទច្បាប់ក្រោយឆ្នាំ ១៩៧៩ នេះវិញជារួមមានបទបញ្ញត្តិសម័យអន្តរកាល និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ជាដើម មិនមានចែងអំពីការធានានានាសម្រាប់ឱ្យរឿងក្តីមួយយុត្តិធមិទេ។ ជាលទ្ធផល យើងសូមផ្តល់អនុសាសន៍ដល់អាជ្ញាធរ ខ្មែរអោយចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់ខ្លួននូវរាល់បទដ្ឋានអន្តរជាតិនានា សម្រាប់ធានាឱ្យរឿងក្តីមួយមានលក្ខណៈយុត្តិធមិ។ ទាំងនេះគឺមិនគ្រាន់តែជាកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាទេ តែការធ្វើបែបនេះអនុញ្ញាតអោយកម្ពុជាអាចរក្សាសមត្ថកិច្ចរបស់ខ្លួនក្នុងការបង្ក្រាបបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមថែមទៀតផង។ គឺក្នុងន័យនេះហើយ ដែលញ៉ាំងឱ្យមានកំណែទំរង់នីតិវិធីព្រហ្មទណ្ឌ និងសេចក្តីព្រាងក្រមនានា។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានភាពខ្វះចន្លោះលើបញ្ហាស្តីពីសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ ការចូលខ្លួនរបស់ជនរងគ្រោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ការផ្សព្វផ្សាយនូវការពិភាក្សាដេញដោល និងសិទ្ធិក្នុងការទទួលបាន នូវការពិនិត្យសុខភាពនៅក្នុងអំឡុងពេលនៃឃាត់ខ្លួន។

## ក. សិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ

### ១- វត្តមានរបស់មេធាវីនៅដំណាក់ចោទសួរនៃការចូលខ្លួនលើកទីមួយ

ការចូលខ្លួនលើកទីមួយ គឺជាដំណាក់កាលដ៏សំខាន់នៅក្នុងនីតិវិធីព្រហ្មទណ្ឌ។ តាមពិត វាជាដំណាក់កាលដែលចៅក្រមស៊ើបសួរធ្វើការចោទប្រកាន់ពីពិរុទ្ធភាពលើជនដែលជាប់សង្ស័យ និងរៀបចំធ្វើការចោទសួរ ដើម្បីជំរុញឱ្យមានការធ្វើសេចក្តីប្រកាសផ្សេងៗផង និងទទួលយកចម្លើយផ្សេងៗផង។ នៅក្នុងដំណាក់កាលនៃការចោទសួរនេះ វត្តមានរបស់មេធាវីម្នាក់ ឬ អ្នកប្រឹក្សាម្នាក់អមជនជាប់ពិរុទ្ធ គឺជាគោលការណ៍ (មាត្រា ១៤ *ឃ.* នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ពិសេសចំណុច ៩៣ ស្តីពីបណ្តុំនៃវិធានអប្បបរមាចំពោះប្រព្រឹត្តកម្មលើជនជាប់ឃុំរបស់អង្គការសហប្រជាជាតិ និងគោលការណ៍ទី ១៧ នៃបណ្តុំគោលការណ៍សំរាប់ការពារជនទាំងឡាយ ដែលស្ថិតនៅក្រោមការឃុំខ្លួន ឬ ការដាក់ក្នុងពន្ធនាគារ) លើកលែងតែមានការបដិសេធ យ៉ាងច្បាស់លាស់របស់ជនជាប់ពិរុទ្ធ។ មាត្រា ១២ កថាខ័ណ្ឌ ២ នៃបទ បញ្ញត្តិសម័យអន្តរកាលបានចែងគោលការណ៍នេះផងដែរ។

---

៩១. ដោយសារមូលហេតុនៃការបកស្រាយ ដោយគ្មានមូលដ្ឋានច្បាស់លាស់ ចំពោះមាត្រា ១៥៨ នៃរដ្ឋធម្មនុញ្ញ : សូមមើលផ្នែកទី២ ជំពូកទី១។

ម៉្យាងវិញទៀត មាត្រា ៥៥ កថាខ័ណ្ឌ ២ វាក្យខ័ណ្ឌ *គ.* និង *ឃ.* នៃ លក្ខន្តិកៈទីក្រុងរ៉ូម បានចែងថា នៅពេលដែលជនម្នាក់ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយថា ជននេះអាចត្រូវបានចោទសួរដោយអាជ្ញាធរជាតិ តាមពាក្យសុំដែលធ្វើឡើងតាមជំពូកទី IX នៃលក្ខន្តិកៈ ជននេះត្រូវតែទទួលបាននូវការជូនដំណឹង មុនការចោទសួរអំពីសិទ្ធិរបស់ខ្លួនក្នុងការ *"ទទួលបាននូវ ជំនួយពីអ្នកការពារ តាមការជ្រើសរើសរបស់ខ្លួន ឬ តាមការចាត់តាំង ប្រសិនបើគ្មានការជ្រើសរើសទេ (...) ដោយគ្មានការបង់ប្រាក់ទេ ប្រសិនបើជននេះគ្មានមធ្យោបាយ"* និង *"ត្រូវបានចោទសួរ ដោយមានវត្តមានមេធាវីរបស់ខ្លួន លើកលែងតែជននេះបានធ្វើការបដិសេធ ដោយស្ម័គ្រចិត្តនូវសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវជំនួយពីអ្នកប្រឹក្សាម្នាក់"*។ វត្តមានរបស់មេធាវី ឬ អ្នកប្រឹក្សាម្នាក់អនុញ្ញាត ម្យ៉ាងអោយជនដែលនៅក្រោមការឃ្លាំមើលរួចផុតពី ការបង្ខិតបង្ខំទាំងឡាយដែលអាចធ្វើឡើងដោយចៅក្រមស៊ើបសួរ និង ម្យ៉ាងទៀតអោយ ចៅក្រមស៊ើបសួរខ្លួនឯង រួចផុតពីបណ្តឹងនានា ដែលអាចតំកល់ដោយជនដែលស្ថិតនៅក្រោមការឃ្លាំមើល។ ទោះបីយ៉ាងនេះក៏ដោយ ក៏សេចក្តី ព្រាងក្រមជាអាទិ៍មាត្រា កម ៤១២-៣ វាក្យខ័ណ្ឌ ២ នៅតែមានការខ្វះចន្លោះដូចមាត្រា ៧៧ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣។ បញ្ញត្តិទាំងនេះសុទ្ធតែអនុញ្ញាតឱ្យចៅក្រមស៊ើបសួរ អាចធ្វើការរៀបចំចោទសួរជន ដែលស្ថិតនៅក្រោមការឃ្លាំមើល ដោយគ្មានវត្តមានមេធាវី ឬ អ្នកប្រឹក្សារបស់គេ ប្រសិនបើក្រោយពីបានកោះហៅដោយត្រឹមត្រូវ គេមិនបានបង្ហាញខ្លួននៅថ្ងៃចោទសួរ។

អវត្តមានមេធាវីដែលត្រូវបានកោះហៅជាមុន និង យ៉ាងត្រឹមត្រូវ អោយចូលរួមក្នុងការចោទសួរ មិនមែនជាហេតុផលសម្រាប់រៀបចំធ្វើការចោទសួរដោយគ្មានមេធាវី ឬ អ្នកប្រឹក្សាម្នាក់ដែលចាំបាច់សម្រាប់ជួយដល់ជនជាប់ ពិរុទ្ធដែលមិនបានបដិសេធអោយបានច្បាស់លាស់នូវសិទ្ធិក្នុងការទទួលបានជំនួយនោះទេ។ សូម្បីតែនៅក្នុងករណី បន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ជីវិតរបស់សាក្សីណាម្នាក់ ឬពីមហន្តរាយ បាត់បង់តំរុយក៏ដោយវត្តមានរបស់មេធាវីនៅតែជាគោលការណ៍ចាំបាច់ដដែល។ ថ្វីដ្បិតតែនៅក្នុងករណីនេះ រយៈពេលដែលបានកំណត់សំរាប់ធ្វើការកោះហៅជននេះនៅក្នុងនីតិវិធីធម្មតា( ប្រាំថ្ងៃ) មិនត្រូវបានគេគោរព ក៏ជននេះត្រូវតែបានគេកោះហៅនៅដំណាក់កាលចោទសួរដែរ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ ៖**

**ដល់អាជ្ញាធរខ្មែរអោយធ្វើការអនុម័តការតាក់តែងបន្ថែមនូវបញ្ញត្តិមួយទៀតនោះគឺ មាត្រា កម ៤១២-៣ នៃសេចក្តីព្រាងក្រមនីតវិធីព្រហ្មទណ្ឌ ដែលនឹងមានចែងដូចតទៅ ៖*"មាត្រា កម ៤១២-៣៖ (វត្តមានរបស់មេធាវីនៅដំណាក់កាលចោទសួរ) ជនជាប់ពិរុទ្ធអាចត្រូវបានចោទសួរតែកាលណា មានវត្តមានរបស់មេធាវីប៉ុណ្ណោះ ប្រសិនបើគេ***

*មិនធ្វើការបដិសេធអោយបានច្បាស់នោះទេ។ ការបដិសេធ នេះត្រូវមានចុះនៅក្នុងកំណត់ហេតុមួយ ផ្សេងពីកំណត់ហេតុចោទសួរ និងត្រូវចុះហត្ថលេខាដោយជនជាប់ពិរុទ្ធ។*

*នៅពេលដែលជនជាប់ពិរុទ្ធត្រូវបានជួយដោយមេធាវីម្នាក់ ចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវី យ៉ាងហោចណាស់នៅក្នុងរយៈពេលប្រាំថ្ងៃមុនការចោទសួរទាំងអស់។ នៅក្នុងអំឡុងពេលនេះ មេធាវី អាចចូលមើលសំណុំឯកសារ នៃនីតិវិធី។ ដោយមិនគិតពីបទបញ្ញត្តិដែលមានចែង នៅក្នុងវាក្យខ័ណ្ឌខាងលើ ចៅក្រមស៊ើបសួរអាចរៀបចំ ការចោទសួរមួយភ្លាមៗ នៅក្នុងករណីបន្ទាន់។ ការបន្ទាន់នេះត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់អាយុជីវិតរបស់សាក្សីណាម្នាក់ ឬ ពីមហន្តរាយនៃការ បាត់បង់ភស្តុតាង។ ប្រភេទនៃការបន្ទាន់នោះត្រូវមានកត់ត្រាទុកនៅក្នុងកំណត់ហេតុ។*

*ប្រសិនបើមេធាវីដែលត្រូវបានកោះហៅដោយត្រឹមត្រូវ មិនបានបង្ហាញខ្លួននៅថ្ងៃ និង ម៉ោងពេលដែលបានកំណត់ទេ ជនជាប់ពិរុទ្ធ ត្រូវតែបានគេប្រាប់ពីសិទ្ធិរបស់ខ្លួន ក្នុងការស្នើសុំអោយមានការចាត់តាំងមេធាវីម្នាក់ អោយខ្លួន តាមលក្ខខណ្ឌ ដែលបានចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដើម្បីជួយខ្លួន នៅក្នុងអំឡុងពេលនៃការចូលខ្លួនលើកទីមួយ"*។ យើងសូមផ្តល់អនុសាសន៍ដល់អាជ្ញាធរខ្មែរអោយផ្តាច់ចេញនូវវាក្យខ័ណ្ឌចុងក្រោយរបស់ មាត្រា កម ៤១២-៣ ដូចដែលវា មានចែងនៅក្នុងសេចក្តីព្រាងក្រម ដើម្បីអោយវាក្លាយជាមាត្រាមួយដាច់ដោយ ឡែកតែឯងដែលនៅបន្ទាប់ពីមាត្រា កម ៤១២-៣។ តាមពិត មាត្រា កម ៤១២-៣ ចែងពីវត្តមានរបស់មេធាវីនៅដំណាក់កាលចោទសួរ ហេតុនេះទើប យើងមិនយល់ទេថា តើហេតុអ្វីបានជាមាត្រានេះ ចែងផងដែរអំពីបញ្ហាអ្នកបកប្រែ។ លើកលែងតែការបញ្ចូលករណី នេះនៅក្នុងមាត្រា កម ៤១២-៣ បទបញ្ញត្តិទាំងអស់ដែលចែងពីជននេះនៅក្នុងសេចក្តីព្រាងក្រម សុទ្ធតែមានចែងនៅ ក្នុងមាត្រាដាច់ដោយឡែកៗ។ ដូចគ្នានេះដែរ វាហាក់ដូចជាមានលក្ខណៈសមស្របទៅនឹងខ្លឹមសារទូទៅរបស់អត្ថបទ ក្នុងការត្រៀមបំរុង បទបញ្ញត្តិស្តីពីជំនួយរបស់អ្នកបកប្រែក្នុងអំឡុងពេលនៃការចោទសួរ សំរាប់មាត្រាមួយដោយឡែក។ យើងសូមស្នើ ធ្វើការចុះលេខមាត្រានេះជា "កម ៤១២-៣ ស្ទួន" ដើម្បីកុំអោយមានការប៉ះពាល់ដល់ ការចុះលេខ របស់សេចក្តីព្រាងក្រមដែលមានស្រាប់។ មាត្រាថ្មី នេះមានចែងដូចតទៅ :

*"មាត្រា កម ៤១២-៣ ស្ទួន (ជំនួយរបស់អ្នកបកប្រែ)*

*នៅពេលចោទសួរ ដូចដែលមានចែងក្នុង មាត្រា កម ៤១២-២ (ស្តីពីជំនួយរបស់អ្នកបកប្រែ) ចៅក្រមស៊ើបសួរត្រូវអំពាវនាវរកអ្នកបកប្រែម្នាក់ នៅក្នុងករណីចាំបាច់"*។

## ២- នីតិវិធីបដិប្បញ្ញត្តិនៃការចូលខ្លួនភ្លាម : ការយល់ព្រមត្រូវធ្វើឡើងដោយមានវត្តមានរបស់មេធាវី

នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ជានីតិវិធីមួយរហ័ស និងពិសេសដែលវាមានលក្ខណៈ បដិប្បញ្ញត្តិទៅនឹងនីតិវិធីរបស់នីតិរូម ពោលគឺ រឿងក្តីអាចជំនុំជំរះនៅថ្ងៃជាមួយគ្នានឹងការចាប់ខ្លួន។ ដូច្នេះ វាមានសារសំខាន់ណាស់ក្នុងការធានាថា សិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការត្រូវបានគោរព។ ដើម្បីការពារតុល្យភាព នៃសិទ្ធិក្នុងការពារខ្លួនតាមផ្លូវតុលាការ នៅក្នុងនីតិវិធីពិសេសនេះ អ្នកតាក់តែងច្បាប់ត្រូវផ្តល់អោយ ជនជាប់ចោទ នូវលទ្ធភាពមួយចំនួនដូចជាលទ្ធភាពក្នុងការសុំអោយទុករយៈពេលមួយដែលចាំបាច់សំរាប់រៀបចំការពារខ្លួន ដោយ អនុលោមតាមបទដ្ឋានអន្តរជាតិ ស្តីពីការធានាដែលចាំបាច់សម្រាប់ឱ្យមានយុត្តិធម៌ (មាត្រា ១៤ កថាខ័ណ្ឌ ៣ *ខ.* នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ)។ ច្បាប់នានាជាធរមាន មិនមានចែងអំពីលទ្ធភាពនេះទេ (មាត្រា ៦៤ នៃច្បាប់ចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ស្តីពីនីតិវិធី ព្រហ្មទណ្ឌ)។ បទបញ្ញត្តិដែលទាក់ទងនឹងការចូលបង្ហាញខ្លួនភ្លាមមិនមានលក្ខណៈគ្រប់គ្រាន់គួរអោយពេញចិត្តនោះទេ ដោយសារតែច្បាប់ចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ចែងពីនីតិវិធីនេះក្នុងលក្ខណៈទូលាយពេក។ ក្រៅពីអវត្តមាននៃសិទ្ធិរបស់ជនជាប់ចោទក្នុងការស្នើសុំរយៈពេលបន្ថែមដើម្បីរៀបចំការការពារខ្លួន ហើយដែនអនុវត្តរបស់វាក៏មិនត្រូវបានគេកំណត់ដែរ។ ហើយការឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំការជំនុំជម្រះលើអង្គសេចក្តីទៀតសោត ក៏អាចពន្យារហួតដល់ ៤ ខែ (មាត្រា ៦៣ ដល់ ៦៦)។ ម្យ៉ាងវិញទៀត អត្ថបទនៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ តាមរយៈមាត្រា កម ២១៤-១៣ និង កម ៥១២-៤ បាននាំនូវការធានាជាច្រើននៅក្នុងវិស័យនេះ។ វិធានស្តីពីការចូលបង្ហាញខ្លួនភ្លាមត្រូវបានរៀបរាប់យ៉ាងលំអិត ព្រមជាមួយ និងវត្តមាននៃសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវច្បាប់។ ការជំនុំជំរះលើអង្គសេចក្តី ត្រូវធ្វើនៅក្នុងរយៈពេលមួយ ដែលមិនអោយលើសពី ២ សប្តាហ៍ គិតចាប់ពីការបង្ហាញខ្លួនរបស់ជនជាប់ពិរុទ្ធ នៅចំពោះមុខតុលាការ។ ហើយការឃុំខ្លួន បណ្តោះអាសន្ន ត្រូវតែបញ្ឈប់ជាដាច់ខាត នៅថ្ងៃផុតកំណត់របស់រយៈពេលនេះ។ បទបញ្ញត្តិទាំងនោះក៏មានចែងយ៉ាងច្បាស់លាស់ផងដែរ អំពីលទ្ធភាពរបស់ជនជាប់ចោទក្នុងការស្នើសុំ រយៈពេលមួយដែលចាំបាច់សំរាប់រៀបចំការការពារខ្លួន។ វាជាការពិត ដែលថា សេចក្តីព្រាងក្រមបានចែងដោយសង្ខេបថា : ការជំនុំជំរះអាចធ្វើបាននៅថ្ងៃចូលបង្ហាញខ្លួនភ្លាម តែក្នុងករណីដែលជនជាប់ចោទមិនបានស្នើសុំរយៈពេល សំរាប់រៀបចំការការពារខ្លួនប៉ុណ្ណោះ។ តែទោះបីជាយ៉ាងណា ក៏សេចក្តីព្រាងនេះមិនបានចែងអោយបានច្បាស់ពីគោលការណ៍ ដែលថា ការជំនុំជម្រះនេះអាច ធ្វើទៅបានលុះណាតែមានការយល់ព្រមពីជនជាប់ចោទនោះទេ។ ដូច្នេះ អេហ្វ អ៊ី ដេ អាស សូមផ្តល់អនុសាសន៍ អោយចែងគោលការណ៍នេះអោយបានច្បាស់នៅក្នុងមាត្រា កម ២១៤-១៣ និង កម ៥១២-៤ នៃសេចក្តីព្រាងក្រម។

ម៉្យាងវិញទៀត អនុលោមតាមបទដ្ឋានអន្តរជាតិដែលធានាអោយមានយុត្តិធម៌ ការយល់ព្រមនេះអាចធ្វើឡើង តែក្នុងករណី ដែលមានវត្តមានរបស់មេធាវីរបស់ជនជាប់ចោទប៉ុណ្ណោះ ដើម្បីគោរពអោយបានពេញលេញនូវសិទ្ធិក្នុងការការពារខ្លួន។ សេចក្តីព្រាងក្រមនៅក្នុង ការតាក់តែងនាពេលបច្ចុប្បន្ននេះ មិនមានចែងពីលក្ខខណ្ឌដ៏សំខាន់

នេះទេ។ ក្នុងន័យនេះ អេហ្វ អ៊ី ដេ អាស សូមផ្តល់អនុសាសន៍ដល់អាជ្ញាធរខ្មែរអោយបន្ថែមលក្ខខណ្ឌនេះ ទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនាពេលអនាគត។

ក្រៅពីលក្ខណៈពិសេស និង បដិប្បញ្ញត្តិទៅនឹងនីតិវិធីនៃនីតិរូម នីតិវិធីបែបនេះជាគោលការណ៍ ជានីតិវិធី ដែលបំរុងទុកសំរាប់តែបទល្មើសទាំងឡាយដែលពុំសូវធ្ងន់ធ្ងរ ហើយដែលភស្តុតាងអាចរកបានដោយស្រួល។ ថ្វីត្បិតតែសេចក្តីព្រាងក្រមយកលំនាំតាមក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំងក៏ដោយ ក៏យើងគួរកត់សំគាល់ផងដែរថា ផ្ទុយពីនីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាមរបស់បារាំង មាត្រា កម ២១៤-១២ នៃសេចក្តីព្រាងក្រម បានកម្រិតយ៉ាងតឹងតែងជាង នូវដែនអនុវត្តរបស់នីតិវិធី នៃការចូលបង្ហាញខ្លួនភ្លាម ដោយអនុញ្ញាតឱ្យប្រើបានចំពោះតែ បទមជ្ឈិម ជាក់ស្តែងដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារពី មួយឆ្នាំដល់ប្រាំឆ្នាំប៉ុណ្ណោះ។ ការនេះជាចំណុចវិជ្ជមានមួយរបស់សេចក្តីព្រាងនេះ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរ ដោយយោងទៅតាមអ្វីៗដែលមានចែងពីមុន អោយធ្វើការកែប្រែការសំណេររបស់ មាត្រា កម ២១៤-១៣ និង កម ៥១២-៤ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយអនុម័តយកការតាក់តែងដូចតទៅ :**

*"មាត្រា កម ២១៤-១៣ និង កម ៥១២-៤ (នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម)*

*នៅពេលដែលគេសំរេចប្រើនីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :*

*-ត្រួតពិនិត្យអត្តសញ្ញាណរបស់ជនដែលប្តឹងមកខ្លួន។*

*-ជូនដំណឹងដល់ជនជាប់ចោទ នូវអង្គហេតុ ដែលបានចោទ និងការសន្និដ្ឋានគតិយុត្តិ។*

*-ទទួលសេចក្តីប្រកាសនានារបស់ជនជាប់ចោទ ប្រសិនបើជននេះចង់ធ្វើ។*

*-ធ្វើកំណត់ហេតុនៃការចូលបង្ហាញខ្លួនភ្លាម។*

*ព្រះរាជអាជ្ញា ត្រូវជូនដំណឹងជនជាប់ចោទថា គេមានសិទ្ធិទទួលបានជំនួយមេធាវីម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ឬ តាមការចាត់តាំង អនុលោមតាមបញ្ញត្តិនៃមាត្រា ៣០ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។*

*មេធាវីដែលបានជ្រើសរើស ឬ ចាត់តាំង ត្រូវតែបានជូនដំណឹងជាបន្ទាន់។ គេអាចចូលមើលសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទដោយសម្ងាត់បាន។*

*និទ្ទេសនៃបែបបទទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើមិនដូច្នោះទេនឹងនាំឱ្យមានមោឃភាពនីតិវិធី។*

*តុលាការថ្នាក់ដំបូង ត្រូវបានប្តឹងតាមរយៈកំណត់ហេតុនៃការចូលបង្ហាញខ្លួនភ្លាម។*

*ជនជាប់ចោទ ត្រូវបានឃាត់ខ្លួនដោយមានអ្នកអមរហូតដល់មានការបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលត្រូវប្រព្រឹត្តទៅនៅក្នុងថ្ងៃតែមួយ។*

*ក្រោយពីបានធ្វើការពិនិត្យអត្តសញ្ញាណរបស់ជនជាប់ចោទ និង ការលើកបង្ហាញអង្គហេតុដែលបានចោទប្រកាន់ តុលាការត្រូវបញ្ជាក់ប្រាប់ជននេះថា ខ្លួននិងត្រូវជំនុំជំរះនៅក្នុងថ្ងៃតែមួយ តែក្នុងករណីដែលខ្លួនផ្តល់ការយល់ព្រមប៉ុណ្ណោះ ។ តុលាការត្រូវបញ្ជាក់ប្រាប់ជននេះផងដែរថា គេអាចមានរយៈពេលមួយ ដើម្បីរៀបចំការពារខ្លួន ។*

*ការយល់ព្រមរបស់ជនជាប់ចោទដែលថែង នៅក្នុងវាក្យខ័ណ្ឌខាងលើ នឹងអាចយកជាការបាន លុះត្រាតែមានវត្តមាន មេធាវីរបស់គេ ឬ លុះត្រាតែមានមេធាវីដែលបានចាត់តាំងតាមលក្ខខណ្ឌដែល បានថែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ប្រសិនបើមេធាវីជ្រើសរើសនោះមិនមានវត្តមាន ។ ប្រសិនបើជនជាប់ចោទយល់ប្រមអោយមានការជំនុំជម្រះ តាមវេនដែលបានលើកឡើង ការយល់ព្រមនេះ ត្រូវកត់ត្រាទុកនៅក្នុងកំណត់ហេតុសវនាការ ។*

*ប្រសិនបើជនជាប់ចោទ ស្នើសុំរយៈពេលមួយ ដើម្បីរៀបចំការពារខ្លួន ឬ ប្រសិនបើតុលាការ សន្និដ្ឋានថា រឿងក្តីមិនស្ថិត នៅក្នុងស្ថានភាពនៃការជំនុំជំរះភ្លាមទេ រឿងក្តីនេះត្រូវលើកទៅសវនាការលើកក្រោយ ។ នៅក្នុងករណីនេះ តុលាការអាចធ្វើការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តាមសេចក្តីសំរេចដែលមានសំអាងហេតុ ។ នៅក្នុងសេចក្តីសំរេចរបស់ខ្លួន តុលាការត្រូវយោងទៅលើលក្ខខណ្ឌទាំងឡាយរបស់មាត្រា កម ៤១៣-២១ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) ។ តុលាការត្រូវចេញដីកាអោយឃុំខ្លួន ។*

*ការជំនុំជំរះលើអង្គសេចក្តី ត្រូវតែធ្វើឡើងនៅក្នុងរយៈពេលមួយដែលមិនអាចលើសពី ២ សប្តាហ៍ ដោយគិតចាប់ពីពេល បង្ហាញខ្លួននៅតុលាការ ។ ការឃុំខ្លួនត្រូវបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលផុតកំណត់រយៈពេល ២ សប្តាហ៍នេះ ។*

*ប្រសិនបើតុលាការដែលបានប្តឹងតាមនីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម សន្និដ្ឋានថា លក្ខខណ្ឌទាំងឡាយដែលមានថែងក្នុង មាត្រា កម ២១៤-១២ (ការចូល បង្ហាញខ្លួនភ្លាម) មិនបានគោរព ឬថាភាពសាំញ៉ាំរបស់រឿងក្តី ទាមទារអោយមានការស៊ើបអង្កេតអោយស៊ីជំរៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាវិញ ដើម្បីអោយបើកការស៊ើបអង្កេត ។ ជនជាប់ចោទ ត្រូវមានវត្តមានក្នុងថ្ងៃដដែល នៅចំពោះមុខចៅក្រមស៊ើបសួរ បើមិនដូច្នោះទេ ជនជាប់ចោទត្រូវតែបានដោះលែងអោយមានសេរីភាពដោយស្វ័យប្រវត្តិ" ។*

---

### ខ. ការចូលរួមរបស់ជនរងគ្រោះ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ

ក្នុងស្មារតីនៃយុត្តិធម៌ លក្ខន្តិកៈទីក្រុងរ៉ូមបានផ្តល់ដល់ជនរងគ្រោះ នូវឋានៈមួយយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការនៃនីតិវិធី ។ រដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("រដ្ឋអាជ្ញា") អាចទទួលព័ត៌មានពីជនរងគ្រោះ ។ បន្ទាប់មកទៀត ដោយការផ្តើមគំនិតរបស់ខ្លួន រដ្ឋអាជ្ញាអាចបើកការអង្កេត ប្រសិនបើខ្លួនយល់ឃើញថា ព័ត៌មានទាំងអស់នេះ

មានលក្ខណៈត្រឹមត្រូវ និង មានមូលដ្ឋានគ្រប់គ្រាន់ (មាត្រា ១៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម)។ ផ្ទុយទៅវិញ ប្រសិនបើគេសន្និដ្ឋានថាព័ត៌មានទាំងឡាយ ដែលបានទទួលពីជនរងគ្រោះ មិនមានមូលដ្ឋាន គ្រប់គ្រាន់សំរាប់បើក ការស៊ើបអង្កេតទេ នោះគេត្រូវជូនដំណឹងជនរងគ្រោះ (មាត្រា ១៥ កថាខ័ណ្ឌ ៦)។ ដូច្នេះ ជនរងគ្រោះអាចបញ្ជូន ការអំណះអំណាងរបស់ខ្លួនដល់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ *(la Chambre préliminaire de la Cour)* ដើម្បីតវ៉ាពីសេចក្តីសំរេចរបស់រដ្ឋអាជ្ញា ចំពោះ ការខកខានមិនបានធ្វើការស៊ើបអង្កេត (មាត្រា ១៥ កថាខ័ណ្ឌ ៣ វាក្យខ័ណ្ឌចុងក្រោយ)។ នៅគ្រប់ករណីទាំងអស់ ដោយរាប់បញ្ចូលទាំងនៅ ពេលដែលការស៊ើបអង្កេត ត្រូវបានបើក បន្ទាប់ពីមានការប្តឹងតុលាការ ដោយរដ្ឋណាមួយ ឬ ដោយក្រុមប្រឹក្សាសន្តិសុខ ជនរងគ្រោះ ទាំងឡាយមានសិទ្ធិចូលរួមនៅក្នុងនីតិវិធីនានា នៅចំពោះមុខតុលាការ នៅពេលដែល "ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេមានការពាក់ព័ន្ធ" ដោយយោងទៅតាម មាត្រា ៦៨ កថាខ័ណ្ឌ ៣ នៃលក្ខន្តិកៈ ដោយរាប់បញ្ចូលទាំង ដំណាក់កាលស៊ើបអង្កេត ដូចដែលសភាជាន់ដំបូងទី I បានលើកឡើង[៥២]។

នៅក្នុងការិយាល័យក្រឡាបញ្ជី ផ្នែកចូលរួមរបស់ជនរងគ្រោះ និងការជួសជុលការខូចខាត សំដៅជួយសំរួលការអនុវត្តសិទ្ធិ ដោយជនរងគ្រោះ។ ជនរងគ្រោះនឹងចូលរួមតាមរយៈអ្នកតំណាងតាមផ្លូវច្បាប់ ដែលការិយាល័យក្រឡាបញ្ជីអាចផ្តល់ជូនបាន។ ការិយាល័យក្រុមប្រឹក្សាសាធារណៈសំរាប់ជនរងគ្រោះ ដែលជាអង្គការមួយមានឯករាជ្យពីតុលាការ នឹងទទួលបន្ទុកទ្រទ្រង់អ្នកតំណាងទាំងនេះដោយរាប់បញ្ចូលទាំងករណីពិសេស នៃការតំណាងជនរងគ្រោះដោយផ្ទាល់ផងដែរ។

នៅក្នុងការិយាល័យក្រឡាបញ្ជីរបស់តុលាការ មានអង្គភាពជួយជនរងគ្រោះ និងសាក្សី ដែលទទួលបន្ទុកជួយក្នុងលក្ខណៈសមស្រប ដល់ជនរងគ្រោះទាំងឡាយណា ដែលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងគ្រួសាររបស់ ពួកគេហើយគ្រោងរៀបចំវិធានការនានាដើម្បីធានាការការពារ និងសន្តិសុខរបស់ពួកគេ (មាត្រា ៤៣ កថាខ័ណ្ឌ ៦)។ ការការពារ និងការចូលរួមនៅក្នុងរឿងក្តីរបស់ជនរងគ្រោះ មានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៦៨ នៃ លក្ខន្តិកៈ និងមាត្រា ៨៩ ដល់ ៩៣ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង។

ចំពោះសភាជាន់ដំបូង គេអាចស្នើសុំ *"ក្នុងផលប្រយោជន៍ខ្ពស់របស់ជនរងគ្រោះ"* អោយមានកិច្ចសហប្រតិបត្តិការ រវាងរដ្ឋ និងរដ្ឋ ទោះបីជាមុនការជំនុំជំរះលើអង្គសេចក្តីក៏ដោយ ដើម្បីអោយរដ្ឋទាំងនេះចាត់វិធានការថែរក្សាក្នុងគោលបំណងធ្វើការដកហូត (មាត្រា ៥៧ កថាខ័ណ្ឌ ៣ *ង*)។ នេះមានន័យថា លក្ខន្តិកៈទីក្រុងរ៉ូម បានផ្តល់ឋានៈមួយដល់ជនរងគ្រោះ។

[៥២] http://www.icc-cpi.int/library/cases/ICC-01-04-101_French.pdf

តាមប្រវត្តិសាស្ត្រជនរងគ្រោះជានិច្ចកាលតែងតែមានតួនាទីសំខាន់ នៅក្នុងការបង្ក្រាបបទល្មើស ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ ឧក្រិដ្ឋកម្មសង្គ្រាម។ ជនរងគ្រោះជាធាតុផ្សំ ដ៏សំខាន់មួយ ដែលមិនអាចប្រកែកបាននៅ ក្នុងការរៀបរាប់អង្គហេតុឡើងវិញ និង ការជំនុំជម្រះឧក្រិដ្ឋជនអោយមានការទទួលខុសត្រូវ។

ដូច្នេះ នៅក្នុងវិស័យបទដ្ឋានអន្តរជាតិនៃការធានារឿងក្តីមួយឱ្យមានភាពយុត្តិធម៌ សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមនៅ ក្នុងរឿងក្តីព្រហ្មទណ្ឌ ផ្តល់សារសំខាន់ជាច្រើននៅក្នុងក្របខ័ណ្ឌនៃការបង្ក្រាបបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះបទឧក្រិដ្ឋទាំងនេះប៉ះពាល់ដល់សហគមន៍អន្តរជាតិទាំងមូល។ ដូច្នេះ ការចូលរួមរបស់ជនរងគ្រោះពីបទឧក្រិដ្ឋទាំងនេះនៅក្នុងរឿងក្តី គឺជាបញ្ហាដ៏សារវន្ត ហើយនាំអោយមានការធានាជាមូលដ្ឋានមួយក្នុងចំណោម ារធានានានានៃរឿងក្តីយុត្តិធម៌។

### ១- ការចាប់ផ្តើមធ្វើ និងការដាក់អោយមានកិច្ចដំណើរការនៃបណ្តឹងអាជ្ញា

ជាទូទៅ សិទ្ធិនៃការចូលរួមក្នុងតុលាការ គឺជាផ្នែកមួយនៃការធានាអោយមានរឿងក្តីយុត្តិធម៌ ដែលបានទទួលស្គាល់ដោយនីតិអន្តរជាតិ (មាត្រា ១៤ កថាខ័ណ្ឌ ១ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ)។ ដូច្នេះ ជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែមានសិទ្ធិអំណាចអោយតុលាការស្តាប់ពីផលវិបាករបស់ខ្លួន។ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ដែលនៅមានជាធរមាន នាពេលបច្ចុប្បន្ននេះ អនុញ្ញាតអោយតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីបាន តែតាមរយៈការចូលធ្វើអន្តរាគមន៍ប៉ុណ្ណោះ។ បើនិយាយ ម៉្យាងទៀត ជនរងគ្រោះមានលទ្ធភាពតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន តែនៅពេលណា ដែលបណ្តឹងអាជ្ញាត្រូវបានធ្វើឡើងជាមុន ដោយព្រះរាជអាជ្ញា ហើយមិនទាន់មានការសំរេចសេចក្តីនៅឡើយ (មាត្រា ១៣១)។ ច្បាប់ចុះ ថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ស្តីពីការចាត់តាំងតុលាការ បានចែងថា ភាគីដែលរងគ្រោះ ដោយបទល្មើសយោធា អាចទទួលយកផលប្រយោជន៍ ពីមធ្យោបាយគតិយុត្តិនេះបានផងដែរ (មាត្រា ៩ កថាខ័ណ្ឌ ៤)។ សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងលើសពីនេះ។ វាអនុញ្ញាតអោយមានការតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី តាមផ្លូវបណ្តឹង (មាត្រា កម ១២១-៣)។ ដូច្នេះ ជនរងគ្រោះអាចអាចដាក់អោយមានកិច្ច ដំណើការនៃបណ្តឹងអាជ្ញា ដោយតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាបណ្តឹងអាជ្ញាមិនទាន់បានធ្វើឡើងដោយព្រះរាជអាជ្ញាក៏ដោយ។ នេះជាសមិទ្ធិផលសំខាន់ថ្មីមួយរបស់សេចក្តីព្រាងក្រមចំពោះបញ្ហានៃការចូលរួមរបស់ជនរង គ្រោះទៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ប៉ុន្តែ សេចក្តីព្រាងក្រមនេះមិនបានចែងជាបឋម ហើយច្បាស់ៗ អំពីគោលការណ៏នៃការដាក់អោយមានកិច្ចដំណើរការ របស់បណ្តឹងអាជ្ញាប្រភេទនេះទេ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**អោយបញ្ចូលទៅក្នុងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ នូវមាត្រា កម ១១១-២ ដែលចែងពីគោលការណ៍ថ្មី នៃការដាក់អោយមានកិច្ចដំណើរការបណ្តឹងអាជ្ញាដោយភាគីរងគ្រោះ នៅក្នុងមាតិកា ១ នៃគន្ថីទី ១ ស្តីពីគោលការណ៍ ទូទៅ។ មាត្រានេះ ចែងដូចតទៅ : *"មាត្រា កម ១១១-២ (* ការចាប់ផ្តើមធ្វើ និង ការដាក់អោយមានកិច្ចដំណើរការនៃបណ្តឹងអាជ្ញា) *បណ្តឹងអាជ្ញា ត្រូវដាក់អោយមានកិច្ចដំណើរការ និងអនុវត្តដោយតំណាងអយ្យការ។ បណ្តឹងនេះ អាចដាក់អោយមានដំណើរការផងដែរ ដោយភាគីរងគ្រោះ តាមលក្ខខណ្ឌដែលបានកំណត់ដោយក្រមនេះ"។***

---

## ២- ការនាំខ្លួនឱ្យចូលជំរះផ្ទាល់

សេចក្តីព្រាងក្រមមិនបានចែងអោយបានច្បាស់ពីបុគ្គល ឬ អាជ្ញាធរដែលអាចធ្វើ ការនាំខ្លួនឱ្យចូលជំរះផ្ទាល់នោះទេ (មាត្រា កម ៧១១-១ និងបន្តបន្ទាប់)។ ប៉ុន្តែ ឆ្លងតាមរយៈអំណានបទបញ្ញត្តិនានាស្តីពីបញ្ហានេះ យើងអាចនិយាយបានថា មានតែព្រះរាជអាជ្ញាម្នាក់គត់ដែលមានលទ្ធភាពធ្វើ ការនាំខ្លួនឱ្យចូលជំរះផ្ទាល់។

ដូច្នេះ យើងសូមផ្តល់អនុសាសន៍ ដល់អាជ្ញាធរខ្មែរអោយចែងអោយបានច្បាស់ នៅក្នុងសេចក្តីព្រាងក្រម នីតិវិធីព្រហ្មទណ្ឌ នាពេលអនាគតថា ការនាំខ្លួនឱ្យចូលជំរះផ្ទាល់ត្រូវធ្វើឡើងដោយការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា។ ម៉្យាងវិញទៀត តាមរយៈអំណានបទបញ្ញត្តិដដែលរបស់សេចក្តីព្រាងក្រមស្តីពីការនាំខ្លួនឱ្យចូលជម្រះផ្ទាល់នេះ យើងឃើញថា ខុសពីការដាក់អោយមានកិច្ចដំណើរការនៃបណ្តឹងអាជ្ញា ការនាំខ្លួនឱ្យចូលជំរះផ្ទាល់ នេះមិនបានបើកចំពោះជនរងគ្រោះទេ។ ការនេះនាំអោយមានការ កាត់បន្ថយសិទ្ធិទទួលបានយុត្តិធម៌របស់ខ្លួន ដែលវាជាការធានាមួយក្នុងចំណោមការធានានានាដែលចាំបាច់សម្រាប់រឿងក្តីមួយយុត្តិធម៌ដែលយើងបានលើកឡើងពីខាងដើម។ ក្នុងន័យនេះ យើងគួរតែអនុញ្ញាតអោយ ជនរងគ្រោះអាចប្រើនីតិវិធីនេះផងដែរ។

ប៉ុន្តែ បទបញ្ញត្តិដែលទាក់ទងនឹងអាជ្ញាសាលាមិនទាន់មាននៅឡើយទេ នាពេលបច្ចុប្បន្ននេះ។ ដូច្នេះ ហើយ វាហាក់ដូចជាមាន ការលំបាកក្នុងការអនុវត្តជាក់ស្តែង ដែលអនុញ្ញាតិអោយជនរងគ្រោះមានសិទ្ធិនេះ។

**ជាលទ្ធផល អេហ្វ អ៊ី ដេ អាស សូមផ្តល់អនុសាសន៍ដល់អាជ្ញាធរខ្មែរ អោយចែងអោយបានច្បាស់ពីលទ្ធភាពរបស់ជនរងគ្រោះក្នុងការនាំខ្លួនឱ្យចូលជំរះផ្ទាល់នៅពេលណាដែលបទបញ្ញត្តិស្តីពីអាជ្ញាសាលាត្រូវបានបង្កើតឡើង។**

## ៣. សិទ្ធិរបស់សមាគមន៍ផ្សេងៗ ក្នុងការធ្វើបណ្តឹង ប្រឆាំងនឹងបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី

សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ មានការរីកចំរើនយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងនីតិវិជ្ជមាននាពេលបច្ចុប្បន្ន ដោយទទួលស្គាល់សមាគមន៍ ដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនមានការប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាខាងផ្លូវភេទ ឬ អំពើហឹង្សាក្នុងគ្រួសារ ប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរ និងការធ្វើអាជីវកម្មមនុស្សជាតិ ឬ ប្រឆាំងនឹងពូជសាសន៍និយម និង ការរើសអើង ពូជសាសន៍ ជាតិពន្ធ និងសាសនា អោយមានលទ្ធភាព អនុវត្តសិទ្ធិ ដែលបានទទួលស្គាល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ( មាត្រា កម ១៣១-៥, កម ១៣១-៦ និង កម ១៣១-៧) ។

នៅក្នុងក្របខ័ណ្ឌ នៃការដាក់សេចក្តីព្រាងក្រម អោយមានលក្ខណៈស៊ីសង្វាក់គ្នា ជាមួយនឹងកាតព្វកិច្ចរបស់លក្ខន្តិកៈទីក្រុងរ៉ូម លទ្ធភាពនេះគួរតែបានផ្តល់អោយ ផងដែរ ដល់សមាគមន៍ដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួន មានចែងដូចជាការប្រយុទ្ធប្រឆាំង នឹងបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ។

---

**អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរ ធ្វើការអនុម័តនូវមាត្រា កម ១៣១-៨ ថ្មី នៅក្នុងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមាន ចែងដូចតទៅ :*"មាត្រា កម ១៣១-៨ (សមាគមន៍ដែលប្រយុទ្ធប្រឆាំងនឹងបទល្មើស ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) សមាគមន៍ទាំងឡាយដែលបានប្រកាស យ៉ាងត្រឹមត្រូវចំនួន ៣ ឆ្នាំ យ៉ាងហោចណាស់ចាប់តាំងពីថ្ងៃ ដែលបទល្មើសបានប្រព្រឹត្ត ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនមានចែងនូវការប្រយុទ្ធប្រឆាំងនឹងបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម អាចអនុវត្តសិទ្ធិទាំងឡាយដែលបានទទួលស្គាល់ដល់ដើម បណ្តឹងរដ្ឋប្បវេណី ចំពោះការដែលពាក់ព័ន្ធនឹងបទល្មើសដែលបានចែងដោយមាត្រា កម ២១១១-១, កម ២១២១-១ និង កម ២១៣១-១ នៃក្រមព្រហ្មទណ្ឌ"* ។**

**ជាលទ្ធផលនៃការបន្ថែមមាត្រា កម ១៣១-៨ ថ្មី មាត្រាដែលពីមុនបានចុះលេខ កម ១៣១-៨ ដល់ កម ១៣១-១៤ នៃសេចក្តីព្រាងក្រម នឹងត្រូវចុះលេខថ្មីជា កម ១៣១-៩ ដល់ កម ១៣១-១៥ ។**

---

## គ. សាធារណៈភាពនៃការពិភាក្សាដេញដោល

សាធារណៈភាពនៃការពិភាក្សាដេញដោល គឺជាការធានាមួយបែបដើម្បីអោយរឿងក្តីមួយមានភាពយុត្តិធម៌ ដែលទទួលស្គាល់ ដោយនីតិអន្តរជាតិ ។ ប៉ុន្តែ ដើម្បីជាប្រយោជន៍ដល់ទំនៀមទំលាប់ប្រពៃណីល្អ សណ្តាប់ធ្នាប់

សាធារណៈ ឬសន្តិសុខជាតិ ឬការគោរពប្រយោជន៍នៃជីវិតឯកជនរបស់ភាគី ឬ ប្រយោជន៍នៃយុត្តិធម៌ ការជំនុំជម្រះជាអសាធារណៈអាចធ្វើឡើងបាន (មាត្រា ១៤ កថាខ័ណ្ឌ ១ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ)។ ដូច្នេះ ភាគីនៃរឿងក្តីអាច ស្នើសុំអោយមានការជំនុំជំរះជាអសាធារណៈបាន។ លទ្ធភាពរបស់ជនរងគ្រោះនេះ ជាការធានាមួយក្នុងចំណោមការធានានានា ដែលចាំបាច់សម្រាប់ឱ្យរឿងក្តីមួយមានយុត្តិធម៌។ នេះ ដោយសារតែគោលការណ៍នេះអនុញ្ញាតឱ្យជនរងគ្រោះនេះបានចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌ ប្រកបដោយការគោរពជីវិតឯកជន និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ មាត្រា ១២៩ នៃច្បាប់ចុះថ្ងៃទី ៨ កុម្ភៈ ១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ បានចែងថា *"ប្រសិនបើតាមលក្ខណៈសាធារណៈ ការពិភាក្សាដេញដោលអាចមាន លក្ខណៈគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសីលធម៌ល្អ ការជំនុំជម្រះជាអសធារណៈ អាចអនុញ្ញាតអោយមាន"*។ មាត្រា ២៣ នៃបទបញ្ញត្តិសម័យអន្តរកាលអនុញ្ញាត ផងដែរ ដល់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការស្នើសុំអោយមានការជំនុំជម្រះជាអសាធារណៈ។ តែបទបញ្ញត្តិនៃនីតិវិធីមាននេះមិនឃើញមានចែងនៅក្នុង សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌទេ។ យោងតាមមាត្រា កម ៥១៣-១ នៃសេចក្តីព្រាងក្រម មានតែតុលាការប៉ុណ្ណោះដែលអាចអនុញ្ញាតអោយមានការ ជំនុំជម្រះជាអសាធារណៈ ដើម្បីជាផលប្រយោជន៍របស់សណ្តាប់ធ្នាប់សាធារណៈ និងសីលធម៌ល្អ។ ការការពារផលប្រយោជន៍ភាគី និងជីវិតឯកជនរបស់ពួកគេមានការខ្វះចន្លោះ។ វាមិនបានចែងពីលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការស្នើសុំឱ្យមានការជំនុំជំរះជាអសាធារណៈទេ។ ដូច្នេះ សេចក្តីព្រាង មានភាពខ្វះចន្លោះជាងច្បាប់ជាធរ មាន។

---

**ជាលទ្ធផល អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរ អោយធ្វើការកែប្រែមាត្រា កម ៥១៣-១ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយធ្វើការអនុម័ត លើការតាក់តែងដូចខាងក្រោម :*"មាត្រា កម ៥១៣-១ (សាធារណភាពនៃការពិភាក្សាដេញដោល និងការជំនុំជំរះជាអសាធរណៈ) ការពិភាក្សាដេញដោល ត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែ វាបង្កគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ល្អ។ ក្នុងករណីចុងក្រោយនេះ តុលាការត្រូវប្រកាសបើកការពិភាក្សាជាអសាធារណៈ តាមសេចក្តីសំរេចដែលធ្វើឡើង នៅក្នុងសវនាការជាសាធារណៈ។ ចៅក្រមអាចធ្វើការហាមឃាត់អនីតិជនទាំងអស់ ឬ អនីតិជនមួយចំនួនមិនឱ្យចូលរួមនៅក្នុងសាលសវនាការបាន។ នៅពេលដែលការចោទប្រកាន់ត្រូវបានធ្វើឡើងពីបទរំលោភសេពសន្ថវៈ ឬ ទារុណកម្ម និង អំពើព្រៃផ្សៃ ដោយមានរួម ជាមួយនូវការរំលោភបំពានខាងផ្លូវភេទ ការជំនុំជំរះជាអសាធារណៈត្រូវធ្វើដោយស្វ័យប្រវត្តិ ប្រសិនបើជនរងគ្រោះទាំងអស់ ជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនរងគ្រោះណាមួយជាដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការស្នើសុំ។ នៅក្នុងករណីផ្សេងៗទៀត***

***ការជំនុំជំរះជាអសាធារណៈអាចធ្វើទៅកើត តែកាលណាជនរង គ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនរងគ្រោះណាមួយ ក្នុងចំណោមជនរងគ្រោះទាំងឡាយដែលជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានតវ៉ា។ តុលាការត្រូវសំរេចតាមសេចក្តីសំរេចដែលមានសំអាងហេតុ ដែលដាច់ដោយឡែកពីសេច ក្តីសំរេចលើអង្គសេចក្តី។ សេចក្តីសំរេចលើអង្គ សេចក្តីជានិច្ចកាលត្រូវប្រកាសនៅក្នុងសវនាកាជាសាធារណៈ"។***

---

## ឃ. សិទ្ធិទទួលបានការពិនិត្យសុខភាពនៅអំឡុងពេលនៃការឃាត់ខ្លួន

នៅគ្រប់ករណីទាំងអស់ ការស្វែងរកធាតុផ្សំនៃបទល្មើស និងធាតុផ្សំនៃភស្តុតាងនៅអំឡុងពេលនៃការឃាត់ខ្លួន មិនអាចជាហេតុផលសម្រាប់អនុញ្ញាតឱ្យមានអំពើទារុណកម្ម និងការដាក់ទោសផ្សេងៗទៀត ឬ ការប្រព្រឹត្តកម្មយ៉ាងឃោរឃៅ អមនុស្សធម៌ ឬ បាត់បង់តំលៃជាមនុស្ស (មាត្រា ៣៨ វាក្យខ័ណ្ឌ ៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ កញ្ញា ១៩៩៣ មាត្រា ១២ កថាខ័ណ្ឌ ១ នៃបទបញ្ញត្តិសម័យអន្តរកាល មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ មាត្រា ១៥ នៃ អនុសញ្ញាប្រឆាំងនឹង អំពើទារុណកម្ម និងការដាក់ទោសផ្សេងៗទៀត ឬ ប្រព្រឹត្តកម្ម យ៉ាងឃោរឃៅ អមនុស្សធម៌ ឬបាត់បង់តំលៃជាមនុស្ស ចុះថ្ងៃទី ១០ ធ្នូ ១៩៨៤ គោលការណ៍ទី ២១ របស់បណ្តុំនៃគោលការណ៍ ដើម្បីការពារគ្រប់បុគ្គលទាំងអស់ ដែលស្ថិតនៅ ក្រោមការឃុំខ្លួន ឬការដាក់ពន្ធនាគារគ្រប់ប្រភេទ)។

លក្ខន្តិកៈទីក្រុងរ៉ូមនៅក្នុងមាត្រា ៥៥ បានចែងម៉្យាងទៀតថា នៅពេលដែលជនម្នាក់ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទ ឧក្រិដ្ឋណាមួយដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយថាជននេះត្រូវបានចោទសួរដោយ អាជ្ញាធរជាតិ តាមការស្នើសុំមួយដែលធ្វើឡើងស្របតាមបញ្ញត្តិនៃជំពូកទី IX នៃលក្ខន្តិកៈ ជននេះ *"មិនត្រូវបានស្ថិតនៅ ក្រោមការគៀបសង្កត់ បង្ខិតបង្ខំ ឬ ការគំរាមកំហែងណាមួយឡើយ និងមិនស្ថិតនៅក្រោមអំពើទារុណកម្ម ព្រមទាំងការដាក់ទណ្ឌកម្មផ្សេងៗទៀត ឬប្រព្រឹត្តកម្មយ៉ាងឃោរឃៅ អមនុស្សធម៌ ឬបាត់បង់តំលៃជាមនុស្សផងដែរ"*។ ជនដែលត្រូវបានឃាត់ខ្លួនត្រូវទទួលបាននូវប្រព្រឹត្តកម្មប្រកបដោយភាព មនុស្សធម៌ និងការគោរពភាពថ្លៃថ្នូររបស់មនុស្សជាតិ (មាត្រា ៣៨ វាក្យខ័ណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា មាត្រា ១២ កថាខ័ណ្ឌ ២ នៃបទបញ្ញត្តិសម័យអន្តរកាល គោលការណ៍ទី ១ នៃបណ្តុំគោលការណ៍ ដើម្បីការពារគ្រប់ជនទាំងអស់ ដែលស្ថិតនៅក្រោមរូបភាពណាមួយនៃការឃុំខ្លួនឬ ការដាក់ពន្ធនាគារ មាត្រា ១០ កថាខ័ណ្ឌ ១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ)។ គ្រូពេទ្យមានតួនាទីតាមដានការគោរពបទបញ្ញត្តិជាមូលដ្ឋានទាំងនេះ ដោយពិនិត្យស្ថានភាពសុខភាពរបស់បុគ្គលនៅ គ្រាដំបូងនៃការឃាត់ខ្លួន (មាត្រា ១២ កថាខ័ណ្ឌ ២ នៃបទបញ្ញត្តិសម័យអន្តរកាល គោលការណ៍ទី ២៤ នៃបណ្តុំគោលការណ៍ដើម្បីការពារជនទាំងអស់ ដែលស្ថិតនៅក្រោមទំរង់

ណាមួយនៃការឃុំខ្លួន ឬ ការដាក់ពន្ធនាគារ)។ គេត្រូវធ្វើការពិនិត្យដូចជា សម្បទារបស់ជន ដែលត្រូវឃាត់ខ្លួន។ គេចូលរួមធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើទារុណកម្ម និងប្រព្រឹត្តកម្មព្រៃផ្សៃទាំងឡាយ តាមរយៈការកត់ត្រាពីលទ្ធផលនៃការពិនិត្យរបស់ខ្លួន (មាត្រា ១២ កថាខ័ណ្ឌ ២ នៃបទបញ្ញត្តិសម័យអន្តរកាល គោលការណ៍ទី ២៦ នៃបណ្តុំគោលការណ៍ដើម្បីការពារជនទាំងឡាយដែលស្ថិត នៅក្រោមរូបភាពណាមួយនៃការឃុំខ្លួន ឬ ការដាក់ពន្ធនាគារ) ដែលលទ្ធផលទាំងនេះ អាចលើកបង្ហាញពីអំពើទារុណកម្ម ឬ ប្រព្រឹត្តកម្មព្រៃផ្សៃផ្សេងៗទៀត ដែលប្រព្រឹត្តទៅលើជនដែលត្រូវបានឃាត់ខ្លួន ប្រសិនបើវាមាន។

ការធានានូវសិទ្ធិក្នុងការទទួលបានការពិនិត្យសុខភាពរបស់ជនដែលត្រូវបានឃាត់ខ្លួន គឺជាការធានាមួយក្នុងចំណោមការធានាដទៃទៀត ដើម្បីឱ្យរឿងក្តីមួយមានភាពយុត្តិធម៌ ដែលទទួលស្គាល់ដោយនីតិអន្តរជាតិ។ ការនេះអនុញ្ញាតអោយដឹងដោយគ្មានមន្ទិលថា ចម្លើយដែលទទួលបានពីអំពើទារុណកម្ម ឬ ប្រព្រឹត្តកម្មព្រៃផ្សៃផ្សេងៗទៀត មិនអាចត្រូវបានលើកជាសំអាង ក្នុងនាមជាធាតុផ្សំនៃភស្តុតាងនៅក្នុងនីតិវិធី សម្រាប់ប្រឆាំងនឹងជនជាប់ពិរុទ្ធបានឡើយ (មាត្រា ១៤ កថាខ័ណ្ឌ ៣ *គ* នៃកតិកា សញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និង ការដាក់ទណ្ឌកម្មផ្សេងៗទៀតៗ ឬ ប្រព្រឹត្តកម្មយ៉ាងឃោរឃៅ អមនុស្សធម៌ ឬ បាត់បង់តំលៃជាមនុស្ស គោលការណ៍ទី ២១ កថាខ័ណ្ឌ ១ នៃបណ្តុំគោលការណ៍ ដើម្បីការពារជនទាំងឡាយដែលស្ថិតនៅក្រោមទំរង់ណាមួយនៃការឃុំខ្លួន ឬ ការដាក់ពន្ធនាគារ)។

មាត្រា កម ៣២៣-៤ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ តាមរយៈបទបញ្ញត្តិបច្ចុប្បន្នរបស់វា មិនអនុញ្ញាត អោយមានការធានាបែបនេះទេ។ និយាយឱ្យចំ សិទ្ធិក្នុងការទទួលបានការពិនិត្យសុខភាពរបស់ជន ដែលត្រូវបានឃាត់ខ្លួន មិនត្រូវបាន ចែងទេនៅក្នុងមាត្រានេះ។ មានតែព្រះរាជអាជ្ញាប៉ុណ្ណោះ *"ដែលអាចចេញដីកាថា ជនដែលត្រូវបានឃាត់ខ្លួននោះ ត្រូវពិនិត្យដោយគ្រូពេទ្យណាម្នាក់"* សូម្បីតែជននេះផ្ទាល់ ឬ គ្រួសាររបស់គេ ក៏មិនអាចធ្វើការស្នើសុំអោយមានការពិនិត្យសុខភាពបានឡើយ។

---

**ជាលទ្ធផល អេហ្វ អ៊ី ដេ អាស ផ្តល់អនុសាសន៍ :**

**ដល់អាជ្ញាធរខ្មែរឱ្យបញ្ចូលសិទ្ធិទទួលបានការពិនិត្យសុខភាពចំពោះជនដែលត្រូវបានឃាត់ខ្លួន និង ចំពោះគ្រួសាររបស់គេ ទៅក្នុងការតាក់តែងថ្មី របស់មាត្រា កម ៣២៣-៤ ដែលមានចែងដូចតទៅ : *"មាត្រា កម ៣២៣-៤ (ជំនួយរបស់គ្រូពេទ្យក្នុងអំឡុងពេលនៃការឃាត់ខ្លួន) គ្រប់ជនទាំងអស់ដែលត្រូវបានឃាត់ខ្លួន អាចត្រូវបានពិនិត្យដោយគ្រូពេទ្យដែលបានចាត់តាំងដោយព្រះរាជអាជ្ញា តាមការស្នើសុំរបស់ខ្លួន។ ជននេះអាចប្រើប្រាស់សិទ្ធិនេះនៅក្នុងរយៈពេល ២៤ ម៉ោង ដោយគិតចាប់ពីពេលសួរដេញដោល និងអាចបន្តការស្នើសុំក្រោយរយៈពេលនេះផងដែរ។***

*នៅគ្រប់ពេលទាំងអស់ ព្រះរាជអាជ្ញាអាចចេញដីកាថាជនដែលត្រូវបានឃាត់ខ្លួនត្រូវពិនិត្យសុខ ភាពដោយគ្រូពេទ្យណាម្នាក់។ គ្រូពេទ្យត្រូវពិនិត្យជាអាទិ៍ថាតើស្ថានភាពសុខភាពរបស់ជននេះមានលក្ខណៈ សមស្របទៅនឹងការឃាត់ខ្លួន ឬ អត់។ ក្នុងករណីគ្មានការស្នើសុំពីជនដែលត្រូវបានឃាត់ខ្លួន ឬ ពីព្រះរាជអាជ្ញាទេការពិនិត្យសុខភាពត្រូវធ្វើដោយស្វ័យប្រវត្តិ ប្រសិនបើសមាជិកគ្រួសារណាម្នាក់របស់គេ បានធ្វើការស្នើសុំ។ គ្រូពេទ្យត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។ ប្រសិនបើគ្រូពេទ្យយល់ឃើញថាស្ថានភាពសុខភាពរបស់ជននេះមិន សមស្របសម្រាប់ការឃុំខ្លួនទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងព្រះរាជអាជ្ញាភ្លាមៗ។ គ្រូពេទ្យត្រូវចេញលិខិតបញ្ជាក់សុខភាពមួយ ដែលត្រូវភ្ជាប់ទៅនឹងនីតិវិធី។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនៅក្នុងកំណត់ហេតុ នូវឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងកាលបរិច្ឆេទ និងពេលវេលានៃ ការពិនិត្យសុខភាព។ ព្រះរាជអាជ្ញា អាចទៅដល់ទីកន្លែង ដើម្បីត្រួតពិនិត្យលក្ខខណ្ឌទាំងឡាយនៃការឃុំខ្លួន"។*

## ជំពូក២: ការធានានានាជាអន្តរជាតិស្តីពីប្រព្រឹត្តកម្មជនជាប់ឃុំ និង ជនជាប់ពន្ធនាគារ

ការធានាទាំងឡាយដែលបានទទួលស្គាល់នៅក្នុងនីតិអន្តរជាតិ ចំពោះប្រព្រឹត្តកម្មលើជនជាប់ឃុំមានចែងនៅក្នុងសេចក្តីសំរេច លេខ ៤៣/១៧៣ ចុះថ្ងៃ ទី ៩ ធ្នូ ១៩៨៨ ៤៥/១១១ ចុះថ្ងៃទី ១៤ ធ្នូ ១៩៩0 នៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និង នៅក្នុងបណ្តុំនៃវិធានអប្បរមា ចំពោះប្រព្រឹត្តកម្មលើជនជាប់ឃុំ ("បណ្តុំ នៃវិធាន") ដែលបានអនុម័តដោយសមាជទី ១ របស់អង្គការសហប្រជាជាតិ (le premier Congrès des Nations-Unies) ដើម្បីបង្កាបទឧក្រិដ្ឋ និង ប្រព្រឹត្តកម្មទៅលើជនល្មើស ដែលបានធ្វើឡើងនៅទីក្រុងហ្សឺណែវឆ្នាំ ១៩៥៥ និង បានអនុម័តដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម នៅក្នុងសេចក្តីសំរេចលេខ ៦៦៣ C (XXIV) ចុះថ្ងៃទី ៣១ កក្កដា ១៩៥៧ និង ២0៧៦ (LXII) ចុះថ្ងៃទី ១៣ ឧសភា ១៩៧៧។

សេចក្តីសំរេចលេខ ៤៣/១៧៣ មានចំណងជើងថា *បណ្តុំគោលការណ៍ដើម្បីការពារជនទាំងឡាយ ដែលស្ថិតនៅក្រោម រូបភាពណាមួយនៃការឃុំខ្លួន ឬ ការដាក់ពន្ធនាគារ* ("បណ្តុំនៃគោលការណ៍") និង សេចក្តីសំរេចលេខ ៤៥/១១១ *គោលការណ៍ជាមូលដ្ឋានដែលទាក់ទងនឹង ប្រព្រឹត្តកម្មលើជនជាប់ឃុំ* ("គោលការណ៍ជាមូលដ្ឋាន")។

យោងតាមមាត្រា ៧៤ នៃបទបញ្ញត្តិសម័យអន្តរកាល បណ្តុំនៃវិធាន និង បណ្តុំនៃគោលការណ៍ សុទ្ធតែ "អាចអនុវត្តបាន នៅប្រទេសកម្ពុជា"។

វិធាន ឬ គោលការណ៍ដែលបានលើកឡើងនៅក្នុងសេចក្តីសំរេចទាំងនេះ មិនមានគោលបំណងដើម្បីរៀបរាប់ពិពណ៌នា អោយបានលំអិតអំពីប្រព័ន្ធពន្ធនាគារគំរូនោះទេ។ សេចក្តីសំរេចលេខ ៤៣/១៧៣ និង ៤៥/១១១ បាន

បង្កើតគោលការណ៍ និង វិធាននៃការរៀបចំពន្ធនាគារល្អមួយព្រមទាំងប្រព្រឹត្តកម្មលើជនជាប់ឃុំ ដែលត្រូវបានទទួលស្គាល់ជាទូទៅ នៅក្នុងនីតិអន្តរជាតិ។

ម្យ៉ាងទៀត គ្រប់វិស័យទាំងអស់នៃសិទ្ធិមនុស្សត្រូវអនុវត្តជាទូទៅ ចំពោះជនជាប់ឃុំ និង ជនជាប់ពិរុទ្ធ។ ក្នុងន័យនេះ ពួកគេអាចទទួលបានផលប្រយោជន៍ផ្សេងៗ ដូចជាការធានាទាំងឡាយដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និង នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ។ ពន្ធនាគារគឺជាកន្លែងមួយដែលមានទិសដៅសំរាប់អនុវត្តទោសដែលបានប្រកាសដោយតុលាការមានសមត្ថកិច្ច ឬ សំរាប់ឃាត់ខ្លួនជនល្មើស។ មានតែជនដែលជាកម្មវត្ថុនៃសេចក្តីសំរេចដែលបានចេញដោយ តុលាការមានសមត្ថកិច្ច ឬ កម្មវត្ថុនៃដីកាចាប់ខ្លួនដែលបានចេញដោយត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ទើបអាចយល់ព្រមឱ្យស្ថិតនៅក្នុងពន្ធនាគារ ដោយអនុលោមតាម មាត្រា ៩ កថាខ័ណ្ឌ ១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានចែងថា *"គ្រប់បុគ្គលទាំងអស់មានសិទ្ធិទទួលបាននូវសិទ្ធិសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាមួយអាចជាកម្មវត្ថុនៃការចាប់ខ្លួន ឬ ការឃុំខ្លួន ដោយបំពាននោះទេ។ គ្មានជនណា មួយត្រូវបានគេដកហូតសិទ្ធិសេរីភាពទេ ប្រសិនបើការនេះមិនមានមូលហេតុត្រឹមត្រូវ និងសមស្របតាមនីតិវិធីដែលបានកំណត់ដោយច្បាប់"*។

ពន្ធនាគារមានទិសដៅសំរាប់ផ្តល់នីតិសម្បទាដល់ជនជាប់ឃុំ។ ដូច្នេះ គ្រប់អំពើទារុណកម្ម ឬ ប្រព្រឹត្តកម្មអមនុស្សធម៌ និង បាត់បង់តំលៃជាមនុស្ស ត្រូវតែលប់បំបាត់ចោល ដោយយោងតាមមាត្រា ១០ កថា ខ័ណ្ឌ ១ នៃកតិកាសញ្ញាដដែល ដែលបាន ចែងថា *"គ្រប់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ត្រូវបានប្រព្រឹត្តលើ ប្រកបដោយមនុស្សធម៌ និងដោយមានការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស"*។

ក្រៅពីនេះ ប្រកាសក្រសួងលេខ ២១៧ ចុះថ្ងៃទី ៣១ មិនា ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ បានយោងទៅរកបណ្តុំនៃវិធាន ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិនយោបាយ។ មាត្រា ៤ កថាខ័ណ្ឌ ៧ វាក្យខ័ណ្ឌ *ក* នៃប្រកាសក្រសួង បានចែងថា *"សិទ្ធិរបស់ជនជាប់ឃុំ ដែលបានចែងដោយមាត្រានេះ ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ និងដោយបណ្តុំនៃវិធានអប្បរមាចំពោះ ប្រព្រឹត្តកម្មលើជនជាប់ឃុំត្រូវបានធានា"*។ យើងសូមរំលឹកដល់អាជ្ញាធរខ្មែរ អំពីភាពចាំបាច់ក្នុងការធានាឱ្យបាននូវ ប្រព្រឹត្តកម្មលើជនជាប់ឃុំ ស្របតាមការធានាជាអន្តរជាតិនានាដែលពាក់ព័ន្ធ ទាំងការធានានៅក្នុងអត្ថបទច្បាប់ ទាំងនៅក្នុងបទបញ្ជាផ្សេងៗរបស់កម្ពុជា ក៏ដូចជាការអនុវត្តជាក់ស្តែង ឬ ការអនុវត្តបទបញ្ញត្តិទាំងនេះ។ ដូចដែលបានពោលខាង ដើមរួចហើយថា នៅក្នុងករណីដែលប្រទេសកម្ពុជាមិន ឆ្លើយតបទៅនឹងការធានាទាំងអស់នេះទេ នោះតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចមិនធ្វើការចាត់តាំងគេអោយទទួលពិរុទ្ធជន (មាត្រា ១០៣ កថាខ័ណ្ឌ ៣ *ខ*)។ ហើយ ស្ថានភាពបែប

នេះនឹងធ្វើអោយអាប់ឱនដល់កិត្តិសព្ទរបស់ខ្លួននៅលើឆាកអន្តរជាតិ ប្រសិនបើប្រជាពលរដ្ឋខ្លួនណាម្នាក់ដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយនៅលើទឹកដីរបស់គេ ត្រូវបានបង្ខំអោយអនុវត្ត ទោសនៅឯបរ ទេស។

របាយការណ៍នេះរៀបរៀងឡើងដោយបានការគាំទ្រពីគណៈកម្មការសហគមន៍អឺរ៉ុប
( គណកម្មការផ្តួចផ្តើមរបស់អឺរ៉ុបដើម្បី ប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស– **IEDDH-** )
ទស្សនៈនានាដែលបានសំដែងចេញក្នុងរបាយការណ៍នេះគឺជាទស្សនៈផ្ទាល់របស់ **FIDH**
មិនមែនជារបស់សហគមអឺរ៉ុបទេ។